ព្រះអភិធម្មត្ថសង្គហ

បរិច្ឆេទទី ៧

សមុច្ចយសង្គហវិភាគ

ប្រែ និងរៀបរៀងដោយ

ភិក្ខុ ញ្ញាតិធម្មោ ពុយ សុវត្ថិឌី

សម្រាប់ជាធម្មទាន

ពុទ្ធសករាជ ២៥៦៥

ព្រះអភិធម្មត្ថសង្គហៈ

បរិច្ឆេទទី ៧

សមុច្ចយសង្គហវិភាគ

ប្រៃ និងរៀបរៀងដោយ

ភិក្ខុ ញ្ញាតិធម្មោ ពុយ សុវត្ថិឌី

ធ្លើនៅវត្តសីតវ័ន (មហាវិហារ) ខេត្តបាត់ដំបង

(សម្រាប់ជាធម្មទាន)

ពុទ្ធសករាជ ២៥៦៥

នាមអ្នកជួយពិនិត្យអក្ខរាវិរុទ្ធនិងវាយអត្ថបទ

១- លោកម្ចាស់គ្រូ **ចូឡវរធម្មោ ហ៊ឺ ជីតៅ** សម្រួលសេចក្ដី

២- លោកម្ចាស់គ្រូ **កល្យាណធម្មោ យឿន កល្យាណ** សម្រួលសេចក្ដី

៣- លោកម្ចាស់ **ញាណសារោ យ៉ាវ សំអឿន** សម្រួលសេចក្ដី

៤- លោកម្ចាស់ **សន្តចិត្តោ រេន រដ្ឋា** ពិនិត្យអក្ខរាវិរុទ្ធ

៥- លោកម្ចាស់ **ញាណានន្ទោ ងួន ភារុណ** ពិនិត្យអក្ខរាវិរុទ្ធ

៦- លោកម្ចាស់ **មេត្តាធនោ មឿន សឺន** ពិនិត្យអក្ខរាវិរុទ្ធ

៧- សាមណេរ **ឡុង ជីវ៉ា** ពិនិត្យអក្ខរាវិរុទ្ធ

៨- ភិក្ខុ **កោវិទោ ឡោះ សូវៀត** វាយអត្ថបទ

៩- ភិក្ខុ **ញាតិធម្មោ ពុយ សុវត្ថិឌី** (រី ភឿត) បកប្រែអត្ថបទ

អារម្ភកថា

បរិយត្តិសាសនា រមែងជាចំណែកដែលសំខាន់ក្រៃលែង ប្រការមួយដែលនឹងគាំទ្រព្រះពុទ្ធសាសនាឱ្យស្ថិតស្ថេរ និងចម្រើនរុងរឿងក្រៃលែងឡើងទៅ ក្នុងអនាគតកាល រាប់តាំងពីព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់រំលត់ខន្ធបរិនិព្វានមក បើព្រះថេរានុថេរៈទាំងឡាយមិនចាប់ចិត្តក្នុងការសិក្សារៀនទន្ទេញពុទ្ធវចនៈ និងអដ្ឋកថាជាប់តគ្នាមកហើយ ព្រះពុទ្ធសាសនាក៏មិនអាចជាប់តរហូតដល់សព្វថ្ងៃនេះទេ បើដូច្នោះ បណ្តាមនុស្សទាំងឡាយដែលកើតមក ក្នុងសម័យក្រោយតាំងពីព្រះសម្មាសម្ពុទ្ធបរិនិព្វានមកក៏មិនអាចដឹងព្រះពុទ្ធសាសនា មិនមានឱកាសបានសិក្សារៀនធម៌ក្នុងព្រះពុទ្ធសាសនា កាលមិនបានសិក្សាធម៌ក្នុងព្រះពុទ្ធសាសនាហើយ ក៏រមែងបែរទៅនិយមរាប់អានលទ្ធិដទៃ ដែលមិនមែនព្រះពុទ្ធសាសនា ធ្វើឱ្យវដ្ដៈរបស់បុគ្គលទាំងឡាយនោះមិនមានទីបំផុត គួរឱ្យស្តាយយ៉ាងក្រៃលែង ដូច្នោះ ការសិក្សារៀនសូត្រព្រះបរិយត្តិទើបជាការសំខាន់ក្រៃលែង ។

យេ ធម្មា ហេតុប្បភវា
តេសំ ហេតុំ តថាគតោ (អាហ)
តេសញ្ច យោ និរោធោ (ច)
ឯវំវាទី មហាសមណោតិ ។

ធម៌ទាំងឡាយណា គឺ ខន្ធ ៥ តែងកើតអំពីហេតុ ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះ ម្យ៉ាងទៀតសេចក្ដីរលត់និងឧបាយជាគ្រឿងរលត់នូវធម៌ទាំងឡាយណា ព្រះតថាគតពោលនូវសេចក្ដី

រលត់និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយនោះ ព្រះមហាសមណៈ មានប្រក្រតីពោលយ៉ាងនេះ ។

ក្នុងសៀវភៅព្រះអភិធម្មត្ថសង្គហបរិច្ឆេទទី ១ ដល់បរិច្ឆេទទី ៩ ខ្ញុំមានសេចក្ដីជ្រះថ្លាបានរៀបចំជាសៀវភៅនេះឡើង ក៏អាស្រ័យការបានសិក្សាព្រះអភិធម្មក្នុងច្បាប់ដើម (មូលនិធិនៃបមហានីវានន្ទ) ឃើញថាមានការអធិប្បាយពិស្តារជំនួយដល់ការយល់បានល្អ ខ្ញុំក៏ព្យាយាមប្រែជាខេមរភាសា ដើម្បីជាធម្មទាន និងដើម្បីជាប្រយោជន៍ដល់ការសិក្សារបស់ពុទ្ធបរិស័ទ ។

ក្នុងសៀវភៅនេះ ខ្ញុំពុំបានលើកយកគំនិតផ្ទាល់ខ្លួននោះទេ គឺស្រង់យកសេចក្ដីក្នុងច្បាប់ដើមទាំងស្រុង និងតាមព្រះត្រៃបិដកអដ្ឋកថាខ្លះ ប៉ុន្តែសេចក្ដីដែលបានលើកមកនេះខ្ញុំជឿជាក់ថា ការរៀបរៀងសៀវភៅនេះ ពិតជាមានកំហុសខុសឆ្គងខ្លះជាពុំខាន ពីព្រោះជាស្នាដៃលើកដំបូងបង្អស់របស់ខ្ញុំ ខ្ញុំសូមទទួលរាល់កំហុសខុសឆ្គងទាំងអម្បាលម៉ាន អំពីសម្នាក់លោកអ្នកសប្បុរសទាំងឡាយ ដែលមានបំណងក្នុងការកែលំអ និងស្ថាបនាក្នុងពេលជាខាងក្រោយៗ ទៀត ។

ជាទីបញ្ចប់ ដោយផលនៃការខំប្រឹងប្រែងរបស់ខ្ញុំ សូមលើកឡើងនូវមហាកុសលផ្នាក់ធម្មទាននេះ និងបុណ្យកុសលគ្រប់បែបយ៉ាងដែលបានសន្សំហើយក្នុងព្រះពុទ្ធសាសនានេះ ជាពិសេសបុណ្យកុសលដែលសម្រេចនៅលើទឹកដីពុទ្ធភូមិ មានប្រទេសឥណ្ឌា ស្រីលង្កា និងប្រទេសភូមា ដែលបានទៅហើយថ្មីៗ នេះសូមលើកប្រគេនចំពោះ

-ព្រះអង្គគ្រូឧបជ្ឈាយ៍ **បញ្ញាវុឌ្ឍិ គ្រូច តាជ** វត្តព្រះនារាយណ៍ ជាព្រះគ្រូអនុគណស្រុក សង្កែ និងឧទ្ទិសប្រគេនចំពោះ

-ព្រះអង្គគ្រូឧបជ្ឈាយ៍ ព្រះនាម **យូ អ៊ី** វត្តតាហែន

-ព្រះអង្គគ្រូឧបជ្ឈាយ៍ **ឧជិរប្បញ្ញោ ហម ឈើន** វត្តភ្នំតាមាយ អតីតជាព្រះគ្រូអនុគណស្រុករតនមណ្ឌល

-ឧទ្ទិសជូនលោកគ្រូវិនយាចារ្យ **គាំ អ៊ីវ** ជាគ្រូព្រះវិន័យ ជូនចំពោះលោកអ្នកដ៏មានគុណទាំងអស់ក្នុងសង្សារដ្ត និងសព្វសត្វ ទាំងអស់ក្នុងត្រៃភព សូមបានចំណែកបុណ្យស្មើៗ គ្នា មួយចំណែក សូមជូនចំពោះញោមប្រុស **ពុយ រី** ញោមស្រី **រស់ ស៊ីហៀង** ដែលមានជីវិតរស់នៅសព្វថ្ងៃនេះ ។

និងសូមជូនចំពោះលោកគ្រូ អគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សារង្ស** លោកគ្រូ ធម្មបណ្ឌិត **រស់ សុជាត** ព្រមទាំងពុទ្ធបរិស័ទទាំងអស់ សូមបានចំណែកបុណ្យធម្មទាននេះគ្រប់ព្រះអង្គគ្រប់គ្នាកុំបីអាក់ខានឡើយ ។

សូមអនុមោទនា.....!!!

បាត់ដំបង វត្តសីតវ័ន ថ្ងៃ ១៥ កើត ខែទុតិយាសាឈ ព.ស. ២៥៦៥

គ.ស. 2021

ភិក្ខុ ញ្ញាតិធម្មោ ពុយ សុវត្ថិឌី

(វត្តសីតវ័ន (មហាវិហារ) ស្ថិតនៅភូមិក្រឡាញ់ ឃុំកំពុងព្រះ ស្រុកសង្កែ)

មាតិកា

លេ.រ. **ទំព័រ**

គាថាសង្គហ ១
ព្រះអភិធម្មត្ថសង្គហ..... ៤
គាថាសង្គហ:ទី ១ ..... ៥
ពួកទី ១ អកុសលសង្គហ: ៦
គាថាសង្គហ:ទី ២ ..... ៧
គាថាសង្គហ:ទី ៣ ..... ៧
អាសវ ៨
ឱឃ..... ១៣
យោគ..... ១៥
គន្ថ ១៨
ឧបាទាន..... ២១
នីវរណ ២៤
អនុសយ..... ៣០
សំយោជន ៣៤
កិលេស ៤២
កិលេសពិស្តារ ១.៥០០ ប្រការ ៤៦
តណ្ហា ១០៨ ..... ៤៦
ពួកទី ២ មិស្សកសង្គហ: ៤៩
គាថាសង្គហ:ទី ៤-៥ ..... ៤៩
ហេតុ ៥០
ឈានង្គ ៥២
មគ្គង្គ ៥៦

ឥន្ទ្រិយ ៦០
ពល ៦៧
អធិបតី ៧១
អាហារ ៧៥
ពួកទី ៣ ពោធិបក្ខិយសង្គហ ៨២
គាថាសង្គហ:ទី ៦-៧ ..... ៨៣
សតិប្បដ្ឋាន ៨៤
ចរិត ២ ប្រភេទ ៩០
កាយានុបស្សនាសតិប្បដ្ឋាន ៩២
វេទនានុបស្សនាសតិប្បដ្ឋាន ៩៩
ចិត្តានុបស្សនាសតិប្បដ្ឋាន ១០៤
ធម្មានុបស្សនាសតិប្បដ្ឋាន ១១០
សម្មប្បធាន ១១៤
ឥទ្ធិបាទ ១១៩
ឥន្ទ្រិយ ១២៣
ពល ១២៩
ពោជ្ឈង្គ ១៣៥
មគ្គង្គ ១៤១
គាថាសង្គហ:ទី ៨ ..... ១៤៧
គាថាសង្គហ:ទី ៩ ..... ១៤៩
វិសុទ្ធិ ៧ ..... ១៥០
ពួកទី ៤ សព្វសង្គហ: ១៥៣
ខន្ធ ១៥៣
គាថាសង្គហទី ១០ ..... ១៥៥
ឧបាទានក្ខន្ធ ១៥៩

គាថាសង្គហៈទី ១១ ..... ១៥៩
៣. អាយតនៈ..... ១៦២
គាថាសង្គហៈទី ១២ ..... ១៦៦
អាយតនៈ ១២ ..... ១៦៦
៤. ធាតុ..... ១៦៩
ធាតុ ១៨ ..... ១៧១
៥. អរិយសច្ចៈ..... ១៧៦
គាថាសង្គហៈទី ១៣ ..... ១៧៧
ទុក្ខសច្ច ១៧៨
សមុទយសច្ច..... ១៧៩
និរោធសច្ច..... ១៨០
មគ្គសច្ច ១៨៤
ញាណក្នុងអរិយសច្ចៈ ៤ ..... ១៨៩
គាថាសង្គហៈទី ១៤ ..... ១៩២
អវសានគាថា..... ១៩៣

ព្រះអភិធម្មត្ថសង្គហ

បរិច្ឆេទទី ៧

សមុច្ចយសង្គហវិភាគ

គាថាសង្គហ

១. ទ្វាសត្តតិវិធា រុត្តា វត្ថុធម្មា សលក្ខណា
តេសំ ទានិ យថាយោគំ បវក្ខ្យាមិ សមុច្ចយំ ។
២. អាសវោឃា ច យោគា ច តយោ គន្ថា ច វត្ថុតោ
ឧបាទានា ទុវេ រុត្តា អដ្ឋ នីវរណា សិយុំ ។
៣. ឆឡេវានុសយា ហោន្តិ នវ សំយោជនា មតា
កិលេសា ទស រុត្តាយំ នវធា បាបសង្គហោ ។
៤. ឆ ហេតូ បញ្ច ឈានង្គា មគ្គង្គា នវ វត្ថុតោ
សោឡសិន្ទ្រិយធម្មា ច ពលធម្មា នវេរិតា ។
៥. ចត្តារោធិបតិ រុត្តា តថាហារាតិ សត្តធា
កុសលាទិសមាកិណ្ណា រុត្តាមិស្សកសង្គហោ ។
៦. ឆន្ទោ ចិត្តមុបេក្ខា ច សទ្ធាបស្សទ្ធិបីតិយោ
សម្មាទិដ្ឋិ ច សង្កប្បោ វាយាមោ វិរតិត្តយំ ។
៧. សម្មាសតិ សមាធីតិ ចុទ្ទសេតេ សភាវតោ

សត្តត្តឹសប្បភេទេន		សត្តធា តត្ថ សង្គហោ ។

៨.	សង្កប្បបស្សទ្ធិ ច បីតុបេក្ខា
ឆន្ទោ ច ចិត្តំ វិរតិត្តយញ្ច
នវេកឋានា វីរិយំ នវដ្ឋ
សតី សមាធី ចតុ បញ្ច បញ្ញា
សទ្ធា ទុឋានុត្តមសត្តតឹស-
ធម្មានមេសោ បវរោ វិភាគោ ។

៩. សព្វេ លោកុត្តរេ ហោន្តិ		ន វា សង្កប្បបីតិយោ
លោកិយេបិ យថាយោគំ		ឆព្វិសុទ្ធិបវត្តិយំ ។

១០. រូបញ្ច វេទនា សញ្ញា		សេសចេតសិកា តថា
វិញ្ញាណមិតិ បញ្ចេតេ		បញ្ចក្ខន្ធាតិ ភាសិតា ។

១១. បញ្ចុបាទានក្ខន្ធាតិ		តថា តេភូមកា មតា
ភេទាភាវេន និព្វានំ		ខន្ធសង្គហនិស្សដំ ។

១២. ទ្វារាលម្មណភេទេន		ភវន្តាយតនានិ ច
ទ្វារាលម្ពតទុប្បន្ន-		បរិយាយេន ធាតុយោ ។

១៣. ទុក្ខំ តេភូមកំ វដ្ដំ		តណ្ហា សមុទយោ ភវេ
និរោធោ នាម និព្វានំ		មគ្គោ លោកុត្តរោ មតោ ។

១៤. មគ្គយុត្តា ផលា ចេវ		ចតុសច្ចវិនិស្សដា
ឥតិ បញ្ចប្បភេទេន		បវុត្តោ សព្វសង្គហោ ។

ឥតិ អភិធម្មត្ថសង្គហោ សមុច្ចយសង្គហវិភាគো នាម
សត្តមো បរិច្ឆេទো ។

ចប់អភិធម្មត្ថសង្គហបាលី បរិច្ឆេទទី ៧
ពោលដោយ សមុច្ចយសង្គហវិភាគ ។

ព្រះអភិធម្មត្ថសង្គហ

បរិច្ឆេទទី ៧

សមុច្ចយសង្គហវិភាគ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ពាក្យថា **សមុច្ចយសង្គហ** នេះ កាលកាត់បទបានដូច្នេះ គឺ

សំ + ឧច្ចយ = សមុច្ចយ ។

សំ = ចូលគ្នា ឬប្រកបព្រម ។

ឧច្ចយ = រូបរូម កាលរូមទាំង ២ បទជា **សមុច្ចយ** ប្រែថា ការរូបរូមចូលគ្នា បានសេចក្តីថា ការរូបរូមធម៌ដែលមានសភាពចូលគ្នាបានដូចវចនត្ថ: សម្តែងថា

សហ ឧច្ចីយន្តេ ឯត្ថាតិ = សមុច្ចយោ វា

សម្បិណ្ឌេត្វា ឧច្ចីយន្តេ ឯតេនាតិ = សមុច្ចយោ

ប្រែថា បរិច្ឆេទដែលឈ្មោះថា **សមុច្ចយ** ព្រោះជាបរិច្ឆេទដែលសម្តែងការរូបរូមបរមត្ថធម៌ទាំង ៤ ប្រការព្រមគ្នា ឬបរិច្ឆេទដែលឈ្មោះថា **សមុច្ចយ** ព្រោះជាហេតុឱ្យសម្តែងការរូបរូមបរមត្ថធម៌ ដែលមានសភាពចូលគ្នាបាន ឱ្យនៅជាពួក ជាក្រុម ព្រះអនុរុទ្ធាចារ្យ បានចងជាគាថា

សង្គហ:ទុកជាគោលក្នុងការសម្តែងសមុច្ចយសង្គហ:នេះជា ១៤ គាថា ដូចសម្តែងអនុសន្ធិនិងបដិញ្ញាទុក ក្នុងគាថាសង្គហ:ទី ១ ថា

គាថាសង្គហ:ទី ១

១. ទ្វាសត្តតិវិធា វុត្តា វត្ថុធម្មា សលក្ខណា
តេសំ ទានិ យថាយោគំ បវក្ខាមិ សមុច្ចយំ ។

ប្រែថា សភាវធម៌ទាំងឡាយដែលមានលក្ខណ:របស់ខ្លួន មាន ៧២ ប្រការនោះ គឺ ខ្ញុំពោលរួចហើយ ឥឡូវនេះនឹងពោលនូវពួកធម៌ទាំងនោះ តាមសមគួរដល់ការប្រកប ។

វត្ថុធម៌ សំដៅដល់ ធម៌ដែលមានសភាវបរមត្ថរបស់ខ្លួនដោយចំពោះអាចប្រាកដដល់បញ្ញាបាន បណ្តាវត្ថុទាំងឡាយមិនថា មានជីវិតឬមិនមានជីវិតក្តី កាលរាប់យកតែធម៌ដែលមានសភាវលក្ខណ:របស់ខ្លួនដោយចំពោះហើយ រមែងមានត្រឹមតែ ៧២ ប្រការ គឺ

ចិត្ត ១ រាប់ដោយសភាវលក្ខណ: គឺ មានការដឹងអារម្មណ៍ជាលក្ខណ: ។

ចេតសិក ៥២ រាប់តាមសភាវលក្ខណ:របស់ខ្លួន ។

និប្ផន្នរូប ១៨ រាប់តាមសភាវលក្ខណ: ដែលមាននៅក្នុងរូបធម៌ដោយចំពោះរមែងបានដល់ **និប្ផន្នរូប ១៨** ។

និព្វាន ១ រាប់តាមសភាវលក្ខណ: គឺ **សន្តិលក្ខណ** ។

សម្រាប់អនិប្ផន្នរូប ១០ នោះ មិនមានសភាវលក្ខណ:របស់ខ្លួនឯង

ដោយចំពោះ រូបទាំងនោះត្រឹមតែជាការកំណត់រូបកលាប និងរូបកលាប និងអាការប្រព្រឹត្តទៅរបស់និប្ផន្នរូបប៉ុណ្ណោះ ទើបមិនចាត់ចូលនៅក្នុងវត្ថុធម៌ឱ្យជាពិសេសទៀត ។

មួយទៀត ការសម្តែងវត្ថុធម៌ ៧២ ប្រការនេះ ព្រះអនុរុទ្ធាចារ្យ បានសម្តែងមកហើយដោយពិស្តារ តាំងពីបរិច្ឆេទទី ១ ដល់ ៦ ក្នុងបរិច្ឆេទទី ៧ នេះ លោកសំដៅយកការរួបរួមចិត្ត ចេតសិក រូប និព្វាន ដែលហៅថាវត្ថុធម៌ ៧២ ប្រការនេះ តាមដែលរួបរួមចូលគ្នាជាពួកបានមួយវារៈទៀត ទើបឈ្មោះថា សមុច្ចយសង្គហៈ ដែលរួបរួមសភាវធម៌ចូលគ្នាបាន ៤ ពួក ដូចមានវចនត្ថៈថា

អកុសលសង្គហោ មិស្សកសង្គហោ ពោធិបក្ខិយសង្គហោ សព្វសង្គហោ ចេតិ សមុច្ចយសង្គហោ ចតុព្វិធោ វេទិតព្វោ ។

ប្រែថា សមុច្ចយសង្គហនេះ ចែកជា ៤ ពួក គឺ ១. អកុសលសង្គហ, ២. មិស្សកសង្គហ, ៣. ពោធិបក្ខិយសង្គហ, ៤. សព្វសង្គហ នឹងបានសម្តែងទៅតាមលំដាប់ដូច្នេះ

ពួកទី ១ អកុសលសង្គហៈ

អកុសលសង្គហៈ សម្តែងការរួបរួមអកុសលធម៌ផ្សេងៗ ដោយចែកទៅតាមអាការរបស់កិលេស មានវចនត្ថៈថា

ឯកន្តាកុសលជាតិកានំ ឱយចតុក្កាទីនំ សង្គហោតិ = អកុសលសង្គហោ ។

ប្រែថា ពួកធម៌ដែលសង្ត្រោះសភាវធម៌ផ្សេងៗ មាន **ឱឃ** ៤ ជាដើម ដែលជាអកុសលជាតិទាំងអស់ ដូច្នោះពួកធម៌នោះ ឈ្មោះថា អកុសលសង្គហ ។ មានគាថាសង្គហ:សម្តែងថា

គាថាសង្គហ:ទី ២

២. អាសវោយា ច យោគា ច តយោ គន្ថា ច វត្ថុតោ
ឧបាទានា ទុវេ វុត្តា អដ្ឋ នីវរណា សិយុំ ។

ប្រែថា អាសវ: ឱឃ: យោគ: និងគន្ថ: ទាំងនេះ កាលពោល ដោយអង្គធម៌មួយៗ មាន ៣ ឧបាទាន មាន ២ និងនីវរណ: មាន ៨ ។

គាថាសង្គហ:ទី ៣

៣. ឆឡេវានុសយា ហោន្តិ នវ សំយោជនា មតា
កិលេសា ទស វុត្តោយំ នវធា បាបសង្គហោ ។

ប្រែថា អនុស័យ មានអង្គធម៌បរមត្ថ ៦ សំយោជន:មាន ៩ កិលេសមាន ១០ អកុសលសង្គហ: រមែងមាន ៩ កង ដូច្នេះ

រួមសេចក្តីថា **អកុសលសង្គហ:** មានធម៌ ៩ កង ឬ ៩ ពួក គឺ **១. អាសវ:, ២. ឱឃ:, ៣. យោគ:, ៤. គន្ថ:, ៥. ឧបាទាន, ៦. នីវរណ:, ៧. អនុស័យ, ៨. សំយោជន:, ៩. កិលេស** ។

នឹងសម្តែងអកុសលសង្គហ: ៩ កង ដោយលំដាប់តទៅ

១. អាសវ

អាសវ បានដល់ វត្ថុដែលត្រូវត្រាំនៅយូរ ឧបមាដូចសុរាជាវត្ថុដែលត្រូវត្រាំទុកយូរ អាចធ្វើឱ្យអ្នកផឹកកើតអាការស្រវឹងបាត់សតិ ធ្វើវត្ថុដែលមិនគួរធ្វើបានយ៉ាងណា សភាវធម៌ដែលជាវត្ថុត្រាំជាប់តគ្នានៅក្នុងខន្ធសន្តានរបស់សត្ត ធ្វើឱ្យសត្ត្ទាំងឡាយត្រូវស្រវឹងវង្វេងបាត់សតិ ធ្វើក្នុងវត្ថុដែលមិនគួរធ្វើបាន សភាវធម៌នេះ ឈ្មោះថា **អាសវ** បានដល់ **លោភ ទិដ្ឋិ មោហ** ធម៌ទាំង ៣ ប្រការនេះ ត្រាំនៅក្នុងខន្ធសន្តានរបស់សត្ត្ទាំងឡាយជាយូរ រាប់ចំនួនភពជាតិមិនបាន ហើយធម៌ទាំងនេះ កាលប្រាកដដល់បុគ្គលណា ធ្វើឱ្យចិត្តរបស់បុគ្គលនោះស្រវឹងវង្វេងបាត់សតិ ធ្លាក់នៅក្នុងអំណាចរបស់លោភខ្លះ ទិដ្ឋិខ្លះ និងមោហាខ្លះ ជាហេតុឱ្យធ្វើទុច្ចរិតកម្មផ្សេងៗ មានកាយទុច្ចរិតជាដើម ព្រោះការស្រវឹងដោយ **លោភ ទិដ្ឋិ មោហ** នោះឯង ព្រះពុទ្ធអង្គទ្រង់សម្តែងវចនត្ថ:ថា

អាសវន្តិ ចិរំ បរិវសន្តីតិ = អាសវា

វត្ថុណាត្រូវត្រាំយូរៗ វត្ថុនោះឈ្មោះថា **អាសវ** (បានដល់ សុរា)

អាសវា វិយាតិ = អាសវា

ធម្មជាតិណា មានសភាពដូចសុរា ធម្មជាតិនោះ ឈ្មោះថា **អាសវ** (បានដល់ **លោភ ទិដ្ឋិ មោហ**) ។

ពាក្យថា **អាសវ** នេះ កាត់បទ បាន ២ បទ គឺ

អា + សវ = អាសវ, អា ប្រែថា វដ្ដទុក្ខដែលវែងឆ្ងាយមិនមានកំណត់ ។

សវ ប្រែថា ចម្រើនរុងរឿង រួមសេចក្តីថា **អាសវ** ប្រែថា ធម៌ដែលធ្វើឱ្យវដ្តទុក្ខដែលវែងឆ្ងាយមិនមានកំណត់នោះ ចម្រើនរុងរឿងមិនមានទីបំផុត ។

សេចក្តីថា ការប្រព្រឹត្តទៅនៃរូបនាមខន្ធ ៥ របស់សត្វទាំងឡាយម្នាក់ៗ សុទ្ធតែកើតហើយស្លាប់ៗ ហើយកើតយ៉ាងនេះទៀត កំណត់រាប់មិនបាន និងតទៅខាងមុខរមែងត្រូវកើតហើយស្លាប់ៗ ហើយកើតនៅដូច្នេះតទៅទៀត សម្តែងឱ្យឃើញថា វដ្តទុក្ខរបស់សត្វទាំងឡាយនោះ ចម្រើនរុងរឿងមិនមានទីបំផុត ដូចមានវចនត្ថ:ក្នុងសារត្ថទីបនីដីកាសម្តែងថា

អាយតំវា សំសារទុក្ខំ សវន្តិបសវន្តិ វឌ្ឍន្តីតិ = អាសវា

ប្រែថា ធម៌ណាធ្វើឱ្យវដ្តទុក្ខដែលវែងឆ្ងាយនោះចម្រើនរុងរឿង ធម៌នោះឈ្មោះថា **អាសវ** (បានដល់ **លោភ ទិដ្ឋិ មោហ**) ។

ន័យម្យ៉ាងទៀត **អា** ប្រែថា មានកំណត់ព្រំដែនដល់ភវគ្គភូមិ គឺដល់នេវសញ្ញានាសញ្ញាយតនភូមិ ឬមានព្រំដែនរហូតដល់គោត្រភូ **សវ** ប្រែថា កើតបាន ឬហូរទៅបាន ។

កាលរួម ២ បទចូលគ្នាហើយ **អាសវ** ប្រែថា កើតបាន ឬហូរទៅបាន រហូតដល់ភវគ្គភូមិ ឬគោត្រភូ ដោយអំណាចធ្វើឱ្យជាអារម្មណ៍ ។

ធម្មតាលោភ ទិដ្ឋិ មោហ ទាំងនេះ កើតឡើងដោយអាស្រ័យលោកិយធម៌ និងបញ្ញត្តិធម៌ ដែលសម្តែងថា កើតបានរហូតដល់ភវគ្គភូមិ ឬគោត្រភូនោះ មិនមានសេចក្តីសម្តែងទុកជាពិសេសយ៉ាងណាទេ បាន

សេចក្តីថា នេរវសញ្ញានាសញ្ញាយតនភូមិក្តី គោត្រភូញ្ញាណក្តី ទាំងនេះ រមែងជាលោកិយធម៌ ដូច្នោះទើបជាអារម្មណ៍របស់លោភ ទិដ្ឋិ មោហបាន ដោយហេតុនេះ ទើបពោលថា **លោភ ទិដ្ឋិ មោហ** ដែលជាអាសវធម៌ទាំង ៣ នេះកើតបាន ឬហូរទៅបានរហូតដល់ភវគ្គភូមិ ឬគោត្រភូ ដូចវចនត្ថ:ក្នុងបរមត្ថទីបនីដីកា សម្តែងថា

ភវតោ អាភវគ្គា ធម្មតោ អាគោត្រភុម្ហា សវន្តិ អារម្មណករណ-រសេន បវត្តន្តីតិ = អាសវា

ប្រែថា ធម៌ទាំងឡាយណាហូរទៅដល់ ឬកើតបានដល់ ពោលដោយភូមិហើយ ដល់ភវគ្គភូមិ ពោលដោយធម៌ហើយ ដល់គោត្រភូ ដោយអំណាចធ្វើឱ្យជាអារម្មណ៍ ដូច្នោះធម៌ទាំងនោះឈ្មោះថា **អាសវ** ។

មែនពិត សូម្បីអកុសលចេតសិកដទៃៗ ដូចជា **អហិរិក អនោត្តប្ប ឧទ្ធច្ច មាន** ក៏កើតបាននិងហូរទៅដល់ភវគ្គភូមិ ឬគោត្រភូ ដោយអំណាចធ្វើឱ្យជាអារម្មណ៍ដូចគ្នា តែព្រះពុទ្ធអង្គទ្រង់មិនចាត់អកុសលចេតសិកដទៃៗ នោះជាអាសវ: ទាំងនេះព្រោះ **លោភ ទិដ្ឋិ មោហ** ទាំង ៣ នេះ មានសភាពទូលំទូលាយនិងប្រាកដច្បាស់ជាងអកុសលចេតសិកដទៃៗ ដូចពន្លឺផ្សាយចេញពីដួងព្រះអាទិត្យ រមែងផ្សាយពន្លឺខ្លាំងជាងពន្លឺដទៃៗ ដូចជាពន្លឺរបស់ដួងច័ន្ទ ឬដួងប្រទីប ដូច្នោះព្រះពុទ្ធអង្គទើបទ្រង់សម្តែងធម៌ដែលជាគ្រឿងត្រាំ និងហូរទៅបានរហូតដល់ភវគ្គភូមិ ឬគោត្រភូ ចំពោះដែលប្រាកដច្បាស់ខ្លាំងបំផុត បានដល់ធម៌ដែលជា **លោភ ទិដ្ឋិ មោហ** ដោយចំណែកមួយដែលជា **អាសវ** ។

អាសវៈ មាន ៤ ប្រការ គឺ

១. កាមាសវ ធម្មជាតិដែលជាគ្រឿងត្រាំ ឬហូរទៅក្នុងកាម-គុណារម្មណ៍ អង្គធម៌ បានដល់ លោភចេតសិក ដែលនៅក្នុងលោភមូលចិត្ត ៨ ដួង ។

២. ភវាសវ ធម្មជាតិដែលជាគ្រឿងត្រាំ ឬហូរដោយសេចក្តីត្រេកអរជាប់ចិត្តក្នុងអត្តភាពនៃខ្លួន ក្នុងរូបភព អរូបភព ឬក្នុងរូបជ្ឈាន អរូបជ្ឈាន អង្គធម៌ បានដល់ លោភចេតសិក ដែលនៅក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង ។

៣. ទិដ្ឋាសវ ធម្មជាតិដែលជាគ្រឿងត្រាំ ឬហូរទៅក្នុងសេចក្តីយល់ឃើញខុស អង្គធម៌ បានដល់ ទិដ្ឋិចេតសិក ដែលនៅក្នុងទិដ្ឋិគតសម្ប-យុត្តចិត្ត ៤ ដួង ។

៤. អវិជ្ជាសវ ធម្មជាតិដែលជាគ្រឿងត្រាំ ឬហូរដោយសេចក្តីវង្វេង សេចក្តីល្ងង់ មិនដឹងហេតុផលតាមសេចក្តីពិត អង្គធម៌ បានដល់ មោហចេតសិក ដែលនៅក្នុងអកុសលចិត្ត ១២ ដួង ។

អាសវៈទាំង ៤ ប្រការនេះ មានអង្គធម៌ត្រឹមតែ ៣ ប៉ុណ្ណោះ គឺ លោភចេតសិក ទិដ្ឋិចេតសិក មោហចេតសិក ។

ក្នុងអដ្ឋសាលិនីអដ្ឋកថា សម្តែងសេចក្តីរបស់អាសវធម៌ទាំង ៤ ប្រការនេះថា **បញ្ចកាមគុណិកោ រាគោ កាមាសវោ នាម** ។

សេចក្តីត្រេកអរពេញចិត្តក្នុងកាមគុណារម្មណ៍ទាំង ៥ ឈ្មោះថា **កាមាសវ** ។

រូបារូបភវេសុ ឆន្ទរាគោ ឈាននិកន្តិ សស្សតទិដ្ឋិសហជាតោ រាគោ ភវវសេន បត្ថនា ភវាសវោ នាម ។

ឆន្ទរាគ:ក្នុងរូបភពនិងអរូបភព សេចក្តីពេញចិត្តក្នុងឈាន រាគ: ដែលប្រកបដោយសស្សតទិដ្ឋិ និងសេចក្តីប្រាថ្នាដែលជាប់ដោយភព ឈ្មោះថា **ភវាសវ** ។

ទ្វាសដ្ឋិ ទិដ្ឋិយោ ទិដ្ឋាសវោ នាម ។

ការយល់ឃើញខុសក្នុង ៦២ យ៉ាង ឈ្មោះថា **ទិដ្ឋាសវ** ។

អដ្ឋសុ ឋានេសុ អញ្ញាណំ អវិជ្ជាសវោ នាម ។

ការមិនដឹងក្នុងសភាវធម៌ ៨ ប្រការ ឈ្មោះថា **អវិជ្ជាសវ** បានដល់ ការមិនដឹងក្នុងអរិយសច្ច: ៤ មិនដឹងក្នុងខន្ធ អាយតន: ធាតុ ដែលជា អតីត ១, ដែលប្រព្រឹត្តទៅក្នុងអនាគត ១, មិនដឹងទាំងអតីត និងអនាគត ១, មិនដឹងបដិច្ចសមុប្បាទ ១ ។

ធម៌ដែលលះអាសវ: ៤

កាមាសវោ អនាគាមិមគ្គេន បហីយតិ, ភវាសវោ អរហត្តមគ្គេន, ទិដ្ឋាសវោ សោតាបត្តិមគ្គេន, អវិជ្ជាសវោ អរហត្តមគ្គេន ។

កាមាសវ លះបានដោយបញ្ញាក្នុងអនាគាមិមគ្គចិត្ត, **ភវាសវ** លះបានដោយបញ្ញាក្នុងអរហត្តមគ្គចិត្ត, **ទិដ្ឋាសវ** លះបានដោយបញ្ញា ក្នុងសោតាបត្តិមគ្គចិត្ត, **អវិជ្ជាសវ** លះបានដោយបញ្ញាក្នុងអរហត្តមគ្គ ចិត្ត ។

២. ឱឃ

ឱឃធម៌ គឺ ធម៌ដែលប្រៀបដូចអន្លង់ទឹក បានដល់ **លោភ ទិដ្ឋិ មោហ** អកុសលចេតសិកទាំង ៣ ប្រការនេះ ជាធម៌ដែលដូចអន្លង់ទឹក ព្រោះធម្មតាអន្លង់ទឹកទាំងឡាយ កាលមានវត្ថុណាមួយធ្លាក់ទៅហើយ អន្លង់ទឹកនោះ រមែងជន់ពន្លិចបៀតបៀនវត្ថុទាំងនោះធ្វើឱ្យលិចចុះ លំបាកនឹងធ្វើឱ្យងើបឡើងផុតមកពីអន្លង់ទឹកនោះបាន សេចក្តីលោភ សេចក្តីយល់ឃើញខុស និងសេចក្តីលង់ គឺ **លោភ ទិដ្ឋិ មោហ** ធម៌ទាំង ៣ ប្រការនេះក៏ដូចគ្នា រមែងជន់ពន្លិចនិងបៀតបៀនសត្វទាំងឡាយធ្វើឱ្យលិចចុះក្នុងសង្សារវដ្ត រហូតដល់ អបាយភូមិ លំបាកនឹងងើបឡើងឱ្យផុតពីសង្សារវដ្តនោះ និងឱ្យចូលទៅដល់ព្រះនិព្វានបាន ។

សេចក្តីថា កាលសត្វទាំងឡាយត្រូវគ្របសង្កត់ដោយសេចក្តីលោភ សេចក្តីយល់ឃើញខុស និងសេចក្តីលង់នៅក្នុងវត្ថុដែលមិនជាសារៈ រមែងត្រូវអំណាចអកុសលធម៌ទាំងនោះដឹកនាំឱ្យធ្វើទុច្ចរិតកម្មផ្សេងៗ នាំទៅកាន់អបាយភូមិ ជាភូមិថ្នាក់ក្រោម ដែលហៅថា **ហេដ្ឋិមសង្សារ** រកឱកាសដែលនឹងឱ្យផុតចាកភពភូមិនោះបានលំបាកក្រៃលែង ឬមិនដូច្នោះក៏នឹងនាំឱ្យជាប់ចិត្តនៅក្នុងការវិលវល់កើតស្លាប់នៅក្នុងភូមិដែលមានសេចក្តីសុខសប្បាយ ដែលជាសុគតិភូមិថ្នាក់កណ្តាលហៅថា **មជ្ឈិមសង្សារ** ឬភូមិថ្នាក់ខ្ពស់ដែលហៅថា **ឧបរិមសង្សារ** នៅក្នុងភូមិផ្សេងៗ ដូចពោលនោះ ក៏សុទ្ធតែមិនផុតចាកវដ្តទុក្ខនោះឯង ។

ដោយហេតុនេះ **លោភ ទិដ្ឋិ មោហ** ទាំង ៣ នេះ ទើបឈ្មោះថា

ឱឃ គឺ អន្លង់ទឹក ដូចមានវចនត្ថៈសម្តែងថា

អវត្ថរិត្វា ហានន្តីតិ = ឱឃា

ប្រែថា ធម្មជាតិណារមែងជន់ពន្លិចបៀតបៀនសត្វទាំងឡាយ ធម្មជាតិនោះឈ្មោះថា **ឱឃ** (បានដល់អន្លង់ទឹក) ន័យម្យ៉ាងទៀតសម្តែងថា

អវហានន្តិ ឱសីទាបេន្តីតិ = ឱឃា

ប្រែថា ធម្មជាតិណាធ្វើឱ្យសត្វទាំងឡាយលិចចុះ ធម្មជាតិនោះឈ្មោះថា **ឱឃ** ។

ឱឃា វិយាតិ = ឱឃា

ប្រែថា ធម្មជាតិទាំងឡាយណាជន់ពន្លិចបៀតបៀនសត្វទាំងឡាយ និងធ្វើឱ្យសត្វទាំងឡាយនោះលិចចុះ ក្នុងសង្សារវដ្តរហូតដល់អបាយភូមិ ដូចអន្លង់ទឹក ដូច្នោះធម្មជាតិទាំងឡាយនោះ ឈ្មោះថា **ឱឃ** (បានដល់ **លោភ ទិដ្ឋិ មោហ**) ។

ឱឃ ទាំងនេះ កាលពោលដោយភូមិនិងដោយធម៌ ក៏ដូចគ្នាជាមួយអាសវៈនោះឯង ។

ឱឃៈ មាន ៤ ប្រការ គឺ

១. កាមោឃ ធម្មជាតិដែលធ្វើឱ្យសត្វលិចចុះនៅក្នុងអន្លង់នៃកាម-គុណារម្មណ៍ អង្គធម៌ បានដល់ លោភចេតសិក ក្នុងលោភមូលចិត្ត ៨ ដួង ។

២. ភវោឃ ធម្មជាតិដែលធ្វើឱ្យសត្វលិចចុះនៅក្នុងអន្លង់នៃសេចក្ដីត្រេកអរក្នុងអត្តភាពរបស់ខ្លួន ក្នុងរូបភព អរូបភព ឬក្នុងរូបជ្ឈាន អរូបជ្ឈាន អង្គធម៌ បានដល់ លោភចេតសិក ដែលនៅក្នុងទិដ្ឋិគតវិប្ប-យុត្តចិត្ត ៤ ដួង ។

៣. ទិដ្ឋោឃ ធម្មជាតិដែលធ្វើឱ្យសត្វលិចចុះនៅក្នុងសេចក្ដីយល់ខុស អង្គធម៌ បានដល់ ទិដ្ឋិចេតសិក ក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង ។

៤. អវិជ្ជោឃ ធម្មជាតិដែលធ្វើឱ្យសត្វលិចចុះនៅក្នុងសេចក្ដីល្ងង់មិនដឹងសភាវធម៌តាមសេចក្ដីពិត អង្គធម៌ បានដល់ មោហចេតសិកដែលនៅក្នុងអកុសលចិត្ត ១២ ដួង ។

ឱឃ ទាំង ៤ មានអង្គធម៌ត្រឹមតែ ៣ ប្រការប៉ុណ្ណោះ គឺ **លោភចេតសិក ទិដ្ឋិចេតសិក មោហចេតសិក** ។

ធម៌ដែលលះឱឃ ៤

បញ្ញាក្នុង សោតាបត្តិមគ្គចិត្ត លះទិដ្ឋោឃ ។

បញ្ញាក្នុង អនាគាមិមគ្គចិត្ត លះកាមោឃ ។

បញ្ញាក្នុង អរហត្តមគ្គចិត្ត លះភវោឃ និងអវិជ្ជោឃ ។

៣. យោគ

យោគធម៌ បានដល់ ធម៌ដែលប្រកបសត្វឱ្យជាប់នៅក្នុងវដ្ដទុក្ខ មានវចនត្ថៈថា

វដ្តស្មឹ សត្តេ យោជេន្តីតិ = យោគា

ធម៌ទាំងឡាយណាប្រកបសត្វឱ្យជាប់នៅក្នុងវដ្តទុក្ខ គឺ ភពផ្សេងៗ ធម៌ទាំងនោះ ឈ្មោះថា **យោគ** ។

យោគ ទើបសំដៅដល់ គ្រឿងប្រកប ធម្មតាការឫជ័ររមែងប្រកប ជាមួយវត្ថុ ២ ឱ្យជាប់គ្នាយ៉ាងណា **លោភ ទិដ្ឋិ មោហ** ក៏រមែងប្រកបសត្វ ទាំងឡាយឱ្យជាប់ជាមួយវដ្តទុក្ខក៏យ៉ាងនោះដែរ ។

ន័យម្យ៉ាងទៀត ឧបមាដូចគោដែលទឹមរទេះ កាលគោដើរទៅក្នុង ផ្លូវណា ក៏រមែងអូសរទេះជាប់តាមទៅជាមួយជានិច្ច សត្វទាំងឡាយដែល វិលវល់កើតស្លាប់នៅក្នុងវដ្តទុក្ខក៏ដូចគ្នា រមែងវិលវល់នៅក្នុងវដ្តទុក្ខ រួច ផុតទៅមិនបាន ព្រោះត្រូវប្រកបទុកដោយ **លោភ ទិដ្ឋិ មោហ** ប្រៀបដូច ខ្សែទាមដែលចងគោជាប់ជាមួយរទេះ ព្រះពុទ្ធអង្គទើបទ្រង់សម្តែង **លោភ ទិដ្ឋិ មោហ** ទាំង ៣ ប្រការនេះ ថាជាយោគ: គឺ គោប្រៀបដូច សត្វទាំងឡាយ រទេះប្រៀបដូចភពផ្សេងៗ មានកាមភពជាដើម ខ្សែទាម ដែលចងគោជាប់ជាមួយរទេះ គឺ **លោភ ទិដ្ឋិ មោហ** ជាយោគធម៌នោះ ឯង ។

យោគ: មាន ៤ ប្រការ គឺ

១. កាមយោគ ធម្មជាតិដែលប្រកបសត្វ ឱ្យជាប់នៅក្នុងកាម-គុណារម្មណ៍ អង្គធម៌ បានដល់ លោភចេតសិកដែលប្រកបក្នុងលោភ មូលចិត្ត ៨ ដួង ។

២. ភវយោគ ធម្មជាតិដែលប្រកបសត្វឱ្យជាប់ចិត្ត ក្នុងអត្តភាពនៃ

ខ្លួន និងក្នុងរូបភព អរូបភព ឬរូបជ្ឈាន អរូបជ្ឈាន អង្គធម៌ បានដល់ លោភចេតសិក ដែលប្រកបក្នុងទិដ្ឋិគតវិប្ប យុត្តចិត្ត ៤ ដូង ។

៣. ទិដ្ឋិយោគ ធម្មជាតិដែលជាគ្រឿងប្រកបសត្ត ឱ្យជាប់នៅក្នុងសេចក្តីយល់ឃើញខុស អង្គធម៌ បានដល់ **ទិដ្ឋិចេតសិក** ដែលនៅក្នុងទិដ្ឋិគតសម្ប យុត្តចិត្ត ៤ ដូង ។

៤. អវិជ្ជាយោគ ធម្មជាតិដែលជាគ្រឿងប្រកបសត្តទាំងឡាយ ឱ្យជាប់នៅក្នុងសេចក្តីលង់ សេចក្តីវង្វេង មិនដឹងធម៌តាមសេចក្តីពិត អង្គធម៌ បានដល់ មោហចេតសិកដែលនៅក្នុង អកុសលចិត្ត ១២ ដូង ។

រួមយោគ: មាន ៤ តែអង្គធម៌មានត្រឹមតែ ៣ គឺ **លោភចេតសិក ទិដ្ឋិចេតសិក** និង **មោហចេតសិក** ។

ធម៌ដែលលះយោគ: ៤

បញ្ញាក្នុង សោតាបត្តិមគ្គចិត្ត លះទិដ្ឋិយោគ: ។

បញ្ញាក្នុង អនាគាមិមគ្គចិត្ត លះកាមយោគ: ។

បញ្ញាក្នុង អរហត្តមគ្គចិត្ត លះភវយោគ: និងអវិជ្ជាយោគ: ។

ចំណុចសម្គាល់ អាសវ: ឱឃ: និង យោគ: អកុសលសង្គហ:ទាំង ៣ ប្រការដែលពោលហើយនេះ នីមួយៗ មានធម៌ ៤ ប្រការ និងមានអង្គធម៌ដូចគ្នា និងស្មើគ្នា គឺ **លោភ ទិដ្ឋិ មោហ** ។

៤. គន្ថ

គន្ថ ប្រែថា គ្រឿងចង សំដៅដល់ គ្រឿងចងសត្វឱ្យជាប់នៅក្នុងភព មានវចនត្ថ:ថា

កាយំ គន្ថេន្តីតិ = កាយគន្ថា (វា) ការយេន កាយំ គន្ថេន្តីតិ = កាយគន្ថា

ប្រែថា ធម៌ទាំងឡាយណារមែងចង គឺ ដោតក្រងទុកនូវនាមកាយ ឈ្មោះថា **កាយគន្ថ** ឬធម៌ទាំងឡាយណារមែងចង គឺ ដោតក្រងទុករវាងនាមកាយ និងរូបកាយក្នុងបច្ចុប្បន្នភព ជាមួយនាមកាយ រូបកាយក្នុងអនាគតភព ធម៌ទាំងនោះ ឈ្មោះថា **កាយគន្ថ** ធម្មតាគ្រឿងចងដោយអាការដោតក្រង ដែលប្រើក្នុងសេចក្ដីរបស់គន្ថ:នេះមិនមែនសំដៅដល់ការចងទុកធូរៗ មិនណែន នឹងងាយដល់ការស្រាយឱ្យរបូតចេញពីគ្នាបានដោយស្រួលទេ តែសំដៅដល់ចងទុកក្នុងលក្ខណ:ដោតក្រងជាប់គ្នា ដូចច្រវាក់ដែករកចំណងដែលនឹងស្រាយឱ្យរបូតចេញពីគ្នាបានលំបាក ព្រោះច្រវាក់ដែកនោះជារង្វង់ដែកដែលទាក់ជាប់គ្នាជាខ្សែ ដូចវចនត្ថ:សម្ដែងក្នុងធម្មសង្គណីមូលដីកាថា

គន្ថករណំ សង្ខលិកចក្កលកានំ វិយ បដិពទ្ធតាករណំ វា គន្ថនំ = គន្ថោ ប្រែថា ការដោតក្រងឬចងព័ទ្ធឱ្យជាប់គ្នាដូចច្រវាក់នោះ ឈ្មោះថា **គន្ថ** ។

ដូច្នោះ **គន្ថ** ទើបមានសេចក្ដីដូចខ្សែចង ឬដោតក្រង ដោយអាការដែលទាក់ជាប់គ្នាដូចច្រវាក់ដែក ។

ធម្មតាច្រវាក់ដែកនោះ ជារង្វង់ទាក់ជាប់តគ្នាជាខ្សែយ៉ាងណា សភាវធម៌ គឺ លោភ: ទោស: ទិដ្ឋិ ទាំង ៣ ប្រការនេះ ក៏ដោតក្រងសត្វ ទុកក្នុងរវាងបដិសន្ធិជាមួយចុតិ និងចុតិជាមួយបដិសន្ធិ ជាប់តគ្នាជាខ្សែ មិនមានពេលរួចផុតពីគ្នាបាន ដូចច្រវាក់ដែលជាប់តគ្នាទៅយ៉ាងណា ដោយហេតុនេះ ព្រះពុទ្ធអង្គទើបទ្រង់ត្រាស់ថា លោភ: ទោស: ទិដ្ឋិ ទាំង ៣ នេះថាជា គន្ថ: ហើយក្នុងគន្ថ:នេះនៅមាន ពាក្យថា **កាយ** ប្រកបផង ក៏ដើម្បីសម្តែងដល់ធម៌ ដែលត្រូវដោតក្រងដោយ លោភ: ទោស: និងទិដ្ឋិ រាប់ថាជានាមកាយ និងរូបកាយ បានដល់ សត្វទាំងឡាយនោះ ឯង ពោលគឺ លោភ: ទោស: ទិដ្ឋិ ជាទីដោតក្រងសត្វទុកក្នុងរវាងចុតិ ជាមួយបដិសន្ធិ ឱ្យជាប់តគ្នាទៅមិនឱ្យរួចផុតចាកវដ្តទុក្ខបាន ។

គន្ថ: នេះមាន ៤ ប្រការ គឺ

១. អភិជ្ឌាកាយគន្ថ ជាធម្មជាតិដែលដោតក្រងនាមកាយ និងរូបកាយ ទុកដោយអាការឱ្យជាប់ជំពាក់នៅក្នុងកាមគុណារម្មណ៍ អង្គធម៌ បានដល់ **លោភចេតសិក** ដែលប្រកបនៅក្នុងលោភមូលចិត្ត ៨ ដួង ។

២. ព្យាបាទកាយគន្ថ ជាធម្មជាតិដែលដោតក្រងនាមកាយ រូបកាយ ទុកដោយអាការក្រោធ សោកសៅខូចចិត្ត អង្គធម៌ បានដល់ **ទោសចេតសិក** ដែលប្រកបនៅក្នុងទោសមូលចិត្ត ២ ដួង ។

៣. សីលព្វតបរាមាសកាយគន្ថ ជាធម្មជាតិដែលដោតក្រងនាមកាយ និងរូបកាយ ទុកដោយប្រកាន់មាំក្នុងការបដិបត្តិខុស អង្គធម៌ បាន

ដល់ **ទិដ្ឋិចេតសិក** នៅក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដូង ។

៤. ឥទំសច្ចាភិនិវេសកាយគន្ថ ជាធម្មជាតិដែលដោតក្រងនាមកាយ និងរូបកាយ ទុកដោយអាការប្រកាន់មាំក្នុងការយល់ឃើញខុសរបស់ខ្លួនថាត្រូវ ចំណែកការយល់ឃើញរបស់អ្នកដទៃខុស អង្គធម៌បានដល់ ទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដូង រាប់ជាការយល់ឃើញខុសដែលប្រកាន់ទុកយ៉ាងមាំដូចការយល់ឃើញខុសរបស់បុគ្គលថ្នាក់គ្រូបាចារ្យ គន្ថ:មាន ៤ ប្រការ តែអង្គធម៌មានត្រឹមតែ ៣ គឺ លោភចេតសិក ទិដ្ឋិចេតសិក និងទោសចេតសិក ។

ធម៌ដែលលះគន្ថ: ៤

បញ្ញាក្នុង សោតាបត្តិមគ្គចិត្ត លះសីលព្វតបរាមាសកាយគន្ថ:
និងឥទំសច្ចាភិនិវេសកាយគន្ថ: ។
បញ្ញាក្នុង អនាគាមិមគ្គចិត្ត លះព្យាបាទកាយគន្ថ: ។
បញ្ញាក្នុង អរហត្តមគ្គចិត្ត លះអភិជ្ឈាកាយគន្ថ: ។

សេចក្តីផ្សេងគ្នារវាងអភិជ្ឈានិងព្យាបាទដែលជាមនោទុច្ចរិត ជាមួយអភិជ្ឈា និងព្យាបាទដែលជាគន្ថ:

អភិជ្ឈាមនោទុច្ចរិត បានដល់ លោភចេតសិកដែលប្រកបក្នុងលោភមូលចិត្ត ជាសេចក្តីលោភយ៉ាងគ្រោតគ្រាត មានសភាពប្រាថ្នា

ចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃមកជារបស់ខ្លួនៗ ដោយមិនត្រូវតាមធម៌ ។

អភិជ្ឌាកាយគន្ថ ជាការលោភទាំងគ្រោតគ្រាតនិងល្អិត ដែលទាក់ទងជាមួយសេចក្តីចង់បាន និងសេចក្តីពេញចិត្តក្នុងទ្រព្យសម្បត្តិរបស់អ្នកដទៃឬរបស់ខ្លួនឯង ដោយត្រូវតាមធម៌ឬមិនត្រូវតាមធម៌ក្តី សេចក្តីពេញចិត្តចង់បានទាំងនេះចាត់ជា **អភិជ្ឌាកាយគន្ថ** ទាំងអស់ ។

ព្យាបាទមនោទុច្ចរិត បានដល់ ទោស:យ៉ាងគ្រោតគ្រាតដែលទាក់ទងនឹងសេចក្តីក្រោធ គិតប្រទូស្តអ្នកដទៃដោយបំណងឱ្យបានទទួលការបាត់បង់ផ្សេងៗ ឬគិតប្រទេចផ្តាសាឱ្យអ្នកដែលខ្លួនស្អប់ខ្ពើមនោះដល់នូវសេចក្តីវិនាស ។

ព្យាបាទកាយគន្ថ បានដល់ ទោស: ទាំងគ្រោតគ្រាត និងល្អិតដែលមានសភាពជាការមិនចូលចិត្ត មិនពេញចិត្ត ក្រោធ ស្អប់ កើតទុក្ខ ភ័យខ្លាច សោកសៅខូចចិត្ត រហូតដល់ការធ្វើទុច្ចរិតកម្ម មានកាយទុច្ចរិតជាដើម ទាំងនេះចាត់ជា **ព្យាបាទកាយគន្ថ** ទាំងអស់ ។

ដូច្នោះ **អភិជ្ឌា** និង**ព្យាបាទ** ដែលជាគន្ថ: ទើបប្រព្រឹត្តទៅក្នុងសភាពដែលទូលំទូលាយជាងដែលជាមនោទុច្ចរិត ។

៥. ឧបាទាន

ឧបាទាន បានដល់ ការប្រកាន់មាំក្នុងអារម្មណ៍ដោយអំណាចតណ្ហា និងទិដ្ឋិដែលមានកម្លាំង ពាក្យថា **ឧបាទាន** នេះ កាលកាត់បទ

បាន ២ បទ គឺ

ឧប + អាទាន = ឧបាទាន ។

ឧប បានដល់ មាំ **អាទាន** បានដល់ ប្រកាន់ រួមសេចក្តីហើយ **ឧបាទាន** បានដល់ ការប្រកាន់មាំក្នុងអារម្មណ៍ ធម៌ដែលប្រកាន់មាំក្នុងអារម្មណ៍ទើបហៅថា **ឧបាទាន** ដូចវចនត្ថៈថា

ឧបាទីយន្តីតি = ឧបាទានានি

ប្រែថា ធម៌ទាំងឡាយណារមែងប្រកាន់មាំក្នុងអារម្មណ៍ ដូច្នោះ ធម៌ទាំងឡាយនោះ ឈ្មោះថា **ឧបាទាន** ។

ន័យម្យ៉ាងទៀត **ភុសំ អាទិយន្តি អមុញ្ចនគាហំ គណ្ហន្តីតি = ឧបាទានានি** (បរមត្ថទីបនីដីកា)

ប្រែថា ធម៌ទាំងឡាយណាដែលចាប់ប្រកាន់យ៉ាងខ្លាំងក្លា ធម៌ទាំង-ឡាយនោះ ឈ្មោះថា **ឧបាទាន** ឧបមាឧបាទានដូចពស់ដែលខាំកូនក្អាត់ ឬកង្កែប រមែងខាំយ៉ាងណែនមិនព្រមលែងយ៉ាងណា សភាវធម៌គឺ លោភ: ទិដ្ឋិ ក៏រមែងមានសភាពប្រកាន់មាំក្នុងអារម្មណ៍របស់ខ្លួនទុកមិនព្រមលែងក៏យ៉ាងនោះដែរ ។

តាមន័យបដិច្ចសមុប្បាទ ឧបាទានកើតឡើងបានអាស្រ័យតណ្ហាជាហេតុ ដូច្នោះតណ្ហាទើបជាការចង់បានក្នុងអារម្មណ៍ដែលមកមិនទាន់ដល់ ចំណែក **ឧបាទាន** ជាសេចក្តីប្រកាន់មាំក្នុងអារម្មណ៍ដែលមកដល់ខ្លួនហើយ ដោយមិនព្រមលែង ឬន័យម្យ៉ាងទៀត

តណ្ហា ជាសេចក្តីត្រេកអរជាប់ចិត្តក្នុងអារម្មណ៍ជួបដំបូង ។

ឧបាទាន ជាសេចក្ដីត្រេកអរជាប់ចិត្តក្នុងអារម្មណ៍ដែលបានជួបហើយនៅជាប់ក្នុងចិត្ត ឬន័យម្យ៉ាងទៀត

តណ្ហា ប្រៀបដូចដើមឈើដែលនៅតូច ឬទើបតែដាំថ្មីៗ រមែងដកបានងាយ ចំណែក ឧបាទាន ដូចដើមឈើនោះដាំទុកធំហើយ ដកបានដោយលំបាក ព្រោះឫសកែវចាក់មាំហើយ **ឧបាទាន** ទើបជាការប្រកាន់មាំក្នុងអារម្មណ៍យ៉ាងណែនជាងតណ្ហា ។

ឧបាទាន មាន ៤ ប្រការ គឺ

១. កាមុបាទាន គឺ ធម៌ដែលប្រកាន់មាំក្នុងកាមគុណារម្មណ៍ រហូតប្រកាន់មាំក្នុងភវសម្បត្តិដោយអំណាចតណ្ហាដែលមានកម្លាំង អង្គធម៌ បានដល់ លោភចេតសិក ដែលនៅក្នុងលោភមូលចិត្ត ៨ ដួង ។

២. ទិដ្ថុបាទាន គឺ ធម្មជាតិដែលប្រកាន់មាំក្នុងការយល់ឃើញខុសដែលក្រៅពីសីលព្វតបរាមាសទិដ្ថិ និងអត្តវាទទិដ្ថិ អង្គធម៌ បានដល់ ទិដ្ថិចេតសិក ដែលនៅក្នុងទិដ្ថិគតសម្បយុត្តចិត្ត ៤ ដួង ។

៣. សីលព្វតុបាទាន គឺ ធម្មជាតិដែលប្រកាន់មាំក្នុងការបដិបត្តិខុសគិតថាការបដិបត្តិរបស់ខ្លួននិងនាំឱ្យផុតទុក្ខបាន អង្គធម៌ បានដល់ ទិដ្ថិចេតសិក ដែលនៅក្នុងទិដ្ថិគតសម្បយុត្តចិត្ត ៤ ដួង ។

៤. អត្តវាទុបាទាន គឺ ធម្មជាតិដែលប្រកាន់មាំក្នុងរូបនាមខន្ធ ៥ ថាជាតួខ្លួន ដោយអំណាចសក្កាយទិដ្ថិ អង្គធម៌ បានដល់ ទិដ្ថិចេតសិក ដែលនៅក្នុងទិដ្ថិគតសម្បយុត្តចិត្ត ៤ ដួង ។

ឧបាទានទាំង ៤ ប្រការនេះ មានអង្គធម៌ត្រឹមតែ ២ ប៉ុណ្ណោះ គឺ លោភចេតសិក និងទិដ្ឋិចេតសិក ។

ធម៌ដែលលះឧបាទាន ៤

កាមុបាទាន លះបានដោយ បញ្ញាក្នុង អរហត្តមគ្គចិត្ត ។
ទិដ្ឋុបាទាន លះបានដោយ បញ្ញាក្នុង សោតាបត្តិមគ្គចិត្ត ។
សីលព្វតុបាទាន លះបានដោយ បញ្ញាក្នុង សោតាបត្តិមគ្គចិត្ត ។
អត្តវាទុបាទាន លះបានដោយ បញ្ញាក្នុង សោតាបត្តិមគ្គចិត្ត ។

ចំណុចសម្គាល់

កាមុបាទាន បានដល់ ការប្រកាន់មាំក្នុងរូបភព និងអរូបភពផង
ទិដ្ឋុបាទាន កម្មស្សកតាញ្ញាណ រមែងលះបានក្នុងខាងដើម
អត្តវាទុបាទាន វិបស្សនាបញ្ញា រមែងលះបានក្នុងខាងដើម
វិបស្សនាបញ្ញា ជាហេតុនៃការលះឧបាទានទាំងពួង ។

៦. នីវរណ

នីវរណ បានដល់ ធម៌ដែលជាគ្រឿងរារាំងសេចក្តីល្អ គឺ កុសលធម៌ផ្សេងៗ ដែលកើតឡើង ត្រូវនីវរណធម៌រារាំងទុកមិនឱ្យកើត ក៏កើតឡើងមិនបាន ហើយកុសលធម៌ខ្លះ ដូចជាឈានកុសលជាដើម ដែលកំពុងកើតឡើង នីវរណធម៌នេះក៏ធ្វើឱ្យសាបសូន្យទៅបាន មានវចនត្ថៈថា

ឈានាទិកំ និវារេន្តីតិ = នីវរណានិ

ប្រែថា ធម៌ទាំងឡាយណារារាំងសេចក្តីល្អមានឈានជាដើម មិនឱ្យកើតឡើង ធម៌ទាំងឡាយនោះឈ្មោះថា **នីវរណ** ។

ធម្មតាបុគ្គលទាំងឡាយរមែងមិនត្រេកអរក្នុងការបំពេញទាន រក្សាសីល ចម្រើនភាវនាដោយច្រើន ដែលដូច្នេះនេះព្រោះហេតុនៃអំណាចនីវរណធម៌ បានដល់ លោភ: ទោស: ថីន: មិទ្ធ: ឧទ្ធច្ច: កុក្កុច្ច: វិចិកិច្ឆា និងមោហ: ណាមួយ ឬច្រើនយ៉ាងនោះឯង គ្រាខ្លះខណ: កំពុងធ្វើកុសលនោះកើតសេចក្តីស្ទាក់ស្ទើរចិត្ត ធុញទ្រាន់កើតសេចក្តីមិនពេញចិត្តក្នុងការធ្វើឡើងបាន ធ្វើឱ្យសទ្ធា សតិ បញ្ញា ថយចុះទៅ ទាំងនេះអាចជាអំណាចរបស់ ថីនមិទ្ធនីវរណ:កើតឡើងរារាំងសេចក្តីល្អមានសទ្ធាជាដើមនោះ ឬដោយអំណាចកាមឆន្ទនីវរណ: ព្យាបាទនីវរណ: យ៉ាងគ្រោតគ្រាតកើតឡើងដល់ឈានលាភីបុគ្គល ក៏ធ្វើឱ្យឈានដែលសម្រេចហើយនោះសាបសូន្យទៅ មិនអាចនៅក្នុងឈានសមាបត្តិបាន។

នីវរណធម៌ ទើបជាធម៌ដែលរារាំងកុសលធម៌ទាំងឡាយមិនឱ្យកើត ដោយចំពោះជាគ្រឿងរារាំង ឈាន មគ្គ ផល អភិញ្ញា សមាបត្តិ ។

នីវរណ: មាន ៦ ប្រការ គឺ

១. កាមឆន្ទនីវរណ ធម្មជាតិដែលជាគ្រឿងរារាំងសេចក្តីល្អ គឺ ការពេញចិត្តក្នុងកាមគុណារម្មណ៍ រមែងរារាំងសមាធិដែលនឹងឱ្យចូលដល់ឈានជាដើម អង្គធម៌ បានដល់ លោភចេតសិក ដែលនៅក្នុងលោភមូល-

ចិត្ត ៨ ដូង ។

២. ព្យាបាទនីវរណ ធម្មជាតិដែលជាគ្រឿងរារាំងសេចក្ដីល្អ គឺ សេចក្ដីក្រោធ រមែងទម្លាយបីតិដែលនឹងឱ្យចូលដល់ឈានជាដើម អង្គធម៌ បានដល់ ទោសចេតសិក ដែលនៅក្នុងទោសមូលចិត្ត ២ ដូង ។

៣. ថីនមិទ្ធនីវរណ ធម្មជាតិដែលជាគ្រឿងរារាំងសេចក្ដីល្អ គឺ សេចក្ដីរួញរាថយចាកអារម្មណ៍ រមែងធ្វើឱ្យខ្វះវិតក្ក:ដែលជាអង្គឧបការ: ដល់ឈានជាដើម អង្គធម៌ បានដល់ ថីនចេតសិកនិងមិទ្ធចេតសិក ដែលនៅក្នុងអកុសលសសង្ខារិកចិត្ត ៥ ដូង ។

៤. ឧទ្ធច្ចកុក្កុច្ចនីវរណ ធម្មជាតិដែលជាគ្រឿងរារាំងសេចក្ដីល្អ គឺ ការរវើរវាយក្ដៅក្រហាយចិត្ត រមែងធ្វើឱ្យខ្វះសេចក្ដីសុខចិត្ត ដែលឧបការ: ដល់ឈានកុសលជាដើម អង្គធម៌ បានដល់ ឧទ្ធច្ចចេតសិកនិងកុក្កុច្ច-ចេតសិក ដែលនៅក្នុងអកុសលចិត្ត តាមសមគួរ ។

៥. វិចិកិច្ឆានីវរណ ធម្មជាតិដែលជាគ្រឿងរារាំងសេចក្ដីល្អ គឺ សេចក្ដីសង្ស័យរវែកចិត្តក្នុងវត្ថុដែលគួរជឿ រមែងទម្លាយវិចារ:ដែលពិចារណាអារម្មណ៍របស់ឈានជាដើម អង្គធម៌ បានដល់ វិចិកិច្ឆាចេតសិក ដែលនៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដូង ។

៦. អវិជ្ជានីវរណ ធម្មជាតិដែលជាគ្រឿងរារាំងសេចក្ដីល្អ គឺ សភាវ: ដែលបិទបាំងសេចក្ដីពិតទុកមិនឱ្យឃើញច្បាស់ក្នុងអារម្មណ៍ របស់ សតិប្បដ្ឋាន រារាំងមគ្គ ផល និព្វាន មិនឱ្យកើតឡើង អង្គធម៌ បានដល់ មោហចេតសិក ដែលកើតក្នុងអកុសលចិត្ត ១២ ដូង ។

ក្នុងនីវរណៈ ៦ ប្រការនេះ កាលពោលដោយអង្គធម៌មាន ៨ ប្រការ គឺ **លោភចេតសិក ទោសចេតសិក ថីនចេតសិក មិទ្ធចេតសិក ឧទ្ធច្ចចេតសិក កុក្កុច្ចចេតសិក វិចិកិច្ឆាចេតសិក មោហាចេតសិក ។**

សម្រាប់ ថីនចេតសិក និងមិទ្ធចេតសិក ទាំង ២ នេះ ដែលចាត់ជានីវរណៈជាមួយគ្នាព្រោះជា **សហាកទាចិ** គឺ ត្រូវកើតព្រមគ្នាជាមួយ អកុសលសសង្ខារិកចិត្តដូចគ្នា ពោលដោយកិច្ចរមែងធ្វើឱ្យចិត្ត និងចេតសិកថយចាកអារម្មណ៍ដូចគ្នា ជាហេតុនៃកោសជ្ជៈ គឺ សេចក្តីខ្ជិលច្រអូសដូចគ្នា និងកាលពោលដោយបដិបក្ខធម៌ មានវីរិយចេតសិកជាបដិបក្ខធម៌ដូចគ្នា ។

ឧទ្ធច្ច និង**កុក្កុច្ចចេតសិក** ចាត់ជានីវរណៈជាមួយគ្នា កាលពោលដោយកិច្ច ធ្វើឱ្យមិនស្ងប់ ពោលដោយបច្ច័យ ជាហេតុឱ្យដល់ព្យសនៈ ៥ ប្រការ កាលពោលដោយបដិបក្ខធម៌ ជាបដិបក្ខដល់សោមនស្សវេទនា គឺ សេចក្តីសុខចិត្ត ដែលជាហេតុឱ្យដល់ អប្បនាភាវនា ដូចគ្នា ។

នីវរណធម៌ ដែលជាគ្រឿងរារាំងឈាន ក្នុងការចម្រើនសមថភាវនានេះ មានត្រឹមតែ ៥ ប្រការ គឺ

១. កាមឆន្ទនីវរណ, ២. ព្យាបាទនីវរណ, ៣. ថីនមិទ្ធនីវរណ, ៤. ឧទ្ធច្ចកុក្កុច្ចនីវរណ, ៥. វិចិកិច្ឆានីវរណ ។

ចំណែកអវិជ្ជានីវរណៈមិនមែនជាគ្រឿងរារាំងឈានឡើយ ព្រោះឈាន ដោយច្រើនអាស្រ័យបញ្ញត្តារម្មណ៍ តែការចម្រើនវិបស្សនា-កម្មដ្ឋានដើម្បីឱ្យកើតមគ្គ ផល និព្វានៗ នឹងត្រូវអាស្រ័យបញ្ញា គឺ

សម្មាទិដ្ឋិជាប្រការសំខាន់ ទើបពោលថា អវិជ្ជានីវរណ:ប៉ុណ្ណោះ ជាគ្រឿងរារាំងមគ្គ ផល និព្វាន យ៉ាងពិតប្រាកដ ។

ចំណែកនីវរណ: ៥ ប្រការដែលជាគ្រឿងរារាំងឈានៈ ក្នុងការចម្រើនវិបស្សនា រមែងប្រើជាអារម្មណ៍របស់សតិប្បដ្ឋាន ក្នុងធម្មានុ-បស្សនាសតិប្បដ្ឋាន នីវរណបព្ជ:បាន ដូចជាកំណត់នាមពេញចិត្ត នាមមិនពេញចិត្ត នាមងងុយ នាមរវើរវាយ នាមកើតទុក្ខ និងនាមសង្ស័យ ឱ្យវិបស្សនាញ្ញាណកើត នឹងចូលដល់ មគ្គ ផល និព្វានបាន នីវរណ: ៥ ទើបមិនជាគ្រឿងរារាំងមគ្គ ផល និព្វាន ដែលប្រាកដបាន ។

យ៉ាងណាក្តី បើអវិជ្ជាមានកម្លាំងខ្លាំង ធ្វើឱ្យអ្នកបដិបត្តិភ្លេចភ្លាំងសតិរឿយៗ ឬធ្លាប់អប់រំបញ្ញាមកតិចតួចក៏មិនអាចពិចារណា នីវរណ: ៥ ដែលកំពុងប្រាកដនោះបាន កាលដូច្នេះក៏ពោលបានថា នីវរណធម៌ទាំង ៦ ប្រការជាគ្រឿងរារាំងមគ្គ ផល និព្វានបាន ។

សរុបសេចក្តីថា នីវរណធម៌ ដែលជាគ្រឿងរារាំងឈានៈ មាន ៥ ប្រការ (រៀរអវិជ្ជានីវរណ:) ចំណែកនីវរណធម៌ដែលជាគ្រឿងរារាំងមគ្គ ផល និព្វាន នោះមាន ៦ ប្រការ ។

នីវរណធម៌ ជាបរិយុដ្ឋានកិលេស គឺ កិលេសយ៉ាងកណ្តាល ធ្វើការយុំគ្រងបានដោយសមថភាវនា តែបើនឹងប្រហារកិលេសនីវរណ:ឱ្យដាច់ខាតទៅ ត្រូវអាស្រ័យការចម្រើនវិបស្សនារហូតសម្រេចមគ្គ ផល និព្វាន ទើបប្រហារកិលេសបានពិតប្រាកដ ។

ធម៌ដែលលះនីវរណៈ

បញ្ញាក្នុង សោតាបត្តិមគ្គចិត្ត លះវិចិកិច្ឆានីវរណៈ និងកុក្កុច្ច-នីវរណៈ ។

បញ្ញាក្នុង អនាគាមិមគ្គចិត្ត លះកាមឆន្ទនីវរណៈ និងព្យាបាទ-នីវរណៈ ។

បញ្ញាក្នុង អរហត្តមគ្គចិត្ត លះនីវរណៈដែលនៅសល់ទាំងអស់ ។

ចំណុចសម្គាល់

អាការងងុយដេក ជាធម៌ប្រចាំកាយរបស់សត្វតែម្យ៉ាង ហៅថា **កាយានុគតធម៌** មាន ១០ ប្រការ គឺ

១. សីត បានដល់ សម្ផស្សត្រជាក់, **២. ឧណ្ហ** បានដល់ សម្ផស្សក្តៅ, **៣. ជិឃច្ឆា** បានដល់ ហេវ, **៤. បិបាស** បានដល់ ស្រេក, **៥. ឧច្ចារ** បានដល់ ឧច្ចារៈ, **៦. បស្សាវ** បានដល់ បស្សាវៈ, **៧. ថីនមិទ្ធ** ការងងុយដេក, **៨. ជរា** បានដល់ ចាស់, **៩. ព្យាធិ** បានដល់ ឈឺ, **១០. មរណ** បានដល់ ស្លាប់ ។

សម្រាប់ថីនមិទ្ធ ដែលជាការដេកលក់នោះ បុថុជ្ជននិងសេក្ខ-បុគ្គល ថីនមិទ្ធដែលជាកិលេសនីវរណៈ រមែងកើតឡើងបាន ចំណែកព្រះអរហន្តខីណាស្រព អ្នកអស់អាសវក្កិលេសហើយ ការដេកលក់មិនបានប្រព្រឹត្តទៅជាមួយថីនមិទ្ធកិលេសឡើយ គង់មានតែការដេកលក់ដែលជាសេចក្តីចាំបាច់របស់ភវង្គកិច្ច គឺ ជាធម៌ប្រចាំកាយប៉ុណ្ណោះ ។

៧. អនុសយ

អនុសយ ជាឈ្មោះរបស់កិលេសយ៉ាងល្អិតដែលដេកសម្ងំនៅក្នុងខន្ធសន្តានរបស់សត្វទាំងឡាយ ដរាបណាដែលនៅមិនទាន់បានសម្រេចជាព្រះអរហន្ត អនុស័យនេះក៏នឹងមានប្រចាំនៅក្នុងខន្ធសន្តានរឿយៗ ទៅ អនុស័យទើបជាធម្មជាតិដែលដេកសម្ងំមិនបង្ហាញខ្លួនឱ្យនរណាឃើញច្បាស់ រៀងតែព្រះសម្មាសម្ពុទ្ធមួយព្រះអង្គប៉ុណ្ណោះ ដែលអាចដឹងអនុស័យរបស់សត្វទាំងឡាយបាន ។

ធម្មតាអនុស័យកិលេសនោះ ជាធម្មជាតិល្អិតដេកសម្ងំនៅជាប្រចាំក្នុងខន្ធសន្តាន មិនសម្តែងចេញមកឱ្យប្រាកដតាមទ្វារណាមួយឡើយ កាលមានអារម្មណ៍ផ្សេងៗ មកប៉ះខ្ទប់ផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្តហើយ អនុស័យកិលេសដែលស្ងប់នោះ ក៏នឹងប្រែសភាពជាបរិយុដ្ឋានកិលេស គឺ កិលេសយ៉ាងកណ្តាលប្រាកដឡើងផ្លូវចិត្ត ជាសេចក្តីត្រេកអរ និងមិនត្រេកអរដល់អារម្មណ៍ដែលជួបនោះ បើបរិយុដ្ឋានកិលេសនេះមានកម្លាំងខ្លាំងឡើង ក៏នឹងជាបច្ច័យដល់វីតិក្កមកិលេស ជាកិលេសយ៉ាងគ្រោតគ្រាត ប្រាកដជាការធ្វើផ្លូវកាយ ផ្លូវវាចាឡើងមក ទាំងបរិយុដ្ឋានកិលេស និងវីតិក្កមកិលេស ២ ប្រការនេះ មិនហៅថា អនុស័យកិលេសទេ តែបរិយុដ្ឋានកិលេសកើតពីអនុស័យកិលេស និងវីតិក្កមកិលេសកើតពីបរិយុដ្ឋានកិលេស ជាហេតុបច្ច័យឧបត្ថម្ភជាប់តគ្នាទៅដូច្នេះ ។

ដោយហេតុនេះ អនុស័យកិលេស ទើបជាកិលេសមួយប្រភេទ ដែលមានសភាពល្អិត សូប់ដេកសម្ងំនៅក្នុងខន្ធសន្តានរបស់សត្វទាំង-ឡាយ ដូចមានវចនត្ថ:សម្តែងថា

អប្ប្ហីនដ្ឋេន អនុ អនុ សន្តានេ សេន្តីតি = អនុសយា ។

ប្រែថា ធម៌ទាំងឡាយ រមែងដេកសម្ងំនៅក្នុងសន្តានរឿយៗ ព្រោះអត្ថថា ជាកិលេសដែលនៅលះមិនទាន់បាន ឈ្មោះថា អនុស័យ (**អនុ** មានអត្ថថា រឿយៗ)

ន័យម្យ៉ាងទៀតថា **អនុរូបំ ការណំ លភិត្វា ឧប្ប្ជ្ជន្តីតি = អនុសយា ។**

ប្រែថា ធម៌ទាំងឡាយណា កាលបានហេតុសមគួរហើយ រមែងកើតឡើងបាន ធម៌ទាំងឡាយនោះ ឈ្មោះថា អនុស័យ ។

ឧបមា អនុស័យកិលេស បរិយុដ្ឋានកិលេស និងវីតិក្កមកិលេស ដូចឈើគូសក្នុងប្រអប់ យកគ្រាប់ឈើគូសៗ ត្រង់ខាងប្រអប់ ភ្លើងក៏ប្រាកដឡើង និងកាលនាំភ្លើងនោះទៅអុជជាមួយវត្ថុណាដែលភ្លើងឆេះ ភ្លើងក៏នឹងឆេះវត្ថុនោះៗ ។

អនុស័យកិលេស ប្រៀបដូចជាចំហេះភ្លើងដែលនៅលើក្បាលឈើគូសនោះ អារម្មណ៍ផ្សេងៗ ដែលមកប៉ះខ្ទប់ផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ប្រៀបដូចជាយកគ្រាប់ឈើគូស ទៅគូសត្រង់កន្លែងសម្រាប់គូស ។

បរិយុដ្ឋានកិលេស ដូចភ្លើងដែលប្រាកដឡើងត្រង់ក្បាលឈើ

គូសនោះ កាលយកភ្លើងដែលប្រាកដឡើងនេះទៅអុជវត្ថុដទៃក៏នឹងឆេះ ភ្លើងដែលឆេះវត្ថុនោះ។ ប្រៀបដូចជាវីតិក្កមកិលេសដូច្នោះដែរ ។

ធម៌ដែលលះកិលេសទាំង ៣ នេះ គឺ

សីល ប្រហារ វីតិក្កមកិលេស ។

សមាធិ ប្រហារ បរិយុដ្ឋានកិលេស ។

បញ្ញាក្នុងមគ្គចិត្ត ប្រហារអនុស័យកិលេស ។

អនុស័យកិលេស មាន ៧ ប្រការ

១. កាមរាគានុសយ ធម្មជាតិដែលជាសេចក្ដីត្រេកអរ ជាប់ចិត្តក្នុងកាមគុណារម្មណ៍ ដែលដេកសម្ងំនៅក្នុងខន្ធសន្តាន កាលបានបច្ច័យប្រែសភាពជាបរិយុដ្ឋានកិលេស ក៏នឹងមានសភាពជា លោភចេតសិក ដែលប្រកបក្នុងលោភមូលចិត្ត ៨ ដួង ។

២. ភវរាគានុសយ ធម្មជាតិដែលជាសេចក្ដីត្រេកអរ ជាប់ចិត្តក្នុងអត្តភាពរបស់ខ្លួន ជាប់ចិត្តក្នុងរូបភព អរូបភព ឬរូបជ្ឈាន អរូបជ្ឈាន ដែលសូប់ដេកសម្ងំនៅក្នុងខន្ធសន្តាន កាលប្រែសភាពជាបរិយុដ្ឋានកិលេសហើយ បានដល់ លោភចេតសិក ដែលប្រកបក្នុងទិដ្ឋិគត-វិប្បយុត្តចិត្ត ៤ ដួង ។

៣. បដិឃានុសយ ធម្មជាតិដែលជាការមិនពេញចិត្តក្នុងអារម្មណ៍ ដែលសូប់ដេកសម្ងំនៅក្នុងខន្ធសន្តាន កាលប្រែសភាពជាបរិយុដ្ឋាន

កិលេសហើយ បានដល់ ទោសចេតសិកដែលនៅក្នុង ទោសមូលចិត្ត ២។

៤. មានានុសយ ធម្មជាតិដែលជាការលើកតម្កើងខ្លួន ប្រកាន់ខ្លួន ដែលស្ងប់ដេកសម្ងំនៅក្នុងខន្ធសន្តាន កាលប៉ះខ្ជប់អារម្មណ៍ ប្រែសភាពជាបរិយុដ្ឋានកិលេសហើយ បានដល់ **មានចេតសិក** ដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដូង ។

៥. ទិដ្ឋានុសយ ធម្មជាតិដែលជាការយល់ខុស ដែលដេកសម្ងំនៅក្នុងខន្ធសន្តាន កាលប៉ះខ្ជប់អារម្មណ៍ ប្រែសភាពជាបរិយុដ្ឋានកិលេសហើយ បានដល់ ទិដ្ឋិចេតសិក ដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដូង ។

៦. វិចិកិច្ឆានុសយ ធម្មជាតិដែលជាការសង្ស័យរារែកចិត្តក្នុងវត្ថុគួរជឿ ដែលដេកសម្ងំនៅក្នុងខន្ធសន្តាន កាលប៉ះខ្ជប់អារម្មណ៍ ប្រែសភាពជាបរិយុដ្ឋានកិលេសហើយ ជាសភាវធម៌ដែលហៅថា វិចិកិច្ឆាចេតសិក ដែលប្រកបក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដូង ។

៧. អវិជ្ជានុសយ ធម្មជាតិដែលជាសេចក្ដីលង់ មិនដឹងសភាវធម៌តាមសេចក្ដីពិត ដែលស្ងប់ដេកសម្ងំនៅក្នុងខន្ធសន្តាន កាលប៉ះខ្ជប់អារម្មណ៍ ប្រែសភាពជាបរិយុដ្ឋានកិលេសហើយ បានដល់ មោហចេតសិក ដែលប្រកបក្នុងអកុសលចិត្ត ១២ ដូង ។

អនុស័យ ៧ ប្រការនេះ កាលប្រែសភាពជាបរិយុដ្ឋានកិលេសហើយ មានប្រភេទអង្គធម៌ត្រឹមតែ ៦ យ៉ាង គឺ

១. លោភចេតសិក, ២. ទោសចេតសិក, ៣. មានចេតសិក, ៤. ទិដ្ឋិចេតសិក, ៥. វិចិកិច្ឆាចេតសិក, ៦. មោហចេតសក ។

ធម៌ដែលលះអនុស័យ ៧

បញ្ញាក្នុង សោតាបត្តិមគ្គចិត្ត លះទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ។

បញ្ញាក្នុង អនាគាមិមគ្គចិត្ត លះកាមរាគានុស័យ និងបដិឃានុស័យ

បញ្ញាក្នុង អរហត្តមគ្គចិត្ត លះភវរាគានុស័យ មានានុស័យ និងអវិជ្ជានុស័យ ។

៨. សំយោជន

សំយោជន បានដល់ ធម្មជាតិដែលជាគ្រឿងចងសត្វទាំងឡាយ ឱ្យជាប់នៅក្នុងវដ្តទុក្ខ ដូចខ្សែដែលចងសត្វទុកជាមួយបង្គោលមិនឱ្យរបូតផុតទៅបាន ដូចវចនត្ថ:សម្តែងថា **សំយោជេន្តិ ពន្ធន្តីតិ = សំយោជនានិ**

ប្រែថា ធម៌ទាំងឡាយណា រមែងចងសត្វទាំងឡាយទុក ធម៌ទាំង-ឡាយនោះ ឈ្មោះថា **សំយោជន** ។

ន័យម្យ៉ាងទៀត ក្នុងធម្មសង្គណីមូលដីកា សម្តែងថា

ទូរគតស្សបិ អាកឌ្ឍនតោ និស្សរិតុំ អប្បទានវសេន ពន្ធនំ = សំយោជនំ ប្រែថា ការចងសត្វឱ្យជាប់នៅក្នុងវដ្តទុក្ខដោយអំណាចមិនឱ្យចេញផុតចាកទុក្ខក្នុងវដ្ត ដោយអាការដែលចាប់អូស ឬទាញសត្វដែលនៅក្នុងទីឆ្ងាយឱ្យចុះមក ឈ្មោះថា **សំយោជន** ។

តាមធម្មតា ក្នុងសន្តានរបស់បុថុជ្ជនទាំងឡាយ រមែងមានធម្មជាតិម្យ៉ាង ប្រៀបដូចខ្សែ ១០ សរសៃ ដែលចងសត្វទុកមិនឱ្យរួចផុតពីកងទុក្ខបាន គឺ ត្រូវវិលវល់ស្លាប់កើតនៅក្នុងវដ្តទុក្ខ ខ្សែ ១០ សរសៃនោះ

ក៏គឺ សំយោជន:នោះឯង បើខ្សែសរសៃណាមួយតឹងឡើងហើយ សំយោជន:ខ្សែនោះក៏នឹងទាញយកសត្វនោះទៅកើតក្នុងភូមិដែលទាក់ទងជាមួយសំយោជន:នោះ។ ដោយអាស្រ័យកម្មដែលសត្វទាំងនោះ បានធ្វើទុក ។

សំយោជន:នេះ ពេលខ្លះក៏ប្រើជា សញ្ញោជន: មានសេចក្តីថា គ្រឿងចងសត្វទុក សម្តែងសំយោជនធម៌ មាន ២ ន័យ គឺ តាមន័យនៃព្រះអភិធម្ម និងតាមន័យនៃព្រះសូត្រ តែទាំង ២ ន័យនេះ ក៏មានចំនួនសំយោជន:មួយ។ ១០ ប្រការស្មើគ្នា និងក្នុងសំយោជន: ១០ ប្រការនេះ ចែកចេញជា ២ ពួក គឺ

១. ឱរម្ភាគិយសំយោជន បានដល់ សំយោជន:ដែលចងទាញសត្វទុកក្នុងភូមិខាងក្រោម គឺ កាមភូមិ ។

២. ឧទ្ធម្ភាគិយសំយោជន បានដល់ សំយោជន:ដែលចងទាញសត្វទុកក្នុងភូមិខាងលើ គឺ រូបភូមិ និងអរូបភូមិ ។

ចែកសំយោជន: ១០ តាមន័យនៃព្រះសូត្រ (សុត្តន្តន័យ)

១. កាមរាគសំយោជន បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត ៨ ដួង ។

២. រូបរាគសំយោជន បានដល់ លោភចេតសិកក្នុងទិដ្ឋិគតវិប្ប-យុត្តចិត្ត ៤ ដួង ។

៣. អរូបរាគសំយោជន បានដល់ លោភចេតសិកក្នុងទិដ្ឋិគត-វិប្បយុត្តចិត្ត ៤ ដូង ។

៤. បដិឃសំយោជន បានដល់ ទោសចេតសិកក្នុងទោសមូលចិត្ត ២ ដូង ។

៥. មានសំយោជន បានដល់ មានចេតសិកដែលនៅក្នុងទិដ្ឋិគត-វិប្បយុត្តចិត្ត ៤ ដូង ។

៦. ទិដ្ឋិសំយោជន បានដល់ ទិដ្ឋិចេតសិកដែលនៅក្នុងទិដ្ឋិគត-សម្បយុត្តចិត្ត ៤ ដូង ។

៧. សីលព្វតបរាមាសសំយោជន បានដល់ ទិដ្ឋិចេតសិកដែលនៅក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដូង ។

៨. វិចិកិច្ឆាសំយោជន បានដល់ វិចិកិច្ឆាចេតសិកក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដូង ។

៩. ឧទ្ធច្ចសំយោជន បានដល់ ឧទ្ធច្ចចេតសិកក្នុងអកុសលចិត្ត ១២ ដូង ។

១០. អវិជ្ជាសំយោជន បានដល់ មោហចេតសិកដែលនៅក្នុងអកុសលចិត្ត ១២ ដូង ។

ឱរម្ភាគិយសំយោជន ៥ ប្រការ

១. កាមរាគសំយោជន, ២. បដិឃសំយោជន, ៣. ទិដ្ឋិសំយោជន, ៤. សីលព្វតបរាមាសសំយោជន, ៥. វិចិកិច្ឆាសំយោជន ។

ឧទ្ធម្ភាគិយសំយោជន ៥ ប្រការ

១. រូបរាគសំយោជន, ២. អរូបរាគសំយោជន, ៣. មានសំយោជន, ៤. ឧទ្ធច្ចសំយោជន, ៥. អវិជ្ជាសំយោជន ។

ធម្មតា បុថុជ្ជនទាំងឡាយដែលមិនបានចម្រើនសមថភាវនាឱ្យចូលដល់ឈាន កាមរាគសំយោជន: រមែងតឹងជាប្រចាំជានិច្ច និងបើបានធ្វើទុច្ចរិតកម្មទុកច្រើន បដិឃសំយោជន:យ៉ាងគ្រោតគ្រាត ទិដ្ឋិសំយោជន: និងវិចិកិច្ឆាសំយោជន: ទាំង ៣ យ៉ាងនេះ ក៏និងមានឱកាសតឹងឡើង និងនាំទៅកាន់អបាយភូមិបាន ចំណែកសីលព្វតបរាមាសសំយោជន: និងមិនប្រាកដដល់បុគ្គលទូទៅ តែបើប្រាកដតឹងឡើងកាលណា ក៏អាចទាញទៅកាន់អបាយបានដូចគ្នា ។

បើបុគ្គលនោះធ្វើសុចរិតកម្មជាចំណែកច្រើន បដិឃសំយោជន: យ៉ាងសាមញ្ញ (មិននាំទៅកាន់អបាយ) សក្កាយទិដ្ឋិសំយោជន:ទាំង ២ នេះ មានឱកាសតឹងឡើងបាន និងនាំទៅកើតជាមនុស្ស ទេវតា ចំណែកមិច្ឆាទិដ្ឋិ សីលព្វតបរាមាស វិចិកិច្ឆាសំយោជន: ទាំង ៣ នេះ មិនមានឱកាសតឹងឡើងបានក្នុងការធ្វើកុសល ។

សម្រាប់បុថុជ្ជនដែលបានឈាន កាមរាគសំយោជន: បដិឃ-សំយោជន: និងសីលព្វតបរាមាសសំយោជន: ទាំង ៣ ប្រការនេះ មិនមានឱកាសនិងតឹងឡើងបានឡើយ ឧទ្ធម្ភាគិយសំយោជន: គឺ រូបរាគ: អរូបរាគ: មាន: ឧទ្ធច្ច: និងអវិជ្ជាសំយោជន:ប៉ុណ្ណោះ ដែលមានឱកាសតឹងឡើង ស្រេចហើយតែរូបជ្ឈាន ឬអរូបជ្ឈានដែលខ្លួនបាន ដោយ

ហេតុនេះ ឈានលាភីបុគ្គល កាលស្លាប់ពីកាមភូមិទើបទៅកើតក្នុងរូបភូមិ ឬអរូបភូមិ តាមសមគួរដល់ឈាន តែបុថុជ្ជនដែលទៅកើតជាព្រហ្មនេះ នៅមិនបានប្រហារកាមរាគសំយោជន: បដិឃសំយោជន: ឱ្យជាសមុច្ឆេទទេ ប្រហារដើម្បីការគ្របសង្កត់ដោយអំណាចរបស់ឈានប៉ុណ្ណោះ ។

ដូច្នោះ កាលព្រហ្មអង្គណាសាបសូន្យចាកឈាន និងស្លាប់ហើយ ក៏នឹងកើតជាព្រហ្មតទៅទៀតមិនបាន ត្រូវមកកើតក្នុងកាមភូមិ ជាមនុស្ស ឬទេវតាពិតប្រាកដ ដែលជាដូច្នេះ ក៏ដោយអំណាចរបស់កាមរាគសំយោជន: បដិឃសំយោជន: ដែលចងព័ទ្ធនៅក្នុងខន្ធសន្តានរបស់ខ្លួនឯង ជាអ្នកទាញចុះមកដោយឱរម្ភាគិយសំយោជន: ។

ចំណែក ព្រះអរិយបុគ្គលអ្នកសម្រេចជាព្រះសោតាបន្ន ឬព្រះសកទាគামិបុគ្គលនោះ ប្រហារទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសសំយោជន: ទាំង ៣ នេះ ដោយដាច់ជាសមុច្ឆេទហើយ ទើបផុតចាកការទាញទៅកាន់ហេដ្ឋិមសង្ឃារ គឺ អបាយភូមិ ៤ តែនៅមិនផុតចាកមជ្ឈិមសង្ឃារ គឺ មនុស្សភូមិ ទេវភូមិ និងឧបរិមសង្ឃារ គឺ រូបភូមិ អរូបភូមិ ដែលជាភូមិថ្នាក់ខ្ពស់ ទាំងនេះព្រោះនៅមានសំយោជន:ដែលសល់ ៧ ទៀត នៅក្នុងខន្ធសន្តាន ដល់កាលសម្រេចជា ព្រះអនាគាមី ក៏នឹងប្រហារកាមរាគសំយោជន: និងបដិឃសំយោជន:ទាំង ២ នេះ បានដោយដាច់ជាសមុច្ឆេទ ២ ប្រការទៀត ជាការដាច់ចាកមជ្ឈិមសង្ឃារ បានដាច់ជាសមុច្ឆេទនោះ គឺ ព្រះអនាគាមីនឹងផុតចាកការកើតក្នុងមនុស្សភូមិ និង

ទេវភូមិ តែនឹងទៅកើតក្នុងរូបភូមិឬអរូបភូមិប៉ុណ្ណោះ ទាំងនេះព្រោះ ឧទ្ធម្ភាគិយសំយោជន:នៅមានដល់កាលសម្រេចជាព្រះអរហន្ត ក៏នឹងផុតចាក ឧបរិមសង្សារទៀត កាលបរិនិញ្ចាននោះ ក៏គឺ ផុតចាកសេចក្តីវិលវល់កើតស្លាប់ហើយ មិនថាក្នុងសង្សារណាៗ ទាំងនេះព្រោះបានកាត់ផ្តាច់សរសៃនៃសំយោជនធម៌ ១០ ប្រការ ដោយអស់ហើយនោះឯង ។

មួយទៀត ក្នុងបរមត្ថទីបនីដីកាសម្តែងថា សំយោជន:ដែលត្រូវប្រហារដោយមគ្គខាងក្រោម គឺ សោតាបត្តិមគ្គ សកទាគាមិមគ្គ និងអនាគាមិមគ្គនោះឈ្មោះថា ឱរម្ភាគិយសំយោជន: ចំណែកសំយោជន: ដែលត្រូវប្រហារដោយ អរហត្តមគ្គនោះ ឈ្មោះថា ឧទ្ធម្ភាគិយ-សំយោជន:។

ចែកសំយោជន: ១០ តាមន័យនៃព្រះអភិធម្ម

១. កាមរាគសំយោជន បានដល់ លោភចេតសិកដែលនៅក្នុងលោភមូលចិត្ត ៨ ដូង ។

២. ភវរាគសំយោជន បានដល់ លោភចេតសិកដែលនៅក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដូង ។

៣. បដិយសំយោជន បានដល់ ទោសចេតសិកដែលនៅក្នុងទោសមូលចិត្ត ២ ដូង ។

៤. មានសំយោជន បានដល់ មានចេតសិកដែលនៅក្នុងទិដ្ឋិគត-វិប្បយុត្តចិត្ត ៤ ដូង ។

៥. ទិដ្ឋិសំយោជន បានដល់ ទិដ្ឋិចេតសិកដែលនៅក្នុងទិដ្ឋិគត-សម្បយុត្តចិត្ត ៤ ដួង ។

៦. សីលព្ធតបរាមាសសំយោជន បានដល់ ទិដ្ឋិចេតសិកដែលនៅក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង ។

៧. វិចិកិច្ឆាសំយោជន បានដល់ វិចិកិច្ឆាចេតសិកដែលនៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង ។

៨. ឥស្សាសំយោជន បានដល់ ឥស្សាចេតសិកដែលនៅក្នុងទោសមូលចិត្ត ២ ដួង ។

៩. មច្ឆរិយសំយោជន បានដល់ មច្ឆរិយចេតសិកដែលនៅក្នុងទោសមូលចិត្ត ២ ដួង ។

១០. អវិជ្ជាសំយោជន បានដល់ មោហចេតសិកដែលនៅក្នុងអកុសលចិត្ត ១២ ដួង ។

ឱរម្ភាគិយសំយោជន ៧ ប្រការ

១. កាមរាគសំយោជន, ២. បដិឃសំយោជន, ៣. ទិដ្ឋិសំយោជន, ៤. សីលព្ធតបរាមាសសំយោជន, ៥. វិចិកិច្ឆាសំយោជន, ៦. ឥស្សា-សំយោជន, ៧. មច្ឆរិយសំយោជន ។

ឧទ្ធម្ភាគិយសំយោជន ៣ ប្រការ

១. ភវរាគសំយោជន, ២. មានសំយោជន, ៣. អវិជ្ជាសំយោជន ។

សំយោជន: ១០ ប្រការ តាមន័យព្រះអភិធម្មនេះ ឱរម្ភាគិយ-សំយោជន គឺ កិលេសធម៌ ដែលជាចំណែកចងសត្វទុកក្នុងភូមិថ្នាក់ទាប មាន ៧ ប្រការ តែចំណែក ឧទ្ធម្ភាគិយសំយោជន: គឺ កិលេសធម៌ដែលជាចំណែកចងសត្វទុកក្នុងថ្នាក់ខ្ពស់នោះ មានត្រឹមតែ ៣ ប្រការ ចំណែកហេតុផលដែលចងសត្វទុកក្នុង ហេដ្ឋិមសង្សារក្តី មជ្ឈិមសង្សារក្តី ឧបរិមសង្សារក្តី រហូតដល់ការកាត់ផ្តាច់សំយោជន:គ្រឿងចងសត្វឱ្យដាច់អស់ទៅ គប្បីជ្រាបអនុលោមតាមន័យដែលបានពោលហើយ ។

សង្ក្រោះអង្គធម៌របស់សំយោជន:តាមន័យទាំង ២

សំយោជន:តាមន័យនៃព្រះសូត្រ ១០ ប្រការ មានអង្គធម៌ ៧ គឺ

១. លោភចេតសិក, ២. ទោសចេតសិក, ៣. មានចេតសិក, ៤. ទិដ្ឋិចេតសិក, ៥. វិចិកិច្ឆាចេតសិក, ៦. ឧទ្ធច្ចចេតសិក, ៧. មោហ-ចេតសិក ។

សំយោជន:តាមន័យនៃព្រះអភិធម្ម ១០ ប្រការ មានអង្គធម៌ ៨

១. លោភចេតសិក, ២. ទោសចេតសិក, ៣. មានចេតសិក, ៤. ទិដ្ឋិចេតសិក, ៥. វិចិកិច្ឆាចេតសិក, ៦. ឥស្សាចេតសិក, ៧. មច្ឆរិយ-ចេតសិក, ៨. មោហាចេតសិក ។

កាលរួបរួមអង្គធម៌របស់សំយោជនៈទាំង ២ ន័យហើយ
បានអង្គធម៌ ៩ គឺ

១. លោភចេតសិក, ២. ទោសចេតសិក, ៣. មានចេតសិក, ៤. ទិដ្ឋិចេតសិក, ៥. វិចិកិច្ឆាចេតសិក, ៦. ឥស្សាចេតសិក, ៧. មច្ឆរិយ-ចេតសិក, ៨. ឧទ្ធច្ចចេតសិក, ៩. មោហាចេតសិក ។

៩. **កិលេស**

កិលេស ជាធម្មជាតិដែលធ្វើឱ្យកើតការសៅហ្មងក្តៅក្រហាយទាំងចិត្ត និងកាយ សេចក្តីថា ចិត្ត ចេតសិក រូប ដែលកើតព្រមជាមួយកិលេស រមែងត្រូវសៅហ្មងក្តៅក្រហាយតាមកិលេសទៅផងដែរ កិលេសជាអកុសលចេតសិកពួកមួយ កាលប្រកបជាមួយចិត្តហើយ រមែងធ្វើចិត្តឱ្យជាអកុសលតាមចេតសិកទៅផងដែរ និងរូបដែលកើតពីអកុសលចិត្តទាំងនោះ ក៏បណ្តោយតាមការសៅហ្មងក្តៅក្រហាយទៅផងដែរ ព្រោះធម្មជាតិចិត្តរបស់បុគ្គលដែលមិនបានប្រកបដោយកិលេស គឺ សេចក្តីលោភ សេចក្តីក្រោធ ឬសេចក្តីល្ងង់ជាដើម បុគ្គលនោះ រមែងដឹងខ្លួនថាចិត្តក្នុងខណៈនោះស្រឡះល្អ សប្បាយចិត្តនិងសប្បាយកាយ មុខស្រស់ថ្លា មិនមានសេចក្តីក្តៅក្រហាយកាយចិត្តដោយប្រការណាឡើយ និងថែមទាំងជាទីសប្បាយភ្នែកសប្បាយចិត្តដល់អ្នកដែលបានជួបទៀតផង តែបើក្នុងខណៈណាចិត្តរបស់បុគ្គលម្នាក់ មានសេចក្តីលោភ សេចក្តីក្រោធក្តៅងំក្នុងចិត្តហើយ អ្នកនោះក៏មានសេចក្តីក្តៅក្រហាយចិត្ត រូប

រាងកាយមុខមាត់មិនស្រស់ថ្លា ដោយអំណាចរបស់កិលេសដូចពោលហើយ ថែមទាំងឱ្យអ្នកដទៃមកឃើញហើយ ក៏មិនសប្បាយចិត្តដល់អ្នកនោះទៀតផង ។

ដូច្នោះ ព្រះពុទ្ធអង្គទើបទ្រង់ហៅអកុសលចិត្តប្រការខ្លះ ដែលមានសភាពធ្វើឱ្យកើតសេចក្តីសៅហ្មងដល់កាយនិងចិត្តនេះថា កិលេស ដូចមានវចនត្ថ:សម្តែងថា

កិលេសេន្តិ ឧបតាបេន្តីតិ = កិលេសា

ប្រែថា ធម្មជាតិណា រមែងធ្វើឱ្យក្តៅក្រហាយសៅហ្មង ធម្មជាតិនោះ ឈ្មោះថា កិលេស ន័យម្យ៉ាងទៀត

កិលិស្សតិ ឯតេហីតិ = កិលេសា

ប្រែថា សម្បយុត្តធម៌ គឺ ចិត្ត ចេតសិក រមែងសៅហ្មងក្តៅក្រហាយដោយធម្មជាតិណា ដូច្នោះ ធម្មជាតិដែលជាហេតុនៃសេចក្តីសៅហ្មងក្តៅក្រហាយរបស់សម្បយុត្តធម៌នោះ ទើបឈ្មោះថា កិលេស ។

កិលេសមាន ១០ ប្រការ

១. លោភកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ ព្រោះត្រេកអរជាប់ចិត្តក្នុងលោកិយារម្មណ៍ អង្គធម៌ បានដល់ លោភ-ចេតសិក ដែលនៅក្នុងលោភមូលចិត្ត ៨ ដួង ។

២. ទោសកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ ព្រោះសេចក្តីក្រោធ គឺ ការមិនពេញចិត្តក្នុងអារម្មណ៍ អង្គធម៌ បានដល់

ទោសចេតសិក ដែលនៅក្នុងទោសមូលចិត្ត ២ ដួង ។

៣. មោហកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ ព្រោះសេចក្តីលង់ មិនដឹងសភាវធម៌តាមសេចក្តីពិត អង្គធម៌ បានដល់ មោហចេតសិក ដែលនៅក្នុងអកុសលចិត្ត ១២ ដួង ។

៤. មានកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ ព្រោះសេចក្តីក្រអឺតក្រអោងប្រកាន់ខ្លួន អង្គធម៌ បានដល់ **មានចេតសិក** ដែលនៅក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង ។

៥. ទិដ្ឋិកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ ព្រោះការយល់ឃើញខុស អង្គធម៌ បានដល់ ទិដ្ឋិចេតសិក ដែលនៅក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង ។

៦. វិចិកិច្ឆាកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ ព្រោះសេចក្តីសង្ស័យរារែកចិត្ត ក្នុងវត្ថុដែលគួរជឿ អង្គធម៌ បានដល់ វិចិកិច្ឆាចេតសិក ដែលនៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង ។

៧. ថីនកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ ព្រោះសេចក្តីរួញរាថយចាកអារម្មណ៍ អង្គធម៌ បានដល់ ថីនចេតសិក ដែលនៅក្នុងអកុសលសសង្ខារិកចិត្ត ៥ ដួង ។

៨. ឧទ្ធច្ចកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ ព្រោះសេចក្តីរវើរវាយ អង្គធម៌ បានដល់ ឧទ្ធច្ចចេតសិក ដែលនៅក្នុងអកុសលចិត្ត ១២ ដួង ។

៩. អហិរិកកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ

ព្រោះការមិនខ្មាសដល់បាបទុច្ចរិត អង្គធម៌ បានដល់ អហិរិកចេតសិក ដែលនៅក្នុង អកុសលចិត្ត ១២ ដូង ។

១០. អនោត្តប្បកិលេស ធម្មជាតិដែលជាគ្រឿងសៅហ្មងក្តៅក្រហាយ ព្រោះការមិនខ្លាចក្រែងដល់បាបទុច្ចរិត អង្គធម៌ បានដល់ អនោត្តប្បចេតសិក ដែលនៅក្នុង អកុសលចិត្ត ១២ ដូង ។

រូមកិលេស ១០ ប្រការនេះ មានអង្គធម៌ ១០ យ៉ាង ស្មើគ្នា ។

ធម៌ដែលលះកិលេស ១០

បញ្ញាក្នុង សោតាបត្តិមគ្គចិត្ត លះទិដ្ឋិ និងវិចិកិច្ឆា ។

បញ្ញាក្នុង អនាគាមិមគ្គចិត្ត លះទោស ។

បញ្ញាក្នុង អរហត្តមគ្គចិត្ត លះកិលេសដែលនៅសល់ ៧ យ៉ាង ទាំងអស់ ។

ឋានរបស់កិលេស ចែកចេញបានជា ៣ ថ្នាក់គឺ

១. អនុសយកិលេស ជាកិលេសយ៉ាងល្អិត ដែលដេកសម្ងំនៅក្នុងខន្ធសន្តាន គឺ កិលេសដែលលះមិនទាន់បាន ។

២. បរិយុដ្ឋានកិលេស ជាកិលេសយ៉ាងកណ្តាល ដែលក្តៅងំនៅក្នុងចិត្ត ។

៣. វីតិក្កមកិលេស ជាកិលេសយ៉ាងគ្រោតគ្រាត ដែលសម្តែងចេញតាមផ្លូវកាយ និងវាចា ។

កិលេសពិស្តារ ១.៥០០ ប្រការ

កិលេសអង្គធម៌ ១០ ប្រការនោះ កាលរាប់ជាប់ដោយសភាវ: របស់អារម្មណ៍ដែលជាបច្ច័យឱ្យកិលេសកើតបានហើយ មានទាំងអស់ ១.៥០០ ប្រការ គឺ

ធម៌ដែលជាអារម្មណ៍របស់កិលេសដោយសភាវធម៌ មាន ៧៥ បានដល់ **ចិត្ត ១, ចេតសិក ៥២, និប្ផន្នរូប ១៨, លក្ខណរូប ៤ = ៧៥**

អារម្មណ៍ទាំងនេះ រមែងមាននៅខាងក្នុងខ្លួន ជាអជ្ឈត្តារម្មណ៍ និងមាននៅក្នុងអ្នកដទៃដែលជាអារម្មណ៍ខាងក្រៅខ្លួន ជាពហិទ្ធារម្មណ៍ បានទាំង ២ ប្រការ អារម្មណ៍របស់កិលេសដែលជា អជ្ឈត្តធម៌ ទើបមាន ៧៥ និងដែលជាពហិទ្ធធម៌ ៧៥ ទៀត រួម **អារម្មណធម៌** របស់កិលេសទាំងខាងក្នុងនិងខាងក្រៅ ទើបមាន ១៥០ ប្រការ គុណដោយកិលេស ១០ ទើបបានកិលេសពិស្តារ ១.៥០០ ប្រការដូច្នេះ ។

រួមសេចក្ដីថា អារម្មណ៍ដែលជាបច្ច័យដល់កិលេស បានទាំងអជ្ឈត្តពហិទ្ធធម៌ ខាងក្នុងនិងខាងក្រៅ ១៥០ គុណដោយកិលេស ១០ ទើបជាកិលេសពិស្តារ ១.៥០០ ប្រការ ។

តណ្ហា ១០៨

សម្រាប់តណ្ហា ក៏មានការចែកចេញទៅដោយពិស្តារថា តណ្ហា ១០៨ ប្រការ គឺ

ដោយអារម្មណ៍របស់តណ្ហាមាន ៦ បានដល់ រូបតណ្ហា សទ្ទតណ្ហា

គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា និងធម្មតណ្ហា ។

ដោយសភាពរបស់តណ្ហាមាន ៣ បានដល់ កាមតណ្ហា ១ ភវតណ្ហា ១ និងវិភវតណ្ហា ១ ។

ដោយអារម្មណ៍ ៦ គុណនឹងសភាពរបស់តណ្ហា ៣ ជាតណ្ហា ១៨

តណ្ហា ១៨ ប្រការនេះ កើតឡើងខាងក្នុងសន្តានរបស់ខ្លួនជាអជ្ឈត្ត និងកើតឡើងខាងក្រៅសន្តាននៃខ្លួនជា ពហិទ្ធ សំដៅដល់ ការកើតជាមួយអ្នកដទៃ ទើបជាតណ្ហា ៣៦ ប្រការ ។

ដោយកាល តណ្ហាទាំង ៣៦ ប្រការនេះ រមែងកើតបានក្នុងកាលទាំង ៣ ជាបច្ចុប្បន្ន ១ អតីត ១ និងអនាគត ១ តណ្ហាដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ គុណតណ្ហា ៣៦ ប្រការ ទើបរួមជាតណ្ហា ១០៨ ប្រការ ។

សរុបសេចក្ដីថា អារម្មណ៍របស់តណ្ហាមាន ៦ សភាពរបស់តណ្ហាមាន ៣ កើតបានទាំង អជ្ឈត្តពហិទ្ធ ២ និងក្នុងកាលទាំង ៣ ចំនួនតណ្ហាដោយពិស្តារ ទើបបានដល់ អារម្មណ៍ ៦ គុណដោយតណ្ហា ៣ គុណដោយខាងក្នុង និងខាងក្រៅសន្តាន ២ គុណដោយកាល ៣ ទើបរួមជាតណ្ហា ១០៨ ប្រការ ។

សរុបអង្គធម៌ក្នុងអកុសលសង្គហៈ ៩ កង

លោភចេតសិក ជាអង្គធម៌របស់អកុសលទាំង ៩ កង ។

ទិដ្ឋិចេតសិក ជាអង្គធម៌របស់អកុសលទាំង ៨ កង (រៀរនីវរណៈ)។

មោហចេតសិក ជាអង្គធម៌របស់អកុសលទាំង ៧ កង (រៀងគន្ត:-ឧបាទាន) ។

ទោសចេតសិក ជាអង្គធម៌របស់អកុសលទាំង ៥ កង គឺ គន្ត: នីវរណ: អនុស័យ សំយោជន: កិលេស ។

វិចិកិច្ឆាចេតសិក ជាអង្គធម៌របស់អកុសលទាំង ៤ កង គឺ នីវរណ: អនុស័យ សំយោជន: កិលេស ។

ឧទ្ធច្ចចេតសិក ជាអង្គធម៌របស់អកុសលទាំង ៣ កង គឺ នីវរណ: សំយោជន: កិលេស ។

មានចេតសិក ជាអង្គធម៌របស់អកុសលទាំង ៣ កង គឺ អនុស័យ សំយោជន: កិលេស ។

ថីនចេតសិក ជាអង្គធម៌របស់អកុសលទាំង ២ កង គឺ នីវរណ: កិលេស ។

មិទ្ធចេតសិក ជាអង្គធម៌របស់អកុសល ១ កង គឺ នីវរណ: ។

កុក្កុច្ចចេតសិក ជាអង្គធម៌របស់អកុសល ១ កង គឺ នីវរណ: ។

ឥស្សាចេតសិក ជាអង្គធម៌របស់អកុសល ១ កង គឺ សំយោជន:។

មច្ឆរិយចេតសិក ជាអង្គធម៌របស់អកុសល ១ កង គឺ សំយោជន:។

អហិរិកចេតសិក ជាអង្គធម៌របស់អកុសល ១ កង គឺ កិលេស ។

អនោត្តប្បចេតសិក ជាអង្គធម៌របស់អកុសល ១ កង គឺ កិលេស។

ចប់ អកុសលសង្គហ:

ពួកទី ២ មិស្សកសង្គហ:

មិស្សកសង្គហ ជាពួកដែលសង្ត្រោះសភាវធម៌ផ្សេងៗ ដោយភាពជាកុសល អកុសល និងអព្យាកត លាយឡំគ្នា ដូចជាហេតុសង្គហ: ជាដើម ជាធម៌ដែលបានទាំងកុសល អកុសល និងអព្យាកត លាយគ្នា ដូចមានវចនត្ថ:ថា

កុសលាកុសលាព្យាកតមិស្សកានំ ហេតុឆក្កាទីនំ សង្គហោតិ = មិស្សកសង្គហោ

ប្រែថា ពួកធម៌ផ្សេងៗ មានហេតុ ៦ ជាដើម ដែលសង្ត្រោះ លាយចូលគ្នាបាន ទាំងកុសល អកុសល និងអព្យាកតនោះ ហៅថា មិស្សកសង្គហ: ។

មិស្សកសង្គហ:នេះ ចែកការសម្តែងធម៌ចេញជា ៧ កង គឺ

១. ហេតុ, ២. ឈានង្គ:, ៣. មគ្គង្គ, ៤. ឥន្ទ្រិយ, ៥. ពល:, ៦. អធិបតី, ៧. អាហារ ។

តាមន័យដែលបានសម្តែងទុកក្នុងគាថាសង្គហ: ដូច្នេះ

គាថាសង្គហ:ទី ៤-៥

៤. ឆ ហេតូ បញ្ច ឈានង្គា មគ្គង្គា នវ វត្ថុតោ
សោឡសិន្ទ្រិយធម្មា ច ពលធម្មា នវេរិតា ។
៥. ចត្តារោធិបតិ វុត្តា តថាហារាតិ សត្តធា
កុសលាទិសមាកិណ្ណោ វុត្តោមិស្សកសង្គហោ ។

ហេតុ មានអង្គធម៌ ៦, **ឈានង្គ** មានអង្គធម៌ ៥, **មគ្គង្គ** មានអង្គធម៌ ៩, **ឥន្ទ្រិយ** មានអង្គធម៌ ១៦, **ពល** មានអង្គធម៌ ៩, **អធិបតី** មានអង្គធម៌ ៤, **អាហារ** មានអង្គធម៌ ៤ ដូចគ្នា គប្បីជ្រាបការសម្តែងមិស្សកសង្គហ: ដែលមានកុសល ជាដើម លាយគ្នា ដោយមាន ៧ កង ដូច្នេះ ។

ពោលដោយប្រភេទ មាន ៦៤ ប្រភេទ នឹងបានសម្តែងតាមលំដាប់តទៅ ។

១. ហេតុ

ហេតុ ជាធម៌ដែលធ្វើឱ្យផលកើតឡើង ធ្វើឱ្យផលធម៌នោះតាំងមាំក្នុងអារម្មណ៍ និងធ្វើឱ្យចម្រើនឡើងបាន មានវចនត្ថ:សម្តែងថា

ហិនោតិ វត្តតិ ផលំ ឯតេហិ ឥតិ ហេតវោ
លទ្ធហេតូហិ តេ ថិរា រុឡ្ហមូលាវ បាទបា ។

ប្រែថា ផលធម៌រមែងកើតឡើងព្រោះធម៌ទាំងនេះ ដូច្នោះធម៌ទាំងនេះ ទើបឈ្មោះថា ហេតុ ។

សេចក្តីថា ធម៌ទាំងឡាយដែលបានឧបការ:អំពីហេតុ រមែងមានសភាពតាំងមាំក្នុងអារម្មណ៍ ដូចដើមឈើដែលមានឫសលូតលាស់ល្អ ផ្សាយទៅដូច្នោះ ។

ហេតុមាន ៦ ប្រការ

១. លោភហេតុ ធម្មជាតិដែលជាការចង់បាន ជាហេតុឱ្យរូបនាមដែលកើតព្រមគ្នាជាមួយខ្លួន តាំងមាំនិងចម្រើនឡើងបានក្នុងអារម្មណ៍

អង្គធម៌ បានដល់ លោភចេតសិក ដែលនៅក្នុងលោភមូលចិត្ត ៨ ដួង ។

២. ទោសហេតុ ធម្មជាតិដែលជាសេចក្ដីក្រោធ ជាហេតុឱ្យ រូបនាមកើតឡើងព្រមគ្នាជាមួយខ្លួន តាំងមាំនិងចម្រើនឡើងបានក្នុង អារម្មណ៍ អង្គធម៌ បានដល់ ទោសចេតសិក ដែលនៅក្នុងទោសមូលចិត្ត ២ ដួង ។

៣. មោហហេតុ ធម្មជាតិដែលជាសេចក្ដីល្ងង់ ជាហេតុឱ្យរូបនាម ដែលកើតព្រមជាមួយខ្លួន តាំងមាំនិងចម្រើនឡើងបានក្នុងអារម្មណ៍ អង្គធម៌ បានដល់ មោហចេតសិក ដែលនៅក្នុងអកុសលចិត្ត ១២ ដួង ។

៤. អលោភហេតុ ធម្មជាតិដែលជាមិនជាប់ចិត្តក្នុងកាមគុណា-រម្មណ៍ គឺ ការមិនលោភ ឬការលះបង់ ជាហេតុឱ្យរូបនាមដែលកើតព្រម គ្នាជាមួយខ្លួន តាំងមាំនិងចម្រើនឡើងបានក្នុងអារម្មណ៍ អង្គធម៌ បានដល់ អលោភចេតសិក ដែលនៅក្នុងសោភណចិត្ត ៥៩ ឬ ៩១ ដួង ។

៥. អទោសហេតុ ធម្មជាតិដែលជាមិនក្រោធ អត់សង្កត់និងជួយ សង្គ្រោះមានចិត្តមេត្តា ជាហេតុឱ្យរូបនាមដែលកើតព្រមគ្នាជាមួយខ្លួន តាំងមាំនិងចម្រើនឡើងបានក្នុងអារម្មណ៍ អង្គធម៌ បានដល់ អទោស ចេតសិក ដែលនៅក្នុងសោភណចិត្ត ៥៩ ឬ ៩១ ដួង ។

៦. អមោហហេតុ ធម្មជាតិដែលឆ្លាត មិនល្ងង់រវើរជាហេតុឱ្យ រូបនាមដែលកើតព្រមគ្នាជាមួយខ្លួន តាំងមាំនិងចម្រើនឡើងបានក្នុង អារម្មណ៍ អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងញាណសម្បយុត្ត ចិត្ត ៤៧ ឬ ៧៩ ដួង ។

លោភហេតុ ទោសហេតុ មោហហេតុ ជាហេតុដែលប្រកបក្នុងអកុសលចិត្ត ហើយអកុសលចេតសិក ទើបហៅថា អកុសលហេតុ ។

អលោភហេតុ អទោសហេតុ អមោហហេតុ កាលប្រកបក្នុងសោភណចិត្ត ប្រភេទដែលជាកុសលចិត្ត ហៅថា កុសលហេតុ ។

អលោភហេតុ អទោសហេតុ អមោហហេតុ កាលប្រកបក្នុងសោភណចិត្ត ប្រភេទដែលជាវិបាកចិត្ត និងកិរិយាចិត្ត ហៅថា អព្យាកតហេតុ ។

ហេតុទាំង ៦ ដូចពោលមកនេះ មានទាំងដែលជាអកុសលហេតុ កុសលហេតុ និងអព្យាកតហេតុ ទើបនាំធម៌ពួកនេះមកសម្តែងក្នុងមិស្សកសង្គហ: ។

ហេតុ ៦ ប្រការនេះ មានពោលដោយពិស្តារទុកក្នុងបរិច្ឆេទទី ៣ ហើយ ។

២. ឈានន្ត

ឈាន ជាធម្មជាតិដែលធ្វើឱ្យចិត្តផ្ចោតចំពោះអារម្មណ៍ ឬសម្លឹងអារម្មណ៍ មានវចនត្ថ:សម្តែងថា

អាលម្ពមុបនិជ្ឌ្យន្តិ ឥតិ ឈានានិ វុច្ចរេ
ឈាបេន្តិ វា បច្ចនិកេ ឥតិបិ ឈានសញ្ញិតា ។

ប្រែថា ធម្មជាតិណា រមែងសម្លឹងអារម្មណ៍ មានកសិណ ជាដើម ដូច្នោះធម្មជាតិនោះ ឈ្មោះថា **ឈាន** ។

ធម្មជាតិណា រមែងដុតនូវធម៌ដែលជាបដិបក្ខនឹងគ្នា ដូច្នោះ ធម្ម-ជាតិនោះ ឈ្មោះថា **ឈាន** ។

ដូច្នោះ ដែលហៅថា **ឈាន** ទើបមាន ២ ន័យ គឺ ឈាន ជាធម្មជាតិដែលមានសភាពសម្លឹងអារម្មណ៍ម្យ៉ាង មិនកំណត់ថា ជាការសម្លឹងអារម្មណ៍កម្មដ្ឋានអ្វីក្តី ជាលោកិយឬលោកុត្តរអារម្មណ៍ បរមត្ថ ឬបញ្ញត្តិអារម្មណ៍ក្តី ការសម្លឹងអារម្មណ៍ទាំងនោះ ជាអារម្មណ៍របស់ឈានទាំងអស់ ។

ន័យម្យ៉ាងទៀត **ឈាន** ប្រែថា ដុត សំដៅដល់ ធ្វើឱ្យធម៌ដែលជាបដិបក្ខជាមួយខ្លួនមានកម្លាំងថយចុះទៅ ឬមិនឱ្យកើតឡើងបាន បានដល់ អង្គឈាន ៦ ដែលប្រកបក្នុង មហាគ្គតចិត្ត ចំណែកអង្គឈានដែលនៅក្នុងកាមចិត្តនោះ មានសភាពចូលទៅសម្លឹងអារម្មណ៍ច្រើនជាងនឹងដុតធម៌ដែលជាបដិបក្ខជាមួយខ្លួន ។

ឈានង្គ:មាន ៧ ប្រភេទ

១. វិតក្ក ធម្មជាតិដែលលើកចិត្តឡើងកាន់អារម្មណ៍ ជាការសម្លឹងអារម្មណ៍ អង្គធម៌ បានដល់ វិតក្កចេតសិក ដែលនៅក្នុងកាមចិត្ត ៤៤ (រៀរទ្វិបញ្ចវិញ្ញាណ ១០) បឋមជ្ឈានចិត្ត ១១ ។

២. វិចារ ធម្មជាតិដែលពិចារណាអារម្មណ៍ ផ្ចងចិត្តឱ្យជាប់នៅក្នុងអារម្មណ៍ អង្គធម៌ បានដល់ វិចារចេតសិក ដែលនៅក្នុងកាមចិត្ត ៤៤ បឋមជ្ឈានចិត្ត ១១ ទុតិយជ្ឈានចិត្ត ១១ ។

៣. បីតិ ធម្មជាតិដែលមានការរីករាយត្រេកអរក្នុងអារម្មណ៍ ជាការសម្លឹងអារម្មណ៍ ដោយសេចក្តីឆ្អែតចិត្ត អង្គធម៌ បានដល់ បីតិចេតសិក ដែលនៅក្នុងកាមសោមនស្សចិត្ត ១៨ បឋមជ្ឈានចិត្ត ១១ ទុតិយជ្ឈានចិត្ត ១១ និងតតិយជ្ឈានចិត្ត ១១ ។

៤. ឯកគ្គតា ធម្មជាតិដែលតាំងមាំនៅក្នុងអារម្មណ៍តែមួយ ជាគ្រឿងសម្លឹងអារម្មណ៍ឱ្យមាំ អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលនៅក្នុងចិត្ត ៧៩ ឬ ១១១ (រៀរទ្វិបញ្ចវិញ្ញាណ ១០) ។

៥. សោមនស្សវេទនា ធម្មជាតិដែលសោយអារម្មណ៍ជាសុខក្នុងការសម្លឹងអារម្មណ៍ អង្គធម៌ បានដល់ វេទនាចេតសិក ដែលនៅក្នុងសោមនស្សសហគតចិត្ត ៦២ ។

៦. ទោមនស្សវេទនា ធម្មជាតិដែលសោយអារម្មណ៍ ជាទុក្ខក្នុងការសម្លឹងអារម្មណ៍ អង្គធម៌ បានដល់ វេទនាចេតសិក ដែលនៅក្នុងទោសមូលចិត្ត ២ ។

៧. ឧបេក្ខាវេទនា ធម្មជាតិដែលសោយអារម្មណ៍ ជាកណ្តាលមិនសុខ មិនទុក្ខ ក្នុងការសម្លឹងអារម្មណ៍ អង្គធម៌ បានដល់ វេទនាចេតសិក ដែលនៅក្នុងឧបេក្ខាសហគតចិត្ត ៤៧ (រៀរឧបេក្ខាវេទនាក្នុងទ្វិចតុវិញ្ញាណ ៨) ។

ឈានង្គ: មាន ៧ ប្រភេទ តែអង្គធម៌មាន ៥ ប្រការ គឺ

វិតក្ក, វិចារ, បីតិ, វេទនា, និងឯកគ្គតា សម្រាប់សោមនស្ស ទោមនស្ស ឧបេក្ខា ទាំង ៣ ប្រភេទរបស់ឈាននេះ មានអង្គធម៌ គឺ

វេទនាចេតសិកតែម្យ៉ាង ។

រួមសេចក្ដីថា ធម៌ដែលជាអ្នកសម្ជឹងអារម្មណ៍នោះ បានដល់ ឈាន ៧ ប្រភេទនេះឯង និងការសម្ជឹងអារម្មណ៍នោះ ក៏ព្រមដោយកុសល អកុសល អព្យាកត បានទាំងអស់ រៀងតែទោមនស្សវេទនា មួយប្រភេទ ដែលបានចំពោះតែអកុសលប៉ុណ្ណោះ ទើបចាត់ឈានង្គ:ទុកក្នុងពួកធម៌ ដែលជាមិស្សកសង្គហ: សម្រាប់ឈានដែលដុតបដិបក្ខធម៌នោះ គង់ បានដល់ ឈាន ៦ ប្រភេទ (រៀងទោមនស្សវេទនា) ដែលនៅក្នុង មហាគ្គតចិត្ត រមែងដុតបដិបក្ខធម៌បានយ៉ាងប្រាកដច្បាស់ជាងដែលនៅ ក្នុងកាមចិត្តដទៃៗ ។

ឈានដែលដុតបដិបក្ខធម៌ គឺ

វិតក្ក ដុតបដិបក្ខធម៌ គឺ ថីនមិទ្ធ ។

វិចារ ដុតបដិបក្ខធម៌ គឺ វិចិកិច្ឆា ។

ปีติ ដុតបដិបក្ខធម៌ គឺ ព្យាបាទ ។

សោមនស្ស ឧបេក្ខា ដុតបដិបក្ខធម៌ គឺ ឧទ្ធច្ច កុក្កុច្ច ទោមនស្ស ។

ឯកគ្គតា ដុតបដិបក្ខធម៌ គឺ កាមឆន្ទ: ។

ចំណុចសម្គាល់

ឯកគ្គតាចេតសិក ដែលប្រកបក្នុងទ្វិបញ្ចវិញ្ញាណចិត្ត ១០ មិន បានជា ឈានង្គ: និងឯកគ្គតាចេតសិកក្នុងអវីរិយចិត្ត ១៦ រមែងមិនដល់ នូវសមាធិន្ទ្រិយ និងសមាធិពល: ។

៣. មគ្គង្គ

មគ្គ ប្រែថា ផ្លូវ សំដៅដល់ ធម៌ដែលនាំទៅកាន់ទិសដៅ ឱ្យដល់ សុគតិភូមិ ទុគ្គតិភូមិ និងព្រះនិព្វាន ដូចវចនត្ថៈថា

សុគត្យា ច ទុគ្គត្យា ច និព្វានស្ស ច បាបណា
តេសញ្ច បថភូតត្តា មគ្គង្គានីតិ វុច្ចរេ
មគ្គស្ស វា អង្គានីតិ មគ្គង្គានីតិ សម្មតា ។

ប្រែថា ធម៌ដែលជាហេតុឱ្យដល់ សុគតិភូមិ ទុគ្គតិភូមិ ព្រះនិព្វាន និងជាផ្លូវឱ្យដល់ សុគតិភូមិ ទុគ្គតិភូមិ និងព្រះនិព្វាន ឬន័យម្យ៉ាងទៀត ព្រោះជាធម៌មួយចំណែករបស់មគ្ត ទើបឈ្មោះថា អង្គមគ្ត ។

ធម្មតាសត្វទាំងឡាយ ដែលវិលវល់កើតស្លាប់នៅក្នុងភូមិផ្សេងៗ ទាំង ៣១ ភូមិក្តី ឬអ្នកដែលចូលដល់ព្រះនិព្វានក្តី រមែងត្រូវអាស្រ័យ ហេតុនិងផ្លូវជួយឧបត្ថម្ភឱ្យដល់ធម៌ដែលជាហេតុ និងជាផ្លូវឱ្យដល់ភូមិ ផ្សេងៗ ឬព្រះនិព្វាននោះ បានដល់ អង្គមគ្ត ១២ ប្រការ គឺ

មគ្គង្គៈ ១២

១. សម្មាទិដ្ឋិ ការយល់ឃើញត្រូវ ជាផ្លូវឱ្យចូលដល់សុគតិ និងនិព្វាន អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងញាណសម្បយុត្ត ចិត្ត ៤៧ ឬ ៧៩ ដួង ។

២. សម្មាសង្កប្ប ការត្រិះរិះត្រូវ ជាផ្លូវឱ្យដល់សុគតិ និងនិព្វាន អង្គធម៌ បានដល់ វិតក្កចេតសិក ដែលនៅក្នុងកាមាវចរសោភណចិត្ត

២៤ និង បឋមជ្ឈានចិត្ត ១១ ដួង ។

៣. សម្មាវាចា ការពោលវាចាប្រពៃ ជាផ្លូវឱ្យដល់ សុគតិ និងនិព្វាន អង្គធម៌ បានដល់ សម្មាវាចាចេតសិក ដែលនៅក្នុងមហាកុសលចិត្ត ៨ និងលោកុត្តរចិត្ត ៤០ ដួង ។

៤. សម្មាកម្មន្ត ការធ្វើការងារប្រពៃ ជាផ្លូវឱ្យដល់សុគតិ និងនិព្វាន អង្គធម៌ បានដល់ សម្មាកម្មន្តចេតសិក ដែលនៅក្នុងមហាកុសលចិត្ត ៨ និងលោកុត្តរចិត្ត ៤០ ដួង ។

៥. សម្មាអាជីវ ការចិញ្ចឹមជីវិតប្រពៃ ជាផ្លូវឱ្យដល់សុគតិ និងនិព្វាន អង្គធម៌ បានដល់ សម្មាអាជីវចេតសិក ដែលនៅក្នុងមហាកុសលចិត្ត ៨ និងលោកុត្តរចិត្ត ៤០ ដួង ។

៦. សម្មាវាយាម ការព្យាយាមប្រពៃ ជាផ្លូវឱ្យដល់សុគតិ និងនិព្វាន អង្គធម៌ បានដល់ វីរិយចេតសិក ដែលនៅក្នុងសោភណចិត្ត ៩១ ដួង ។

៧. សម្មាសតិ ការរលឹកត្រូវ ជាផ្លូវឱ្យដល់សុគតិ និងនិព្វាន អង្គធម៌ បានដល់ សតិចេតសិក ដែលនៅក្នុងសោភណចិត្ត ៩១ ដួង ។

៨. សម្មាសមាធិ ការតាំងចិត្តមាំដោយប្រពៃ ជាផ្លូវឱ្យដល់សុគតិ និងនិព្វាន អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលនៅក្នុងសោភណចិត្ត ៩១ ដួង ។

៩. មិច្ឆាទិដ្ឋិ ការយល់ឃើញខុស ជាផ្លូវឱ្យដល់ ទុគ្គតិភូមិ អង្គធម៌ បានដល់ ទិដ្ឋិចេតសិក ដែលនៅក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង ។

១០. មិច្ឆាសង្កប្ប ការត្រិះរិះខុស ជាផ្លូវទៅកាន់ទុគ្គតិ អង្គធម៌ បានដល់ វិតក្កចេតសិក ដែលនៅក្នុងអកុសលចិត្ត ១២ ដូង ។

១១. មិច្ឆាវាយាម ការព្យាយាមខុស ជាផ្លូវទៅកាន់ទុគ្គតិ អង្គធម៌ បានដល់ វីរិយចេតសិក ដែលនៅក្នុងអកុសលចិត្ត ១២ ដូង ។

១២. មិច្ឆាសមាធិ ការតម្កល់ចិត្តមាំខុស ជាផ្លូវឱ្យទៅដល់ ទុគ្គតិ អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលនៅក្នុងអកុសលចិត្ត ១១ (រៀងវិចិកិច្ឆាសម្បយុត្តចិត្ត ១) ។

មគ្គង្គ: ក្នុងចំនួន ១២ ប្រភេទនេះ ជាហេតុនិងជាផ្លូវឱ្យដល់ សុគតិ និងព្រះនិព្វាន មាន ៨ ប្រភេទ គឺ

សម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្ត ១ សម្មាអាជីវ ១ សម្មាវាយាម ១ សម្មាសតិ ១ សម្មាសមាធិ ១ ។

ចំណែកមគ្គង្គ: ដែលជាហេតុ ជាផ្លូវឱ្យចូលដល់ទុគ្គតិ មាន ៤ ប្រការ គឺ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្ប មិច្ឆាវាយាម មិច្ឆាសមាធិ ។

ក្នុងព្រះសូត្រ ព្រះពុទ្ធអង្គសម្តែងអង្គនៃមគ្គ ១៦ ប្រការ ក្រៅពីអង្គមគ្គ ១២ ប្រការ ដូចពោលហើយ នៅមានមគ្គ ៤ ប្រការទៀត គឺ

មិច្ឆាវាចា, មិច្ឆាកម្មន្ត, មិច្ឆាអាជីវ, មិច្ឆាសតិ,

តែកាលចាត់ដោយអង្គធម៌បរមត្ថមិនមានដោយចំពោះ បានតែ សង្គ្រោះចូលក្នុងអកុសលចិត្តុប្បាទ ដែលទាក់ទងដោយវចីទុច្ចរិត កាយទុច្ចរិត ការចិញ្ចឹមជីវិតខុស និងការរលឹកដល់ក្នុងវត្ថុដែលមិនល្អផ្សេងៗ ឬមិនដូច្នោះ មិច្ឆាសតិ សំដៅយកការរលឹកអារម្មណ៍ដទៃដែលក្រៅពី

សតិប្បដ្ឋាន គឺ មិនមែនអារម្មណ៍របស់កាយ វេទនា ចិត្ត និងធម៌ ។

មគ្គង្គ: ១២ ប្រការនេះ សំដៅយកចំពោះសភាវធម៌ ឬអង្គធម៌ដោយត្រង់ ទាំងសម្មាមគ្គ និងមិច្ឆាមគ្គ ។

ទើបចាត់ប្រភេទរបស់មគ្គង្គ:ទុក ១២ ប្រការ

មគ្គង្គ: ១២ ប្រការនេះ មានអង្គធម៌ត្រឹមតែ ៩ ប៉ុណ្ណោះ

បញ្ញាចេតសិក, វិតក្កចេតសិក, សម្មាវាចាចេតសិក, សម្មាកម្មន្ត-ចេតសិក, សម្មាអាជីវចេតសិក, វីរិយចេតសិក, សតិចេតសិក, ឯកគ្គតាចេតសិក, និងទិដ្ឋិចេតសិក ។

ក្នុងអង្គធម៌ទាំង ៩ នេះ ទិដ្ឋិចេតសិក ជាអកុសលមួយផ្នែក បញ្ញា សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវ និងសតិ ប្រព្រឹត្តទៅបានក្នុងកុសល និងអព្យាកត: ។

ចំណែក វិតក្ក: វីរិយ: និងឯកគ្គតា បានទាំងកុសល អកុសល និងអព្យាកត ដោយហេតុនេះ មគ្គង្គ: ទើបចាត់ទុកក្នុងពួកធម៌ដែលជាមិស្សកសង្គហ: ។

ចំណុចសម្គាល់

អហេតុកចិត្ត ១៨ និងឯកគ្គតាចេតសិកដែលនៅក្នុងវិចិកិច្ឆា-សម្បយុត្តចិត្ត រមែងមិនបានមគ្គង្គ: គឺ មិនចាត់ជាអង្គមគ្គ ទាំងនេះព្រោះ អហេតុកចិត្ត ១៨ មិនមានសម្បយុត្តហេតុឡើយ កាលមិនមានហេតុ ប្រកបហើយ ក៏មិនជាហេតុ ជាផ្លូវឱ្យចូលដល់ សុគតិ ទុគ្គតិ និងព្រះនិព្វាន បានឡើយ ។

ចំណែកឯកគ្គតាចេតសិក ដែលនៅក្នុងវិចិកិច្ឆាសហគតចិត្ត ដែលមិនរាប់ជាអង្គមគ្គ ព្រោះហេតុថា វិចិកិច្ឆាសម្បយុត្តចិត្តនោះ សូម្បីប្រកបដោយមោហ:ក៏ពិត តែមានត្រឹមហេតុមួយ ទើបមានកម្លាំងមិនច្រើន ថែមទាំងមានការមិនជឿជាក់ក្នុងចិត្តប្រកបទៀត ធ្វើឱ្យកម្លាំងដែលមានមិនច្រើននោះ ត្រូវអន់ថយចុះទៀត ព្រោះមានអារម្មណ៍បាចសាច ទើបមិនដល់នូវភាពជាសមាធិក្នុងមគ្គ ។

៤. ឥន្ទ្រិយ

ឥន្ទ្រីយ៍ សំដៅដល់ ភាពជាធំ ជាអ្នកគ្រប់គ្រង ដែលមានអំណាចធ្វើឱ្យសភាវធម៌ដែលកើតឡើងព្រមជាមួយខ្លួននោះ ត្រូវប្រព្រឹត្តទៅតាមអំណាចគ្រប់គ្រងរបស់ខ្លួន ដូចមានវចនត្ថ:សម្តែងថា

ឥន្ទន្តិ បរមិស្សរិយំ ករោន្តីតិ = ឥន្ទ្រិយានិ

ប្រែថា ធម៌ទាំងឡាយណាជាអ្នកគ្រប់គ្រង រមែងធ្វើខ្លួនឱ្យជាឥស្សរ:ក្រៃលែង ធម៌ទាំងឡាយនោះ ឈ្មោះថា ឥន្ទ្រិយ ។

ភាពជាអ្នកគ្រប់គ្រងរបស់សភាវធម៌ដែលជាឥន្ទ្រិយនោះ រមែងជាអ្នកគ្រប់គ្រងចំពោះធម៌ដែលកើតរួមជាមួយខ្លួន និងធ្វើកិច្ចតាមនាទីរបស់ខ្លួនប៉ុណ្ណោះ សេចក្តីថា ធម៌ដែលកើតព្រមគ្នានោះ អាចមានកិច្ចនាទីដែលត្រូវធ្វើច្រើនយ៉ាង តែភាពជាអ្នកគ្រប់គ្រងនោះ រមែងគ្រប់គ្រងបានចំពោះការងារតាមនាទីរបស់ខ្លួនប៉ុណ្ណោះ មិនឈានទៅក្នុងកិច្ចនាទីរបស់អ្នកដទៃ ដូច្នោះក្នុងកិច្ចការងារម្យ៉ាង ដែលមានកិច្ចនាទីត្រូវធ្វើ

ច្រើនយ៉ាង ទើបត្រូវមានឥន្ទ្រិយច្រើនដូចមានអ្នកគ្រប់គ្រងច្រើននាក់ ដូចជារដ្ឋបាល មានកិច្ចនាទីដែលត្រូវគ្រប់គ្រងប្រទេស តាមនយោបាយ ដែលថ្លែងប្រកាសទុកដល់ប្រជាជន ក៏បែងចែកការងារជាក្រសួងផ្សេងៗ ក្រសួងនីមួយៗ មានរដ្ឋមន្ត្រីជាអ្នកគ្រប់គ្រងការងារក្នុងនាទីដែលទទួលខុសត្រូវរបស់ខ្លួន ធម៌ដែលជាឥន្ទ្រិយក៏មានឧបមាដូចរដ្ឋមន្ត្រីនោះឯង ។

ដូច្នោះ ក្នុងការឃើញ ការឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វ:ជាដើម ទាំងនេះរមែងមានធម៌ជាឥន្ទ្រិយច្រើនប្រការ ដូចចក្ខុបសាទរូបជាឥន្ទ្រិយ ហៅថា ចក្ខុន្ទ្រិយ ព្រោះជាអ្នកគ្រប់គ្រងក្នុងការទទួលរូបារម្មណ៍ បើមិនមានចក្ខុបសាទរូបហើយ នឹងមិនអាចទទួលរូបារម្មណ៍បានឡើយ ក្រៅពីចក្ខុន្ទ្រិយ រូបជីវិតិន្ទ្រិយ ជាអ្នកគ្រប់គ្រងរក្សាកម្មជរូប រួមទាំងចក្ខុបសាទរូបដែលកើតព្រមគ្នាជាមួយខ្លួនផង ហើយមនិន្ទ្រិយ គឺ ចក្ខុវិញ្ញាណ ជាអ្នកគ្រប់គ្រងក្នុងការឃើញរូបារម្មណ៍ដូច្នេះ ជាដើម ដែលលើកតួយ៉ាងការឃើញ មានធម៌ដែលជាឥន្ទ្រិយកើតឡើងព្រមៗ គ្នាបានច្រើនឥន្ទ្រិយដូច្នេះព្រោះចែកនាទីគ្នាជាប្រធាន ជាអ្នកគ្រប់គ្រងនោះឯង ។

ក្នុងការឮ ដឹងក្លិន ដឹងរស ប៉ះត្រូវសម្ផស្ស នឹកគិតអារម្មណ៍ក៏ដូចគ្នា រមែងមានឥន្ទ្រិយដទៃៗ កើតព្រមគ្នាបានច្រើនឥន្ទ្រិយ និងគ្រប់ៗ ឥន្ទ្រិយក៏មាននាទីគ្រប់គ្រង គឺ ធ្វើសភាវធម៌ដែលទាក់ទងជាមួយខ្លួនឱ្យ ប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួនផង ។

ឥន្ទ្រិយមាន ២២ ប្រភេទ

១. ចក្ខុន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការទទួលរូបារម្មណ៍ អង្គធម៌ បានដល់ ចក្ខុបសាទរូប ។

២. សោតិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការទទួលសទ្ទារម្មណ៍ អង្គធម៌ បានដល់ សោតបសាទរូប ។

៣. ឃានិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការទទួលគន្ធារម្មណ៍ អង្គធម៌ បានដល់ ឃានបសាទរូប ។

៤. ជិវ្ហិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការទទួលរសារម្មណ៍ អង្គធម៌ បានដល់ ជិវ្ហាបសាទរូប ។

៥. កាយិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការទទួលផោដ្ឋព្វារម្មណ៍ អង្គធម៌ បានដល់ កាយបសាទរូប ។

៦. ឥត្ថិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងភាពជាស្ត្រី អង្គធម៌ បានដល់ ឥត្ថីភាវរូប ។

៧. បុរិសិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងភាពជាបុរស អង្គធម៌ បានដល់ បុរិសភាវរូប ។

៨. ជីវិតិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការរក្សារូប នាម អង្គធម៌ បានដល់ ជីវិតរូប និងជីវិតិន្ទ្រិយចេតសិក ។

៩. មនិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការដឹងអារម្មណ៍ អង្គធម៌ បានដល់ ចិត្តទាំងអស់ ។

១០. សុខិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការសោយសុខក្តី

សុខកាយ អង្គធម៌ បានដល់ វេទនាចេតសិក ដែលនៅក្នុងសុខសហគត-
កាយវិញ្ញាណចិត្ត ១ ។

១១. ទុក្ខិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការសោយសេចក្តី
ទុក្ខកាយ អង្គធម៌ បានដល់ វេទនាចេតសិក ដែលនៅក្នុងទុក្ខសហគត-
កាយវិញ្ញាណចិត្ត ១ ។

១២. សោមនស្សិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការ
សោយសេចក្តីសុខចិត្ត អង្គធម៌ បានដល់ វេទនាចេតសិក ដែលនៅក្នុង
សោមនស្សសហគតចិត្ត ៦២ ។

១៣. ទោមនស្សិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការសោយ
សេចក្តីទុក្ខចិត្ត អង្គធម៌ បានដល់ វេទនាចេតសិក ដែលនៅក្នុងទោស
មូលចិត្ត ២ ។

១៤. ឧបេក្ខិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការសោយ
អារម្មណ៍ជាកណ្តាល អង្គធម៌ បានដល់ វេទនាចេតសិក ដែលនៅក្នុង
ឧបេក្ខាសហគតចិត្ត ៥៥ ។

១៥. សទ្ធិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការជឿដល់វត្ថុ
ដែលគួរជឿ អង្គធម៌ បានដល់ សទ្ធាចេតសិក ដែលនៅក្នុងសោភណ
ចិត្ត ៩១ ។

១៦. វីរិយិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងសេចក្តីព្យាយាម
ដល់អារម្មណ៍ អង្គធម៌ បានដល់ វីរិយចេតសិក ដែលនៅក្នុងវីរិយសម្ប-
យុត្តចិត្ត ១០៥ ។

១៧. សតិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប គ្រងក្នុងការរលឹកត្រូវ អង្គធម៌ បានដល់ សតិចេតសិក ដែលនៅក្នុងសោភណចិត្ត ៩១ ។

១៨. សមាធិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប គ្រង ក្នុងការតាំងចិត្ត មាំក្នុងអារម្មណ៍ អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលនៅក្នុងចិត្ត ៧២ (រៀងអវីរិយ ១៦ វិចិកិច្ឆាសម្បយុត្តចិត្ត ១) ។

១៩. បញ្ញិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប គ្រង ក្នុងការដឹងសភាវធម៌តាមសេចក្តីពិត អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងញាណសម្បយុត្តចិត្ត ៤៧ ឬ ៧៩ ។

២០. អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប គ្រងក្នុងការដឹងច្បាស់អរិយសច្ច: ៤ ដែលខ្លួនមិនធ្លាប់ដឹង អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងសោតាបត្តិមគ្គចិត្ត ១ ។

២១. អញ្ញិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប គ្រង ក្នុងការដឹងច្បាស់អរិយសច្ច: ៤ ដែលខ្លួនធ្លាប់ដឹង អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងមគ្គចិត្តខាងលើ ៣ និងផលចិត្តខាងក្រោម ៣ ។

២២. អញ្ញាតាវិន្ទ្រិយ ធម្មជាតិដែលជាអ្នកគ្រប គ្រង ក្នុងការដឹងច្បាស់អរិយសច្ច: ៤ ដល់ទីបំផុតហើយ អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងអរហត្តផលចិត្ត ១ ។

ឥន្ទ្រិយទាំង ២២ ប្រភេទនេះ មានអង្គធម៌ត្រឹមតែ ១៦ ប្រការ ជារូបធម៌ ៨ ប្រការ បានដល់ ចក្ខុបសាទ សោតបសាទ ឃានបសាទ ជិវ្ហាបសាទ កាយបសាទ ឥត្ថីភាវរូប បុរិសភាវរូប និងជីវិតរូប ។

ជានាមធម៌ ៨ ប្រការ បានដល់ ចិត្ត វេទនាចេតសិក វីរិយចេតសិក ជីវិតិន្ទ្រិយចេតសិក ឯកគ្គតាចេតសិក សទ្ធាចេតសិក សតិចេតសិក និងបញ្ញាចេតសិក ។

ឥន្ទ្រិយ ២២ ចែកដោយលោកិយ: និងលោកុត្តរ: បានដូច្នេះ គឺ លោកិយធម៌មួយចំណែកមាន ១០ ឥន្ទ្រិយ បានដល់

ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ និងទោមនស្សិន្ទ្រិយ ។

លោកុត្តរធម៌មួយចំណែកមាន ៣ ឥន្ទ្រិយ បានដល់ អនញ្ញាតញ្ញ-ស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ។

លោកិយធម៌ និងលោកុត្តរធម៌ ទាំង ២ ផ្នែកមាន ៩ ឥន្ទ្រិយ ដ៏សេស បានដល់ ជីវិតិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ ។

ឥន្ទ្រិយ ២២ ចែកដោយការទាក់ទងនឹងអារម្មណ៍ និងភាវនា ដោយទាក់ទងនឹងអារម្មណ៍មាន ១៤ បានដល់

ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ មនិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ និងឧបេក្ខិន្ទ្រិយ ។

ដោយភាវនាមាន ៨ បានដល់ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ ។

ចែកឥន្ទ្រិយ ២២ ដោយភូមិ

ឥន្ទ្រិយទាំង ២២ កាលចែកដោយភូមិទាំង ៣ បានដូច្នេះ

១. ឥន្ទ្រិយ ១0 ប្រការ គឺ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ និង ទោមនស្សិន្ទ្រិយ ទាំងនេះ ជាកាមធម៌ទាំងអស់ ហៅថា កាមឥន្ទ្រិយ។

២. ឥន្ទ្រិយ ៨ ប្រការ គឺ ជីវិតិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ ទាំងនេះជាកាមធម៌ រូបធម៌ អរូបធម៌ និងលោកុត្តរធម៌ ហៅថា កាមឥន្ទ្រិយ រូបឥន្ទ្រិយ អរូបឥន្ទ្រិយ និងលោកុត្តរឥន្ទ្រិយ ។

៣. សោមនស្សិន្ទ្រិយ ជាកាមធម៌ រូបធម៌ និងលោកុត្តរធម៌ បាន ហៅថា កាមឥន្ទ្រិយ រូបឥន្ទ្រិយ និងលោកុត្តរឥន្ទ្រិយ ។

៤. អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ទាំង ៣ នេះ ជាលោកុត្តរធម៌ទាំងអស់ ហៅថា លោកុត្តរឥន្ទ្រិយ ។

ចំណុចសម្គាល់

ឯកគ្គតាចេតសិកក្នុងអវីរិយចិត្ត ១៦ និងក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ រមែងមិនចូលដល់ សមាធិន្ទ្រិយ ហេតុផលដូចគ្នាដែលបានសម្តែង ទុកក្នុងចំណុចសម្គាល់របស់មគ្គង្គ: ។

៥. ពល

ពល គឺ កម្លាំង បានដល់ ការមិនញាប់ញ័រ មានវចនត្ថ:ថា

អកម្បនដ្ឋេន ពលំ ប្រែថា ធម៌ដែលឈ្មោះថា ពល: ព្រោះអត្ថថា មិនញាប់ញ័រ ។

ន័យម្យ៉ាងទៀតថា **ពលីយន្តិ ឧប្ផន្នេ បដិបក្ខធម្មេ សហន្តិ មទ្ទន្តីតិ = ពលានិ**

ប្រែថា ធម៌ទាំងឡាយណា រមែងមានកម្លាំងឱ្យអត់ធន់ តស៊ូ ទម្លាយ នូវបដិបក្ខធម៌ ដូច្នោះធម៌ទាំងឡាយនោះ ឈ្មោះថា **ពល** ។

ធម្មតាអ្នកដែលជាមេទ័ពនាយពលទាំងឡាយ រមែងមិនញាប់ញ័រ ក្នុងនាទីរបស់ខ្លួនយ៉ាងណា អង្គធម៌ ៩ ប្រការ មានសទ្ធា ជាដើម ក៏មិនញាប់ញ័រក្នុងនាទីរបស់ខ្លួនឯង ក៏យ៉ាងនោះដែរ ហេតុនោះទើប ឈ្មោះថា **ពល** ។

ការមិនញាប់ញ័ររបស់នាយពលនោះ មាន ២ ប្រការ គឺ មិនញាប់ញ័រក្នុងនាទីគ្របគ្រងអ្នកនៅក្រោមបង្គាប់បញ្ជារបស់ខ្លួនមួយ និងកាលប្រឈមជាមួយសឹកសត្រូវក៏មិនញាប់ញ័រ អាចកំចាត់សត្រូវបានមួយ ។

ចំណុចនេះយ៉ាងណា ពលធម៌ដែលជាកុសលធម៌ទាំងនោះ រមែងមិនញាប់ញ័រក្នុងនាទីគ្របគ្រងរបស់ខ្លួនឯង និងថែមទាំងអាចទម្លាយអកុសលធម៌ ដែលជាបដិបក្ខជាមួយខ្លួនឱ្យសាបសូន្យទៅបានទៀតផង ដូចជាសទ្ធាពល: ជាកម្លាំងក្នុងការជឿ សេចក្ដីជ្រះថ្លាយ៉ាងមាំទាំមិន

ញាប់ញ័រ រមែងអាចទម្លាយអកុសលធម៌ ដែលជាហេតុមិនជ្រះថ្លា គឺ អសទ្ធិយឱ្យបាត់អស់ទៅបានជាដើម ឬពលធម៌ ដែលជាផ្នែកអកុសលធម៌ រមែងមានការមិនញាប់ញ័រក្នុងនាទីរបស់ខ្លួន គឺ អាចគ្របគ្រងអ្នកដែលនៅក្រោមការបង្គាប់បញ្ជារបស់ខ្លួនប៉ុណ្ណោះ គឺ តាំងមាំនៅក្នុងអកុសលធម៌ ដែលកើតព្រមគ្នាជាមួយខ្លួន តែកាលអកុសលធម៌ដែលកើតឡើងក៏មិនអាចទម្លាយកុសលធម៌នោះបាន ត្រូវបន្ទូរបន្ថយឱ្យប្រព្រឹត្តទៅតាមផ្នែកកុសលធម៌ដែលជាបដិបក្ខជាមួយខ្លួននោះ ដូចជាអហិរិកពល: មានការមិនញាប់ញ័រ ដោយមិនខ្មាសដល់បាបទុច្ចរិត តែកាលហិរិពល:កើតឡើងហើយ អហិរិកពល: ត្រូវអន់ថយព្រមចាលចាញ់ទៅ មិនអាចរឹងរូសតាំងនៅបានឡើយ ធ្វើឱ្យខ្មាសដល់បាបទុច្ចរិត ដោយអំណាចរបស់ហិរិពល: ដូច្នេះជាដើម ដូចមានសាធកបាលីថា

អសទ្ធិយេ កោសជ្ជេ ច មុដ្ឋស្សច្ចេ ច ឧទ្ធច្ចេ
អវិជ្ជាយ អហិរិកេ នោត្តប្បេ ច ន កម្បរេ ។
តស្មា សទ្ធាទយោ សត្ត កុសលាទី ពលានិ ច
យុត្តេស្វេវ អកម្បេន អបុញ្ញាបិ តំនាមិកា ។

ប្រែថា អង្គធម៌ ៧ ប្រការ មានសទ្ធា ជាដើម ដែលជាកុសល និងអព្យាកត:ទាំងនេះ ឈ្មោះថា **ពល** ព្រោះហេតុមិនញាប់ញ័រ ក្នុងអកុសលធម៌តាមលំដាប់ គឺ **សទ្ធា** រមែងមិនញាប់ញ័រក្នុងអកុសលធម៌ដែលជាហេតុឱ្យកើតការមិនមានសទ្ធា, **វីរិយ** រមែងមិនញាប់ញ័រក្នុងអកុសលធម៌ដែលជាហេតុឱ្យកើតការខ្ជិល, **សតិ** រមែងមិនញាប់ញ័រក្នុងអកុសល

ធម៌ដែលជាហេតុឱ្យកើតការភ្លេច, **សមាធិ** រមែងមិនញាប់ញ័រក្នុងការរវើរវាយ, **បញ្ញា** រមែងមិនញាប់ញ័រដល់ការមិនដឹងធម៌តាមសេចក្តីពិត, **ហិរិ** រមែងមិនញាប់ញ័រដល់ការមិនខ្មាសក្នុងបាបទុច្ចរិត, **ឱត្តប្ប** រមែងមិនញាប់ញ័រក្នុងការមិនខ្លាចដល់បាបទុច្ចរិត សូម្បីក្នុងផ្នែកអកុសលធម៌ក៏មាន, **អហិរិក អនោត្តប្ប** ដែលប្រកបជាមួយអកុសលចិត្តទាំងនោះក៏បាន ឈ្មោះថា **ពល** ព្រោះមិនមានសេចក្តីញាប់ញ័រក្នុងអកុសលធម៌ដូចគ្នាជាមួយខ្លួន តែមិនបានរារាំងទម្លាយដោយប្រការណាឡើយ គង់មានតែការមិនញាប់ញ័រ ព្រោះជាធម៌ដូចគ្នាជាមួយខ្លួន ។

រួមសេចក្តីថា ធម៌ដែលជាកម្លាំងធ្វើឱ្យសម្បយុត្តធម៌ដែលកើតរួមគ្នាជាមួយខ្លួនមានភាពរឹងមាំ រហូតអាចធ្វើសេចក្តីល្អ ឬអាក្រក់ឱ្យសម្រេចបាន ធម៌នោះ ឈ្មោះថា **ពល** ដូច្នោះ **ពល** ទើបមានទាំងកុសលពល: និងអកុសលពល: ។

អកុសលពល មានកម្លាំងអត់ធន់ មិនញាប់ញ័រដល់អកុសលធម៌ដែលជាពួកដូចគ្នាឡើយ តែក៏មិនមានកម្លាំងដែលនឹងញ្ចាំញ្ចីកុសលធម៌ដែលជាបដិបក្ខជាមួយខ្លួនបានដែរ ។

កុសលពល មានកម្លាំងអត់ធន់ មិនញាប់ញ័រដល់អកុសលធម៌ផង និងថែមទាំងមានកម្លាំងញ្ចាំញ្ចីអកុសលធម៌ដែលជាបដិបក្ខធម៌ជាមួយខ្លួនបានទៀតផង ។

ពលមាន ៩ ប្រការ

១. សទ្ធាពល ធម្មជាតិដែលមិនញាប់ញ័រក្នុងការជឿដល់វត្ថុដែលគួរជឿ អង្គធម៌ បានដល់ សទ្ធាចេតសិក ដែលនៅក្នុងសោភណចិត្ត ៩១។

២. វីរិយពល ធម្មជាតិដែលមិនញាប់ញ័រក្នុងការព្យាយាម អង្គធម៌ បានដល់ វីរិយចេតសិក ដែលនៅក្នុងវីរិយសម្បយុត្តចិត្ត ១០៥ ។

៣. សតិពល ធម្មជាតិដែលមិនញាប់ញ័រក្នុងការរលឹកត្រូវ អង្គធម៌ បានដល់ សតិចេតសិក ដែលនៅក្នុងសោភណចិត្ត ៩១ ។

៤. សមាធិពល ធម្មជាតិដែលមិនញាប់ញ័រក្នុងការធ្វើចិត្តឱ្យតាំងមាំនៅក្នុងអារម្មណ៍តែមួយ អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលនៅក្នុងចិត្ត ៧២ (រៀរអវីរិយចិត្ត ១៦ និងវិចិកិច្ឆាសម្បយុត្តចិត្ត ១) ។

៥. បញ្ញាពល ធម្មជាតិដែលមិនញាប់ញ័រ ក្នុងការដឹងធម៌តាមសេចក្ដីពិត អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងញាណសម្ប-យុត្តចិត្ត ៤៧ ឬ ៧៩ ។

៦. ហិរិពល ធម្មជាតិដែលមិនញាប់ញ័រក្នុងការខ្មាសចំពោះទុច្ចរិត អង្គធម៌ បានដល់ ហិរិចេតសិក ដែលនៅក្នុងសោភណចិត្ត ៩១ ។

៧. ឱត្តប្បពល ធម្មជាតិដែលមិនញាប់ញ័រ ក្នុងការតក់ស្លុតខ្លាចចំពោះទុច្ចរិត អង្គធម៌ បានដល់ ឱត្តប្បចេតសិក ដែលនៅក្នុងសោភណចិត្ត ៩១ ។

៨. អហិរិកពល ធម្មជាតិដែលមិនញាប់ញ័រ ក្នុងការមិនខ្មាសចំពោះទុច្ចរិត អង្គធម៌ បានដល់ អហិរិកចេតសិក ដែលនៅក្នុងអកុសលចិត្ត ១២ ។

៩. អនោត្តប្បពល ធម្មជាតិដែលមិនញាប់ញ័រ ក្នុងការមិនតក់ស្លុតខ្លាចចំពោះទុច្ចរិត អង្គធម៌ បានដល់ អនោត្តប្បចេតសិក ដែលនៅក្នុងអកុសលចិត្ត ១២ ។

ពល ៩ ប្រការនេះ មានអង្គធម៌របស់ពល: ៩ ត្រូវគ្នាជាមួយប្រភេទរបស់ពល:គ្រប់ល្មម ដែលមាន អហិរិក អនោត្តប្ប ជាពល:ផ្នែកអកុសលតែម្យ៉ាង ។

សទ្ធា សតិ បញ្ញា ហិរិ និងឱត្តប្ប ជាពល:ក្នុងផ្នែកកុសលតែម៉្យាង វីរិយ សមាធិ ជាពល:បានទាំងផ្នែកកុសលនិងអកុសលលាយគ្នា ដោយហេតុនេះទើបចាត់ពួកពល:នេះទុកក្នុងមិស្សកសង្គហ: ។

ចំណុចសម្គាល់

ឯកគ្គតាចេតសិក ដែលនៅក្នុងអវីរិយចិត្ត ១៦ និងវិចិកិច្ឆាសម្ប-យុត្តចិត្ត ១ រមែងមិនចូលដល់សមាធិពល: ដោយហេតុផលទំនងដូចគ្នាដែលបានសម្តែងទុកក្នុងមគ្គង្គ:នោះឯង ។

៦. អធិបតី

អធិបតី សំដៅដល់ សភាវធម៌ដែលទ្រទ្រង់ភាពជាធំក្រៃលែងជាងធម៌ដទៃដែលកើតឡើងព្រមគ្នាជាមួយខ្លួន ដូចមានវចនត្ថ:ថា

អធិនានំ បតិ = អធិបតិ

ប្រែថា ធម៌ដែលជាម្ចាស់ នៃធម៌ដែលរួមគ្នាជាមួយខ្លួន ឬធម៌ដែល

ធំជាងធម៌ដែលជាប់ទាក់ទងជាមួយខ្លួន ធម៌នោះ ឈ្មោះថា អធិបតិ ។

អធិកោ បតិ = អធិបតិ

ប្រែថា ធម៌ដែលជាម្ចាស់ ជាធំនិងមានអំណាចក្រៃលែង ធម៌នោះ ឈ្មោះថា អធិបតី ។

សេចក្តីថា ក្នុងការធ្វើកិច្ចការងារណាមួយនោះ កាលមានសេចក្តីពេញចិត្ត មានសេចក្តីព្យាយាម មានចិត្តផ្តោតចំពោះការងារ និងមានការឆ្លៀវឆ្លាតការងារនោះរមែងសម្រេចបាន ដូចសម្តែងក្នុងអភិធម្មាវតារ បូរាណដីកាថា

ឆន្ទវតោ ក៏ នាម ន សិជ្ឈតិ កាលមានឆន្ទៈហើយ វត្ថុណាដែលនឹងមិនសម្រេចមិនមាន ។

វីរិយវតោ ក៏ នាម ន សិជ្ឈតិ កាលមានវីរិយហើយ វត្ថុណានឹងមិនសម្រេចមិនមាន ។

ចិត្តវតោ ក៏ នាម ន សិជ្ឈតិ កាលមានចិត្តផ្តោតហើយ វត្ថុណាដែលនឹងមិនសម្រេចមិនមាន ។

បញ្ញវតោ ក៏ នាម ន សិជ្ឈតិ កាលមានបញ្ញាហើយ វត្ថុណាដែលនឹងមិនសម្រេចមិនមាន ។

សេចក្តីរបស់អធិបតីនេះ ទើបមានសភាពជាធំ ជាប្រធាននាំឱ្យសម្រេចកិច្ចការងារបានពិតប្រាកដ ។

ភាពជាធំជាអ្នកគ្របគ្រងរបស់សភាវធម៌នោះ មាន ២ ប្រការ គឺ

១. ជាធំ ជាអ្នកគ្របគ្រងដោយភាពជាឥន្ទ្រិយ ។

២. ជាធំ ជាអ្នកគ្របគ្រងដោយភាពជាអធិបតី ។

ភាពជាធំ ជាអ្នកគ្របគ្រង ដោយភាពជាឥន្ទ្រិយនោះ មិនមែនជាការធំក្រៃលែងទេ គឺ កាលខណៈកើតឡើងនោះ រមែងកើតព្រមៗ គ្នាបានច្រើនឥន្ទ្រិយ ដោយមិនទាស់គ្នា ព្រោះធម៌ដែលជាឥន្ទ្រិយនោះ រមែងជាធំគ្របគ្រងចំពោះក្នុងនាទីរបស់ខ្លួន មិនជំទាស់គ្នាជាមួយឥន្ទ្រិយដទៃណា ព្រោះធ្វើការផ្សេងគ្នា ។

ចំណែកភាពជាធំដោយភាពជាអធិបតីនោះ មានសភាពជាធំក្រៃលែងជាងធម៌ដែលកើតព្រមគ្នាជាមួយខ្លួន ដូច្នោះកាលកើតឡើងនោះ រមែងកើតជាអធិបតីបានត្រឹមតែមួយ ដូចជាក្នុងខណៈដែលឆន្ទៈជាអធិបតី គឺ មានការពេញចិត្តយ៉ាងខ្លាំងក្លា ដែលហៅថា ពេញចិត្តកើតឡើងហើយ វីរិយៈ ចិត្ត និងបញ្ញា ក៏បណ្តោយតាមឆន្ទៈទៅក្នុងអារម្មណ៍នោះៗ ឬបើកាលវីរិយៈជាអធិបតី គឺ មានសេចក្តីព្យាយាមយ៉ាងខ្លាំងក្លាកើតឡើងហើយ ឆន្ទៈ ចិត្ត និងបញ្ញា ក៏បណ្តោយតាមវីរិយៈទៅក្នុងអារម្មណ៍នោះៗ បើចិត្តជាអធិបតី គឺ សេចក្តីតាំងចិត្តយ៉ាងខ្លាំងក្លាកើតឡើងហើយ ឆន្ទៈ វីរិយៈ និងបញ្ញា ក៏បណ្តោយតាមចិត្តទៅក្នុងអារម្មណ៍នោះ និងកាលបញ្ញាជាអធិបតី គឺ មានការដឹងច្បាស់តាមសេចក្តីពិតកើតឡើងហើយ ឆន្ទៈ វីរិយៈ និងចិត្ត ក៏បណ្តោយតាមបញ្ញា ទៅក្នុងអារម្មណ៍នោះៗ ។

រួមសេចក្តីថា ភាពជាធំ ដោយភាពជា ឥន្ទ្រិយ កើតឡើងក្នុងគ្រាជាមួយគ្នាបានច្រើនៗ ឥន្ទ្រិយមិនទាស់គ្នា ។

ចំណែកភាពជាធំដោយភាពជាអធិបតីនោះ ក្នុងគ្រាមួយៗ ជាអធិបតីបានតែមួយ ដទៃទៀតជាអធិបតីមិនបាន ។

អធិបតីមាន ៤ ប្រភេទ

១. ឆន្ទាធិបតិ ធម្មជាតិដែលជាធំក្នុងការពេញចិត្ត អង្គធម៌ បានដល់ ឆន្ទចេតសិក ដែលនៅក្នុងទ្វិហេតុកជវនចិត្ត ១៨ និងតិហេតុក-ជវនចិត្ត ៣៤ ដែលហៅថា សាធិបតិជវនចិត្ត ៥២ ។

២. វីរិយាធិបតិ ធម្មជាតិដែលជាធំក្នុងការព្យាយាមចំពោះអារម្មណ៍ អង្គធម៌ បានដល់ វីរិយចេតសិក ដែលនៅក្នុងសាធិបតិជវនចិត្ត ៥២ (ទ្វិហេតុកជវន: ១៨ និងតិហេតុកជវន: ៣៤) ។

៣. ចិត្តាធិបតិ ធម្មជាតិដែលជាធំក្នុងការតាំងចិត្តទទួលអារម្មណ៍ អង្គធម៌ បានដល់ ទ្វិហេតុកជវនចិត្ត ១៨ តិហេតុកជវនចិត្ត ៣៤ គឺ សាធិបតិជវនចិត្ត ៥២ ។

៤. វិមំសាធិបតិ ធម្មជាតិដែលជាធំ ក្នុងការដឹងសភាវធម៌តាមសេចក្ដីពិត អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងតិហេតុក-ជវនចិត្ត ៣៤ ។

អង្គធម៌របស់អធិបតី ៤ ប្រការនេះ និងឃើញបានថា ធម៌ដែលចាត់ជាអធិបតីបាននោះ ត្រូវជាធម៌ក្នុងជវនចិត្ត ហើយជាជវនចិត្តដែលប្រកបដោយហេតុ ២ ប្រការ ហៅថា ទ្វិហេតុកជវន:យ៉ាងតិច ឬត្រូវប្រកបដោយហេតុ ៣ ប្រការ ហៅថា តិហេតុកជវន: ដូចព្រះអនុរុទ្ធាចារ្ស

សម្តែងទុកក្នុងព្រះអភិធម្មត្ថសង្គហ:ថា

ទ្វិហេតុកតិហេតុកជវនេស្វេ យថាសម្ភវំ អធិបតិឯកោ លព្ភតិ

ប្រែថា ទ្វិហេតុកជវន: និងតិហេតុកជវន:ប៉ុណ្ណោះ ដែលនឹងមានអធិបតីបានតែមួយក្នុងចំនួន ៤ អធិបតិនោះ ជវនចិត្តដែលជាអធិបតីបាននោះ ហៅថា សាធិបតិជវន: បានដល់ ជវនចិត្ត ៥២ ដួង គឺ ទ្វិហេតុក-ជវនចិត្ត ១៨ និងតិហេតុកជវនចិត្ត ៣៤ មានសេចក្តីលម្អិតដូច្នេះ គឺ

ជវនចិត្តមាន ៥៥

អហេតុកជវនចិត្ត ១ បានដល់ ហសិតុប្បាទចិត្ត ១

ឯកហេតុកជវនចិត្ត ២ បានដល់ មោហមូលចិត្ត ២

ទ្វិហេតុកជវនចិត្ត ១៨ បានដល់ លោភមូលចិត្ត ៨ ទោសមូលចិត្ត ២ មហាកុសលញ្ញាណវិប្ផយុត្ត ៤ មហាកិរិយាញ្ញាណវិប្ផយុត្ត ៤ ។

តិហេតុកជវនចិត្ត ៣៤ មហាកុសលញ្ញាណសម្បយុត្ត ៤ មហាកិរិយាញ្ញាណសម្បយុត្ត ៤ មហគ្គតកុសល ៩ មហគ្គតកិរិយា ៩ លោកុត្តរចិត្ត ៨ = សាធិបតិជវនចិត្ត ៥២ ។

៧. អាហារ

អាហារ ប្រែថា **នាំមក** សេចក្តីថា **អាហារ** ជាធម៌ដែលឧបត្ថម្ភនាំឱ្យផលធម៌កើតឡើង ដូចមានវចនត្ថ:ថា **អាហរន្តីតិ = អាហារា**

ប្រែថា ធម៌ទាំងឡាយណារមែងនាំមកនូវធម៌ដែលជាផលរបស់

ខ្លួនៗ ដូច្នោះធម៌ទាំងឡាយនោះ ឈ្មោះថា **អាហារ** ។

សេចក្ដីថា **អាហារ** ជាហេតុឧបត្ថម្ភគាំទ្រឱ្យផលកើតឡើងនិងជួយឱ្យតាំងនៅបាន ចម្រើនឡើងបាន ហាក់ដូចជា **អាហារ** ជាអ្នកនាំឬអ្នកចាត់ចែងកិច្ចការងារផ្សេងៗ ព្រោះតាមធម្មតាកិច្ចការណា និងចាត់តាំងឡើងបាន រក្សាទុកឱ្យគង់រង់តាំងនៅបាន និងឱ្យចម្រើនរុងរឿងឡើងនោះ ត្រូវអាស្រ័យអ្នកចាត់ការឬអ្នកនាំជាសំខាន់ បើខ្វះអ្នកនាំឬអ្នកចាត់ការហើយ កិច្ចការនោះៗ នឹងតាំងនៅនិងចម្រើនឡើងមិនបាន សេចក្ដីនេះយ៉ាងណា ការរស់នៅរបស់សត្វទាំងឡាយក្នុងកាមភូមិ ក៏យ៉ាងនោះដែរ គឺ កាលសត្វទាំងនោះកើតឡើងដោយអំណាចរបស់កុសល អកុសលធម៌ហើយ សត្វនោះនឹងមានជីវិតនៅបាន និងចម្រើនឡើងបាន ក៏ដោយអាស្រ័យឱជាដែលនៅក្នុងអាហារផ្សេងៗ ជាអ្នកនាំឱ្យអាហារជរូបកើតឡើងបានក្នុងសត្វទាំងនោះ កាលអាហារជរូបកើតឡើងហើយ រមែងធ្វើឱ្យសត្វនោះមានជីវិតនៅបាន និងចម្រើនលូតលាស់ឡើងបាន នេះគឺ ភាពជាអ្នកនាំរបស់អាហារ រមែងធ្វើឱ្យផលកើតឡើងឱ្យតាំងមាំនៅបាន និងឱ្យចម្រើនឡើងបាន ។

អាហារមាន ៤ ប្រភេទ

១. **ការលិង្ការាហារ ធម្មជាតិដែលនាំឱ្យអាហារជរូបកើតឡើង អង្គធម៌ បានដល់ ឱជាដែលនៅក្នុងអាហារផ្សេងៗ គឺ អាហាររូប ។

២. ផស្សាហារ ធម្មជាតិដែលនាំឱ្យវេទនាកើតឡើង អង្គធម៌

បានដល់ ផស្សចេតសិក ដែលនៅក្នុងចិត្តទាំងអស់ ។

៣. មនោសញ្ចេតនាហារ ធម្មជាតិដែលនាំឱ្យវិបាកវិញ្ញាណ មានបដិសន្ធិវិញ្ញាណជាដើម កើតឡើង អង្គធម៌ បានដល់ ចេតនាចេតសិក ដែលនៅក្នុងចិត្តទាំងអស់ ។

៤. វិញ្ញាណាហារ ធម្មជាតិដែលនាំឱ្យចេតសិក និងកម្មជរូបកើតឡើង អង្គធម៌ បានដល់ ចិត្តទាំងអស់ ។

អធិប្បាយ

កវលិង្ការាហារ នាំមកនូវរូបធម៌ដែលកើតពីឱជា មានបាយ ទឹក នំ ទឹកដោះជាដើម ធ្វើឱ្យកើតអាហារសុទ្ធដ្ឋកកលាបឡើងខាងក្រោយក្នុងសន្ធានរបស់សត្វទាំងឡាយ ពោលគឺ កាលសត្វទាំងឡាយកើតឡើងបានដោយអំណាចរបស់អកុសល និងកាមាវចរកុសលធម៌ហើយ សត្វនោះនឹងមានជីវិតនៅបាននិងចម្រើនលូតលាស់ឡើងបាន ក៏ត្រូវអាស្រ័យឱជាដែលនៅក្នុងអាហារផ្សេងៗ ជាអ្នកនាំឱ្យអាហារជរូបកើតឡើងដល់សត្វទាំងឡាយនោះ កាលអាហារជរូបកើតឡើងហើយ ក៏ធ្វើឱ្យសត្វនោះមានជីវិតនៅបាន និងចម្រើនលូតលាស់ឡើងបាន ដូច្នោះឱជាដែលនៅក្នុងអាហារផ្សេងៗ នោះឯង ទើបឈ្មោះថា **កវលិង្ការាហារ** គឺ អាហាររូបនោះឯង ។

ផស្សចេតសិក បានឈ្មោះថា ជាអាហារ ព្រោះជាអ្នកនាំមកនូវវេទនាផ្សេងៗ មានសុខខ្លះ ទុក្ខខ្លះ មិនសុខមិនទុក្ខខ្លះ ។

ធម្មតាសត្វទាំងឡាយដែលមានការដឹងខ្លួនថា សប្បាយ មិនសប្បាយ ឬព្រងើយៗ ដែលជាសភាពរបស់វេទនាទាំងនេះ នឹងប្រាកដឡើងបានក៏ត្រូវអាស្រ័យមានការប៉ះខ្ទប់គ្នារវាងអារម្មណ៍ ទ្វារ និងចិត្ត ការប៉ះខ្ទប់គ្នារវាងសភាវធម៌ ៣ ប្រការនេះ ហៅថា **ផស្ស** បើមិនមាន **ផស្ស** គឺ ការប៉ះខ្ទប់របស់ចិត្ត និងអារម្មណ៍ត្រង់ទ្វារនេះហើយ ការដឹងខ្លួនផ្សេងៗ នឹងប្រាកដឡើងមិនបាន និងកាលសត្វទាំងឡាយខ្វះការដឹងខ្លួននេះហើយ សេចក្តីលោភ ពេញចិត្តក្នុងអារម្មណ៍ផ្សេងៗ ដែលជាហេតុនៃការចម្រើនធំធាត់របស់សត្វទាំងឡាយក៏មិនបានដូចគ្នា ដូច្នោះ **ផស្ស** ទើបបានឈ្មោះថា **ផស្សាហារ** ព្រោះនាំមកនូវវេទនា គឺ ការដឹងខ្លួនក្នុងការសោយអារម្មណ៍របស់សត្វទាំងឡាយនោះឯង ។

ចេតនាចេតសិក ឈ្មោះថា អាហារ ព្រោះជាអ្នកនាំឱ្យវិបាកចិត្តមានបដិសន្ធិវិញ្ញាណនិងបញ្ចវិញ្ញាណជាដើមកើតឡើង ទាំងនេះព្រោះធម្មតាសត្វទាំងឡាយក្នុងលោកនេះវៀរតែព្រះអរហន្តចេញ កាលស្លាប់ក៏រមែងមានការកើតឡើងថ្មីជាប់តគ្នាភ្លាម និងតមកក៏មានការឃើញ ការឮ ដឹងក្លិន ដឹងរស ប៉ះត្រូវសម្ផស្សប្រាកដឡើង តមកចិត្តដែលដឹងអារម្មណ៍ទាំងនេះជាវិបាកវិញ្ញាណទាំងអស់ ហើយធម៌ដែលជាហេតុនៃវិបាកវិញ្ញាណទាំងនេះ ក៏បានដល់ ចេតនា ដែលមានសភាពចាត់ចែងការធ្វើផ្សេងៗ ដែលទាក់ទងដោយកាយ វាចា ចិត្ត បើមិនមានចេតនាជាអ្នកចាត់ចែងទេ សត្វទាំងឡាយកាលស្លាប់ហើយ ក៏មិនមានការកើត ការឃើញ ការឮជាដើមដែរ ចេតនាដែលជាអ្នកនាំឱ្យសត្វទាំងឡាយ

កើតឡើង និងមានការឃើញ ការឮ ជាដើមទាំងនេះមាន ២ ប្រភេទ គឺ

ចេតនាដែលប្រកបក្នុងអកុសលនិងលោកិយកុសលនោះ រមែងជាអ្នកនាំឱ្យវិបាកវិញ្ញាណកើតឡើងដោយត្រង់ ។

ចំណែកចេតនា ដែលប្រកបជាមួយចិត្តដទៃ ដែលក្រៅពីអកុសលនិងលោកិយកុសលនោះ ជាអ្នកនាំសម្បយុត្តខន្ធជាមួយគ្នាឱ្យកើតឡើងប៉ុណ្ណោះ គឺ ចេតនាចេតសិក ជាធម្មជាតិដែលដាស់តឿនសម្បយុត្តធម៌ឱ្យកើតឡើងធ្វើនាទីរបស់ខ្លួនៗ នោះឯង ទើបជាចេតនាដែលធ្វើឱ្យផលកើតឡើងដោយមិនប្រាកដច្បាស់យ៉ាងណាក្តី ចេតនាចេតសិកដែលកើតជាមួយចិត្តទាំងអស់នេះ ក៏រមែងធ្វើនាទីនាំឱ្យវិបាកវិញ្ញាណនិងសម្បយុត្តខន្ធកើតឡើងបានទាំងអស់ ដោយហេតុនេះ ចេតនាចេតសិកដែលនៅក្នុងចិត្តទាំងអស់ ទើបឈ្មោះថា **មនោសញ្ចេតនាហារ** ។

វិញ្ញាណ គឺ ចិត្តទាំងអស់ ឈ្មោះថា អាហារ ព្រោះជាអ្នកនាំឱ្យចេតសិក និងកម្មជរូបកើតឡើង ។

ធម្មតានាមខន្ធ ៤ គឺ ចិត្តនិងចេតសិក រមែងមានការកើតព្រមគ្នា រលត់ព្រមគ្នា មានអារម្មណ៍និងវត្ថុទីអាស្រ័យជាមួយគ្នា តែចិត្តនោះរមែងជាប្រធានក្នុងធម៌ទាំងពួង ទើបជាអ្នកនាំចេតសិកនិងកម្មជរូប ពោលគឺ ក្នុងបដិសន្ធិកាល បដិសន្ធិវិញ្ញាណ ជាអ្នកនាំឱ្យចេតសិកនិងកម្មជរូបកើតឡើង តែចំណែកក្នុងបវត្តិកាល បវត្តិវិញ្ញាណជាអ្នកនាំឱ្យចេតសិកនិងចិត្តជរូបកើតឡើង មិនបាននាំឱ្យកម្មជរូបកើតឡើងផងឡើយ ទាំងនេះព្រោះកម្មជរូបមិនមែនរូបដែលកើតពីសមុដ្ឋានរបស់ចិត្ត តែជារូប

ដែលកើតពីសមុដ្ឋានរបស់កម្ម យ៉ាងណាក្តី កម្មជរូបដែលកើតក្នុងបវត្តិកាល និងកម្មជរូបរបស់អសញ្ញសត្តព្រហ្មទាំងនេះ សូម្បីមិនបានកើតឡើងដោយអាស្រ័យចិត្តក្នុងភពបច្ចុប្បន្ននេះក្តី តែរមែងអាស្រ័យកើតមកពីអតីតកម្មដែលហៅថា កម្មវិញ្ញាណ គឺ អកុសលចិត្ត និងលោកិយកុសលចិត្តក្នុងភពមុនៗ ក៏ឈ្មោះថា ជាវិញ្ញាណដូចគ្នា ដោយហេតុនេះ ចិត្តទាំងអស់ ទើបឈ្មោះថា **វិញ្ញាណាហារ** ។

ឱជដ្ឋមកវូបំ យេ វេទនំ បដិសន្ធិកំ

នាមរូបំ អាហារន្តិ តស្មាហារាតិ រុច្ចរេ ។

ធម៌ទាំងឡាយណា រមែងនាំអាហារជសុទ្ធដ្ឋកកលាប វេទនា បដិសន្ធិវិញ្ញាណ ចេតសិកនិងកម្មជរូប ដោយចំពោះខ្លួនៗ ធម៌ទាំងឡាយនោះ ឈ្មោះថា អាហារ ។

សព្វេ សត្តា អាហារដ្ឋិតិកា ។

សត្វទាំងឡាយរស់នៅបានព្រោះអាហារ ។

រួមសេចក្តីថា ការនាំមករបស់អាហារ ៤ ប្រការនេះ គឺ

កវលិង្ការាហារ នាំមកនូវ អាហារជសុទ្ធដ្ឋកកលាប ឱ្យកើតឡើងក្នុងសន្តានរបស់សត្វទាំងឡាយ ។

ផស្សាហារ នាំមកនូវ វេទនា គឺ ការសោយអារម្មណ៍ សុខ ទុក្ខ ជាដើម របស់សត្វទាំងឡាយ ។

មនោសញ្ចេតនាហារ នាំមកនូវបដិសន្ធិវិញ្ញាណជាដើម និងសម្ប-យុត្តខន្ធទាំងពួង បានដល់ ការកើតជាមនុស្ស ទេវតា ព្រហ្ម និងអបាយ

សត្ត្ว រហូតការយើញ ការឮ ជាដើម និងបវត្តិវិញ្ញាណទាំងឡាយរបស់សត្ត្ว ។

វិញ្ញាណាហារ នាំមកនូវ ចេតសិក ចិត្តជរូប និង កម្មជរូប ។

ចប់ មិស្សកសង្គហ

ពួកទី ៣ ពោធិបក្ខិយសङ्គហ

ពោធិបក្ខិយសង្គហ:នេះ កាលកាត់បទបាន ៣ បទ គឺ

ពោធិ + បក្ខិយ + សង្គហ ។

ពោធិ ប្រែថា ដឹង សំដៅដល់ ដឹងការធ្វើឱ្យអស់អាសវ: គឺ ដឹងអរិយសច្ច: ៤ ។

បក្ខិយ ប្រែថា ជាពួក គឺ ជាពួកមគ្គញ្ញាណ ។

សង្គហ ប្រែថា ដោយសង្ខេប ឬ រួបរួម ។

ពោធិបក្ខិយសង្គហ ទើបសំដៅដល់ការរួបរួមធម៌ដែលជាពួកនៃមគ្គញ្ញាណ មានវចនត្ថ:របស់ពោធិបក្ខិយសង្គហ: សម្តែងថា

ចត្តារិ សច្ចានិ ពុជ្ឈតីតិ = ពោធិ

ប្រែថា ធម្មជាតិណា ដឹងអរិយសច្ចទាំង ៤ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **ពោធិ** អង្គធម៌ បានដល់ បញ្ញាដែលនៅក្នុងមគ្គចិត្ត ៤ ។

ក្នុងមហានិទ្ទេសព្រះបាលី មានសម្តែងថា **ពោធិ រុচ្ចតិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ** ។ ប្រែថា ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល: ធម្មវិចយ: សម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គ ៤ លោកហៅថា **ពោធិ** ។ (បិដក ៦៥ ទំព័រ ២៣៥)

ពោធិយា បក្ខេ ភវាតិ = ពោធិបក្ខិយា

ប្រែថា ធម៌ដែលកើតក្នុងពួកមគ្គញ្ញាណ ៤ ឈ្មោះថា **ពោធិបក្ខិយ** បានដល់ ពោធិបក្ខិយធម៌ ៣៧ ប្រការ ។

ពោធិបក្ខិយានំ សង្គហោតិ = ពោធិបក្ខិយសង្គហោ

ប្រែថា ការរួបរួមធម៌ដែលជាពួកនៃមគ្គញ្ញាណ ៤ ដូច្នោះឈ្មោះថា ពោធិបក្ខិយសង្គហៈ ក្នុងពោធិបក្ខិយសង្គហៈ មានពួកធម៌ ៧ ពួក និងកាលពោលដោយប្រភេទមាន ៣៧ ប្រការ ដូចសម្តែងគាថាសង្គហៈថា

គាថាសង្គហៈទី ៦-៧

៦. ឆន្ទោ ចិត្តមុបេក្ខា ច សទ្ធាបស្សទ្ធិបីតិយោ
សម្មាទិដ្ឋិ ច សង្កប្បោ វាយាមោ វិរតិត្តយំ ។

៧. សម្មាសតិ សមាធីតិ ចុទ្ទសេតេ សភាវតោ
សត្តតីសប្បភេទេន សត្តធា ឥត្ថ សង្គហោ ។

ប្រែថា ពោធិបក្ខិយធម៌ទាំងឡាយនេះ ដោយសភាវអង្គធម៌មាន ១៤ គឺ ឆន្ទៈ ១, ចិត្ត ១, ឧបេក្ខា ១, សទ្ធា ១, បស្សទ្ធិ ១, (កាយបស្សទ្ធិ និងចិត្តបស្សទ្ធិទាំង ២ នេះរាប់ ១) បីតិ ១, សម្មាទិដ្ឋិ ១, សម្មាសង្កប្ប ១, សម្មាវាយាម ១, វិរតិ ៣, សម្មាសតិ ១, និងសម្មាសមាធិ ១, ដោយប្រភេទមាន ៣៧ ការប្រមូលធម៌ជាចំណែកក្នុងការត្រាស់ដឹងនោះមាន ៧ យ៉ាង ។

១. សតិប្បដ្ឋាន មាន ៤ ប្រភេទ

២. សម្មប្បធាន មាន ៤ ប្រភេទ

៣. ឥទ្ធិបាទ មាន ៤ ប្រភេទ

៤. ឥន្ទ្រិយ មាន ៥ ប្រភេទ

៥. ពល មាន ៥ ប្រភេទ

៦. ពោជ្ឌង្គ មាន ៧ ប្រភេទ

៧. មគ្គ មាន ៨ ប្រភេទ ។

១. សតិប្បដ្ឋាន

បណ្តាសព្វសត្វទាំងឡាយ ដែលត្រូវវិលវល់កើតស្លាប់នៅក្នុងវដ្តទុក្ខ តាមហេតុតាមបច្ច័យ រាប់ភពជាតិមិនបាន ដរាបដែលព្រះសម្មាសម្ពុទ្ធនៅមិនទាន់បានឧប្បត្តិឡើងក្នុងលោកហើយ ក៏រមែងនឹងត្រូវវិលវល់កើតស្លាប់តទៅទៀតមិនមានទីបំផុត ។

កាលព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ដោយបានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញាណ ឃើញព្រះនិព្វានដែលមិនត្រូវវិលវល់កើតស្លាប់តទៅទៀត ហើយបង្ហាញផ្លូវដែលនិងទៅកាន់ព្រះនិព្វាននោះ ដែលជាផ្លូវឯកផ្លូវតែមួយប៉ុណ្ណោះ ដែលនឹងញ៉ាំងសេចក្តីបរិសុទ្ធឱ្យដល់សត្វទាំងឡាយបាន ផ្លូវនេះ ក៏គឺ មហាសតិប្បដ្ឋាន ៤ ។ ដូចបាលីក្នុងសតិប្បដ្ឋានសូត្រសម្តែងថា

ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា ។

ប្រែថា ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ

ដើម្បីលះបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។ (បិដកភាគ ១៤ ទំព័រ ២៤៤)

ក្នុងបាលីសតិប្ឋានសូត្រនេះ រមែងសម្តែងហេតុនិងផលពិសេសនៃសតិប្ឋានទុកដូច្នេះ

ហេតុ គឺ ជាផ្លូវមួយដែលនឹងនាំទៅកាន់ព្រះនិព្វាន ។

ផល គឺ អ្នកចម្រើនក្នុងផ្លូវសតិប្ឋាននេះនឹងបានទទួលផលពិសេស ៧ ប្រការ

១. បរិសុទ្ធចាកកិលេស

២. ផុតចាកសេចក្តីសោកសៅ

៣. ផុតចាកសេចក្តីខ្សឹកខ្សួល

៤. ផុតចាកសេចក្តីទុក្ខកាយ

៥. ផុតចាកសេចក្តីទុក្ខចិត្ត

៦. ញ្ជាំងផលឱ្យបានអរិយមគ្គ

៧. ធ្វើព្រះនិព្វានឱ្យជាក់ច្បាស់ចំពោះមុខក្នុងភពនេះ ។

សេចក្តីថា ព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងព្រះនិព្វាន ដែលជាធម៌ពិសេសប្រាសចាកទុក្ខ ទោមនស្ស ផុតចាកសេចក្តីយំសោកហើយ ទ្រង់បានបង្ហាញផ្លូវបដិបត្តិឱ្យចូលដល់ សភាវធម៌តាមសេចក្តីពិត មានរូបនាមខន្ធ ៥ ជាដើម ដើម្បីធ្វើព្រះនិព្វានឱ្យជាក់ច្បាស់ ដែលមិនមានការកើត ការស្លាប់តទៅទៀត ។

នឹងបានសម្តែងសេចក្តីរបស់សតិប្ឋដ្ឋាន ដូចតទៅនេះ

សតិ + បដ្ឋាន = សតិបដ្ឋាន

សតិ ប្រែថា រលឹកបាន សេចក្តីថា រលឹក គុណធម៌ និងមិនមែនគុណធម៌ដែលបានធ្វើទៅហើយ ឬកំពុងធ្វើ ឬរលឹកដល់ពុទ្ធគុណ ធម្មគុណ សង្ឆគុណ រហូតដល់ការមានសតិ រលឹកដល់បច្ចុប្បន្នរបស់រូបនាមដោយមិនភ្លេច ខណ:នោះរមែងរារាំងកិលេសនីវរណ:ឱ្យចិត្តតាំងនៅក្នុងសោភណចិត្ត ក្នុងបរមត្ថទីបនីដីកា សម្តែងថា

សរតីតិ សតិ អត្តនា កតានិ កត្តព្វានិ ច កល្យាណកម្មានិ វា ពុទ្ធគុណាទីនិ វា អប្ឋមជ្ជវសេន ឧបគច្ឆតីតិ ។

ប្រែថា សតិ គឺ ការរលឹកបាន ក្នុងសេចក្តីល្អ ដែលខ្លួនបានធ្វើទៅហើយ ឬកំពុងធ្វើតទៅក្តី ឬព្រះពុទ្ធគុណជាដើមក្តី ដោយមិនភ្លេច ។

បដ្ឋាន ប្រែថា ទីតាំង សេចក្តីថា ទីតាំងរបស់ធម៌ មានសតិជាដើម គឺអារម្មណ៍រូបនាម ដែលជាទីកំណត់ដឹងដោយសតិ សម្ឋជញ្ញក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីឱ្យដល់នូវសេចក្តីបរិសុទ្ធផុតចាកកិលេសទាំងឡាយ ដូចក្នុងមហាវារសូត្រសម្តែងថា **បដ្ឋាតីតិ = បដ្ឋានំ**

ប្រែថា ទីតាំងរបស់ធម៌ គឺ អារម្មណ៍ ឈ្មោះថា **បដ្ឋាន** ។

អ្នកដែលចូលទៅដឹងអារម្មណ៍ គឺ តាំងទុកត្រង់រូបធម៌នាមធម៌នោះ បានដល់ សតិ ដែលរលឹកទាន់ ដល់បច្ចុប្បន្នធម៌រឿយៗ ឈ្មោះថា សតិប្ឋដ្ឋាន ដូចក្នុងវិសុទ្ធិមគ្គអដ្ឋកថា សម្តែងថា **សតិយេវ បដ្ឋានំ សតិប្ឋដ្ឋានំ** ប្រែថា សតិ នោះឯងជាទីតាំង ឈ្មោះថា សតិប្ឋដ្ឋាន

សេចក្ដីថា សតិប្ឋដ្ឋាន គឺ ការតាំងសតិរលឹកទាន់ ដល់រូបនាមខន្ធ ៥ ដែលជាឋានឈានទៅកាន់ព្រះនិព្វាន ។

សតិប្ឋដ្ឋាន សតិប្រព្រឹត្តទៅក្នុងខាងមុខ កាន់យកសតិជាប្រធាន សូម្បីធ្វើសេចក្ដីព្យាយាមតាមបែបរបស់សតិប្ឋដ្ឋាន ឬវិបស្សនាកម្មដ្ឋានក្ដី មិនបានកាន់យកត្រឹមតែ សតិ ម្យ៉ាងទេ គួរកាន់យក សតិ ជាខាងមុខនៃការចងចាំដើម្បីប្រយោជន៍នៃបញ្ញា គឺ វិបស្សនាញាណប៉ុណ្ណោះ ។

សតិ និង **បញ្ញា** រមែងនៅមុខ ក្រោយ ជាប់គ្នាជានិច្ចមិនដាច់ពីគ្នា សតិជាមួយបញ្ញាកើតព្រមក្នុងខណៈចិត្តជាមួយគ្នា ក្នុងឋានទីតាំងរបស់ សតិ គឺ ត្រង់កាយ វេទនា ចិត្ត និងធម៌ ។

ក្នុងមហាសតិប្ឋដ្ឋានសូត្រសម្ដែងសតិប្ឋដ្ឋាន មាន ៤ យ៉ាង ដូចព្រះបាលីដែលសម្ដែងថា

ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្ឪជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់ នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ។

វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្ឪជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ។

ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ។

ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ។ (បិដកភាគ ១៤ ទំព័រ ២៤៤)

សតិប្បដ្ឋាន ៤ ក្នុងមហាសតិប្បដ្ឋានសូត្រ សម្តែងថា

១. កាយានុបស្សនាសតិប្បដ្ឋាន សតិតាំងមាំនៅក្នុងការតាមពិចារណាកាយ គឺ រូបក្ខន្ធ មានខ្យល់ចេញចូល ឥរិយាបទតូច ធំ ជាដើមរឿយៗ អង្គធម៌ បានដល់ សតិចេតសិក នៅក្នុងមហាកុសលចិត្ត

៨ មហាកិរិយាចិត្ត ៨ អប្បនាជវន: ២៦ ។

២. វេទនានុបស្សនាសតិប្បដ្ឋាន សតិតាំងមាំក្នុងការពិចារណាវេទនា គឺ សុខ ទុក្ខ ព្រងើយៗ រឿយៗ អង្គធម៌ បានដល់ សតិចេតសិក ដែលនៅក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវន: ២៦ ។

៣. ចិត្តានុបស្សនាសតិប្បដ្ឋាន សតិតាំងមាំនៅក្នុងការពិចារណាចិត្ត គឺ ចិត្តមានរាគ: ចិត្តមានទោស: ជាដើមរឿយៗ អង្គធម៌ បានដល់ សតិចេតសិក ដែលនៅក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវន: ២៦ ។

៤. ធម្មានុបស្សនាសតិប្បដ្ឋាន សតិតាំងមាំក្នុងការពិចារណាសភាវធម៌ គឺ រូបនាមដោយអាការប្រាសចាកតួខ្លួន បានដល់ នីវរណ: ៥ ខន្ធ ៥ ជាដើមរឿយៗ អង្គធម៌ បានដល់ សតិចេតសិក ដែលនៅក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវន: ២៦ ។

អង្គធម៌ដែលសម្តែងទុកក្នុងមហាសតិប្បដ្ឋាននេះ ជាការសម្តែងយ៉ាងទូលំទូលាយ តាំងពីចាប់ផ្តើមក្នុងការចម្រើនសតិ អង្គធម៌ទើបបានដល់ សតិ ដែលប្រកបក្នុងមហាកុសលញាណវិប្បយុត្តចិត្ត ៤ ផងសូម្បីក្នុងការចម្រើនសតិប្បដ្ឋានឱ្យអប្បនាឈានកើត ដើម្បីប្រើក្នុងឈានជាបាទដល់ការចម្រើនវិបស្សនា ក៏រាប់រួមដល់សតិដែលប្រកបក្នុងអប្បនាជវនចិត្ត ២៦ ដូងផង និងកាលព្រះអរហន្តលោកបំណងនឹងចម្រើនសតិប្បដ្ឋាន ក៏អាស្រ័យមហាកិរិយាចិត្ត ៨ ចម្រើនបានតាមន័យដែលពោលហើយ ។

តែកាលពោលដោយការចម្រើនសតិប្ឋានដោយត្រង់ ដើម្បីឱ្យវិបស្សនាញាណកើតឡើងរហូតដល់មគ្គញាណទាំង ៤ នោះ រមែងត្រូវអាស្រ័យសតិដែលប្រកបក្នុងមហាកុសលញាណសម្បយុត្តចិត្ត ៤ និងសម្មាសតិដែលជាអង្គមគ្គ ប្រកបក្នុងមគ្គចិត្ត ៤ នោះឯង ។

ព្រោះហេតុអ្វី ព្រះពុទ្ធអង្គទើបត្រាស់សតិប្ឋាន ៤ ប៉ុណ្ណោះ ក្នុងសម្មោហវិនោទនីអដ្ឋកថា ពន្យល់ថា ដើម្បីប្រយោជន៍ដល់វេនេយ្យសត្វដែលផ្សេងគ្នាដោយចរិត ការអប់រំសមថ: និងវិបស្សនា ឬដោយអំណាចនៃបញ្ញាចាស់ក្លា ទន់ខ្សោយ ក្រៃលែងជាងគ្នា ។

ចរិត ២ ប្រភេទ

បណ្តាបុគ្គលទាំងឡាយ ដែលបានអប់រំចរិត គឺ ការប្រព្រឹត្តបដិបត្តិរបស់ខ្លួន អាចបែងចែកចរិតបានជា ២ ពួក គឺ តណ្ហាចរិត និងទិដ្ឋិចរិត។

កាយានុបស្សនាសតិប្ឋាន ជាអារម្មណ៍រូបធម៌ដែលគ្រោតគ្រាត សមគួរដល់បុគ្គលអ្នកមានតណ្ហាចរិត និងមានបញ្ញាទន់ខ្សោយ (មន្ទបុគ្គលអ្នកមានតណ្ហាចរិតយ៉ាងគ្រោតគ្រាត) ។

វេទនានុបស្សនាសតិប្ឋាន ជាអារម្មណ៍នាមវេទនាដែលសមគួរដល់បុគ្គលអ្នកមានតណ្ហាចរិត និង បញ្ញាចាស់ក្លា (តិក្ខបុគ្គលអ្នកមានតណ្ហាចរិតយ៉ាងល្អិត) ។

ចិត្តានុបស្សនាសតិប្ឋាន ជាអារម្មណ៍របស់នាមចិត្តដែលចែកចេញទៅពីនាមវេទនា សមគួរដល់បុគ្គលអ្នកមានទិដ្ឋិចរិត និងមានបញ្ញា

យ៉ាងទន់ខ្សោយ (មន្ទបុគ្គលអ្នកមានទិដ្ឋិចរិតយ៉ាងគ្រោតគ្រាត) ។

ធម្មានុបស្សនាសតិប្បដ្ឋាន ជាអារម្មណ៍ចែករូបនាមចេញទៅសមគួរដល់បុគ្គលអ្នកមានទិដ្ឋិចរិត និងមានបញ្ញាយ៉ាងខ្លាំងក្លា (តិក្ខបុគ្គលអ្នកមានទិដ្ឋិចរិតយ៉ាងល្អិត) ។

សតិប្បដ្ឋានជាមួយអារម្មណ៍របស់សមថ:និងវិបស្សនា

កាយានុបស្សនាសតិប្បដ្ឋាន ជាអារម្មណ៍ដែលសមគួរដល់សមថយានិកយ៉ាងទន់ខ្សោយ ។

វេទនានុបស្សនាសតិប្បដ្ឋាន ជាអារម្មណ៍ដែលសមគួរដល់សមថយានិកយ៉ាងចាស់ក្លា (អ្នកសម្រេចចតុត្ថជ្ឈាន)

ចិត្តានុបស្សនាសតិប្បដ្ឋាន ជាអារម្មណ៍ដែលសមគួរដល់វិបស្សនាយានិកយ៉ាងទន់ខ្សោយ ។

ធម្មានុបស្សនាសតិប្បដ្ឋាន ជាអារម្មណ៍ដែលសមគួរដល់វិបស្សនាយានិកយ៉ាងចាស់ក្លា ។

ព្រះមានព្រះភាគត្រាស់សតិប្បដ្ឋាន ៤ ដើម្បីលះវិបល្លាស

កាយានុបស្សនាសតិប្បដ្ឋាន ដើម្បីលះសុភវិបល្លាស ។

វេទនានុបស្សនាសតិប្បដ្ឋាន ដើម្បីលះសុខវិបល្លាស ។

ចិត្តានុបស្សនាសតិប្បដ្ឋាន ដើម្បីលះនិច្ចវិបល្លាស ។

ធម្មានុបស្សនាសតិប្បដ្ឋាន ដើម្បីលះអត្តវិបល្លាស ។

សតិប្ឋដ្ឋាន សូម្បីព្រះពុទ្ធអង្គទ្រង់តាំងទុក ៤ ប្រការក្តី តែការចូលដល់ព្រះនិព្វានៃ សតិប្ឋដ្ឋានតែម្យ៉ាងប៉ុណ្ណោះក៏ចូលដល់បាន ឧបមាដូចនគរមួយមានទ្វារ ៤ ជនទាំងឡាយអ្នកមកពីទិសខាងកើត កាន់យកទំនិញដែលមាននៅក្នុងទិសខាងកើត ក៏អាចចូលទៅកាន់នគរនោះបាន អ្នកមកពីទិសខាងត្បូង អ្នកមកពីទិសខាងលិច មកពីទិសខាងជើង ក៏ចូលកាន់នគរតាមទិសនោះបាន យ៉ាងណា កាយ វេទនា ចិត្ត និងធម៌ ក៏ឧបមេយ្យដូចទិសទាំង ៤ យ៉ាងនោះដែរ នឹងបានបរិយាយសតិប្ឋដ្ឋាន ៤ ដោយលំដាប់តទៅ ។

កាយានុបស្សនាសតិប្ឋដ្ឋាន

កាយានុបស្សនាសតិប្ឋដ្ឋាន កាលកាត់បទបាន ៣ បទ គឺ

កាយ + អនុ + បស្សនា ។

កាយ ប្រែថា ប្រជុំដោយ ដី ទឹក ភ្លើង ខ្យល់ ជាដើម បានដល់ រាងកាយជារូបធម៌ ។

អនុ ប្រែថា តាម ។

បស្សនា ប្រែថា ឃើញ ។

កាយានុបស្សនា ទើបប្រែថា តាមឃើញកាយរឿយៗ សេចក្តីថា តាំងសតិ កំណត់ពិចារណាតាមឃើញកាយរឿយៗ រហូតវិបស្សនាញាណកើតឡើង ឃើញកាយ គឺ រូបធម៌តាមសេចក្តីពិត ក្នុងបរមត្ថទីបនីដីកាសម្តែងទុកថា

កាយេ អនុបស្សនា កាយានុបស្សនាតិ ប្រែថា ការយើញកាយ ឈ្មោះថា **កាយានុបស្សនា** បានដល់ ការពិចារណាកាយដោយសតិ បញ្ញា ឱ្យយើញកាយនេះថា ជារូបធម៌ ដែលជារបស់មិនស្អាត មានការ បែកធ្លាយជាធម្មតា ។

កាយានុបស្សនាសតិប្បដ្ឋាន សតិតាំងមាំនៅក្នុងការពិចារណា រឿយៗ នូវកាយ គឺ រូបក្ខន្ធនោះ មាន ១៤ ឋាន ឬ ១៤ បព្វ:

១. អានាបានបព្វ បានដល់ ខ្យល់ដង្ហើមចេញ ចូល ។

២. ឥរិយាបថបព្វ បានដល់ ឥរិយាបថ ៤ មានការ ដើរ ឈរ អង្គុយ ដេក ដែលហៅថា ឥរិយាបថធំ ។

៣. សម្បជញ្ញបព្វ បានដល់ ឥរិយាបថតូច មានអាការ ៧ ប្រការ គឺ ឈានទៅមុខ ថយក្រោយ បែរទៅខាងឆ្វេង បែរទៅខាងស្តាំ បត់ដៃចូល លាដៃចេញ កិរិយាស្លៀកដណ្តប់សំពត់ និងការប្រើគ្រឿង ប្រើប្រាស់ដទៃៗ ការទំពារ ការបរិភោគ ការផឹក ការបន្ទោបង់ឧច្ចារ: បស្សាវ: អាការដើរ ឈរ អង្គុយ ដេក ការនិយាយ ការកម្រើក ។

៤. បដិកូលសញ្ញា បានដល់ អាការ ៣២ របស់ធាតុដី ធាតុទឹក ខាងក្នុងរាងកាយ មានសក់ រោម ក្រចក ធ្មេញ ស្បែក ឈាម ប្រមាត់ ស្លេស្ម៉ជាដើម ។

៥. ចតុធាតុវវដ្ឋាន បានដល់ ការពិចារណាដោយភាពជាធាតុទាំង ៤ មានដី ទឹក ភ្លើង ខ្យល់ដោយលក្ខណ: ។

៦. អសុភ បានដល់ សរីរ:ស្លាប់ដែលគេចោលនៅក្នុងព្រៃស្មសាន

ទោះស្លាប់អស់ ១ ថ្ងៃក្តី ស្លាប់អស់ ២ ថ្ងៃក្តី ស្លាប់អស់ ៣ ថ្ងៃក្តី ដែលកំពុងហើម មានសម្បុរខៀវដោយច្រើនមានខ្ទុះហូរចេញតាមទ្វារផ្សេងៗ ។

៧. អសុភ បានដល់ សរីរៈស្លាប់ដែលគេចោលនៅក្នុងព្រៃស្មសានដែលក្អែកទាំងឡាយកំពុងចឹកស៊ីក្តី ត្រដក់គម្រង់ទាំងឡាយ កំពុងចឹកស៊ីក្តី ត្មាតទាំងឡាយ កំពុងចឹកស៊ីក្តី សត្វស្វានទាំងឡាយ កំពុងកកេរស៊ីក្តី ចចកទាំងឡាយ កំពុងកកេរស៊ីក្តី បាណកជាតិ (សត្វល្អិតៗ មានរុយជាដើម) ទាំងឡាយផ្សេងៗ កំពុងរូងជញ្ជក់ស៊ីក្តី ។

៨. អសុភ បានដល់ សរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន នៅសល់តែរាងឆ្អឹង ប្រកបដោយសាច់និងឈាម មានសរសៃជាគ្រឿងចង ។

៩. អសុភ បានដល់ សរីរៈនៅសល់តែរាងឆ្អឹង ឥតមានសាច់ ប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ។

១០. អសុភ បានដល់ សរីរៈនៅសល់តែរាងឆ្អឹង មិនមានសាច់ និងឈាម មានតែសរសៃជាគ្រឿងចង ។

១១. អសុភ បានដល់ សរីរៈនៅសល់តែរាងឆ្អឹងទទេ មិនមានសរសៃចងរូបរឹត ខ្ចាត់ខ្ចាយរាត់រាយទៅក្នុងទិសតូចនិងទិសធំ គឺឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក ឆ្អឹងទ្រនុងខ្នងទៅដោយឡែក ឆ្អឹងជំនីទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹងកំភូនដៃទៅដោយឡែក

ឆ្ពឹងកទៅដោយឡែក ឆ្ពឹងចង្កាទៅដោយឡែក ធ្មេញទៅដោយឡែក លលាដ៏ក្បាលទៅដោយឡែក ។

១២. អសុភ បានដល់ សរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែឆ្ពឹងទទេ មានសម្បុរ ស ដូចសម្បុរនៃស័ង្ខ ។

១៣. អសុភ បានដល់ សរីរៈសល់នៅតែឆ្ពឹងទទេ ពោយរាយជាពុំនូកៗ កន្លងហួសទៅមួយឆ្នាំហើយ ។

១៤. អសុភ បានដល់ សរីរៈសល់នៅតែឆ្ពឹងទទេ ពុកផុយខ្ទេចខ្ទី ជាកម្ទេចតូច កម្ទេចធំផ្សេងៗ ។ (បិដកភាគ ១៤ ទំព័រ ២៥៥)

អធិប្បាយពាក្យថា **កាយេ កាយានុបស្សី**

ពាក្យថា **កាយានុបស្សី** សេចក្តីថា មានប្រក្រតីតាមឃើញកាយ ពាក្យថា **កាយេ** ទ្រង់តាំង កាយ ឡើងមកទៀត ដើម្បីនិងសម្តែងការកំណត់ និងការទម្លាយឃនសញ្ញាជាដើម មិនឱ្យលាយគ្នា ដោយហេតុនេះ ទើបមិនបានត្រាស់ថា មានប្រក្រតីឃើញវេទនាក្នុងកាយ ឬមានប្រក្រតីតាមឃើញចិត្តក្នុងកាយ ឬមានប្រក្រតីឃើញធម៌ក្នុងកាយ ដោយហេតុនេះ **កាយេ កាយានុបស្សី** ទើបសំដៅដល់ មានប្រក្រតីតាមឃើញកាយក្នុងកាយប៉ុណ្ណោះ ពោលគឺ មានសតិរលឹកដឹងរូបកាយ ដោយភាពជារូបធម៌ក្នុង ១៤ បព្វនោះ មិនបានភ្លាំងភ្លាត់សតិកំណត់ដឹងរូបធម៌ ដោយភាពជាទុក្ខខ្លះ ឬដោយភាពជាស្ត្រីជាបុរសខ្លះដូច្នេះ ។

ពាក្យថា **វិហរតិ** សំដៅដល់ ឱ្យប្រព្រឹត្តទៅ គឺ ពិចារណារឿយៗ

នោះឯង ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ ។

ភិក្ខុពិចារណាឃើញ នូវកាយក្នុងកាយជាខាងក្នុង (កាយរបស់ខ្លួន) ជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ យ៉ាងនេះផង ពិចារណាឃើញ នូវកាយក្នុងកាយខាងក្រៅ (កាយរបស់បុគ្គលដទៃ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវកាយក្នុងកាយខាងក្នុង និងកាយខាងក្រៅ (កាយរបស់ខ្លួននិងកាយរបស់បុគ្គលដទៃ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ (បិដកភាគ ១៤ ទំព័រ ២៤៧)

ក្នុងសម្មោហវិនោទនីអដ្ឋកថា សតិប្ឋដ្ឋានវិភង្គបករណ៍ បរិយាយសេចក្ដីថា

ពាក្យថា **អជ្ឈត្តំ កាយេ** បានដល់ ឃើញកាយរបស់ខ្លួន ។

ពហិទ្ធា កាយេ បានដល់ ឃើញកាយរបស់អ្នកដទៃ ។

អជ្ឈត្តពហិទ្ធា កាយេ សេចក្ដីថា ក្នុងកាយរបស់ខ្លួនតាមសមគួរ ក្នុងកាយរបស់អ្នកដទៃតាមសមគួរ ដោយន័យដំបូង កំណត់កាយក្នុងកាយរបស់ខ្លួន ន័យទី ២ កំណត់កាយក្នុងកាយរបស់អ្នកដទៃ ន័យទី ៣ កំណត់កាយក្នុងកាយរបស់ខ្លួនតាមកាលសមគួរ ក្នុងកាយរបស់អ្នកដទៃតាមកាលសមគួរ ឈ្មោះថា អារម្មណ៍ដែលប៉ះខ្ទប់ព្រមគ្នា ទាំងខាងក្នុងនិងខាងក្រៅរមែងមិនមាន តែពោលដោយកាលដែលជាទីសញ្ជ្ញារបស់កម្មដ្ឋានដែលជំនាញទុកក្នុងពាក្យថា **អជ្ឈត្តពហិទ្ធា** ។

តែសេចក្តីយល់ឃើញរបស់អាចារ្យផ្នែកវិបស្សនា យល់ឃើញថា ពាក្យថា **ពហិទ្ធា កាយេ** បានដល់ កាយអ្នកដទៃនោះ អាចជាការយល់ឃើញរបស់អ្នកប្រែដែលប៉ាន់ប្រមាណសេចក្តី តាមសេចក្តីយល់ឃើញរបស់ខ្លួនឯង ព្រោះដោយហេតុផលហើយ ការកំណត់កាយ គឺ រូបធម៌ របស់អ្នកដទៃ យកមកជាអារម្មណ៍កម្មដ្ឋាននោះ ក្រៅពីអ្នកបដិបត្តិនិងត្រូវចៀសចេញចាកពួកគណ:ទៅនៅតែម្នាក់ឯង មិនមានអ្នកណាតាមទៅជាអារម្មណ៍ឱ្យពិចារណាហើយ នៅមិនបានប្រព្រឹត្តដើម្បីការទម្លាយឃនសញ្ញាដែលនឹងលះសក្កាយទិដ្ឋិយ៉ាងណាបាន មួយទៀត ក្នុងបាលីលោកក៏មិនបានសម្តែង **ពហិទ្ធា កាយេ** ទុកដោយត្រង់ លោកសម្តែងថា **ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ** ពិចារណាឃើញកាយក្នុងកាយជាកាយខាងក្រៅ ដែលមិនបានសំដៅដល់កាយរបស់អ្នកដទៃ ដោយហេតុផលគួរនិងជាកាយ គឺ រូបធម៌ ដែលជាអារម្មណ៍ខាងក្រៅច្រើនជាងនិងពាក្យថា **អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ** ពិចារណាឃើញកាយក្នុងកាយទាំងខាងក្នុងទាំងខាងក្រៅ ពាក្យថា ខាងក្នុងគួរនឹងសំដៅដល់ចិត្ត គឺ ត្រូវវិបស្សនា ខាងក្រៅគួរនឹងសំដៅដល់អារម្មណ៍ គឺ រូបនាមដែលជាត្រូវសតិប្បដ្ឋាននោះឯង ទាំងនេះព្រោះកាលអ្នកបដិបត្តិចម្រើនកាយានុបស្សនាសតិប្បដ្ឋាន រហូតមានការជំនាញក្នុងការកំណត់រូបធម៌ដែលជាអារម្មណ៍ ដូចជាកំណត់ឥរិយាបថទាំង ៤ រហូតជំនាញល្អហើយ សូម្បីអារម្មណ៍ដទៃ ខាងក្រៅក៏អាចកំណត់ទាន់បច្ចុប្បន្នអារម្មណ៍នោះ។ បានផង ។

ឬន័យម្យ៉ាងទៀត **អជ្ឈត្តំ វា** កាយខាងក្នុង សំដៅដល់ **កាយ** (រូប) ដែលប្រើជាអារម្មណ៍ របស់កាយានុបស្សនាសតិប្បដ្ឋាននោះ ។

ពហិទ្ធំ វា កាយខាងក្រៅ សំដៅដល់ កាយានុបស្សនាសតិប្បដ្ឋានក្នុងបព្វដទៃ ដែលក្រៅពីកាយដែលកំណត់ (**អជ្ឈត្តំ**) នោះ ។

អ្នករូបរូមយល់ស្របជាមួយហេតុផល របស់អាចារ្យផ្នែកវិបស្សនានោះ ។

ពាក្យថា **អាតាបី សម្បជានោ សតិមា** ជាការសម្តែងការប្រកបដោយសេចក្តីព្យាយាម ដោយបញ្ញា ព្រមដោយសតិ ។

អាតាបី គឺ ការព្យាយាមដុតកិលេសដោយការកំណត់កាយជាអារម្មណ៍ ។

សម្បជានោ គឺ មានសម្បជញ្ញ សំដៅដល់ ប្រកបដោយបញ្ញាដឹងអារម្មណ៍ តាមសេចក្តីពិតថា ជារូបអ្វី ឬនាមអ្វី?

សតិមា ជាអ្នកប្រកបដោយសតិរលឹកអារម្មណ៍កម្មដ្ឋាន រមែងរុងរឿងដល់អ្នកដែលមានសេចក្តីព្យាយាម មានបញ្ញា មិនភ្លេចសតិ ដោយហេតុនេះព្រះមានព្រះភាគ ទើបត្រាស់គុណរបស់កាយានុបស្សនាសតិប្បដ្ឋានថា **អាតាបី សម្បជានោ សតិមា** ដើម្បីសម្តែងអង្គនៃការលះកិលេស ទើបត្រាស់ថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ។

ពាក្យថា **វិនេយ្យ** សំដៅដល់ នាំចេញហើយដោយតទង្គវិន័យ ឬវិក្ខម្ភនវិន័យ ។

លោកេ សំដៅដល់ កាយ គឺ សង្ខារលោក បានដល់ រូបនាមខន្ធ

៥ ដែលប្រជុំគ្នា ។

អភិជ្ឌាទោមនស្សំ គឺ សេចក្ដីត្រេកអរ មិនពេញចិត្ត បានដល់ កាមឆន្ទ: និងព្យាបាទដែលរាប់នៅក្នុងនីវរណធម៌ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ការលះសេចក្ដីត្រេកអរ ដែលមានកាយសម្បត្ដិ ជាមូល ដោយការនាំអភិជ្ឌាចេញ និងការមិនពេញចិត្ត ដែលមានកាយ វិបត្ដិជាមូល ដោយការនាំទោមនស្សចេញ ក្នុងកាយានុបស្សនា សតិប្ឋដ្ឋាន ១៤ បព្វនេះ ។

ឥរិយាបថបព្វ សម្បជញ្ញបព្វ និង**ចតុធាតុមនសិការ** ជាអារម្មណ៍ របស់សតិ ក្នុងការចម្រើនវិបស្សនាភាវនា ។

ចំណែកបដិកូលសញ្ញាបព្វ អសុភបព្វ និងអានាបានបព្វ ជា អារម្មណ៍របស់សតិ ក្នុងការចម្រើនសមថភាវនា ទើបត្រូវចម្រើនសមថ: ជាមុនសិន ហើយទើបលើកឡើងកាន់វិបស្សនាដោយប្រើរូបនាម ដែល ជាអារម្មណ៍ក្នុងខាងក្រោយ ហៅថា សមថ: ជាបាទរបស់វិបស្សនា ។

វេទនានុបស្សនាសតិប្ឋដ្ឋាន

វេទនានុបស្សនា កាត់បទបាន ៣ បទ គឺ **វេទនា + អនុ + បស្សនា**

វេទនា ប្រែថា សោយអារម្មណ៍ បានដល់ សេចក្ដីដឹងសុខ ទុក្ខ និងមិនសុខមិនទុក្ខ ។

អនុ ប្រែថា តាម ។

បស្សនា ប្រែថា ឃើញ ។

វេទនានុបស្សនា ទើបប្រែថា តាមឃើញវេទនា គឺ ការសោយ-អារម្មណ៍ សេចក្តីថា មានសតិតាមពិចារណាមើលវេទនាដោយបញ្ញារឿយៗ ថា វេទនានេះ ជាសភាវធម៌ម្យ៉ាង មិនមែនសត្វបុគ្គល ត្វខ្លួនយើងគេ ជាសភាវ:របស់វេទនា ដែលសម្តែងការដឹងសុខ ទុក្ខ ឬព្រងើយៗ ពោលគឺ ខណ:សោយសុខវេទនា ក៏មានសតិតាមដឹងការសោយសុខវេទនា ខណ:សោយទុក្ខវេទនា ក៏មានសតិតាមដឹងការសោយទុក្ខវេទនា ឬខណ:សោយអទុក្ខមសុខវេទនា ក៏មានសតិតាមដឹងអទុក្ខមសុខវេទនានោះ ។

វេទនានុបស្សនាសតិប្បដ្ឋាន មាន ៩ បព្វ គឺ

បព្វទី ១ មានសតិពិចារណារឿយៗ សុខវេទនា ។

បព្វទី ២ មានសតិពិចារណារឿយៗ ទុក្ខវេទនា ។

បព្វទី ៣ មានសតិពិចារណារឿយៗ អទុក្ខមសុខវេទនា ។

បព្វទី ៤ មានសតិពិចារណារឿយៗ សុខវេទនាលាយដោយអាមិស (កាមគុណ) ។

បព្វទី ៥ មានសតិពិចារណារឿយៗ ទុក្ខវេទនាលាយដោយអាមិស។

បព្វទី ៦ មានសតិពិចារណារឿយៗ អទុក្ខមសុខវេទនាលាយដោយអាមិស ។

បព្វទី ៧ មានសតិពិចារណារឿយៗ សុខវេទនាដែលមិនលាយដោយអាមិស ។

បព្វទី ៨ មានសតិពិចារណារឿយៗ ទុក្ខវេទនាដែលមិនលាយដោយអាមិស ។

បព្វទី ៩ មានសតិពិចារណារឿយៗ អទុក្ខមសុខវេទនាដែលមិនលាយដោយអាមិស ។

អាមិស ប្រែថា វត្ថុ គ្រឿងបញ្ជោតចិត្ត នុយឬកាមគុណារម្មណ៍ លាយដោយអាមិស សំដៅដល់ សុខ ទុក្ខ អទុក្ខមសុខ ដែលអាស្រ័យកាមគុណារម្មណ៍ជាបច្ច័យ ឬមិនលាយដោយអាមិស សំដៅដល់ មិនបានអាស្រ័យកាមគុណារម្មណ៍ជាបច្ច័យ ។

វេទនានុបស្សនា ដែលជាអារម្មណ៍របស់សតិប្ឋានេះ មានសភាពជាបរមត្ថារម្មណ៍ទើបជាអារម្មណ៍របស់វិបស្សនាតែម្យ៉ាង ជាអារម្មណ៍របស់សមថ:មិនបាន វេទនាទាំង ៩ ប្រការដូចពោលនោះ អ្នកមានសតិតាមរលឹកដឹងត្រឹមតែណាមួយ ដែលមកប្រាកដច្បាស់ ជាអារម្មណ៍ដែលមានប្រាកដតាមសេចក្ដីពិត រមែងធ្វើឱ្យដឹងបាន ទាំងកើតឡើងនិងរលត់ទៅ កាលតាមដឹងឃើញអារម្មណ៍ទាន់ក្នុងបច្ចុប្បន្ន ដោយសតិសម្បជញ្ញដូច្នេះហើយ តណ្ហា គឺ ការចង់បានសេចក្ដីសុខ ទិដ្ឋិ គឺ ការយល់ឃើញខុសថា វេទនាជារបស់ទៀង ជាសុខ ជាតួខ្លួន ជាយើង ជាគេ ក៏រមែងកើតមិនបានក្នុងខន្ធសន្តាន វេទនូបាទានខន្ធ គឺ ការប្រកាន់មាំនៅក្នុងកងវេទនាដែលមកប្រាកដឱ្យជាអារម្មណ៍ ក៏មានមិនបានផងដែរ ដោយហេតុនេះ ការតាមឃើញវេទនារឿយៗ ក៏ជាហេតុឱ្យចូលដល់មគ្គ ផល និព្វានបាន ដូចគ្នានឹងការតាមពិចារណាកាយក្នុង

កាយរឿយៗ តែវេទនានុបស្សនាសតិប្បដ្ឋាននោះ សមគួរដល់អ្នកមានតណ្ហាចរិតបញ្ញាខ្លាំងក្លា កាលសតិកំណត់វេទនា រមែងលះវេទនាថាជាសុខ និងរមែងសម្រេចមគ្គផង ព្រោះដូច្នោះ សតិនោះ ទើបឈ្មោះថា **វេទនានុបស្សនាសតិប្បដ្ឋាន** ។

វេទនានុបស្សនានិទ្ទេស តាមន័យអភិធម្ម សម្តែងថា

ភិក្ខុក្នុងសាសនានេះ កាលសោយសុខក៏ដឹងច្បាស់ថា យើងសោយសុខវេទនា កាលសោយទុក្ខវេទនា ក៏ដឹងច្បាស់ថា យើងសោយទុក្ខវេទនា កាលសោយអទុក្ខមសុខវេទនា ក៏ដឹងច្បាស់ថា យើងសោយអទុក្ខមសុខវេទនា កាលសោយសុខវេទនាមានអាមិស ក៏ដឹងច្បាស់ថា យើងសោយសុខវេទនាមានអាមិស កាលសោយសុខវេទនាមិនមានអាមិស ក៏ដឹងច្បាស់ថា យើងសោយសុខវេទនាមិនមានអាមិស កាលសោយទុក្ខវេទនាមានអាមិស ក៏ដឹងច្បាស់ថា យើងសោយទុក្ខវេទនាមានអាមិស កាលសោយទុក្ខវេទនាមិនមានអាមិស ក៏ដឹងច្បាស់ថា យើងសោយទុក្ខវេទនាមិនមានអាមិស កាលសោយអទុក្ខមសុខវេទនាមានអាមិស ក៏ដឹងច្បាស់ថា យើងសោយអទុក្ខមសុខវេទនាមានអាមិស ឬកាលសោយអទុក្ខមសុខវេទនាមិនមានអាមិស ក៏ដឹងច្បាស់ថា យើងសោយអទុក្ខមសុខវេទនាមិនមានអាមិស ។

ភិក្ខុនោះ រមែងសេព រមែងចម្រើន ធ្វើឱ្យច្រើន កំណត់ទុកដោយល្អនូវនិមិត្តនោះ ភិក្ខុកាលសេពហើយ ចម្រើន ធ្វើឱ្យច្រើន កំណត់ទុក

ដោយល្អ នូវនិមិត្តនោះហើយ រមែងបង្ហោនចិត្តចូលទៅក្នុងវេទនាសូម្បីខាងក្រៅ សម្មោហវិនោទនីអដ្ឋកថាបរិយាយសេចក្តីថា ទារកសូម្បីដែលនៅដេកបៅដោះ សោយសុខវេទនា ក៏រមែងដឹងថា យើងសោយសុខវេទនាក៏ពិត តែព្រះមានព្រះភាគមិនបានត្រាស់បំណងយកការដឹងដូច្នោះទេ ព្រោះការដឹងដូច្នោះរមែងមិនលះ **សត្តុបលទ្ធិ** (សេចក្តីយល់ឃើញថាជាសត្ត) រមែងមិនដកចេញ **សត្តសញ្ញា** (សេចក្តីសម្គាល់ថាជាសត្ត) ទាំងមិនមែនអារម្មណ៍របស់កម្មដ្ឋាន ឬមិនមែនជាការចម្រើនសតិប្បដ្ឋាន ។ តែសេចក្តីដឹងរបស់ភិក្ខុរមែងលះសត្តុបលទ្ធិ រមែងដកចេញសត្តសញ្ញា ទាំងជាកម្មដ្ឋានផង ជាការចម្រើនសតិប្បដ្ឋានផង សំដៅយកការសោយ គឺ សេចក្តីដឹងខ្លួនថា នរណាសោយវេទនា វេទនារបស់នរណា វេទនាមានអ្វីជាហេតុ ក៏វេទនានោះឯងមានវត្ថុជាអារម្មណ៍ បុគ្គលនោះជ្រាបច្បាស់យ៉ាងនេះថា វេទនានោះឯង ជាអ្នកសោយអារម្មណ៍ តែព្រោះកាន់យកការប្រព្រឹត្តទៅនៃវេទនានោះ រមែងត្រឹមតែជាវោហារថា យើងសោយវេទនា ដោយធម៌ រមែងដឹងថា ជានាមធម៌ដូច្នេះ ។

ដូច្នោះ កាលសោយសុខវេទនា ជាដើមនោះ ក៏ដឹងច្បាស់ថា នាមសោយសុខវេទនា ព្រោះការមិនមានទុក្ខវេទនាក្នុងខណៈនៃសុខវេទនា សេចក្តីថា ទុក្ខវេទនាណាដែលធ្លាប់មានមកពីមុន ឥឡូវនេះទុក្ខវេទនានោះមិនបានមាន ព្រោះមិនមានវេទនាដទៃក្រៅពីសុខវេទនានេះ ដោយហេតុនេះ វេទនាទើបជាវត្ថុមិនទៀង មិនបិតថេរ មានការប្រែប្រួល

ទៅជាធម្មតា ។

ម្យ៉ាងទៀត វេទនាដែលជាខាងក្នុង វេទនាដែលជាខាងក្រៅ វេទនាទាំងខាងក្នុងនិងខាងក្រៅ ព្រះមានព្រះភាគត្រាស់ការកំណត់ទុក ៣ យ៉ាង គឺ វេទនាខាងក្នុង សំដៅដល់ វេទនារបស់ខ្លួន ១, វេទនាខាងក្រៅ សំដៅដល់ វេទនារបស់អ្នកដទៃ ១, និងវេទនាទាំងខាងក្នុងនិងខាងក្រៅ សំដៅដល់ វេទនារបស់ខ្លួនតាមកាលសមគួរ និងរបស់អ្នកដទៃតាមកាលសមគួរ ។

អាចារ្យផ្នែកវិបស្សនា មានការយល់ឃើញថា វេទនាខាងក្រៅ មិនមែនវេទនារបស់អ្នកដទៃ តែជាវេទនាដែលបានទទួលពីអារម្មណ៍ខាងក្រៅ ដោយហេតុផលដែលពោលហើយ ក្នុងកាយានុបស្សនាសតិប្បដ្ឋាន ព្រោះក្នុងវារៈនេះ មិនបានកំណត់ខ្លួន និងមិនបានកំណត់អ្នកដទៃ តែបំណងសម្តែងត្រឹមតែការកំណត់វេទនាប៉ុណ្ណោះ ព្រះមានព្រះភាគទើបត្រាស់ថា ភិក្ខុក្នុងសាសនានេះ កាលសោយសុខវេទនា ក៏ដឹងច្បាស់ថា នាមសោយសុខវេទនា ។ល។ ដូច្នេះ ។

ចិត្តានុបស្សនាសតិប្បដ្ឋាន

ចិត្តានុបស្សនាសតិប្បដ្ឋាន កាត់បទបាន ៣ បទ គឺ

ចិត្ត + អនុបស្សនា + សតិប្បដ្ឋាន ។

ចិត្ត ប្រែថា ចិត្ត ឬវិញ្ញាណក្ខន្ធ ។

អនុបស្សនា ប្រែថា តាមឃើញ បានដល់ ការពិចារណារៀយៗ ។

សតិប្បដ្ឋាន ប្រែថា ទីតាំងរបស់សតិ ។

រូមសេចក្តីថា **ចិត្តានុបស្សនាសតិប្បដ្ឋាន** ប្រែថា សតិតាមពិចារណារឿយៗ នូវចិត្ត សេចក្តីថា យកសតិកំណត់ដឹងតាមចិត្តដែលជាប់អារម្មណ៍រឿយៗ ថា ចិត្តនេះជាសភាវធម៌ម្យ៉ាង ដែលដឹងអារម្មណ៍ មិនមែនសត្ច បុគ្គល ត្ចខ្លួន យើង គេ តែជានាមធម៌ដែលដឹងអារម្មណ៍បាន និងប្រព្រឹត្តទៅព្រមគ្នាជាមួយចេតសិកដែលតាក់តែង ដូចជាចិត្តមានរាគ: ចិត្តរួញរា ឬចិត្តរវើរវាយជាដើម ចិត្តដែលជាអារម្មណ៍របស់សតិប្បដ្ឋាននេះ ចែកបានជា ១៦ យ៉ាង ហៅថា ១៦ បព្ច:

ចិត្តានុបស្សនាសតិប្បដ្ឋានមាន ១៦ បព្ច គឺ

បព្ចទី ១ **សរាគចិត្ត** គឺ ចិត្តដែលមានរាគ: ។

បព្ចទី ២ **វីតរាគចិត្ត** គឺ ចិត្តដែលប្រាសចាករាគ: ។

បព្ចទី ៣ **សទោសចិត្ត** គឺ ចិត្តដែលមានទោស: ។

បព្ចទី ៤ **វីតទោសចិត្ត** គឺ ចិត្តដែលប្រាសចាកទោស: ។

បព្ចទី ៥ **សមោហចិត្ត** គឺ ចិត្តដែលមានមោហ: ។

បព្ចទី ៦ **វីតមោហចិត្ត** គឺ ចិត្តដែលប្រាសចាកមោហ: ។

បព្ចទី ៧ **សង្ខិត្តចិត្ត** គឺ ចិត្តដែលមានថីនមិទ្ធ: ។

បព្ចទី ៨ **វិក្ខិត្តចិត្ត** គឺ ចិត្តដែលរវើរវាយ ។

បព្ចទី ៩ **មហគ្គតចិត្ត** គឺ ចិត្តដែលជារូបាវចរចិត្ត និងអរូបាវចរចិត្ត។

បព្ចទី ១០ **អមហគ្គតចិត្ត** គឺ ចិត្តដែលមិនមែនជារូបាវចរចិត្ត និង

អរូបាវចរចិត្ត ។

បព្វទី ១១ **សឧត្តរចិត្ត** គឺ ចិត្តដែលជាកាមាវចរចិត្ត ។

បព្វទី ១២ **អនុត្តរចិត្ត** គឺ ចិត្តដែលជារូបាវចរចិត្ត និងអរូបាវចរចិត្ត (មិនជាលោកុត្តរ:) ។

បព្វទី ១៣ **សមាហិតចិត្ត** គឺ ចិត្តដែលមានសមាធិដល់ឧបចារ-សមាធិ ឬអប្បនាសមាធិ ។

បព្វទី ១៤ **អសមាហិតចិត្ត** គឺ ចិត្តដែលរៀរចាកសមាធិទាំង ២ ។

បព្វទី ១៥ **វិមុត្តចិត្ត** គឺ ចិត្តដែលរួចផុតដោយតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ (ប្រហារកិលេស) ។

បព្វទី ១៦ **អវិមុត្តចិត្ត** គឺ ចិត្តដែលរៀរចាកវិមុត្តិទាំង ២ គឺ នៅមិនបានលះកិលេសឡើយ ។

ចិត្តានុបស្សនាសតិប្បដ្ឋាន តាមពុទ្ធវចន:សម្តែងថា ក៏ភិក្ខុពិចារណាឃើញចិត្តក្នុងចិត្តខាងក្នុងរឿយៗ តើដូចម្តេច ?

ភិក្ខុក្នុងសាសនានេះ កាលចិត្តមានរាគ: ក៏ដឹងច្បាស់ថា ចិត្តមានរាគ: ឬចិត្តប្រាសចាករាគ: ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគ: ។

កាលចិត្តមានទោស: ក៏ដឹងច្បាស់ថា ចិត្តមានទោស: ។ល។

កាលចិត្តមានមោហ: ក៏ដឹងច្បាស់ថា ចិត្តមានមោហ: ។ល។

កាលចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរបស់យើងរួញរា ឬកាលចិត្តរវើរវាយ ក៏ដឹងច្បាស់ថាចិត្តរបស់យើងរវើរវាយ ។

កាលចិត្តរបស់យើងជាមហគ្គត ក៏ដឹងច្បាស់ថា ចិត្តរបស់យើងជា

មហាគ្គត កាលចិត្តមិនជាមហាគ្គត ក៏ដឹងច្បាស់ថា ចិត្តរបស់យើងមិនជាមហាគ្គត ។

កាលចិត្តជាសឧត្តរ: ក៏ដឹងច្បាស់ថា ចិត្តរបស់យើងជាសឧត្តរ: ឬ កាលចិត្តជាអនុត្តរ: ក៏ដឹងច្បាស់ថា ចិត្តរបស់យើងជាអនុត្តរ: ។

ចិត្តជាសមាធិតាំងមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់យើងតាំងមាំ ឬ កាលចិត្តមិនតាំងមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់យើងមិនតាំងមាំ ។

កាលចិត្តរួចផុត ក៏ដឹងច្បាស់ថា ចិត្តរបស់យើងរួចផុត កាលចិត្តមិនរួចផុត ក៏ដឹងច្បាស់ថា ចិត្តរបស់យើងមិនទាន់រួចផុត ។

ភិក្ខុរមែងសេព ចម្រើន ធ្វើឱ្យច្រើន កំណត់ដោយល្អ នូវនិមិត្តនោះ ហើយរមែងបង្ហោនចិត្តចូលទៅក្នុងចិត្តខាងក្រៅ ។

ព្រះអដ្ឋកថាចារ្យអធិប្បាយថា

សរាគំ ចិត្តដែលកើតព្រមដោយលោភ: បានដល់ លោភមូលចិត្ត ៨ ។

វីតរាគំ ចិត្តដែលប្រាសចាករាគ: គឺ ចិត្តដែលជាកុសល និងអព្យាកត: ក្នុងផ្នែកលោកិយ ព្រោះការពិចារណានេះ នៅមិនទាន់រួចផុត មិនមែនធម្មសមោធាន ទើបមិនបានលោកុត្តរចិត្តសូម្បីត្រឹមតែមួយបទ។

សទោសំ ចិត្តដែលកើតព្រមដោយទោមនស្ស បានដល់ ទោសមូលចិត្ត ២ ។

វីតទោសំ ចិត្តដែលប្រាសចាកទោស: គឺ ចិត្តដែលជាកុសល

និងអព្យាកត:ផ្នែកលោកិយ ។

សមោហំ មោហមូលចិត្ត ២ ដួង ដែលប្រកបជាមួយវិចិកិច្ឆា និងប្រកបជាមួយឧទ្ធច្ច: អកុសលចិត្ត ១០ ដ៏សេសក៏សង្គ្រោះចូលទៅក្នុងទីនេះទាំងអស់ ។

វីតមោហំ ចិត្តដែលប្រាសចាកមោហ: គឺ ចិត្តដែលជាកុសល និងអព្យាកត:ផ្នែកលោកិយ ។

សង្ខិត្តំ ចិត្តដែលមានថីនមិទ្ធ ឈ្មោះថា ចិត្តរួញរា ។

វិក្ខិត្តំ ចិត្តដែលប្រកបជាមួយឧទ្ធច្ច: ឈ្មោះថា ចិត្តរវើរវាយ ។

មហគ្គតំ បានដល់ រូបាវចរចិត្ត និងអរូបាវចរចិត្ត ។

អមហគ្គតំ បានដល់ កាមាវចរចិត្ត ។

សឧត្តរំ បានដល់ កាមាវចរចិត្ត ។

អនុត្តរំ បានដល់ រូបាវចរចិត្ត និងអរូបាវចរចិត្ត ន័យម្យ៉ាងទៀត

សឧត្តរ ចិត្ត បានដល់ រូបាវចរចិត្ត ។

អនុត្តរ ចិត្ត បានដល់ អរូបាវចរចិត្ត ។

សមាហិតំ បានដល់ ចិត្តរបស់អ្នកដែលចូលដល់អប្បនាសមាធិ ឬឧប្បចារសមាធិ ។

អសមាហិតំ បានដល់ ចិត្តដែលរៀរចាកសមាធិទាំង ២ ។

វិមុត្តំ បានដល់ ចិត្តដែលរួចផុតចាកកិលេសដោយតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ។

អវិមុត្តំ បានដល់ ចិត្តដែលរៀរចាកវិមុត្តិទាំង ២ ។

ចំណែកសមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ មិនមានឱកាសចាត់ទុក ព្រោះចិត្តានុបស្សនាសតិប្ឋដ្ឋាននេះ ជាអារម្មណ៍របស់សតិប្ឋដ្ឋាន និងវិបស្សនាញាណប៉ុណ្ណោះ នៅមិនទាន់ចូលដល់មគ្គញាណ ផលញាណ ទើបមិននៅក្នុងឋាន: ដែលជាអារម្មណ៍របស់សតិប្ឋដ្ឋានបាន ។

ចិត្តានុបស្សនាសតិប្ឋដ្ឋាន ទាំង ១៦ បព្ធ នេះ មានអង្គធម៌បានចិត្តតែម្យ៉ាង បានដល់ យកសតិតាមកំណត់ដឹងលក្ខណៈរបស់ចិត្ត ដែលមានសភាពដឹងអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ កាលតាមពិចារណាមើលចិត្តរឿយៗ ក៏ដឹងច្បាស់ថា ជានាមធម៌ម្យ៉ាង ដែលមិនមែនជាតួខ្លួនមនុស្ស សត្ធ យើង គេ យ៉ាងណាឡើយ កាលតាមដឹងទៅរឿយៗ ក៏ជាក់ច្បាស់ក្នុងការមិនទៀង ជាទុក្ខ ជាអនត្តា របស់ចិត្តនោះ ។

កាលតាមដឹងសភាពរបស់ចិត្តដែលប្រាកដដល់ខ្លួន តាមកាលដែលសមគួរហើយ ក៏នឹងដឹងរបស់អ្នកដទៃតាមកាលសមគួរ និងទាំងរបស់ខ្លួន របស់អ្នកដទៃ ក៏នឹងបានតាមសមគួរដូចគ្នា តែអាចារ្យផ្ទែកវិបស្សនា ជំទាស់ថា ចិត្តរបស់អ្នកដទៃតាមដឹងមិនបាន គួរតែជាចិត្តដែលដឹងអារម្មណ៍ដទៃៗ ខាងក្រៅ តាមន័យកាយានុបស្សនាសតិប្ឋដ្ឋាន និងវេទនានុបស្សនាសតិប្ឋដ្ឋានដូចពោលហើយ ។

ធម្មានុបស្សនាសតិប្បដ្ឋាន

ធម្មានុបស្សនាសតិប្បដ្ឋាន កាត់បទបាន ៣ បទ គឺ

ធម្ម + អនុបស្សនា + សតិប្បដ្ឋាន ។

ធម្ម ប្រែថា ធម្មជាតិដែលទ្រទ្រង់សភាវៈរបស់ខ្លួនទុកតាមសេចក្តីពិត បានដល់ រូបធម៌ និងនាមធម៌ ។

អនុបស្សនា ប្រែថា តាមឃើញ បានដល់ ពិចារណារឿយៗ ។

សតិប្បដ្ឋាន ប្រែថា ទីតាំងរបស់សតិ ។

ធម្មានុបស្សនាសតិប្បដ្ឋាន ប្រែថា សតិតាមឃើញធម៌ គឺ រូបធម៌ និងនាមធម៌រឿយៗ មាន ៥ បព្វ គឺ

បព្វទី ១ **នីវរណបព្ព** អារម្មណ៍របស់សតិ គឺ នីវរណៈ ៥ ។

បព្វទី ២ **ខន្ធបព្ព** អារម្មណ៍របស់សតិ គឺ ខន្ធ ៥ ។

បព្វទី ៣ **អាយតនបព្ព** អារម្មណ៍របស់សតិ គឺ អាយតនៈ ១២ ។

បព្វទី ៤ **ពោជ្ឈង្គបព្ព** អារម្មណ៍របស់សតិ គឺ ពោជ្ឈង្គ ៧ ។

បព្វទី ៥ **សច្ចបព្ព** អារម្មណ៍របស់សតិ គឺ អរិយសច្ចៈ ៤ ។

សេចក្តីក្នុងព្រះពុទ្ធវចនៈ ទ្រង់ត្រាស់ថា

ក៏ភិក្ខុពិចារណាឃើញធម៌ក្នុងធម៌ខាងក្នុងរឿយៗ តើដូចម្តេច ?

ក្នុងនីវរណបព្ព ត្រាស់វិសជ្ជនាថា ភិក្ខុក្នុងសាសនានេះ កាលកាមឆន្ទៈខាងក្នុងចិត្តមាននៅ ក៏ដឹងច្បាស់ថា កាមឆន្ទៈខាងក្នុងចិត្តរបស់យើងមាន ឬកាលកាមឆន្ទៈខាងក្នុងចិត្តមិនមាន ក៏ដឹងច្បាស់ថា

កាមឆន្ទ:ខាងក្នុងចិត្តរបស់យើងមិនមាន សូម្បីកាមឆន្ទ:ដែលនៅមិនទាន់កើតឡើង នឹងកើតឡើងដោយហេតុណា ក៏ដឹងច្បាស់ហេតុនោះផង ម្យ៉ាងទៀត ការលះកាមឆន្ទ:ដែលកើតឡើងហើយ និងមានបានដោយហេតុណា ក៏ដឹងច្បាស់ហេតុនោះផង ម្យ៉ាងទៀត កាមឆន្ទ:ដែលលះបានហើយ នឹងមិនកើតឡើងដោយហេតុណា ក៏ដឹងច្បាស់ហេតុនោះផង ។

កាលព្យាបាទខាងក្នុងចិត្តមាននៅ ក៏ដឹងច្បាស់ ។ល។ កាលថីនមិទ្ធ:ខាងក្នុងចិត្តមាននៅ ។ល។ កាលឧទ្ធច្ចកុក្កុច្ច:ខាងក្នុងចិត្តមាននៅ ។ល។ កាលវិចិកិច្ឆាខាងក្នុងចិត្តមាននៅ ។ល។ ម្យ៉ាងទៀត វិចិកិច្ឆាដែលនៅមិនទាន់កើតឡើង នឹងកើតឡើងដោយហេតុណា ក៏ដឹងច្បាស់ដោយហេតុនោះ ម្យ៉ាងទៀត ការលះវិចិកិច្ឆាដែលកើតឡើងដោយហេតុណា ក៏ដឹងច្បាស់ដោយហេតុនោះ ម្យ៉ាងទៀត វិចិកិច្ឆាដែលលះបានហើយនិងមិនកើតឡើងតទៅទៀតដោយហេតុណា ក៏ដឹងច្បាស់ដោយហេតុនោះផង ។

នីវរណធម៌ បានសម្តែងហើយក្នុងអកុសលសង្គហ:ខាងដើមចំណែកខន្ធ ៥ អាយតន: ១២ ពោជ្ឈង្គ ៧ និងអរិយសច្ច: ៤ នឹងបានពោលតទៅក្នុងពោធិបក្ខិយសង្គហ: និងសព្វសង្គហ: ។

សម្មោហវិនោទនីអដ្ឋកថា អធិប្បាយសេចក្តីថា

ព្រះមានព្រះភាគ ត្រាស់ការកំណត់ រូបក្ខន្ធ ដោយកាយានុបស្សនាសតិប្បដ្ឋាន ត្រាស់ការកំណត់ វេទនាខន្ធ ដោយវេទនានុបស្សនាសតិប្បដ្ឋាន និងត្រាស់ការកំណត់វិញ្ញាណក្ខន្ធ ដោយចិត្តានុបស្សនាសតិប្បដ្ឋាន ដូច្នោះដើម្បីនឹងត្រាស់ការកំណត់សញ្ញាខន្ធ និងសង្ខារក្ខន្ធ ដោយនាំមាតិកានៃសម្បយុត្តធម៌ មកសម្តែងក្នុងធម្មានុបស្សនាសតិប្បដ្ឋាន ។

កាលពោលដោយទូទៅហើយ ធម្មានុបស្សនាសតិប្បដ្ឋាន គឺតាំងសតិតាមឃើញទាំងរូបធម៌ និងនាមធម៌ទាំងពួង ដូច្នោះទើបពោលបានថា កាយានុបស្សនាសតិប្បដ្ឋាន វេទនានុបស្សនាសតិប្បដ្ឋាន និងចិត្តានុបស្សនាសតិប្បដ្ឋាន ទាំង ៣ ប្រការនេះ រមែងសង្ត្រោះចូលបានក្នុងធម្មានុបស្សនាសតិប្បដ្ឋាននេះទាំងអស់ ។

សតិប្បដ្ឋានតាមន័យនៃបករណ៍ ព្រះអង្គត្រាស់សតិប្បដ្ឋាន ៤ ក៏ដើម្បីលះវិបល្លាស ៤ ប៉ុណ្ណោះក៏មិនមែន ព្រះអង្គនៅត្រាស់សតិប្បដ្ឋាន ៤ ដើម្បីលះឱឃ: ៤ យោគ: ៤ អាសវ: ៤ គន្ថ: ៤ ឧបាទាន ៤ អគតិ ៤ និងដើម្បីឱ្យកំណត់ដឹង អាហារ ៤ ផង ។

ចំណែកក្នុងអដ្ឋកថាសតិប្បដ្ឋានវិភង្គ លោកពោលពាក្យទុកត្រឹមប៉ុណ្ណោះថា

សតិប្បដ្ឋានមានតែម្យ៉ាងប៉ុណ្ណោះ ដោយអំណាចនៃការរលឹក និងដោយអំណាចនៃការប្រជុំរួមចុះជាមួយគ្នាតែមួយ តែត្រាស់សតិប្បដ្ឋាន

ទុក ៤ ដោយអំណាចនៃអារម្មណ៍ដូច្នេះ ។

ដូចយ៉ាងថា ក្នុងនគរមួយ មានទ្វារចេញចូល ៤ ទ្វារ ជនទាំងឡាយអ្នកមកពីទិសខាងកើត នាំទំនិញដែលមាននៅទិសខាងកើត ហើយចូលកាន់នគរទ្វារទិសខាងកើត អ្នកមកពីទិសខាងត្បូង ទិសខាងលិច ទិសខាងជើង ក៏នាំទំនិញដែលមាននៅទិសនោះ។ ហើយក៏ចូលកាន់ទ្វារនគរតាមទិសនោះ។ ឧបមានេះយ៉ាងណា ឧបមេយ្យនេះក៏យ៉ាងនោះ បណ្ឌិតគប្បីជ្រាបថា ព្រះនិព្វាន ប្រៀបដូចនគរ លោកុត្តរមគ្គ ដែលប្រកបដោយអង្គ ៨ ប្រៀបដូចទ្វារនគរ អារម្មណ៍ ៤ មានកាយជាដើម ប្រៀបដូចទិសទាំង ៤ ជនទាំងឡាយដែលមកពីទិសខាងកើត កាន់យកវត្ថុដែលកើតឡើងទិសខាងកើត ហើយចូលកាន់ទ្វារនគរតាមទិសខាងកើត ដូចព្រះយោគាវចរទាំងឡាយ អ្នកមកដោយការចម្រើនកាយានុបស្សនាសតិប្ឋានណាមួយក្នុង ១៤ បព្វ: ហើយចុះកាន់ព្រះនិព្វានជាមួយគ្នា ដោយអរិយមគ្គ ដែលកើតឡើងដោយអានុភាពនៃការចម្រើនកាយានុបស្សនានោះឯង ។

ជនទាំងឡាយមកពីទិសខាងត្បូង កាន់យកវត្ថុដែលកើតឡើងទិសខាងត្បូង ហើយចូលកាន់ទ្វារនគរតាមទិសខាងត្បូង ដូចព្រះយោ-គាវចរទាំងឡាយ អ្នកមកដោយការចម្រើនវេទនានុបស្សនាក្នុងវេទនានុបស្សនា ណាមួយក្នុង ៩ បព្វ: ហើយចុះកាន់ព្រះនិព្វានជាមួយគ្នា ដោយអរិយមគ្គ ដែលកើតដោយអានុភាពនៃការចម្រើនវេទនានុបស្សនា ។

ជនទាំងឡាយអ្នកមកពីទិសខាងលិច កាន់យកវត្ថុដែលមាននៅទិសខាងលិចហើយ ចូលកាន់ទ្វារនគរតាមទិសខាងលិចនោះ ដូចព្រះយោគាវចរ អ្នកមកដោយចិត្តានុបស្សនាយ៉ាងណាមួយក្នុង ១៦ បព្វ: ហើយចុះកាន់ព្រះនិព្វានជាមួយគ្នា ដោយអរិយមគ្គ ដែលកើតពីអានុភាពនៃចិត្តានុបស្សនា ។

ជនទាំងឡាយអ្នកមកពីទិសខាងជើង កាន់យកវត្ថុដែលមាននៅទិសខាងជើង ហើយចូលកាន់ទ្វារនគរតាមទិសខាងជើងនោះ ដូចព្រះយោគាវចរ អ្នកមកដោយធម្មានុបស្សនាយ៉ាងណាមួយក្នុង ៥ បព្វ: នោះ ហើយចុះកាន់ព្រះនិព្វានជាមួយគ្នា ដោយអរិយមគ្គ ដែលកើតដោយអានុភាពនៃធម្មានុបស្សនាដូច្នេះ ។

ដូច្នោះគប្បីជ្រាប ព្រះមានព្រះភាគត្រាស់ សតិប្បដ្ឋាន ១ ដោយអំណាចនៃការរលឹក និងដោយអំណាចនៃការប្រជុំចុះជាមួយគ្នា ក្នុងព្រះនិព្វាន ។

សតិប្បដ្ឋាន ៤ ដោយអំណាចនៃអារម្មណ៍របស់សតិ ដូច្នេះ ។

២. សម្មប្បធាន

សម្មប្បធាន ជាឈ្មោះរបស់ធម៌ ដែលជាសេចក្ដីព្យាយាមដល់កុសលធម៌យ៉ាងខ្លាំងក្លា ដូចវចនត្ថ:ថា

សម្មា បទហន្តិ ឯតេនាតិ = សម្មប្បធានំ

ប្រែថា សម្ប្យុត្តធម៌ទាំងឡាយ មានការព្យាយាមដោយត្រូវតាម

ធម៌ ដោយអាស្រ័យធម្មជាតិណា ដូច្នោះធម្មជាតិដែលជាហេតុនៃសេចក្តីព្យាយាមរបស់សម្បយុត្តធម៌នោះ ឈ្មោះថា សម្មប្បធាន អង្គធម៌ បានដល់ វីរិយចេតសិក ។

សេចក្តីថា វីរិយចេតសិក ដែលជាសម្មប្បធានបាននោះ ត្រូវជាវីរិយ:យ៉ាងខ្លាំងក្លាដែលព្យាយាមលះអកុសល សូម្បីនឹងសល់តែស្បែកសរសៃ ឆ្អឹង ឬសាច់និងឈាមរីងស្ងួតក្តី នឹងមិនរាថយដល់ការព្យាយាមនោះឡើយ, វីរិយ:ធម្មតាសាមញ្ញនៅមិនចាត់ជាសម្មប្បធានទេ ។

វីរិយចេតសិកដែលជាសម្មប្បធាននោះ ត្រូវជាវីរិយ:ដែលប្រាសចាកបមាទធម៌ គឺ ត្រូវជាវីរិយចេតសិកដែលប្រកបនៅក្នុងកុសលជវន: ប៉ុណ្ណោះ ចំណែកវីរិយ:ដែលនៅក្នុងកិរិយាជវន: ឬផលចិត្តរបស់ព្រះអរិយបុគ្គលនោះ រមែងមិនជាសម្មប្បធាន ព្រោះវីរិយ:ក្នុងកិរិយាជវន:នោះ ផុតកិច្ចដែលត្រូវលះអកុសល ឬធ្វើឱ្យកុសលកើតឡើងហើយ និងជវន: ក្នុងផលចិត្តក៏មិនមានកិច្ចទាក់ទងគ្នាជាមួយការប្រហារអកុសលដូចគ្នាព្រោះជាវិបាកហើយ ។

ធម្មតាមនុស្សដោយច្រើនក្នុងបច្ចុប្បន្ន ច្រើនអង្វរសូមពរគ្នាក្នុងវត្ថុដែលខ្លួនប្រាថ្នា គ្រប់គ្នាមិនត្រូវការដែលនិងឱ្យបានអ្វីមកដោយលំបាកនឹងត្រូវប្រើសេចក្តីព្យាយាមយ៉ាងក្រៃលែងទេ ពុទ្ធសាសនិកជនខ្លះប្រាថ្នាព្រះនិព្វាន តែចាំដល់វេលាសម័យព្រះអរិយមេត្តេយ្យមកប្រោសអ្នកខ្លះមានការព្យាយាមល្អ តែខ្វះសេចក្តីយល់ដឹងបរិយត្តិសាសនាឬខ្វះបញ្ញាបារមីដែលអប់រំសន្សំទុកពីជាតិមុន ទើបជាហេតុមិនបាន

សម្រេចមគ្គផលក្នុងជាតិបច្ចុប្បន្ននេះ ឬព្រោះខ្ជះវីរិយ: គឺ សម្មប្បធាន ដែលជាការព្យាយាមយ៉ាងខ្លាំងក្លា ដែលនឹងបដិបត្តិដល់ពុទ្ធសាសនា ឱ្យសម្រេចអរិយមគ្គ អរិយផលបានក្នុងជាតិនេះ នាទីរបស់វីរិយ:ដែលជាសម្មប្បធាន មាន ៤ ប្រការ អង្គធម៌ បានដល់ វីរិយចេតសិក ដែលប្រកបក្នុងកុសលចិត្ត ២១ ដូចគ្នាទាំងអស់ គឺ

១. អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហាតិ ។

ញ៉ាំងឆន្ទ:ឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញ៉ាំងធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឱ្យកើតឡើងបាន ១ ។

២. ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហាតិ ។

ញ៉ាំងឆន្ទ:ឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់ធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ១ ។

៣. អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហាតិ ។

ញ៉ាំងឆន្ទ:ឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយមមាំ ដើម្បីញ៉ាំងធម៌ទាំងឡាយជាកុសល ដែលមិនទាន់ កើតឡើង ឱ្យកើតឡើងបាន ១ ។

៤. ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហាតិ ។

ញ៉ាំងឆន្ទៈឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញ៉ាំងធម៌ទាំងឡាយជាកុសល ដែលកើតឡើង ហើយឱ្យស្ថិតស្ថេរ មិនឱ្យវិនាស ឱ្យចម្រើនធំទូលាយ ឱ្យបរិបូណ៌ ជាភិយ្យោភាព ១ ។ (បិដកភាគ ៣៨ ទំព័រ ២៤៨) ។

ធម្មតាសត្វទាំងឡាយ ដែលនៅវិលវល់កើតស្លាប់ក្នុងវដ្តទុក្ខនោះ រមែងមានអកុសលធម៌ ជាប្រចាំ ២ ប្រការនោះ គឺ

១. ឧប្បន្នអកុសល គឺ អកុសលដែលកើតមកហើយ ក្នុងសន្តាន របស់ខ្លួន បានទាំងអកុសលរបស់អតីត និងបច្ចុប្បន្ន សេចក្តីថា អកុសលធម៌ផ្សេងៗ ទាំងឡាយដែលបានធ្វើមកហើយនោះ ប្រភេទខ្លះ ឱ្យផលទៅហើយក៏មាន និងអកុសលប្រភេទខ្លះនៅមិនទាន់ឱ្យផល ព្រោះនៅមិនមានឱកាសក្នុងការឱ្យផលក៏មាន អកុសលដែលកើតហើយ ទាំងនេះ មានសក្កាយទិដ្ឋិ បានដល់ការយល់ឃើញខុសដែលប្រកាន់មាំ ក្នុង រូបនាម ខន្ធ ៥ ថា ជាតួខ្លួន មនុស្ស សត្វ យើង គេ ជាដើម ដរាបណាសក្កាយទិដ្ឋិនៅមាន ក៏ដូចជានៅមានបំណុលចាស់ដែលត្រូវ សងក្នុងអបាយភូមិ ៤ នៅសល់រកប្រមាណមិនបាន បំណុលចាស់ទាំង នេះ ហៅថា ឧប្បន្នអកុសល កាលណាអាចប្រហារសក្កាយទិដ្ឋិបាន អកុសលទាំងឡាយក៏រមែងអន្តរធានសូន្យបាត់ទៅក្នុងទីបំផុត ។

២. អនុប្បន្នអកុសល ជាអកុសលដែលនៅមិនទាន់បានកើតឡើងក្នុងសន្តានរបស់ខ្លួន សំដៅដល់ អកុសលទាំងឡាយដែលនៅមិនទាន់បានធ្វើក្នុងអនាគត ពោលគឺ សត្វទាំងឡាយតាំងពីនេះជាដើមទៅ ដរាបណាដែលនៅមិនទាន់ដល់ព្រះនិព្វាន ដរាបនោះអកុសលទាំង-ឡាយដែលនឹងធ្វើតទៅ ក៏មានច្រើនទៀតរហូតរកប្រមាណមិនបាន ដល់កាលសក្កាយទិដ្ឋិរលត់កាលណា អកុសលទាំងនោះក៏រមែងត្រូវអន្តរធានសូន្យបាត់ទៅក្នុងទីបំផុត អកុសលដែលកើតឡើងក្នុងអនាគតនោះ ឈ្មោះថា អនុប្បន្នអកុសល ។

រួមសេចក្តីថា បុគ្គលណាក្តី មិនថា មនុស្សធម្មតា ប្រជាជន ព្រះរាជាស្តេចចក្រពត្តិ ឬទេវតា ព្រះឥន្ទ្រ ព្រះព្រហ្មក្តី ដរាបណានៅក្រោមអំណាចរបស់សក្កាយទិដ្ឋិហើយ ដរាបនោះក៏ជាអ្នកនៅក្រោមអំណាចរបស់ឧប្បន្នអកុសល និងអនុប្បន្នអកុសល ទាំង ២ ប្រការនោះឯង ។

ការកើតមកជាមនុស្សជួបព្រះពុទ្ធសាសនា ទើបរាប់ថា ជាបុណ្យកុសលដ៏ប្រសើរ ព្រោះអ្នកប្រាជ្ញាផុតចាកអកុសលទាំង ២ ប្រការដូចពោលនេះ ត្រូវការសាងនិស្សយប្បច្ច័យតទៅក្នុងជាតិខាងមុខ រហូតចូលដល់មគ្គ ផល និព្វាននោះបាន ត្រូវអាស្រ័យពាក្យប្រៀនប្រដៅតាមផ្លូវព្រះពុទ្ធសាសនាប៉ុណ្ណោះ ទើបនឹងអាចលះសក្កាយទិដ្ឋិចេញបាននោះ គឺ ការលះឧប្បន្នអកុសល និងអនុប្បន្នអកុសល ។

ចំណែក ឧប្បន្នកុសល និង អនុប្បន្នកុសល គឺ កុសលដែលកើតឡើងហើយ ជាកុសលរបស់អតីតនិងបច្ចុប្បន្ន ជាមួយកុសលដែលនៅ

មិនទាន់បានធ្វើ ជាកុសលរបស់អនាគត ការបែងចែក ឧប្បន្នកុសល និងអនុប្បន្នកុសល ក៏គឺទានកុសលដែលធ្លាប់បរិច្ចាគហើយ សីលកុសលដែលធ្លាប់រក្សាហើយ សមថភាវនា និងវិបស្សនាភាវនា ដែលធ្លាប់ចម្រើនហើយ ជាឧប្បន្នកុសល បើទានកុសលខ្លួននៅមិនទាន់បានធ្វើ សីលកុសលនៅមិនធ្លាប់បានរក្សាសមាទាន សមថភាវនា និងវិបស្សនាភាវនា នៅមិនធ្លាប់ចម្រើន ទាំងនេះជាអនុប្បន្នកុសល រួមសេចក្តីថា កុសលណាដែលនៅមិនធ្លាប់ប្រាកដដល់ខ្លួន កុសលនោះ ចាត់ថា ជាអនុប្បន្នកុសល ។

សម្មប្បធាន ៤ នេះ រមែងកើតឡើងក្នុងការចម្រើនភាវនាកុសលមានការចម្រើនសមថ: និងវិបស្សនា សម្រាប់ក្នុងពោធិបក្ខិយធម៌ដែលជាគ្រឿងឱ្យត្រាស់ដឹងនេះ ទើបសំដៅដល់សេចក្តីព្យាយាមដែលកើតឡើងក្នុងខណ:ចម្រើនវិបស្សនាភាវនា ។

៣. ឥទ្ធិបាទ

ឥទ្ធិបាទ ជាធម៌ដែលជាហេតុឱ្យសម្រេច ឈាន អភិញ្ញា និងមគ្គ ផល កាលកាត់បទបាន ២ បទ គឺ **ឥទ្ធិ + បាទ** ។

មានវចនត្ថ:ថា **ឥជ្ឈនំ = ឥទ្ធិ**

ប្រែថា សេចក្តីសម្រេចបរិបូណ៌នោះ ឈ្មោះថា ឥទ្ធិ បានដល់ ឈាន អភិញ្ញា មគ្គ ផល ។

បជ្ជតិ ឯតេនាតិ = បាទោ

ប្រែថា បុគ្គលណាមួយ រមែងចូលដល់ដោយអាស្រ័យធម៌ណា ដូច្នោះ ធម៌ជាហេតុឱ្យចូលដល់របស់បុគ្គលនោះ ឈ្មោះថា **បាទ** បានដល់ អង្គធម៌របស់ឥទ្ធិបាទ ៤ ។

ឥទ្ធិយា បាទោ = ឥទ្ធិបាទោ

ប្រែថា ធម៌ដែលជាហេតុឱ្យដល់សេចក្តីសម្រេចឈាន អភិញ្ញា មគ្គ ផល ឈ្មោះថា ឥទ្ធិបាទ ។

ឥទ្ធិបាទមាន ៤

១. ឆន្ទិទ្ធិបាទ សេចក្តីពេញចិត្តយ៉ាងខ្លាំងក្លា ជាបាទខាងដើមនៃការសម្រេចឈាន មគ្គ ផល អង្គធម៌ បានដល់ ឆន្ទចេតសិក ដែលនៅក្នុងកុសលចិត្ត ២១ ។

២. វីរិយិទ្ធិបាទ សេចក្តីព្យាយាមយ៉ាងខ្លាំងក្លា ជាបាទខាងដើមនៃការសម្រេចឈាន មគ្គ ផល អង្គធម៌ បានដល់ វីរិយចេតសិក ដែលនៅក្នុងកុសលចិត្ត ២១ ។

៣. ចិត្តិទ្ធិបាទ សេចក្តីតាំងចិត្តយ៉ាងខ្លាំងក្លា ជាបាទខាងដើមនៃការសម្រេចឈាន មគ្គ ផល អង្គធម៌ បានដល់ កុសលចិត្ត ២១ ។

៤. វិមំសិទ្ធិបាទ បញ្ញាយ៉ាងខ្លាំងក្លា ជាបាទខាងដើមនៃការសម្រេចឈាន មគ្គ ផល អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងកុសលញាណសម្បយុត្តចិត្ត ១៧ ។

សេចក្តីផ្សេងគ្នារបស់ឥទ្ធិបាទ និង អធិបតី

ឥទ្ធិបាទ និង អធិបតី ក៏មានអង្គធម៌ស្មើគ្នា និងដូចគ្នា គឺ ឆន្ទ: វីរិយ: ចិត្ត និងបញ្ញា ។

ឥទ្ធិបាទនោះ ជាធម៌ដែលជាហេតុឱ្យសម្រេចការងារ ដែលជាកុសលដ៏ប្រសើរដែលនឹងឱ្យសម្រេចមហាគ្គតកុសល និងលោកុត្តរកុសល គឺ ឱ្យសម្រេចឈាន អភិញ្ញា មគ្គ ផល នោះឯង ។

ចំណែកអធិបតីនោះ ជាធម៌ដែលជាធំ ជាប្រធានឱ្យសម្រេចការងារ បានទាំងកុសល អកុសល និងអព្យាកត: បានទាំងអស់ មនុស្សភាគច្រើននិយមយកឥទ្ធិបាទទៅប្រើជំនួសអធិបតី ដូចជាពោលថា ការសិក្សាក្តី ការធ្វើជំនួញក្តី បើមិនមានធម៌ដែលជាឥទ្ធិបាទហើយ ការងារនោះ រមែងមិនសម្រេចបំណង ។

សេចក្តីពិតឥទ្ធិបាទនោះ រមែងមានមារ គឺ កិលេស ជាគ្រឿងរារាំងការធ្វើឈាន មគ្គ ផល និព្វាន មិនឱ្យសម្រេចការងារនោះ។ តែមារ គឺ កិលេស មិនបានជាការរារាំងការសិក្សា ឬការធ្វើជំនួញដោយប្រការណាទ្បើយ ផ្ទុយទៅវិញ ត្រឡប់ជាបច្ច័យជួយឱ្យការសិក្សា ការធ្វើជំនួញក្នុងផ្លូវលោកចម្រើនដោយកិលេសតណ្ហាទៅទៀត ត្រូវចាត់ទុកក្នុងធម៌ដែលជាអធិបតីប៉ុណ្ណោះ ។

ម្យ៉ាងទៀត ឆន្ទ: វីរិយ: ចិត្ត: និងបញ្ញា របស់ព្រះអរហន្តក៏មិនឈ្មោះថា ជាឥទ្ធិបាទ ព្រោះព្រះអរហន្តរមែងចូលដល់ធម៌ដែលសម្រេចដល់កំពូលហើយ ទើបមិនត្រូវអាស្រ័យធម៌ដែលជាហេតុឱ្យចូលដល់

ទៀត ព្រោះឥទ្ធិបាទបំណងយកធម៌ដែលជាហេតុឱ្យចូលដល់មគ្គចិត្ត គឺ លោកុត្តរកុសលដោយត្រង់ ចំណែកដែលសង្គ្រោះថា ចូលដល់ឈាន អភិញ្ញាផងនោះ ជាការពោលដោយអម សូម្បីក្នុងលោកុត្តរវិបាក គឺ ផលចិត្តដែលប្រកបដោយឆន្ទ: វីរិយ: ផលចិត្ត និងបញ្ញា ក៏មិនបាន ឈ្មោះថា ជាឥទ្ធិបាទដូចគ្នា ទាំងនេះព្រោះឥទ្ធិបាទជាធម៌ដែលមាន តែចំពោះកុសលប៉ុណ្ណោះ វិបាកនិងកិរិយាចិត្តជាអព្យាកត:ទើបបាន ត្រឹមតែជាអធិបតី ។

ឥទ្ធិបាទ ដែលជាធម៌ឱ្យសម្រេចលោកុត្តរកុសលនោះ មាន អធិប្បាយថា **ឥទ្ធិ** គឺ ឫទ្ធិដែលចូលដល់ការសម្រេចនោះមាន ៥ ប្រការ គឺ

ឥទ្ធិបាទ ៥ ប្រការ

១. អភិញ្ញេយ្យេសុ ធម្មេសុ អភិញ្ញាសិទ្ធि បានដល់ ឫទ្ធិ គឺ បញ្ញា ដែលចូលដល់សេចក្ដីដឹងពិសេសនៃរូបធម៌និងនាមធម៌ដែលគួរដឹង ។

២. បរិញ្ញេយ្យេសុ ធម្មេសុ បរិញ្ញាសិទ្ធि បានដល់ ឫទ្ធि គឺ បញ្ញា ដែលចូលដល់សេចក្ដីដឹងពិតនៃទុក្ខសច្ចដែលគួរដឹង ។

៣. បហាតព្វេសុ ធម្មេសុ បហានសិទ្ធि បានដល់ សេចក្ដីសម្រេច ក្នុងការលះសមុទយដែលគួរលះ ។

៤. សច្ឆិកាតព្វេសុ ធម្មេសុ សច្ឆិកិរិយាសិទ្ធि បានដល់ សេចក្ដី សម្រេចក្នុងការឃើញច្បាស់ក្នុងនិរោធសច្ចដែលគួរឃើញច្បាស់ ។

៥. ភាវេតព្វេសុ ធម្មេសុ ភាវនាសិទ្ធិ បានដល់ សេចក្តីសម្រេចក្នុងការចម្រើនមគ្គសច្ចដែលគួរចម្រើន ។

ឥទ្ធិបាទ ទើបជាធម៌ដែលមានកម្លាំងខ្លាំងក្លា កាលមានឆន្ទ: ប្រាថ្នាព្រះនិព្វានរមែងសុខចិត្តលះបង់ជីវិត ព្រោះសេចក្តីពេញចិត្តនោះ បាន សូម្បីវីរិយ: ចិត្ត: ក៏ដូចគ្នា រមែងមានសេចក្តីព្យាយាមមិនរាថយ រមែងតាំងចិត្តមាំយ៉ាងដាច់ខាត បញ្ញាក៏ខ្លាំងក្លា មិនជាប់ជំពាក់ដល់លោកិយធម៌ អ្នកបរិបូណ៌ដោយឥទ្ធិបាទទាំង ៤ ប្រការ រមែងសម្រេចលោកុត្តរឥទ្ធិបាន ។

ចំណែកអ្នកដែលប្រាសចាកឥទ្ធិដូចពោលមក ត្រូវព្យាយាមស្វែងរកកល្យាណមិត្ត ដែលអាចដើម្បីជាឧបនិស្សយទៅក្នុងភពខាងមុខ ដូចអ្នកប្រាសចាកវីរិយិទ្ធិបាទ ត្រូវបដិបត្តិធុតង្គវត្ត ១៣ ប្រការ ឬឧស្សាហ៍ព្យាយាមពិចារណាសង្ខេគធម៌ ចំណែកអ្នកដែលប្រាសចាកវិមំសិទ្ធិបាទ ត្រូវសិក្សាបរមត្ថ ដើម្បីឱ្យកើតបញ្ញា អាចទម្លាយចេញនូវសក្កាយទិដ្ឋិ ឱ្យអស់ទៅបាន ។

៤. ឥន្ទ្រិយ

ក្នុងពោធិបក្ខិយធម៌ សម្តែងធម៌ដែលជាឥន្ទ្រិយ ដែលមានភាពជាធំ ជាអ្នកគ្រប់គ្រងក្នុងសភាវធម៌ដែលកើតព្រមជាមួយខ្លួនដូចគ្នា តែសំដៅដល់ទីកើតក្នុងមហាគ្គតកុសល និងលោកុត្តរកុសលជាប្រការសំខាន់ ចំណែកក្នុងមហាកុសលញ្ញាណសម្បយុត្ត មហាកិរិយាញ្ញាណ

សម្បយុត្ត មហាគ្គតកិរិយា និងលោកុត្តរវិបាកនោះ ជាបច្ច័យនិងជាផល ស្របតាមបានប៉ុណ្ណោះ ឥន្ទ្រិយក្នុងពោធិបក្ខិយសង្គហៈនេះ ទើបមាន ៥ ប្រការ គឺ

ឥន្ទ្រិយ ៥

១. សទ្ធិន្ទ្រិយ សទ្ធាជាអ្នកគ្របគ្រង ញ៉ាំងសេចក្តីជ្រះថ្លាក្នុងសមថ ភាវនា និងវិបស្សនាភាវនា អង្គធម៌ បានដល់ សទ្ធាចេតសិក ដែលនៅក្នុង តិហេតុកជវនចិត្ត ៣៤ ។

២. វីរិយិន្ទ្រិយ សេចក្តីព្យាយាមដល់អារម្មណ៍ ក្នុងការចម្រើន សមថភាវនា និងវិបស្សនាភាវនាយ៉ាងខ្លាំងក្លា ចូលដល់ការបរិបូណ៌ ដោយសម្មប្បធាន អង្គធម៌ បានដល់ វីរិយចេតសិក ដែលនៅក្នុង តិហេតុកជវនចិត្ត ៣៤ ។

៣. សតិន្ទ្រិយ សតិជាធំ ជាអ្នកគ្របគ្រងក្នុងការរលឹកដឹង អារម្មណ៍កម្មដ្ឋាន អង្គធម៌ បានដល់ សតិចេតសិក ដែលប្រកបក្នុង តិហេតុកជវនចិត្ត ៣៤ ។

៤. សមាធិន្ទ្រិយ សមាធិជាធំ ជាអ្នកគ្របគ្រងក្នុងការធ្វើចិត្ត ឱ្យ តាំងមាំនៅក្នុងអារម្មណ៍កម្មដ្ឋាន អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលនៅក្នុងតិហេតុកជវនចិត្ត ៣៤ ។

៥. បញ្ញិន្ទ្រិយ បញ្ញាជាធំ ជាអ្នកគ្របគ្រងក្នុងការដឹងតាមសេចក្តី ពិតរបស់អារម្មណ៍កម្មដ្ឋាន បានដល់ ដឹងរូបនាមខន្ធ ៥ ជាដើម អង្គធម៌ បានដល់ បញ្ញា ដែលនៅក្នុងតិហេតុកជវនចិត្ត ៣៤ ។

ក្នុងមិស្សកសង្គហ: សម្តែងឥន្ទ្រិយថា មាន ២២ ប្រការ ព្រោះសំដៅដល់ ភាពជាអ្នកគ្រប់គ្រងក្នុងសភាវធម៌ដែលកើតរួមគ្នាជាមួយខ្លួនទាំងអស់ មិនថាសភាវធម៌នោះ ជាកុសល អកុសល ឬអព្យាកត: រួមទាំងភាពជាធំ ជាអ្នកគ្រប់គ្រងក្នុងផ្នែករូបធម៌ផង ទើបរាប់ជាឥន្ទ្រិយ ២២ ។

ចំណែកក្នុងពោធិបក្ខិយសង្គហ:នេះ រាប់ភាពជាធំជាអ្នកគ្រប់គ្រងចំពោះក្នុងធម៌ដែលជាកុសល ដោយអំណាចនៃការចម្រើនភាវនាប៉ុណ្ណោះ ឥន្ទ្រិយ ទើបមានត្រឹម ៥ ប្រការ ។

ម្យ៉ាងទៀត គួរសង្កេតថា ឥន្ទ្រិយ ៥ ក្នុងពោធិបក្ខិយធម៌នេះ បញ្ញាដែលជាឥន្ទ្រិយនោះ ចំពោះតែបញ្ញិន្ទ្រិយតែម្យ៉ាងប៉ុណ្ណោះ មិនរួមដល់បញ្ញាក្នុងឥន្ទ្រិយដទៃ។ គឺ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ និង អញ្ញាតាវិន្ទ្រិយផងទេ ទាំងនោះព្រោះពោធិបក្ខិយធម៌ ជាធម៌ដែលជាហេតុឱ្យចូលដល់ការត្រាស់ដឹង មគ្គ ផល និព្វានប៉ុណ្ណោះ ចំណែកបញ្ញាដែលជាឥន្ទ្រិយទាំង ៣ នោះ ជាបញ្ញារបស់ព្រះអរិយបុគ្គលដែលចូលដល់ មគ្គ ផល និព្វានហើយ ទើបមិនចាត់ទុកក្នុងឥន្ទ្រិយ ៥ ជាមួយគ្នា ។

ឥន្ទ្រិយ ៥ ក្នុងពោធិបក្ខិយធម៌នេះ ជាធម៌ដែលជាធំ ជាអ្នកគ្រប់គ្រងដែលនឹងឱ្យចូលដល់ មគ្គ ផល និព្វាន ទើបមិនមែនសភាវធម៌តាមប្រក្រតីធម្មតា ដូចជាសទ្ធាចេតសិក ជាការជឿ សេចក្តីជ្រះថ្លាក្នុងកុសលធម៌ មាន ២ យ៉ាង គឺ

១) **បកតិសទ្ធា** បានដល់ សទ្ធាក្នុងការបរិច្ចាគទាន រក្សាសីល ស្តាប់ធម៌ ជាកុសលសាមញ្ញរបស់មនុស្សទាំងឡាយដែលប្រព្រឹត្តទៅដោយប្រក្រតី តែក៏ត្រូវអាស្រ័យសទ្ធាជាអ្នកគ្រប គ្រងក្នុងការទទួលអារម្មណ៍នោះ បើប្រាសចាកសទ្ធាជាអ្នកគ្របគ្រងហើយ ទានកុសល សីលកុសល ក៏មិនអាចនឹងធ្វើបាន ចិត្តនឹងធ្លាក់ចុះទៅក្នុងផ្នែកអកុសលទាំងអស់ កាលផ្តើមបណ្តុះសទ្ធាឡើងមក ក៏ផ្តើមគិតថានឹងធ្វើកុសល ហើយការធ្វើកុសលខាងដើមនោះ ក៏បានដល់ការវៀរចាកបាបធម៌ គឺតាំងនៅក្នុងកុសលកម្មបទ ១០ ឬធ្វើសេចក្តីល្អក្នុងបុញ្ញកិរិយាវត្ថុ ១០ ដូច្នេះជាដើម ដូច្នោះទើបពោលថា ទានកុសល សីលកុសល និងភាវនាកុសលខាងដើមរបស់មនុស្សទាំងឡាយ រមែងប្រព្រឹត្តទៅដោយមានបកតិសទ្ធា ។

២) **ភាវនាសទ្ធា** បានដល់ សទ្ធាក្នុងការចម្រើនសមថភាវនា និងវិបស្សនាភាវនា បើសទ្ធារបស់បុគ្គលមិនខ្លាំងក្លា ក៏មិនអាចនឹងទៅចម្រើនកម្មដ្ឋានបាន ដូចជាត្រូវគេចចេញចាកពួកគណៈទៅកាន់ស្ថានវិវេក មានគល់ឈើ ផ្ទះស្ងាត់ជាដើម និងកាលចម្រើនកម្មដ្ឋាន សទ្ធាដែលខ្លាំងក្លានេះ នឹងស៊ាប់ស្ងួនក្នុងចិត្តច្រើន អាចធ្វើចិត្តដែលប្រកបដោយសេចក្តីសៅហ្មងឱ្យជ្រះថ្លា ដាស់ចិត្តឱ្យខ្ជាប់ខ្ជួនក្នុងការបដិបត្តិដើម្បីទម្លាយសក្កាយទិដ្ឋិឱ្យបាន ភាវនាសទ្ធានេះ រមែងចូលដល់ភាពជាសទ្ធិន្ទ្រិយ កាលបដិបត្តិវិបស្សនាកម្មដ្ឋានចូលដល់ មគ្គ ផល និព្វាន ជាព្រះអរិយ

បុគ្គលហើយ អំណាចនៃសទ្ធិន្ទ្រិយ ក៏រមែងប្រាកដច្បាស់ក្រៃលែងឡើង មានព្រះបាលីក្នុងទដ្ឋព្ធសូត្រ សំយុត្តនិកាយមហាវារវគ្គ ថា

កត្ត ច ភិក្ខវេ សទ្ធិន្ទ្រិយំ ទដ្ឋព្ធំ ។ ចតូសុ សោតាបត្តិយង្គេសុ ឯត្ត សទ្ធិន្ទ្រិយំ ទដ្ឋព្ធំ ។

ប្រែថា ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធិន្ទ្រិយបណ្ឌិតគប្បីឃើញ ក្នុងទីដូចម្តេច ។ បណ្តាឥន្ទ្រិយទាំង ៥ នុ៎ះ សទ្ធិន្ទ្រិយបណ្ឌិតគប្បីឃើញ ក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ។ (បិ. ៣ផ ទំព័រ ១៣៦) ។

សទ្ធាដែលធ្វើអង្គ ៤ ប្រការ របស់ព្រះសោតាបន្នបុគ្គលឱ្យប្រាកដគឺ

១. ការធ្វើសេចក្តីជ្រះថ្លា ក្នុងគុណរបស់ព្រះសម្មាសម្ពុទ្ធ យ៉ាងខ្លាំងក្លា ។

២. ធ្វើសេចក្តីជ្រះថ្លាក្នុងធម្មគុណ គឺ ស្វាក្ខាតធម៌ យ៉ាងខ្លាំងក្លាបំផុត ។

៣. ធ្វើសេចក្តីជ្រះថ្លាក្នុងសង្ឆគុណ គឺ សុបដិបន្នោ ភគវតោ សាវកសង្ឆោ យ៉ាងខ្លាំងក្លាបំផុត ។

៤. ធ្វើឱ្យបរិបូណ៌ដោយសីលវិសុទ្ធិ ដែលជាបទដ្ឋាននៃលោកុត្តរ សមាធិ ។

ទាំង ៤ ប្រការនេះ ជាអង្គរបស់សទ្ធា ដែលកើតពីសោតាបត្តិមគ្គ ដោយពិត ។

វីរិយចេតសិក ជាធម្មជាតិដែលមានសេចក្តីព្យាយាមដល់អារម្មណ៍ ក៏មាន ២ យ៉ាងដូចគ្នា គឺ **បកតិវីរិយ** និង**ភាវនាវីរិយ** ហើយវីរិយ:ដែល

ចូលដល់ភាពជាឥន្ទ្រិយនោះ បានដល់ **ភាវនាវីរិយ** ដែលជាសេចក្តីព្យាយាមដល់អារម្មណ៍ក្នុងសតិប្បដ្ឋានទាំង ៤ ដោយចូលដល់ភាពជាសម្មប្បធាន ៤ ប្រការនោះ ហើយក្នុងវីរិយិន្ទ្រិយទើបជាការព្យាយាមយ៉ាងខ្លាំងក្លាសុខចិត្តសូម្បីលះបង់ជីវិត គឺ ឱ្យសល់តែស្បែក សល់តែសរសៃ សល់តែឆ្អឹង នឹងសូម្បីសាច់និងឈាមរីងស្ងួតទៅ ដរាបណាដែលសក្កាយទិដ្ឋិនៅមិនទាន់ទម្លាយ ក៏នឹងសុខចិត្តស្លាប់ល្អជាង ដូច្នេះជាដើម វីរិយ:នេះរមែងចូលដល់ភាពជាឥន្ទ្រិយដោយពិតប្រាកដ ។

សតិ សមាធិ និងបញ្ញាដែលខ្លាំងក្លា ចូលដល់ភាពជាឥន្ទ្រិយ ក៏ដូចគ្នានឹងសទ្ធា និងវីរិយ: ដូចពោលហើយ គឺ

អំណាចនៃសតិន្ទ្រិយ រមែងធ្វើសតិប្បដ្ឋានឱ្យប្រាកដ ។

អំណាចនៃសមាធិន្ទ្រិយ រមែងធ្វើឈាន អភិញ្ញាឱ្យប្រាកដ ។

អំណាចនៃបញ្ញិន្ទ្រិយ រមែងធ្វើអរិយសច្ច: ៤ ឱ្យប្រាកដ ។

ឥន្ទ្រិយទាំង ៥ ប្រការនេះ រមែងប្រាប់ប្រយោជន៍ក្នុងការចម្រើនសមថភាវនា និងវិបស្សនាភាវនាឱ្យប្រព្រឹត្តទៅដោយល្អគ្រប់កាល ខ្វះឥន្ទ្រិយណាមួយ សមថ: និងវិបស្សនា ទាំងឡាយក៏អន្តរាយ ។

អ្នកណាមិនបានចម្រើនឥន្ទ្រិយទាំង ៥ ប្រការ ដូចស្រុកដែលប្រាសចាកអ្នកគ្របគ្រង ជាស្រុកព្រៃ ស្រុកទួល ដែលខ្វះអ្នកគ្របគ្រងមើលថែ គ្រប់គ្នារមែងធ្វើអ្វី បានតាមអំពើចិត្ត ចោរនឹងសម្បូរ ស្រុកនោះ និងខ្វះភាពសូប់ត្រជាក់ ឧបមានេះយ៉ាងណា ចិត្តរបស់អ្នកដែលមិនបានចម្រើនឥន្ទ្រិយទាំង ៥ ប្រការក៏យ៉ាងនោះដែរ ចិត្តរបស់អ្នកនោះ

ក៏នឹងមានតែកិលេសរួបរឹត សម្តែងឫទ្ធិគ្រប់ពេលវេលា ភ្នែកក៏ដូចភ្នែកបិសាច ត្រចៀកក៏ស្រដៀងត្រចៀករបស់យក្ស មិនអាចអត់ធន់ដល់ការឃើញការបានឮសំឡេងសរសើរពុទ្ធគុណ ធម្មគុណ និងសង្ឆគុណបានទេ ចិត្តរមែងក្តៅក្រហាយដូចនៅក្នុងរណ្តៅនរក ។

ដូច្នោះ សាធុជនទាំងឡាយ គួរបានចម្រើនឥន្ទ្រិយទុកឱ្យបានច្រើនដើម្បីឃាត់សេចក្តីអាក្រក់ដែលជាហេតុឱ្យធ្វើទុច្ចរិតកម្មផ្សេងៗ ដូចបានពណ៌នាមកនេះចុះ ។

៥. ពល

ពល គឺ ការមិនញាប់ញ័រ រមែងអត់ធន់ នឹងទម្លាយបដិបក្ខធម៌នោះឱ្យវិនាស ពល:ក្នុងមិស្សកសង្គហ: ទើបសំដៅដល់ពល:ដែលញ៉ាំងបដិបក្ខធម៌ គឺ ធម៌ដែលផ្ទុយគ្នាជាមួយខ្លួនឱ្យវិនាសទៅ ដូចជាធម៌ផ្នែកកុសលទម្លាយផ្នែកអកុសល តែផ្នែកអកុសល រមែងមិនទម្លាយផ្នែកកុសលទេ ត្រឹមតែទំនុកបម្រុងផ្នែកអកុសលផងគ្នាឱ្យមានកម្លាំងបន្ថែមឡើង ដូច្នេះទើបសម្តែងថា ពល: មាន ៩ ប្រការ

ចំណែកក្នុងពោធិបក្ខិយធម៌ សំដៅយកចំពោះកុសលពល: ដែលជាកម្លាំងញ៉ាំងសេចក្តីត្រាស់ដឹង មគ្គ ផល និព្វាន ឱ្យកើតឡើង ទើបសម្តែងពល:ទុកត្រឹម ៥ ប្រការ គឺ

១. **សទ្ធាពល** សទ្ធាជាការជឿ សេចក្តីជ្រះថ្លាក្នុងកុសលធម៌ ជាកម្លាំងអត់ធន់ មិនញាប់ញ័រ នឹងញ៉ាំញីអកុសលធម៌ គឺ តណ្ហាដែល

ជាសត្រូវ អង្គធម៌ បានដល់ សទ្ធាចេតសិក ដែលនៅក្នុងតិហេតុក-ជវនចិត្ត ៣៤ ។

២. វីរិយពល វីរិយ:ដែលជាការព្យាយាមយ៉ាងខ្លាំងក្លា មិនញាប់ញ័រ នឹងទម្លាយកោសជ្ជធម៌ គឺ សេចក្ដីខ្ជិលដែលជាសត្រូវ អង្គធម៌ បានដល់ វីរិយចេតសិក ដែលនៅក្នុងតិហេតុកជវនចិត្ត ៣៤ ។

៣. សតិពល សតិដែលជាការរលឹកក្នុងអារម្មណ៍សតិប្បដ្ឋាន មានកម្លាំងតាំងមាំ មិនញាប់ញ័រ នឹងទម្លាយមុដ្ឋសតិ គឺ ការភ្លេចសតិ ដែលជាសត្រូវ អង្គធម៌ បានដល់ សតិចេតសិក ដែលនៅក្នុងតិហេតុក-ជវនចិត្ត ៣៤ ។

៤. សមាធិពល សមាធិដែលជាការតាំងចិត្តមាំ មិនញាប់ញ័រ ក្នុងវិក្ខេបធម៌ គឺ ការរវើរវាយ ដែលជាសត្រូវដល់អារម្មណ៍កម្មដ្ឋាន អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលនៅក្នុងតិហេតុកជវនចិត្ត ៣៤ ។

៥. បញ្ញាពល បញ្ញាដែលកំណត់ដឹងអារម្មណ៍កម្មដ្ឋាន តាមសេចក្ដីពិត មិនញាប់ញ័រ នឹងទម្លាយសម្មោហ: គឺ សេចក្ដីងងឹតលង់ ដែលជាសត្រូវ អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងតិហេតុក-ជវនចិត្ត ៣៤ ។

ពល:ទាំង ៥ ប្រការនេះ ដូចជាមេទ័ព ដែលមានសេចក្ដីក្លាហាន ក្នុងការប្រយុទ្ធជាមួយសត្រូវ គឺ សក្កាយទិដ្ឋិ អាចទម្លាយសក្កាយទិដ្ឋិឱ្យ វិនាសទៅបាន ។

តាមដែលបានសម្តែងហើយក្នុងឥន្ទ្រិយ ៥ ថា សទ្ធាមាន ២ ប្រការ គឺ បកតិសទ្ធា ជាមួយភាវនាសទ្ធា និងបកតិវីរិយ:ជាមួយ ភាវនាវីរិយ: ។

បកតិសទ្ធា បានដល់ សទ្ធាដែលលាយដោយតណ្ហា ពោលគឺ ក្នុងការបំពេញទាន រក្សាសីលជាដើម ជាកុសលសាមញ្ញថ្នាក់បកតិធម្មតា កុសលប្រភេទនេះ នៅក្រោមអំណាចរបស់តណ្ហា សេចក្តីថា តណ្ហានិងសទ្ធា ទាំង ២ យ៉ាងនេះជាគូប្រជែងគ្នា បើតណ្ហាមានកម្លាំងខ្លាំងជាងហើយ តណ្ហាក៏នឹងនាំឱ្យធ្វើវត្ថុគ្រប់យ៉ាង ដូចក្នុងបច្ចុប្បន្ននេះ តណ្ហាមានកម្លាំងខ្លាំងជាង ក៏នាំឱ្យបុគ្គលទាំងឡាយបែរខ្នងដាក់អរិយវសធម៌ ៤ ប្រការ គឺ ធម៌ដែលជាគ្រឿងអាស្រ័យរបស់ព្រះអរិយបុគ្គល បានដល់

១. ពេញចិត្តក្នុងភត្តាហារដោយងាយស្រួល ។

២. ពេញចិត្តក្នុងចីវរដោយងាយស្រួល ។

៣. ពេញចិត្តក្នុងសេនាសន:ដោយងាយស្រួល ។

៤. មានសេចក្តីត្រេកអរក្នុងការចម្រើនភាវនា ។

អរិយធម៌ទាំង ៤ ប្រការ ដែលធ្លាប់ប្រាកដដូចដួងព្រះអាទិត្យ ដួងព្រះចន្ទ តែបច្ចុប្បន្ននេះហាក់ដូចជាលិចបាត់ទៅហើយ ព្រោះកម្លាំងតណ្ហាក្នុងចតុបច្ច័យ និងកម្លាំងតណ្ហាក្នុងកិត្តិយស ក្នុងភោគសម្បត្តិ ក្នុងភវសម្បត្តិ ឥស្សរិយសម្បត្តិទាំងនេះ មានកម្លាំងចម្រើនឡើង ខ្លាំងជាងសទ្ធាថែមទៀត ដូចអន្លង់ទឹកដែលកំពុងជន់ពន្លិចសត្វទាំងឡាយ ឱ្យលិចចុះដូច្នោះ ។

ភាវនាសទ្ធា ដែលកើតឡើងពីការសម្រេចក្នុងកម្មដ្ឋានប៉ុណ្ណោះ ដែលនឹងមានកម្លាំងអំណាចទប់ទល់ប្រឆាំងតណ្ហាបាន ជួយឱ្យអ្នកបដិ-បត្តិកម្មដ្ឋានរួចផុតចាកអន្លង់ទឹក គឺ តណ្ហាដែលនឹងជន់ពន្លិចនោះបាន ។

វីរិយ: ក៏មាន ២ ប្រការ ដូចគ្នានឹងសទ្ធា គឺ

បកតិវីរិយ: និង ភាវនាវីរិយ:

បកតិវីរិយ នោះ រមែងមានលាយឡំជាមួយកោសជ្ជ: គឺ ការខ្ជិលច្រអូស បុគ្គលនឹងព្យាយាមក្នុងការធ្វើកុសលបាន ក៏ត្រឹមតែកុសលប្រភេទធម្មតាសាមញ្ញ ដូចជាការបរិច្ចាគ រក្សាសីល ឬសិក្សាបរិយត្តិធម៌ជាដើម ដែលជាកុសលធម្មតា ក៏ព្រោះកុសលទាំងនេះ រមែងមិនមានកម្លាំងអាចនឹងទម្លាយកោសជ្ជ:បាននោះ គឺ កុសលទាំងនេះនៅក្រោមអំណាចនៃសេចក្ដីខ្ជិលច្រអូសនោះឯង ។

គួរយ៉ាងដែលនឹងបង្ហាញឱ្យឃើញបាន ក៏គឺក្នុងព្រះពុទ្ធសាសនានេះ ពុទ្ធសាសនិកជន ដោយច្រើនរមែងដឹងថា យើងមានវដ្ដភ័យ មានអបាយភ័យ ដែលនឹងបានទទួលក្នុងសង្សារវដ្ដ ដរាបណាដែលនៅមានកិលេសសន្សំទុកក្នុងខន្ធសន្ដាន ត្រូវវិលវល់កើតស្លាប់នៅក្នុងវដ្ដសង្សារដរាបនោះ តែព្រោះកោសជ្ជ: គឺ ការខ្ជិលច្រអូសក្នុងការបដិបត្ដិសតិប្បដ្ឋាននោះឯង សូម្បីមើលឃើញគុណរបស់អរិយវសធម៌ ៤ ប្រការ ដូចពោលនោះក៏ពិត តែក៏មិនអាចធ្វើការព្យាយាម ប្រព្រឹត្ដបដិបត្ដិក្នុងព្រះកម្មដ្ឋាននោះបាន ។

វីរិយភាវនាប៉ុណ្ណោះ ដែលនឹងមានសេចក្តីព្យាយាមខ្លាំងក្លា អាចតស៊ូជាមួយកោសជ្ជ: ក្នុងការចម្រើនសតិប្បដ្ឋានបាន ។

វីរិយ:ប្រភេទនេះ អាចឃើញបានថា ក្នុងបច្ចុប្បន្ននេះ កំពុងតែសាបសូន្យអស់ទៅហើយ ព្រោះមនុស្សដោយច្រើន សូម្បីដឹងថា យើងមានមហាភ័យ គឺ អបាយភូមិ ៤ ចាំទទួលនៅខាងមុខក៏ពិត តែយើងក៏មិនអាចនឹងប្រហារកោសជ្ជធម៌ សេចក្តីខ្ជិលច្រអូសនេះបាន ដូច្នោះត្រូវប្រញាប់សាងវីរិយភាវនាឱ្យប្រាកដឡើង ទើបនឹងអាចតស៊ូជាមួយកោសជ្ជធម៌បាន ។

សម្រាប់សតិពល: សមាធិពល: និងបញ្ញាពល: ក៏មានអធិប្បាយទំនងដូចគ្នានឹងឥន្ទ្រិយនោះឯង ។

បដិបក្ខធម៌ គឺ ធម៌ដែលផ្ទុយគ្នាជាមួយពល: ៥ ប្រការនោះ បានដល់

តណ្ហា ជាបដិបក្ខធម៌ដល់ សទ្ធាពល:

កោសជ្ជ ជាបដិបក្ខធម៌ដល់ វីរិយពល:

មុដ្ឋសតិ ជាបដិបក្ខធម៌ដល់ សតិពល:

វិក្ខេប ជាបដិបក្ខធម៌ដល់ សមាធិពល:

សម្មោហ ជាបដិបក្ខធម៌ដល់ បញ្ញាពល:

កាលកម្លាំងរបស់ពល:ណាមួយទន់ខ្សោយ ការចម្រើនសមថភាវនានិងវិបស្សនាភាវនាក៏តាំងមាំមិនបាន ពិតមែនសូម្បីបុគ្គលខ្លះមានកម្លាំងនៃសទ្ធាច្រើនក្តី ត្រឹមតែមានសន្ធុដ្ឋី គឺ សេចក្តីសន្តោសជាខេត្តដែន

ប៉ុណ្ណោះ ក៏មិនផុតចាកតណ្ហាដែលក្រៃលែងជាងនោះទៅបាន ។

បុគ្គលខ្លះមានកម្លាំងសទ្ធា និងវីរិយ:ច្រើន តែពល:ដ៏សេស គឺ សតិ សមាធិ បញ្ញា នៅទន់ខ្សោយ អ្នកនោះរមែងសូប់រម្ងាប់ចាកតណ្ហា និងកោសជ្ជ:បានខ្លះ តែក៏នៅមិនអាចចម្រើនសមថភាវនា និងវិបស្សនាភាវនាបាន ។

អ្នកខ្លះកម្លាំងពល: ៣ ប្រការ គឺ សទ្ធា វីរិយ: និងសតិ បានអប់រំទុកច្រើន តែពល:ដ៏សេស គឺ សមាធិពល: និងបញ្ញាពល: នៅមានតិចតួច អ្នកនោះលួមអប់រំសមថភាវនាឱ្យចម្រើនឡើងបាន តែមិនអាចចូលដល់ឈានសមាបត្តិបាន និងមិនអាចចម្រើនវិបស្សនាភាវនាឱ្យចម្រើនឡើងបាន ។

បុគ្គលខ្លះមានកម្លាំងពល:ទាំង ៤ គឺ សទ្ធា វីរិយ: សតិ សមាធិ តែបញ្ញានៅមានកម្លាំងទន់ខ្សោយ អ្នកនោះរមែងចម្រើនសមថកម្មដ្ឋានចូលដល់ឈានសមាបត្តិបាន តែចម្រើនបញ្ញាឱ្យចូលដល់ វិបស្សនាមិនបាន ។

អ្នកខ្លះមានបញ្ញាច្រើន តែពល:ដទៃទន់ខ្សោយទៅ ក៏រមែងអាចរៀនបរិយត្តិធម៌ ទាំងបញ្ញត្តិនិងបរមត្ថបានល្អ តែតណ្ហា កោសជ្ជ: មុដ្ឋសតិ និងវិក្ខេបទាំងនេះនៅមានកម្លាំងខ្លាំង ក៏មិនអាចចម្រើនសមថ: និងវិបស្សនាបាន ដូច្នេះជាដើម ។

ក្នុងពល: ៥ ប្រការនេះ អាស្រ័យវីរិយ: សតិ បញ្ញា ទាំង ៣ ប្រការនេះ វិបស្សនារមែងប្រាកដបាន តែអ្នកណាបំណងចម្រើនសមថ:

និងវិបស្សនាឱ្យដល់ មគ្គ ផល និព្វាន ហើយត្រូវបរិបូណ៌ដោយពល: ទាំង ៥ ប្រការនេះ ។

កាលពោលដោយការប្រហារកិលេសរបស់ពល: អ្នកណាបរិបូណ៌ដោយសទ្ធា វីរិយ: និងសតិ រមែងប្រហារបដិបក្ខធម៌ គឺ

សទ្ធា រមែងប្រហារបច្ចយាមិសតណ្ហា និងលោកាមិសតណ្ហា គឺ សេចក្តីត្រេកអរជាប់ចិត្តក្នុងបច្ច័យ ៤ និង លាភ យស សរសើរ សុខ ។

វីរិយ រមែងប្រហារកោសជ្ជ: ការខ្ជិលច្រអូស ។

សតិ រមែងប្រហារមុដ្ឋសតិ គឺ ការភ្លេចសតិ ។

កាលពល:ទាំង ៣ ធ្វើការទប់ទល់កិលេសដូច្នេះហើយ រមែងឧបការ:ដល់សមាធិ និងបញ្ញា ឱ្យប្រាកដឡើងតាមកម្លាំង ។

ដូច្នោះភាវនាសទ្ធា ភាវនាវីរិយ: ភាវនាសតិ ភាវនាសមាធិ និងភាវនាបញ្ញា ពលធម៌ ៥ ប្រការនេះប៉ុណ្ណោះ ជាគ្រឿងឧបការ:ដល់សមថ: និងវិបស្សនារបស់ព្រះយោគាវចរបុគ្គលដោយពិត ព្រោះអាចញ្ចាំញ្ចីកិលេសនីវរណ:ឱ្យវិនាសបាន ។

៦. ពោជ្ឌង្គ

ពោជ្ឌង្គ ជាអង្គប្រកបបញ្ញា ដែលជាហេតុនៃការត្រាស់ដឹងអរិយសច្ច: ៤ មានវចនត្ថ:ថា

ពុជ្ឌន្តិ ឯតាយាតិ = ពោធិ

ប្រែថា ព្រះអរិយបុគ្គលទាំងឡាយ រមែងដឹងអរិយសច្ច: ៤ ដោយ

ពួកធម៌នេះ ដូច្នេះ ពួកធម៌ដែលជាហេតុឱ្យត្រាស់ដឹងអរិយសច្ច: ៤ នេះ ឈ្មោះថា ពោធិ ។

ពោធិយា អង្គោ = ពោជ្ឌង្គោ

ប្រែថា ធម៌ដែលជាអង្គប្រកបរបស់ធម៌ដែលជាហេតុឱ្យដឹងអរិយសច្ច: ៤ ឈ្មោះថា ពោជ្ឌង្គ បានដល់ អង្គធម៌របស់ពោជ្ឌង្គ ៧ ។

ពោជ្ឌង្គ ៧

១. សតិសម្ពោជ្ឌង្គ ២. ធម្មវិចយសម្ពោជ្ឌង្គ

៣. វីរិយសម្ពោជ្ឌង្គ ៤. ប៉ីតិសម្ពោជ្ឌង្គ

៥. បស្សទ្ធិសម្ពោជ្ឌង្គ ៦. សមាធិសម្ពោជ្ឌង្គ

៧. ឧបេក្ខាសម្ពោជ្ឌង្គ ។

រួមពោជ្ឌង្គមាន ៧ ប្រការ នឹងបានបរិយាយសេចក្ដីតទៅនេះ

១. សតិសម្ពោជ្ឌង្គ សតិដែលមានការចម្រើនតាំងនៅជាប់តគ្នាបានក្នុងអារម្មណ៍របស់សតិប្ឋានទាំង ៤ ដោយភាវនាកិច្ចជាប់តគ្នា សតិប្ឋាន សតិន្ទ្រិយ សតិពល: សម្មាសតិ ដោយអំណាចនៃវិបស្សនាភាវនា រមែងទម្លាយសេចក្ដីប្រមាទ នឹងធ្វើឱ្យសម្ពោធិញ្ញាណ គឺ មគ្គចិត្ត ទាំង ៤ កើតឡើង ឈ្មោះថា សតិសម្ពោជ្ឌង្គ អង្គធម៌ បានដល់ សតិ ចេតសិក ដែលនៅក្នុងតិហេតុកជវនចិត្ត ៣៤ ។

២. ធម្មវិចយសម្ពោជ្ឌង្គ បញ្ញាដែលមានការចម្រើន គឺ ដឹងរូបនាម ដោយភាពជាត្រៃលក្ខណ៍ ដោយអំណាចវិបស្សនាភាវនា ទម្លាយមោហ: នឹងធ្វើឱ្យសម្ពោធិញ្ញាណ គឺ មគ្គចិត្តទាំង ៤ កើតឡើង

ឈ្មោះថា ធម្មវិចយសម្ពោជ្ឌង្គ អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលនៅក្នុងតិហេតុកជវនចិត្ត ៣៤ ។

៣. វីរិយសម្ពោជ្ឌង្គ វីរិយ:ដែលមានការចម្រើនយ៉ាងខ្លាំងក្លាមកពីសម្មប្ផធានទាំង ៤ ចូលដល់វីរិយិទ្ធិបាទ វីរិយិន្ទ្រិយ វីរិយពល: សម្មាវាយាម ដោយអំណាចនៃវិបស្សនាភាវនា រមែងទម្លាយកោសជ្ជ: គឺ ការខ្ជិលច្រអូសបាន នឹងធ្វើឱ្យសម្ពោធិញ្ញាណ គឺ មគ្គចិត្តទាំង ៤ កើតឡើង ហៅថា វីរិយសម្ពោជ្ឌង្គ អង្គធម៌ បានដល់ វីរិយចេតសិក ដែលនៅក្នុងតិហេតុកជវនចិត្ត ៣៤ ។

៤. ប៉ីតិសម្ពោជ្ឌង្គ ជាប៉ីតិដែលមានសេចក្ដីចម្រើនត្រេកអរក្នុងអារម្មណ៍របស់ការចម្រើនវិបស្សនាភាវនា រមែងទម្លាយ **អរតិ** គឺ ការមិនត្រេកអរ នឹងធ្វើឱ្យសម្ពោធិញ្ញាណ គឺ មគ្គចិត្តទាំង ៤ កើតឡើង ឈ្មោះថា ប៉ីតិសម្ពោជ្ឌង្គ អង្គធម៌ បានដល់ ប៉ីតិចេតសិក ដែលនៅក្នុងសោមនស្សមហាកុសលញាណសម្បយុត្តចិត្ត ២ សោមនស្សមហា-កិរិយាញាណសម្បយុត្តចិត្ត ២ និងសប្បីតិកអប្បនាជវន: ៣០ (លោកិយបឋមជ្ឌានកុសល ១ ទុតិយជ្ឌានកុសល ១ តតិយជ្ឌាន-កុសល ១ បឋមជ្ឌានកិរិយា ១ ទុតិយជ្ឌានកិរិយា ១ តតិយជ្ឌានកិរិយា ១ លោកុត្តរបឋមជ្ឌានចិត្ត ៨ ទុតិយជ្ឌានចិត្ត ៨ តតិយជ្ឌានចិត្ត ៨) ។

៥. បស្សទ្ធិសម្ពោជ្ឌង្គ គឺ សេចក្ដីស្ងប់កាយស្ងប់ចិត្ត ក្នុងការចម្រើនសតិប្ឋដ្ឋាននៅក្នុងអារម្មណ៍រូបនាម ដោយភាពជាត្រៃលក្ខណ៍ សេចក្ដីស្ងប់នេះ កើតឡើងដោយអំណាចរបស់វិបស្សនាភាវនា អាច

ទម្លាយសេចក្តីរឹងត្អឹង និងសេចក្តីក្តៅក្រហាយចិត្តបាន នឹងចូលដល់សម្ពោធិញាណ គឺ មគ្គចិត្តទាំង ៤ កើតឡើង អង្គធម៌ បានដល់ កាយបស្សទ្ធិចេតសិក និង ចិត្តបស្សទ្ធិចេតសិក ដែលនៅក្នុងតិហេតុក-ជវនចិត្ត ៣៤ ។

៦. សមាធិសម្ពោជ្ឈង្គ គឺ សមាធិដែលមានសេចក្តីចម្រើនតាំងមាំនៅក្នុងអារម្មណ៍ សតិប្បដ្ឋាន ជាសមាធិន្ទ្រិយ សមាធិពល: សមាធិ-សម្ពោជ្ឈង្គ សម្មាសមាធិ ដោយអំណាចនៃការចម្រើនវិបស្សនាភាវនារហូតអាចទម្លាយវិក្ខេប គឺ សេចក្តីរវើរវាយ នឹងធ្វើឱ្យសម្ពោធិញាណ គឺ មគ្គចិត្តទាំង ៤ កើតឡើង ឈ្មោះថា សមាធិសម្ពោជ្ឈង្គ អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលនៅក្នុងតិហេតុកជវនចិត្ត ៣៤ ។

៧. ឧបេក្ខាសម្ពោជ្ឈង្គ គឺ តត្រមជ្ឈត្តតាចេតសិក មានកិច្ចមិនធ្លាក់ទៅក្នុងអគតិ ៤ ជាការផ្គងមិនឱ្យធ្លាក់ទៅក្នុងអភិជ្ឈា និង ទោមនស្ស ខណ:នេះវិបស្សនាញាណមានការចម្រើនខ្លាំង អាចធ្វើឱ្យអង្គធម៌នៃការដឹងអរិយសច្ច: ៤ ធ្វើនាទីរបស់ខ្លួនៗ ជារឿយៗ ពោលគឺ រមែងធ្វើសទ្ធានិងបញ្ញា វីរិយ:និងសមាធិ ឱ្យស្មើភាគគ្នា មិនបានលើសខ្វះគ្នា រក្សាតុល្យភាព ដោយភាពជាមជ្ឈិមាបដិបទា ទុកបានយ៉ាងមាំទាំ ព្រមទាំងទម្លាយនីវរណធម៌ នឹងធ្វើឱ្យសម្ពោធិញាណ គឺ មគ្គចិត្តទាំង ៤ កើតឡើង ឈ្មោះថា ឧបេក្ខាសម្ពោជ្ឈង្គ អង្គធម៌ បានដល់ តត្រមជ្ឈត្តតាចេតសិក ដែលនៅក្នុងតិហេតុកជវនចិត្ត ៣៤ ។

ក្នុងពោជ្ឌង្គទាំង ៧ ប្រការនេះ មានអធិប្បាយថា

សម្ពោជ្ឌង្គនេះ ជាអង្គនៃការសម្រេចលោកុត្តរមគ្គញាណ មានឧបមាថា ធម្មតាបក្សាបក្សីជាសត្វដែលកើតបាន ៣ គ្រា។ ដំបូងកើតជាពងចាកផ្ទៃរបស់មេ គ្រាទី ២ កើតជាខ្លួនបក្សាបក្សីចេញចាកសំបកពង កាលរោមស្ងួតបរិបូណ៌ដោយស្លាប និងកន្ទុយរឹងមាំល្មមនឹងហើរទៅតាមការពេញចិត្តបាន ចាត់ថាជាការកើតគ្រាទី ៣ ឧបមាសេចក្តីនេះយ៉ាងណា ព្រះយោគាវចរដែលមានសេចក្តីព្យាយាមក្នុងការចម្រើនសតិប្បដ្ឋាន ក៏ដូច្នោះ កាលប្រាកដសីលវិសុទ្ធិ និងចិត្តវិសុទ្ធិហើយ រួចផុតចាកកាមឆន្ទនីវរណ:ជាដើមនោះ រាប់ថាបានកើតចេញមកពីផ្ទៃមេជាគ្រាទី ១ កាលចូលដល់ ទិដ្ឋិវិសុទ្ធិ បានឃើញនាមរូប ដោយភាពជាត្រៃលក្ខណ៍ វិបស្សនាញាណកើតហើយ រមែងផុតចាកអវិជ្ជាយ៉ាងគ្រោតគ្រាត រាប់បានថា ចេញចាកសំបកពងហើយជាគ្រាទី ២ និងកាលសម្ពោជ្ឌង្គទាំង ៧ ប្រការ ចាស់ក្លានិងសម្រេចលោកុត្តរមគ្គ និង ផលបានតាមសេចក្តីប្រាថ្នាហើយ ក៏រួចផុតចាកលោកិយធម៌ទាំងពួង រាប់ថាជាកូនបក្សាបក្សីធំ បរិបូណ៌ដោយស្លាប និងកន្ទុយ អាចហើរទៅតាមការពេញចិត្ត ជាគ្រាទី ៣ ក៏ឧបមេយ្យយ៉ាងនោះដែរ ។

កាលពិចារណាតាមសភាវធម៌របស់សម្ពោជ្ឌង្គទាំង ៧ ប្រការ និងឃើញបានថា សតិចេតសិកនោះ ដែលហៅថា សតិប្បដ្ឋាន កាលចម្រើនឡើងក៏មានសភាពជាសតិន្ទ្រិយ សតិពល: សូម្បីសម្មាសតិ ក៏ហៅថា សតិសម្ពោជ្ឌង្គ ។

បញ្ញាចេតសិក ដែលចម្រើនឡើងជាវិមំសិទ្ធិបាទ បញ្ញិន្ទ្រិយ បញ្ញាពល: សម្មាទិដ្ឋិ ហៅថា ធម្មវិចយសម្ពោជ្ឈង្គ បានដល់ ការចូលដល់បញ្ញាវិសុទ្ធិ ៥ ប្រការ មានទិដ្ឋិវិសុទ្ធិ ជាដើម ។

វីរិយចេតសិក ដែលចម្រើនឡើងជាសម្មប្បធាន វីរិយិទ្ធិបាទ វីរិយិន្ទ្រិយ វីរិយពល: សម្មាវាយាម: ហៅថា វីរិយសម្ពោជ្ឈង្គ ។

ប�ីតិចេតសិក ដែលចម្រើនឡើងពីការចម្រើនសតិប្បដ្ឋាន ជាដើម ហៅថា ប៉ីតិសម្ពោជ្ឈង្គ ។

បស្សទ្ធិចេតសិក គឺ កាយបស្សទ្ធិ និងចិត្តបស្សទ្ធិ ដែលចម្រើនឡើងពីការចម្រើនសតិប្បដ្ឋាន ហៅថា បស្សទ្ធិសម្ពោជ្ឈង្គ ។

ឯកគ្គតាចេតសិក ដែលចម្រើនឡើងជាសមាធិន្ទ្រិយ សមាធិពល: សម្មាសមាធិ ក្នុងការចម្រើនសមថភាវនា ជាតូបរិកម្មសមាធិ ឧបចារសមាធិ អប្បនាសមាធិ សម្រេចជាសមាបត្តិ ៨ និងក្នុងវិបស្សនាភាវនា មានសុញ្ញតសមាធិ អនិមិត្តសមាធិ និងអប្បណិហិតសមាធិ គឺ សមាធិតាមដែលឃើញត្រៃលក្ខណ៍ រហូតដល់ មគ្គ ផល និព្វាន ហៅថា សមាធិសម្ពោជ្ឈង្គ ។

តត្រមជ្ឈត្តតាចេតសិក ដែលកើតពីការចម្រើនកម្មដ្ឋាន ប្រាសចាកបលិពោធណាៗ ដាក់ចិត្តស្មើក្នុងកម្មដ្ឋាននោះ ហៅថា ឧបេក្ខា-សម្ពោជ្ឈង្គ ។

ពោជ្ឈង្គទាំង ៧ ប្រការនេះ ទើបមានតាំងពីប្រភេទដែលជាសាមញ្ញ គឺ សតិ បញ្ញា វីរិយ: ប៉ីតិ បស្សទ្ធិ សមាធិ និងតត្រមជ្ឈត្តតា

ដែលជាវិវដ្ដនិស្សិតចេតនា គឺ ព្យាយាមដែលនឹងឱ្យរួចផុតចាកកិលេស រហូតដល់ ពោជ្ឈង្គពិសេស អាចនាំខ្លួនឱ្យផុតចាកកិលេសបាន ដែលហៅថា វិវេកនិស្សិត វិរាគនិស្សិត និងនិរោធនិស្សិត គឺ ការស្ងាត់ចាកកិលេស ចេញចាកកិលេស និង ចូលដល់ការរលត់កិលេសបាន ។

៧. មគ្គង្គ

មគ្គ គឺ ផ្លូវ ដែលនាំទៅកាន់ទុគ្គតិ សុគតិ និងនិព្វាន បានសម្ដែងហើយក្នុងមិស្សកសង្គហ: មគ្គដែលជាការពោលដល់ផ្លូវដែលល្អនិងផ្លូវអាក្រក់ តែក្នុងពោធិបក្ខិយសង្គហ:នេះសម្ដែងដល់ មគ្គ ចំពោះដែលជាផ្នែកល្អដែលនឹងនាំឱ្យចូលដល់និព្វាន ដូចវចនត្ថ:ថា

កិលេសេ មារយន្តា និព្វានំ គច្ឆន្តិ ឯតេនាតិ = មគ្គោ

ប្រែថា ព្រះអរិយបុគ្គលទាំងឡាយ រមែងសម្លាប់កិលេស និងចូលដល់ព្រះនិព្វានដោយធម៌ណា ធម៌ដែលជាហេតុនៃការសម្លាប់កិលេស និងឱ្យចូលដល់ព្រះអរិយបុគ្គលទាំងឡាយនោះ ឈ្មោះថា មគ្គ បានដល់អង្គមគ្គទាំង ៨ រួមគ្នា មានសម្មាទិដ្ឋិ ជាដើម ។

ប្រែតាមអត្ថថា ពួកធម៌ទាំងឡាយណា ប្រហារកិលេសទាំងពួង មានសក្កាយទិដ្ឋិ ជាដើម ហើយឱ្យរួចផុតពីអបាយទាំង ៤ ឬវដ្ដសង្សារ បាន ឈ្មោះថា មគ្ត ។

មគ្គស្ស អង្គោ = មគ្គង្គោ

ប្រែថា ធម៌ដែលជាគ្រឿងប្រកប របស់ធម៌ដែលជាហេតុនៃការ

សម្លាប់កិលេស និងឱ្យចូលដល់ព្រះនិព្វាន ឈ្មោះថា មគ្គង្គ បានដល់ អង្គមគ្គ ៨ ដោយចំពោះ ។

អង្គមគ្គ ៨

១. សម្មាទិដ្ឋិ = សេចក្តីយល់ឃើញត្រូវ ។

២. សម្មាសង្កប្ប = សេចក្តីត្រិះរិះត្រូវ ។

៣. សម្មាវាចា = ការពោលវាចាត្រូវ (រៀរវាចីទុច្ចរិត) ។

៤. សម្មាកម្មន្ត = ការងារត្រឹមត្រូវ (រៀរកាយទុច្ចរិត) ។

៥. សម្មាអាជីវ = ការចិញ្ចឹមជីវិតត្រូវ (រៀរមិច្ឆាអាជីវ:) ។

៦. សម្មាវាយាម = ការព្យាយាមត្រូវ ។

៧. សម្មាសតិ = ការរលឹកត្រូវ ។

៨. សម្មាសមាធិ = ការតាំងចិត្តមាំត្រូវ ។

អធិប្បាយអង្គមគ្គ ៨

១. សម្មាទិដ្ឋិ គឺ ការយល់ឃើញត្រូវ សំដៅដល់ សេចក្តីយល់ឃើញត្រូវតាមសេចក្តីពិត អង្គធម៌ បានដល់ បញ្ញាចេតសិក ដែលពិចារណារូបនាម ជាអារម្មណ៍ ក្នុងការចម្រើនសតិប្បដ្ឋាន និងវិបស្សនាញាណកើតរហូតដល់មគ្គញាណ ផលញាណ ដែលមាននិព្វានជាអារម្មណ៍ សម្មាទិដ្ឋិដែលសម្តែងទុកក្នុងអង្គុត្តរនិកាយឯកធម្មបាលិទុតិយវគ្គមាន ៥ ប្រការ

នៅក្នុងមហាចត្តារីសកសូត្រមាន ៥ ប្រការ ដូចគ្នា ខុសគ្នាត្រង់ឈាន-សម្មាទិដ្ឋិ និងបច្ចវេក្ខណសម្មាទិដ្ឋិ

១) កម្មស្សកតាសម្មាទិដ្ឋិ សំដៅដល់ បញ្ញាដែលមានការយល់ឃើញត្រូវថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន ធ្វើកម្មល្អ រមែងបានទទួលផលល្អ ធ្វើកម្មអាក្រក់រមែងទទួលផលអាក្រក់ ដូច្នេះ ។

២) ឈានសម្មាទិដ្ឋិ ការយល់ឃើញត្រូវក្នុងការធ្វើចិត្តឱ្យស្ងប់តាំងមាំនៅក្នុងអារម្មណ៍តែមួយ រមែងអាចគ្របសង្កត់កិលេសនីវរណធម៌ទុកមិនឱ្យកើតឡើងក្នុងចិត្ត ជាការយើញត្រូវក្នុងការដឹងឧបាយដែលនឹងចម្រើនសមថភាវនា រហូតសម្រេចឈានកុសល នៅក្នុងឈានសមាបត្តិបាន ។

៣) វិបស្សនាសម្មាទិដ្ឋិ ជាការយល់ឃើញត្រូវដែលកើតឡើងខណៈពិចារណារូប នាម ដោយភាពជាត្រៃលក្ខណ៍ គឺ អនិច្ចំ ទុក្ខំ និងអនត្តា ដែលហៅថា វិបស្សនាញាណកើត រហូតដល់អនុលោមញាណមានត្រៃលក្ខណ៍ជាអារម្មណ៍ ។

៤) មគ្គសម្មាទិដ្ឋិ បញ្ញាក្នុងមគ្គញាណដែលចូលដល់អរិយសច្ច: ៤ មាននិព្វានជាអារម្មណ៍ ព្រមទាំងប្រហារកិលេស ជាសមុច្ឆេទប្បហាន ។

៥) ផលសម្មាទិដ្ឋិ បញ្ញាក្នុងផលញាណដែលដឹងនិព្វានជាអារម្មណ៍ ដើម្បីសោយវិមុត្តិសុខរបស់ព្រះនិព្វាន កាលមគ្គញាណប្រហារកិលេសហើយ ។

៦) បច្ចវេក្ខណាសម្មាទិដ្ឋិ បញ្ញាដែលកើតឡើងខាងក្រោយមគ្គវីថិ មានអារម្មណ៍ឱ្យពិចារណាបាន ៥ ប្រការ គឺ

(១) ពិចារណាមគ្គចិត្តដែលកើតឡើងហើយដល់ខ្លួន ។

(២) ពិចារណាផលចិត្ត ។

(៣) ពិចារណាព្រះនិព្វាន ។

(៤) ពិចារណាកិលេសដែលបានលះហើយ ។

(៥) ពិចារណាកិលេសដែលនៅសល់ ។

សម្មាទិដ្ឋិ ក្នុងពោធិបក្ខិយធម៌នេះ សំដៅយកសម្មាទិដ្ឋិ តាំងពីវិបស្សនាសម្មាទិដ្ឋិ ដល់ ផលសម្មាទិដ្ឋិ គឺ រាប់ជាប់តាំងពីលោកិយមគ្គ ដល់ លោកុត្តរមគ្គ ជាទីបំផុត ។

តែបើពោលដោយភាពជាសម្មាទិដ្ឋិដោយពិត ក៏ត្រូវកាន់យកត្រង់ មគ្គសម្មាទិដ្ឋិ និង ផលសម្មាទិដ្ឋិ ដែលជាការឃើញច្បាស់ក្នុងអរិយសច្ច: ៤ បរិបូណ៌នោះឯង ពោលគឺ

ឃើញច្បាស់ក្នុងទុក្ខសច្ច: ដោយបរិញ្ញាកិច្ច

ឃើញច្បាស់ក្នុងសមុទយសច្ច: ដោយបហានកិច្ច

ឃើញច្បាស់ក្នុងនិរោធសច្ច: ដោយសច្ឆិករណកិច្ច

ឃើញច្បាស់ក្នុងមគ្គសច្ច: ដោយភាវនាកិច្ច ។

២. សម្មាសង្កប្ប សេចក្ដីត្រិះរិះត្រូវ សំដៅដល់ ការត្រិះរិះនៅក្នុងរឿងរ៉ាវដែលជាកុសល អង្គធម៌ បានដល់ វិតក្កចេតសិក ដែលប្រកបជាមួយកុសលចិត្ត ដែលហៅថា **កុសលវិតក្ក** មាន ៣ ប្រការ គឺ

(១) **នេក្ខម្មវិតក្ក** បានដល់ សេចក្ដីត្រិះរិះដែលចេញចាកកាមនិងភព

(២) **អព្យាបាទវិតក្ក** បានដល់ សេចក្ដីត្រិះរិះដែលប្រកបដោយមេត្តា

(៣) **អវិហិង្សាវិតក្ក** បានដល់ សេចក្ដីត្រិះរិះដែលប្រកបដោយករុណា ។

កុសលវិតក្ក:ទាំងនេះ ឈ្មោះថា **សម្មាសង្កប្បនេក្ខម្មវិតក្ក** សំដៅដល់ ការគិតដែលនឹងរួចផុតពីវដ្ដទុក្ខក្នុងជាតិនេះ កុសលវិតក្ក:ក្នុងទីនេះ សំដៅយកវិតក្ក:ក្នុងលោកិយមគ្គ និងលោកុត្តរមគ្គ ដែលកើតព្រមជាមួយបឋមជ្ឌានប៉ុណ្ណោះ (រមែងមិនកើតក្នុងលោកុត្តរមគ្គដែលកើតព្រមជាមួយទុតិយជ្ឌានចិត្តឡើងទៅឡើយ) ។

៣. សម្មាវាចា ការពោលវាចាត្រូវ សំដៅដល់ ការវៀរចាកវចីទុច្ចរិតទាំង ៤ ដែលមិនទាក់ទងនឹងអាជីព គឺ វៀរចាកការនិយាយកុហក និយាយសិកសៀត និយាយទ្រគោះបោះបោក និងនិយាយឥតប្រយោជន៍ អង្គធម៌ បានដល់ សម្មាវាចាចេតសិក ខណ:មគ្គញ្ញាណកើត ឈ្មោះថា សម្មាវាចា ។

៤. សម្មាកម្មន្ត ការងារត្រឹមត្រូវ សំដៅដល់ ការវៀរចាកកាយទុច្ចរិត ដែលមិនទាក់ទងនឹងអាជីព គឺ វៀរចាកការសម្លាប់សត្ត្ব ការលួចទ្រព្យ និងប្រព្រឹត្ដខុសក្នុងកាម អង្គធម៌ បានដល់ សម្មាកម្មន្តចេតសិក ខណ:មគ្គញ្ញាណកើត ឈ្មោះថា សម្មាកម្មន្ត ។

៥. សម្មាអាជីវ ការចិញ្ចឹមជីវិតត្រូវ សំដៅដល់ ការទ្រទ្រង់ជីវិតនៅដោយវៀរចាកវចីទុច្ចរិត ៤ កាយទុច្ចរិត ៣ ដែលជាប់មកពី

យោនិសោមនសិការ ការរស់នៅដោយភាពចាំបាច់ដើម្បីដោះស្រាយសេចក្ដីទុក្ខ អង្គធម៌ បានដល់ សម្មាអាជីវចេតសិក ខណៈមគ្គញ្ញាណកើត ឈ្មោះថា សម្មាអាជីវ ។

៦. សម្មាវាយាម សេចក្ដីព្យាយាមត្រូវ សំដៅដល់ សេចក្ដីព្យាយាមក្នុងអារម្មណ៍ កម្មដ្ឋាន តាំងពីចម្រើនសតិប្បដ្ឋាន ប្រព្រឹត្តទៅតាមសម្មប្បធាន ៤ វីរិយិទ្ធិបាទ វីរិយិន្ទ្រិយ វីរិយពលៈ វីរិយសម្ពោជ្ឌង្គ និងសម្មាវាយាម ទាំងនេះ ឈ្មោះថា សម្មាវាយាម ទាំងអស់ អង្គធម៌ បានដល់ វីរិយចេតសិក ខណៈចម្រើនសតិប្បដ្ឋានរហូតមគ្គញ្ញាណកើត។

៧. សម្មាសតិ សេចក្ដីរលឹកត្រូវ បានដល់ សតិចេតសិក ធ្វើនាទីរលឹកដឹងតែចំពោះអារម្មណ៍របស់សតិប្បដ្ឋាន ៤ បើសតិរលឹកនៅក្នុងរឿងរ៉ាវរបស់កុសលដទៃ។ ដូចជាទានកុសល ឬសីលកុសល ដែលមិនមែនជាឥន្ទ្រិយសំវរសីល ជាដើម មិនឈ្មោះថា ជាសម្មាសតិ ដែលជាអង្គមគ្គ តែសតិដែលប្រព្រឹត្តទៅតាមសតិប្បដ្ឋាន ៤ រហូតដល់ មគ្គ ផល ជាទីបំផុតប៉ុណ្ណោះ ទើបឈ្មោះថា សម្មាសតិ ។

៨. សម្មាសមាធិ ការតាំងចិត្តមាំត្រូវ សំដៅដល់ ការតាំងចិត្តមាំក្នុងអារម្មណ៍វិបស្សនា អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលតាំងមាំនៅក្នុងសតិប្បដ្ឋាន ៤ រហូតដល់មគ្គញ្ញាណ ផលញ្ញាណ មាននិព្វានជាអារម្មណ៍ ទើបឈ្មោះថា សម្មាសមាធិ ។

ចែកអង្គមគ្ត ៨ ដោយ សីលខន្ធ សមាធិខន្ធ បញ្ញាខន្ធ

សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវ: អង្គធម៌ទាំង ៣ សង្ត្រោះចូលក្នុងសីលខន្ធ ។

សម្មាវាយាម សម្មាសតិ សម្មាសមាធិ អង្គធម៌ទាំង ៣ សង្ត្រោះចូលក្នុងសមាធិខន្ធ ។

សម្មាទិដ្ឋិ សម្មាសង្កប្ប អង្គធម៌ទាំង ២ សង្ត្រោះចូលក្នុងបញ្ញាខន្ធ។

ពោធិបក្ខិយធម៌ ៣៧ ប្រការ តាមន័យដែលបានសម្តែងមកហើយនេះ កាលពោលដោយអង្គធម៌បរមត្ថ មាន ១៤ យ៉ាង ដូចដែលពោលទុកក្នុងគាថាសង្គហ:ទី ៦ និងទី ៧ ចំណែកការសង្ត្រោះអង្គធម៌ ១៤ ប្រការ ក្នុងឋានរបស់ពោធិបក្ខិយធម៌នោះ មានសម្តែងទុកដូច្នេះ ។

ចែកអង្គធម៌ ១៤ ដោយឋានពោធិបក្ខិយធម៌ ៣៧

គាថាសង្គហ:ទី ៨

៨. សង្កប្បបស្សទ្ធិ ច បីតុបេក្ខា ឆន្ទោ ច ចិត្តំ វិរតិត្តយញ្ច
នវេកឋានា វីរិយំ នវដ្ឋ សតី សមាធី ចតុ បញ្ច បញ្ញា
សទ្ធា ទុឋានុត្តមសត្តតឹស- ធម្មានមេសោ បវរោ វិភាគោ ។

ប្រែថា ធម៌ ៩ ប្រការ គឺ សម្មាសង្កប្ប បស្សទ្ធិ បីតិ ឧបេក្ខា ឆន្ទ: ចិត្ត: និងវិរតិ ៣ ជាធម៌ប្រាកដក្នុងឋានតែ ១ វីរិយប្រាកដក្នុងឋាន ៩ សតិប្រាកដក្នុងឋាន ៨ សមាធិប្រាកដក្នុងឋាន ៤ បញ្ញាប្រាកដក្នុងឋាន

៥ សទ្ធាប្រាកដក្នុងហាន ២ ទាំងអស់នេះជាការចែកធម៌ដ៏ឧត្តម ៣៧ ប្រការយ៉ាងប្រសើរ ។

អខ្ពធម៌

វិតក្កចេតសិក ជា សម្មាសង្កប្បមគ្គ ។

បស្សទ្ធិចេតសិក ជា បស្សទ្ធិសម្ពោជ្ឈង្គ ។

បីតិចេតសិក ជា បីតិសម្ពោជ្ឈង្គ ។

តត្រមជ្ឈត្តតាចេតសិក ជា ឧបេក្ខាសម្ពោជ្ឈង្គ ។

ឆន្ទចេតសិក ជា ឆន្ទិទ្ធិបាទ ។

ចិត្ត ជា ចិត្តិទ្ធិបាទ ។

សម្មាវាចាចេតសិក ជា សម្មាវាចាមគ្គ ។

សម្មាកម្មន្តចេតសិក ជា សម្មកម្មន្តមគ្គ ។

សម្មាអាជីវចេតសិក ជា សម្មាអាជីវមគ្គ ។

វីរិយចេតសិក ជាពោធិបក្ខិយធម៌ ៩ ហាន

សម្មប្បធាន ៤ ហាន, វីរិយិទ្ធិបាទ ១ ហាន, វីរិយិន្ទ្រិយ ១ ហាន, វីរិយពល: ១ ហាន, វីរិយសម្ពោជ្ឈង្គ ១ ហាន, សម្មាវាយាមមគ្គ ១ ហាន, = រួមជា ៩ ហាន ។

សតិចេតសិក ជាពោធិបក្ខិយធម៌ ៨ ឋាន

សតិប្បដ្ឋាន ៤ ឋាន, សតិន្ទ្រិយ ១ ឋាន, សតិពល: ១ ឋាន, សតិសម្ពោជ្ឈង្គ ១ ឋាន, សម្មាសតិមគ្គ ១ ឋាន = រួមជា ៨ ឋាន

ឯកគ្គតាចេតសិក ជាពោធិបក្ខិយធម៌ ៤ ឋាន

សមាធិន្ទ្រិយ ១ ឋាន, សមាធិពល: ១ ឋាន, សមាធិសម្ពោជ្ឈង្គ: ១ ឋាន, សម្មាសមាធិមគ្គ ១ ឋាន, = រួមជា ៤ ឋាន

បញ្ញាចេតសិក ជាពោធិបក្ខិយធម៌ ៥ ឋាន

វិមំសិទ្ធិបាទ ១ ឋាន, បញ្ញិន្ទ្រិយ ១ ឋាន, បញ្ញាពល: ១ ឋាន, ធម្មវិចយសម្ពោជ្ឈង្គ ១ ឋាន, សម្មាទិដ្ឋិមគ្គ ១ ឋាន, = រួមជា ៥ ឋាន

សទ្ធាចេតសិក ជាពោធិបក្ខិយធម៌ ២ ឋាន

សទ្ធិន្ទ្រិយ ១ ឋាន, សទ្ធាពល: ១ ឋាន, = រួមជា ២ ឋាន ។

សម្តែងទីកើតរបស់ពោធិបក្ខិយធម៌

គាថាសង្គហ:ទី ៩

៩. សព្វេ លោកុត្តរេ ហោន្តិ ន វា សង្កប្បបីតិយោ
លោកិយេបិ យថាយោគំ ឆព្វិសុទ្ធិបវត្តិយំ ។

ប្រែថា ពោធិបក្ខិយធម៌ទាំងឡាយទាំងពួងរមែងមានក្នុងលោកុត្តរចិត្ត សម្មាសង្កប្ប និងបីតិរមែងមិនមានក្នុងលោកុត្តរចិត្តដូងខ្លះ ប៉ុន្តែរមែងមានតាមសមគួរដល់ការប្រកបក្នុងការប្រព្រឹត្តទៅនៃវិសុទ្ធិទាំងឡាយ ៦ សូម្បីក្នុងលោកិយកុសលចិត្តទាំងឡាយ ១៧ ។

គឺ សម្មាសង្កប្បមគ្គ រមែងមិនកើតក្នុងលោកុត្តរចិត្ត តាំងពីទុតិយជ្ឈានឡើងទៅ និងបីតិសម្ពោជ្ឈង្គ រមែងមិនកើតក្នុងលោកុត្តរ-ចតុត្ថជ្ឈានឡើងទៅ ពោធិបក្ខិយធម៌ ៣៧ ប្រការនេះ កាលប្រព្រឹត្តទៅក្នុងលោកិយកុសល និងកិរិយាចិត្ត ឬសូម្បីកាលសម្រេចជាវិសុទ្ធិទាំង ៦ (រៀរញ្ញាណទស្សនវិសុទ្ធិ) ហើយរមែងកើតឡើងតាមសមគួរដែល និងប្រកបជាមួយធម៌នោះបាន ។

វិសុទ្ធិ ៧

វិសុទ្ធិ ដែលពោលទុកក្នុងគាថាសង្គហ:ទី ៩ នេះ សំដៅដល់សេចក្តីបរិសុទ្ធក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ ដែលកើតពីការចម្រើនវិបស្សនាកម្មដ្ឋាន ដើម្បីធ្វើកាយ វាចា ចិត្ត និងបញ្ញា ឱ្យបរិសុទ្ធបរិបូណ៌ មានវិសុទ្ធិ ៧ ប្រការ សេចក្តីពិស្តារនៅក្នុងបរិច្ឆេទទី ៩ តែសូមនាំមកពោលដោយសង្ខេបដូច្នេះ គឺ

១. សីលវិសុទ្ធិ សេចក្តីបរិសុទ្ធនៃសីល ដែលបានពីការចម្រើនសតិប្បដ្ឋានដោយការសង្រួមឥន្ទ្រិយសំវរសីល ក្នុងចតុបារិសុទ្ធិសីល ៤ ប្រការ អង្គធម៌ បានដល់ សតិដែលរលឹកនៅក្នុងអារម្មណ៍សតិប្បដ្ឋាន គឺ

រូបនាមនោះឯង កាលសតិរលឹកដឹងតែចំពោះរូបនាម ដែលកំពុងប្រាកដ តាមសេចក្តីពិតនោះ កិលេសតណ្ហាអាស្រ័យទ្វារ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត កើតឡើងមិនបាន ដោយមានសតិគ្របគ្រងទុកនោះ ទើបឈ្មោះថា សីលវិសុទ្ធិ ។

២. ចិត្តវិសុទ្ធិ ជាសេចក្តីបរិសុទ្ធរបស់ចិត្តដែលស្ងប់តាំងមាំនៅ ក្នុងអារម្មណ៍របស់កម្មដ្ឋាន ដែលជាប់តមកពីសីលវិសុទ្ធិនោះឯង អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ដែលមានបច្ចុប្បន្ន នាមរូប ជាអារម្មណ៍ ។

៣. ទិដ្ឋិវិសុទ្ធិ ជាសេចក្តីបរិសុទ្ធរបស់បញ្ញា ដែលដឹងអារម្មណ៍ របស់នាមរូប តាមសេចក្តីពិត ពីការចម្រើនសតិប្បដ្ឋាន អង្គធម៌ បាន ដល់ បញ្ញាចេតសិក ដែលដឹងសភាវៈអារម្មណ៍តាមសេចក្តីពិត ដោយមិន មានយើង ចូលទៅនៅក្នុងនាមរូប ដែលជាអារម្មណ៍នោះ ។

៤. កង្ខាវិតរណវិសុទ្ធិ ជាសេចក្តីបរិសុទ្ធរបស់បញ្ញា ដែលដឹង ហេតុបច្ច័យធ្វើឱ្យនាមរូបដែលជាអារម្មណ៍នោះប្រាកដឡើង និងជា ហេតុឱ្យលះសេចក្តីសង្ស័យក្នុងឥស្សរនិម្មានវាទ គឺ យល់ឃើញថា មាន អ្នកជាធំ បង្កើតសត្វនិងលោកឡើងបាន អង្គធម៌បានដល់ បញ្ញា ដែល មានបច្ចុប្បន្ន នាមរូបជាអារម្មណ៍ អស់សេចក្តីសង្ស័យថា អ្នកណា បង្កើតយើង ។

៥. មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធរបស់បញ្ញា ដែល ដឹងវិបស្សនូបកិលេសថា មិនមែនផ្លូវ គឺ មិនមែនអារម្មណ៍ ដែលនឹងគប្បី កំណត់ដឹង រូបនាមដែលជាបច្ចុប្បន្នអារម្មណ៍ប៉ុណ្ណោះ ជាអារម្មណ៍ដែល

គប្បីកំណត់យ៉ាងដទៃមិនមែន អង្គធម៌ បានដល់ បញ្ញា ដែលឃើញ នាមរូប ដោយភាពជាត្រៃលក្ខណ៍ ក្នុងសម្មសនញ្ញាណ និងឧទយព្ព-យញ្ញាណ ។

៦. បដិបទាញ្ញាណទស្សនវិសុទ្ធិ សេចក្ដីបរិសុទ្ធរបស់បញ្ញា ដែលដឹងផ្លូវបដិបត្តិ ដែលត្រឹមត្រូវ គឺ ពិចារណានាមរូបដោយភាពជាត្រៃលក្ខណ៍នោះ ជាប់តពីបញ្ញាដែលបរិសុទ្ធដោយមគ្គាមគ្គញ្ញាណ-ទស្សនវិសុទ្ធិហើយ អង្គធម៌ បានដល់ បញ្ញាចេតសិកដែលនៅក្នុងមហាកុសលញ្ញាណសម្បយុត្ត ដែលចូលដល់ ពលវឧទយព្ព្ययញ្ញាណ រហូតដល់ អនុលោមញ្ញាណ ដែលហៅថា សច្ចានុលោមិកញ្ញាណ ។

វិសុទ្ធិទាំង ៦ នេះ ដែលពោលក្នុងគាថាសង្គហ:ទី ៩ នៅជាលោកិយបញ្ញាវិសុទ្ធិ កាលណានិព្ធិទាវិរាគ: គឺ សេចក្ដីនឿយណាយក្នុងសង្ខារធម៌ទាំងនោះកើតឡើង រហូតបង្ហោនយកនិព្ធានជាអារម្មណ៍ ជំនួសនាមរូបដែលកំពុងកើតរលត់នោះ រមែងជាហេតុឱ្យចូលដល់ មគ្គ ផល និព្ធាន ។

៧. ញ្ញាណទស្សនវិសុទ្ធិ សេចក្ដីបរិសុទ្ធរបស់បញ្ញា ដែលមាននិព្ធានជាអារម្មណ៍ និងចូលដល់ការរលត់កិលេស លះសក្កាយទិដ្ឋិ និងវិចិកិច្ឆាបានដាច់ខាត ជាដើម អង្គធម៌ បានដល់ បញ្ញា ដែលនៅក្នុងលោកុត្តរចិត្ត មានសោតាបត្តិមគ្គចិត្ត ជាដើម រហូតដល់អរហត្តផលជាទីបំផុត ។

ចប់ ពោធិបក្ខិយសង្គហ:

ពួកទី ៤ សព្វសខ្គហ:

សព្វសង្គហ សម្តែងការរួបរួមបរមត្ថធម៌ទាំងអស់ គឺ ចិត្ត ចេតសិក រូប និងនិព្វាន ទុកក្នុងធម៌ពួកនេះ មានវចនត្ថ:ថា

សព្វេសំ បរមត្ថធម្មានំ សង្គហោតិ = សព្វសង្គហោ

ប្រែថា ពួកដែលសម្តែងការសង្ត្រោះបរមត្ថធម៌ទាំងអស់ ទើបឈ្មោះថា **សព្វសង្គហ** ។

សេចក្តីថា ព្រះអនុរុទ្ធាចារ្យបានរួបរួមបរមត្ថធម៌ទាំង ៤ មកសង្ត្រោះ ទុកក្នុងពួកធម៌ ដែលនឹងសម្តែងតទៅនេះទាំងអស់ដោយមិនមានសល់ ។

ក្នុងសព្វសង្គហ:នេះ ចែកការសង្ត្រោះបរមត្ថធម៌ទាំងអស់ជា ៥ កង គឺ

១. ខន្ធ, ២. ឧបាទានក្ខន្ធ, ៣. អាយតន:, ៤. ធាតុ, ៥. សច្ច: ។

នឹងសម្តែងតាមលំដាប់តទៅ

១. ខន្ធ

ពាក្យថា **ខន្ធ** ប្រើក្នុងអត្ថច្រើនយ៉ាង គឺ ប្រើក្នុងឋាន:ថា កង គំនរ ពួក ប្រជុំ កំណត់ គុណ ឬ ចំណែក ជាដើម ឧទកខន្ធ = គំនរទឹក , គវក្ខន្ធ = ពួកគោ , ពលខន្ធ = កងពល , បុញ្ញខន្ធ = គំនរបុណ្យ , ឬ សីលខន្ធ = គុណ គឺ សីល , សមាធិខន្ធ = គុណ គឺ សមាធិ , បញ្ញាខន្ធ = គុណ គឺ បញ្ញា តែក្នុងទីនេះ បំណងយកដោយឋាន:ថា កង ។

ក្នុងសព្វងសង្គហៈនេះ "ខន្ធ" ទើបមានសេចក្ដីថា ជាក្រុម ជាកង ដូចព្រះបាលីសម្ដែងទុក តាមន័យព្រះសូត្រថា

រាសដ្ឋេន រាសិអដ្ឋេន ខន្ធោ

ប្រែថា ដែលឈ្មោះថា ខន្ធ ព្រោះអត្ថថា ជាក្រុម ជាកង ភាពជាក្រុមជាកងក្នុងទីនេះ មិនបានសំដៅយកចំនួនរួមគ្នាទេ តែសំដៅយកមានប្រភេទផ្សេងគ្នា ៥ ប្រភេទ ១១ យ៉ាងគឺ

ប្រភេទទី ១ ធម៌ដែលជាអតីត អនាគត បច្ចុប្បន្ន ៣ យ៉ាង ។

ប្រភេទទី ២ ធម៌ដែលជាអជ្ឈត្ត និងពហិទ្ធ ២ ។

ប្រភេទទី ៣ ធម៌ដែលជាឱឡារិក និងសុខុម ២ ។

ប្រភេទទី ៤ ធម៌ដែលជាហីន និងបណីត ២ ។

ប្រភេទទី ៥ ធម៌ដែលជាទូរ និងសន្តិក ២ ។

រួម ៥ ប្រភេទ ១១ យ៉ាង សេចក្ដីថា

ប្រភេទទី ១ ធម៌ដែលឈ្មោះថា ខន្ធ នោះ ត្រូវប្រកបដោយគុណសម្បត្តិ ៣ ប្រការ គឺ មានការកើតឡើង តាំងនៅ និងរលត់ទៅ គឺ ធម៌នោះត្រូវមានសភាពជាអតីត អនាគត និងបច្ចុប្បន្ន បានដល់ ចិត្ត ចេតសិក រូបដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ នោះឯង ។

ប្រភេទទី ២ ធម៌ដែលឈ្មោះថា ខន្ធ ត្រូវជាធម៌ដែលប្រាកដខាងក្នុងខន្ធសន្តាន ជាអជ្ឈត្តក៏មាន និងជាខាងក្រៅ គឺ ពហិទ្ធក៏មាន ។

ប្រភេទទី ៣ ធម៌ដែលឈ្មោះថា ខន្ធ នោះត្រូវមានចំណែកដែលជាធម៌គ្រោតគ្រាត និងល្អិត គឺ ឱឡារិក និងសុខុមបាន (រាប់ដោយជាតិ

បុគ្គល ភូមិ លោកិយ: លោកុត្តរ: សភាវ:) ។

ប្រភេទទី ៤ ជាធម៌ដែលនៅក្នុងឋាន:ថោកទាប និងធម៌ប្រណីត ដែលហៅថា ហីន និងបណីត ។

ប្រភេទទី ៥ ជាធម៌ដែលប្រាកដបានទាំងជិត និងឆ្ងាយ ដែលហៅថា សន្តិក និងទូរ (រូប នាម ដែលកំពុងកើតឡើង ឈ្មោះថា ជិត ដែលនៅមិនទាន់កើត ឬកើតមកហើយ ឈ្មោះថា ឆ្ងាយ) ។

ធម៌ដែលសង្គ្រោះបានទាំង ៥ ប្រភេទនេះ ជាសង្ខារធម៌ទាំងពួង បានដល់ ចិត្ត ចេតសិក និងរូបធម៌ ចំណែកអសង្ខតធម៌ គឺ ព្រះនិព្វាន មានគុណសម្បត្តិមិនគ្រប់ទាំង ៥ ប្រភេទ ១១ យ៉ាង ទើបជាខន្ធមិនបាន ក៏ផុតចាកសភាពជាខន្ធ ហៅថា ខន្ធវិមុត្តិ មានគាថាសង្គហ: សម្តែងចំនួនខន្ធទុកដូច្នេះ គឺ

គាថាសង្គហទី ១០

១០.រូបញ្ច វេទនា សញ្ញា សេសចេតសិកា តថា
វិញ្ញាណមិតិ បញ្ចេតេ បញ្ចក្ខន្ធាតិ ភាសិតា ។

ប្រែថា ធម៌ទាំងឧ្សាយ ៥ នេះ គឺ រូប វេទនា សញ្ញា ចេតសិកដ៏សេស (៥០ ដួង) និងវិញ្ញាណ គឺ ព្រះមានព្រះភាគទ្រង់ត្រាស់ ហៅថា បញ្ចក្ខន្ធ ដូច្នេះ ។

ខន្ធ ៥

១ រូបក្ខន្ធ គឺ កងរូប អង្គធម៌បាន រូប ២៨ ។

២ វេទនាខន្ធ គឺ កងវេទនា អង្គធម៌បានដល់ វេទនាចេតសិក ។

៣ សញ្ញាខន្ធ គឺ កងសញ្ញា អង្គធម៌បានដល់ សញ្ញាចេតសិក ។

៤ សង្ខារខន្ធ គឺ កងសង្ខារ អង្គធម៌បានដល់ ចេតសិកដ៏សេស ៥០។

៥ វិញ្ញាណខន្ធ គឺ កងចិត្ត អង្គធម៌បានដល់ ចិត្តទាំងអស់ ។

វចនត្ថ:របស់ខន្ធន័យម្យ៉ាងទៀតសម្តែងថា

អនេកទុក្ខេហិ ខជ្ជន្តីតិ = ខន្ធា

ប្រែថា ធម៌ទាំងឡាយដែលត្រូវទុក្ខផ្សេងៗ ទំពាស៊ី ដូច្នោះ ធម៌ទាំងនោះ ឈ្មោះថា ខន្ធ សំដៅដល់ ខន្ធ ៥ ដូច្នោះ ខន្ធ ៥ នេះជាធម៌ដែលជាអ្នកកើត ចាស់ ឈឺ ស្លាប់ គឺ ជាតិ ជរា ព្យាធិ មរណ:ជាដើម បើមិនមានខន្ធ ៥ ហើយ ទុក្ខផ្សេងៗ នឹងកើតឡើងមិនបានឡើយ ។

ន័យម្យ៉ាងទៀតសម្តែងថា **សុញ្ញាការំ ធារេន្តីតិ = ខន្ធា**

ប្រែថា ធម៌ទាំងឡាយណា រមែងទ្រទ្រង់ទុកនូវអាការសូន្យចាកអត្ត ដូច្នោះ ធម៌ទាំងឡាយនោះ ឈ្មោះថា **ខន្ធ** ។

ធម្មតាមនុស្សទាំងឡាយក្នុងលោក ច្រើនតែមានការយល់ថា សភាពផ្សេងៗ ដែលប្រាកដឡើងដល់ខ្លួន ដូចជាការធ្វើ ការនិយាយ ការនឹកគិត សេចក្តីសុខសប្បាយ ឬមិនសប្បាយ សេចក្តីត្រេកអរ ខូចចិត្ត រហូតដល់ការប្រែប្រួលផ្សេងៗ របស់រាងកាយជាដើម ទាំងនេះជាខ្លួនយើង ជារបស់យើងស្ទើរតែទាំងអស់ ដែលជាសភាពរបស់សក្កាយទិដ្ឋិ

គឺ ការយល់ឃើញខុសដែលប្រកាន់ជាប់ណែននៅក្នុងនាមរូបខន្ធ ៥ ថាជាខ្លួនយើង ដូច្នោះទើបច្រើនតែសម្គាល់ថា យើងធ្វើ យើងនិយាយ យើងគិត យើងសប្បាយ មិនសប្បាយ យើងរីករាយចិត្ត ខូចចិត្ត យើងក្មេង យើងចាស់ ដូច្នេះជាដើម និងបើអាការទាំងនោះ ប្រាកដដល់អ្នកដទៃ ក៏ច្រើនចាប់ប្រកាន់ថា អ្នកនោះ អ្នកនេះ ឬគេធ្វើ និយាយ គិត សប្បាយ មិនសប្បាយ រីករាយចិត្ត ខូចចិត្ត ទាំងនេះជាដើម រួមសេចក្តីហើយ វត្ថុគ្រប់យ៉ាងក្នុងលោកនេះ មានយើងមានគេ និងរបស់យើង របស់គេ ដែលសុទ្ធតែជាអត្តទិដ្ឋិ គឺ សេចក្តីយល់ឃើញខុសថា មានតួខ្លួនក្នុងទំនងដូចគ្នានឹងសក្កាយទិដ្ឋិនោះឯង សេចក្តីពិតនោះ ការប្រព្រឹត្ត ទៅផ្សេងៗ ទាំងនេះ មិនមែនជាយើង ខ្លួនយើង តែជាអាការប្រព្រឹត្ត ទៅរបស់នាមរូបខន្ធ ៥ ពោលគឺ ការប្រែប្រួលរាងកាយដោយធំធាត់ឡើង ហើយចាស់ សក់ស្កូវ ធ្មេញបាក់ជាដើមក្តី ឬប្រែប្រួលដោយការកម្រើកកាយ និងការនិយាយក្តី ទាំងនេះសេចក្តីពិតជាអាការរបស់រូបក្ខន្ធ និងក្នុងការដឹងខ្លួនថាសប្បាយ មិនសប្បាយ ព្រងើយៗ ទាំងនេះជាសភាពរបស់វេទនាខន្ធ ការចាំវត្ថុផ្សេងៗ បានថាជារបស់យើង របស់អ្នកដទៃ ជាដើម ជាសញ្ញាខន្ធ ការចង់បាន ការក្រោធ ការមានសទ្ធាជ្រះថ្លា ការព្យាយាម ឬការដឹងតាមសេចក្តីពិតជាដើម ទាំងនេះ ជាសង្ខារក្ខន្ធ និងសេចក្តីដឹងក្នុងអារម្មណ៍ផ្សេងៗ មានការឃើញរូប ឮសំឡេង ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វ និងនឹកគិត ជាវិញ្ញាណក្ខន្ធ ។

ដោយហេតុនេះ អ្នកដែលប្រកបដោយសុតមយបញ្ញា ចិន្តាមយ-បញ្ញា និងភាវនាមយបញ្ញាទាំងឡាយ ទើបដឹងថា បណ្តាវត្ថុផ្សេងៗទាំងឡាយដែលមាននៅក្នុងលោកនេះ មិនមានអ្វីដទៃក្រៅអំពីខន្ធ ៥ និងរមែងពិចារណាឃើញថា ខន្ធ ៥ នោះ ជាទីតាំងនៃទុក្ខ មានសភាពដែលមិនមានសារៈ ដែលគប្បីប្រកាន់ទុក មានអាការប្រព្រឹត្តទៅដោយភាពជាត្រៃលក្ខណ៍ គឺ អនិច្ចំ ទុក្ខំ អនត្តា ការដឹងដល់អាការប្រព្រឹត្តទៅរបស់នាមរូបខន្ធ ៥ នឹងដឹងច្បាស់ត្រឹមណា ត្រូវអាស្រ័យកម្លាំងបញ្ញាដោយលំដាប់ ។

ទើបឃើញបានថា ការដែលព្រះពុទ្ធអង្គទ្រង់ចាត់ប្រភេទរបស់បរមត្ថធម៌ដោយភាពជា ខន្ធ ថាមានយ៉ាងច្រើនត្រឹម ៥ ប្រការនោះ ក៏ព្រោះអាស្រ័យចំណែកធម៌ដែលសង្គ្រោះចូលគ្នាបាន គឺ រូបទាំងអស់ រាប់ជា រូបក្ខន្ធ វេទនា គឺ ការដឹងខ្លួនក្នុងការសោយអារម្មណ៍ផ្សេងៗ ដោយសុខក្តី ទុក្ខក្តី ឬព្រងើយៗ ក្តី ទាំងនេះរាប់ថាជា វេទនាខន្ធ ការចាំបានក្នុងអារម្មណ៍ផ្សេងៗ ក្នុងកាមសញ្ញាក្តី រូបសញ្ញាក្តី ឬអរូបសញ្ញាក្តី ទាំងនេះរាប់ជា សញ្ញាខន្ធ ចំណែកធម៌ គឺ ចេតសិកធម៌ដទៃៗ ដែលក្រៅពីវេទនាចេតសិក និងសញ្ញាចេតសិក ដែលតាក់តែងឱ្យកើតការធ្វើ ការនិយាយ ការគិត សង្គ្រោះទុកក្នុង សង្ខារក្ខន្ធ ចិត្តទាំងអស់ គឺ វិញ្ញាណដែលជាធម្មជាតិដឹងសព្វារម្មណ៍ទាំងពួង រាប់ថាជា វិញ្ញាណក្ខន្ធ ជាការសង្គ្រោះសង្ខតធម៌បានជា ខន្ធ ៥ ចំណែកអសង្ខតធម៌ គឺ ព្រះនិព្វានជាខន្ធវិមុត្តិ ដោយហេតុផលដូចពោលហើយ ។

ន័យម្យ៉ាងទៀត ខន្ធ ៥ ព្រោះបណ្តាវត្ថុដែលសត្វទាំងឡាយ ប្រកាន់ថា ជាតួខ្លួន ជារបស់ខ្លួននោះ ក៏មានខន្ធ ៥ ប្រការនេះ ជាវត្ថុនៃការប្រកាន់ ពោលគឺ ប្រកាន់រូបថាជាយើង ជារបស់យើង ប្រកាន់វេទនាថាជាយើង ជារបស់យើង ប្រកាន់សញ្ញាថាជាយើង ជារបស់យើង ប្រកាន់សង្ខារថាជាយើង ជារបស់យើង ប្រកាន់វិញ្ញាណថាជាយើង ជារបស់យើង ។

ដោយហេតុនេះ ទើបចាត់ថា មានខន្ធ ៥ នេះជាយ៉ាងក្រៃលែង ។

២. ឧបាទានក្ខន្ធ

ឧបាទានក្ខន្ធ សំដៅដល់ ខន្ធដែលតណ្ហានិងទិដ្ឋិចាប់ប្រកាន់ទុក ដោយធ្វើឱ្យជាអារម្មណ៍ មានវចនត្ថៈថា

ឧបាទានានំ គោចរា ខន្ធា = ឧបាទានក្ខន្ធា

ប្រែថា ខន្ធដែលជាអារម្មណ៍របស់ឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ មានគាថាសង្គហៈសម្តែងថា

គាថាសង្គហៈទី ១១

១១. បញ្ចុបាទានក្ខន្ធាតិ តថា តេភូមកា មតា
ភេទាភាវេន និព្ពានំ ខន្ធសង្គហនិស្សដំ ។

ប្រែថា បណ្ឌិតគប្បីជ្រាបថា ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ គឺ ឧបាទានក្ខន្ធ ៥ ព្រះនិព្វាន គឺ ធម៌ដែលរួចផុតចាកការរាប់ថាជាខន្ធ ព្រោះមិនមានសេចក្តីផ្សេងគ្នា (ទាំងប្រភេទនិងកាល) ។

សេចក្តីថា សត្វទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ គឺ កាមភូមិ រូបភូមិ និងអរូបភូមិនោះ ដោយច្រើននៅមិនទាន់បានលះ សក្កាយទិដ្ឋិ ដែលជាតួអត្តវាទុបាទាន ប្រកាន់មាំថា ជាតួខ្លួន មនុស្ស សត្ត ជាយើង ជាគេ នៅប្រកាន់មាំដូច្នោះតទៅ នេះក៏គឺ អត្តវាទុបាទាន ដែលមានសេចក្តីប្រកាន់មាំនៅក្នុងខន្ធ ៥ ហើយខន្ធ ៥ ដែលជាអារម្មណ៍ របស់ឧបាទាននោះ ឈ្មោះថា ឧបាទានក្ខន្ធ ចំណែកព្រះនិព្វាននោះ មិនមានសេចក្តីផ្សេងគ្នាដោយធម៌ ៥ ប្រភេទ ១១ យ៉ាងនៃភាពជាខន្ធ ទើបផុតចាកភាពជាខន្ធ ហៅថា **ខន្ធវិមុត្តិ** ។

ឧបាទានក្ខន្ធ ៥

១. រូបូបាទានក្ខន្ធ គឺ កងរូបដែលជាអារម្មណ៍របស់ឧបាទាន អង្គធម៌ បានដល់ រូប ២៨ ។

២. វេទនូបាទានក្ខន្ធ គឺ កងវេទនា ដែលជាអារម្មណ៍របស់ឧបាទាន អង្គធម៌ បានដល់ វេទនាចេតសិក នៅក្នុងលោកិយចិត្ត ៨១ ។

៣. សញ្ញូបាទានក្ខន្ធ គឺ កងសញ្ញា ដែលជាអារម្មណ៍របស់ឧបាទាន អង្គធម៌ បានដល់ សញ្ញាចេតសិក នៅក្នុងលោកិយចិត្ត ៨១ ។

៤. សង្ខារូបាទានក្ខន្ធ គឺ កងសង្ខារ ដែលជាអារម្មណ៍របស់ឧបាទាន អង្គធម៌ បានដល់ ចេតសិក ៥០ ដ៏សេស (រៀរ វេទនា សញ្ញា) នៅក្នុងលោកិយចិត្ត ៨១ ។

៥. វិញ្ញាណូបាទានក្ខន្ធ គឺ កងចិត្តជាអារម្មណ៍របស់ឧបាទានអង្គធម៌ បានដល់ លោកិយចិត្ត ៨១ ។

ព្រះពុទ្ធអង្គទ្រង់សម្តែងខន្ធ ៥ ហើយទ្រង់សម្តែងឧបាទានក្ខន្ធ ៥ ដដែលទៀត ដែលមានចំនួនខន្ធ ៥ ប្រការស្មើគ្នា តែដើម្បីសម្តែងសេចក្តីផ្សេងគ្នា ដែលពោលដល់ខន្ធ ៥ ដោយភាពជាវិសុទ្ធិខន្ធ មិនបានលាយគ្នាជាមួយអាសវ: ទាំងមិនបានជាអារម្មណ៍របស់ឧបាទានដែលបានដល់ខន្ធ ៥ របស់ព្រះអរហន្តទាំងឡាយ មិនបានជាអារម្មណ៍ដល់ឧបាទានរបស់លោកដោយប្រការណាឡើយ គង់សល់ត្រឹមតែជាផលរបស់អតីតឧបាទានរបស់លោកប៉ុណ្ណោះ តែកាលពោលដល់ខន្ធ ៥ របស់បុថុជ្ជននិងរបស់ព្រះសេក្ខបុគ្គលហើយ រមែងប្រព្រឹត្តទៅជាមួយអាសវ: និងជាទីតាំងរបស់ឧបាទានបាន តាមសមគួរដល់ទ្វារនិងបុគ្គល ព្រះអង្គទើបទ្រង់សម្តែងឧបាទានក្ខន្ធ ៥ ដើម្បីជាប្រយោជន៍នៃការចម្រើនវិបស្សនាភាវនាដើម្បីលះកិលេស ព្រោះអ្នកចម្រើនវិបស្សនាកម្មដ្ឋានត្រូវកំណត់នាម រូប ខន្ធ ៥ ដែលជាទីអាស្រ័យរបស់កិលេសមានទិដ្ឋិកិលេសជាដើម ឱ្យដឹងសភាវធម៌តាមសេចក្តីពិតរបស់ខន្ធ ៥ ដែលជាលោកិយារម្មណ៍នោះ នឹងមិនបានធ្លាក់ទៅជាអារម្មណ៍របស់តណ្ហា ឧបាទាន ព្រះយោគាវចរត្រូវមានសេចក្តីសង្រ្ទមនៅក្នុងនាមរូបខន្ធ ៥ នោះដោយសតិសម្បជញ្ញ នាមរូបខន្ធ ៥ នោះ ទើបមិនជាទីអាស្រ័យរបស់ឧបាទានទាំងពួងបាន តែបើមិនមានការសង្រ្ទមឥន្ទ្រិយ ហើយ រមែងភ្លាត់សតិ ខន្ធ ៥ ក៏ធ្លាក់ទៅក្នុងអារម្មណ៍របស់ឧបាទានបាន

យ៉ាងរហ័ស ។

អត្តវាទុបាទាននេះ រមែងអាស្រ័យកើតក្នុងរូបនាមខន្ធ ៥ ស្ទើរតែពោលបានថា មាននៅជាប្រចាំ ចំណែកឧបាទានដទៃ មានកាមុបាទាន ទិដ្ឋុបាទាន និងសីលព្វតុបាទាន រមែងមានឱកាសកើតឡើងបានក្នុងលំដាប់តៗ មក ទើបពោលបានថា ខន្ធ ៥ ដែលមានអាសវ: និងជាទីតាំងរបស់ឧបាទានទាំងនោះ ជាឧបាទានក្ខន្ធ ៥ ទៅ ។

ចំណែកខន្ធ ៥ របស់ព្រះអរហន្តទាំងឡាយដែលជាសឧបាទិសេសនិព្វាននោះ មិនមានអាសវ:អាស្រ័យ ទាំងមិនជាបច្ច័យដល់ឧបាទានទាំងពួង របស់លោកទៀតផង ដោយហេតុនេះ ព្រះអង្គទើបទ្រង់សម្តែងខន្ធ ៥ និងឧបាទានក្ខន្ធ ៥ ទុកដោយសេចក្តីប្លែកពីគ្នាដូច្នេះ ។

៣. អាយតន:

ពាក្យថា **អាយតន** នោះ មានអត្ថសម្តែងទុកច្រើនប្រការ

សម្តែងអត្ថរបស់អាយតន: ៥ ប្រការ គឺ

១. សញ្ជាតិទេសដ្ឋ ជាទីកើត សេចក្តីថា ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ឈ្មោះថា អាយតន: ព្រោះជាទីកើតនៃវីថិចិត្ត រឿយៗ គឺ បាបបុណ្យទាំងឡាយ ត្រូវអាស្រ័យកើតពីអាយតន:នេះឯង ។

២. និវាសដ្ឋ ជាទីនៅ សេចក្តីថា ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ដែលជាអាយតន:ខាងក្នុងនេះ រមែងជាទីអាស្រ័យឱ្យចិត្តចេតសិកតាំងនៅដើម្បីទទួលដឹងអារម្មណ៍ ដែលមកប៉ះខ្ទប់ទ្វារនោះ។

ហាក់ដូចជាទីនៅអាស្រ័យរបស់វីថិចិត្ត ទើបហៅថា អាយតន: ដែលជាការពោលដោយអម វីថិចិត្តមិនបាននៅក្នុងអាយតន: តែកាលមានហេតុបច្ច័យព្រមព្រៀងគ្នាហើយ វីថិចិត្តទាំងនោះក៏តាំងនៅបាន ដូចរគាំងនិងសំឡេងរគាំង រមែងពោលមិនបានថា មានសំឡេងរគាំងនៅក្នុងតួរគាំងនោះ តែកាលបុគ្គលវាយរគាំងសំឡេងក៏ប្រាកដឡើង ហាក់ដូចជាសំឡេងនោះនៅក្នុងរគាំង សេចក្តីនេះយ៉ាងណា វីថិចិត្តនិងអាយតន: ខាងក្នុងក៏ដូចគ្នា បើមានហេតុបច្ច័យបរិបូណ៌ ក៏ដូចវីថិចិត្តទាំងនោះតាំងនៅក្នុងអជ្ឈត្តិកាយតន:ទាំងនោះ ។

៣. អាការដ្ឋ កើតដល់សត្វទាំងឡាយ សេចក្តីថា ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត រមែងមិនកើតឡើងត្រង់ទីដទៃ ក្រៅពីកើតឡើងនៅក្នុងសត្វ មិនរើសភេទ រើសភូមិ ទាំងអបាយសត្វ មនុស្ស ទេវតានិងព្រហ្ម រមែងមានអាយតន:កើតបានទូទៅទាំងអស់ (រៀរអសញ្ញ-សត្តព្រហ្ម) ។

៤. សមោសរណដ្ឋ ជាទីប្រជុំ សេចក្តីថា អាយតន:ខាងក្នុងនិងអាយតន:ខាងក្រៅមកប្រជុំគ្នា ពោលគឺ រូបាយតន: ជាដើម រហូតដល់ធម្មាយតន: រមែងត្រូវមកប្រជុំគ្នាត្រង់ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ទើបហៅថា អាយតន: ព្រោះជាទីប្រជុំនៃទ្វារនិងអារម្មណ៍ ដូចជាទីប្រជុំនៃវីថិចិត្តទាំងឡាយផង បើអាយតន:មិនមកប្រជុំគ្នា វីថិចិត្តទាំងនោះនឹងមានមិនបាន (ដូចជា **ចក្ខា + រូបា + មនា + ធម្មា**) ។

៥. ករណដ្ឋ ជាហេតុឱ្យកើត សេចក្ដីថា បើមិនមានអាយតន:ខាងក្នុងនិងអាយតន:ខាងក្រៅហើយ រីឋិចិត្តទាំងឡាយក៏កើតមិនបាន ព្រោះធម្មតារីឋិចិត្តនឹងកើតឡើងបាន ត្រូវអាស្រ័យអាយតន:ខាងក្នុងនិងអាយតន:ខាងក្រៅជាហេតុឱ្យកើតឡើង ។

ន័យម្យ៉ាងទៀត ក្នុងសម្មោហវិនោទនីអដ្ឋកថាវិភង្គបករណ៍ សម្ដែងសេចក្ដីរបស់អាយតន:ដែលមិនផ្សេងគ្នាទុក ៣ ប្រការ គឺ

១. ព្រោះជាទីខ្ទល់ខ្ជាយ ។

២. ព្រោះជាទីផ្សាយទៅនូវធម៌ គឺ ចិត្តនិងចេតសិក ដែលជាទីកើត ។

៣. ព្រោះជាអ្នកនាំទៅកាន់សង្សារទុក្ខដែលយូរអង្វែងមកហើយ ហៅថា អាយតន: ព្រោះជាទីខ្ទល់ខ្ជាយ មានវចនត្ថ:ក្នុងបរមត្ថទីបនីដីកា សម្ដែងថា

អាយតន្តិ អត្តនោ ផលុប្បត្តិយា កុសំ ឧស្សហន្តា វិយ ហោន្តីតិ = អាយតនានិ

ប្រែថា ធម៌ទាំងឡាយណាមានសភាពហាក់ដូចជាមានសេចក្ដីព្យាយាមក្រៃលែងដើម្បីនឹងញ៉ាំងផលរបស់ខ្លួនឱ្យកើតឡើង ដូច្នោះធម៌ទាំងឡាយនោះ ឈ្មោះថា អាយតន: ។

សេចក្ដីថា ចក្ខ្វាយតន: និងរូបាយតន: ទាំង ២ ជាហេតុឱ្យកើតការឃើញ គឺ ចិត្តនិងចេតសិក ការឃើញទើបជាផលរបស់អាយតន: ទាំង ២ ដែលមានចក្ខុ និងរូបារម្មណ៍ ជាអ្នកខ្ទល់ខ្ជាយក្នុងកិច្ចឱ្យមាន

ការសោយអារម្មណ៍របស់ខ្លួនឡើង ចក្ខុនិងរូប ទើបឈ្មោះថា អាយតនៈ ព្រោះជាទីខ្ជល់ខ្ជាយ ។

ហៅថា អាយតនៈ ព្រោះជាទីផ្សាយទៅនូវធម៌ គឺ ចិត្ត និងចេតសិក ដែលជាទីកើត មានវចនត្ថៈសម្តែងថា

អាយសង្ខាតេ ចិត្តចេតសិកធម្មេ ឯតានិ តនោន្តិ វិត្ថារេន្តីតិ = អាយតនានិ

ប្រែថា ចក្ខុបសាទនិងរូបារម្មណ៍ជាដើមទាំងនេះ រមែងធ្វើចិត្តនិងចេតសិកធម៌ ដែលហៅថា អាយៈ ឱ្យផ្សាយទូលំទូលាយចម្រើនឡើង ដូច្នោះចក្ខុបសាទ និងរូបារម្មណ៍ជាដើមទាំងនេះ ឈ្មោះថា អាយតនៈ ។

ដែលហៅថា អាយតនៈ ព្រោះជាអ្នកនាំទៅកាន់សង្សារទុក្ខដែលយូរអង្វែងមកហើយ សេចក្ដីថា អាយតនៈទាំងនេះនាំទៅ គឺ នាំទៅតែម្យ៉ាង កាន់សង្សារទុក្ខដែលយូរអង្វែងមកពីអតីត ដែលកន្លងទៅក្នុងសង្សាររកទីបំផុតខាងដើម និងទីបំផុតខាងចុងមិនបាន គ្រប់ពេលវេលាមិនត្រឡប់ថយក្រោយ ដែលយើងដឹងដោយទូទៅថា ជាការវិលវល់កើតស្លាប់របស់សត្វទាំងឡាយ មែនពិត គឺ ការនាំទៅរបស់អាយតនៈក្នុងសង្សារទុក្ខដែលយូរអង្វែងនោះឯង ។

អាយតនៈដែលមានសេចក្ដីផ្សេងគ្នា ព្រះពុទ្ធអង្គទ្រង់សម្តែងផ្សេងគ្នាទុក ១២ យ៉ាង មានគាថាសង្គហៈ សម្តែងទុកដូច្នេះ

គាថាសង្គហៈទី ១២

១២. ទ្វារារម្មណភេទេន ភវន្តាយតនានិ ច
ទ្វារាលម្ពតទុប្បន្ន- បវិយាយេន ធាតុយោ ។

ប្រែថា អាយតនទាំងឡាយ ១២ ដោយប្រភេទនៃទ្វារ និងអារម្មណ៍ ចំណែកធាតុទាំងឡាយមាន ១៨ យ៉ាង តាមលំដាប់នៃវិញ្ញាណដែលកើតឡើង ព្រោះអាស្រ័យទ្វារ និងអារម្មណ៍ទាំងនោះ ។

សេចក្តីថា អាយតន: ដោយប្រភេទនៃទ្វារមាន ៦ ជាអាយតន: ខាងក្នុង ហៅថា អជ្ឈត្តិកាយតន: ពោលដោយប្រភេទនៃអារម្មណ៍ក៏មាន ៦ ជាអាយតន:ខាងក្រៅ ហៅថា ពហិទ្ធាយតន: រួមអាយតន:មាន ១២ ។

អាយតន: ១២

១. ចក្ខ្វាយតន ចក្ខុ ឈ្មោះថា អាយតន: ព្រោះជាហេតុឱ្យចិត្ត ចេតសិកកើត អង្គធម៌ បានដល់ ចក្ខុបសាទរូប ។

២. សោតាយតន សោត: ឈ្មោះថា អាយតន: ព្រោះជាហេតុឱ្យចិត្ត ចេតសិកកើត អង្គធម៌ បានដល់ សោតបសាទរូប ។

៣. ឃានាយតន ឃាន: ឈ្មោះថា អាយតន: ព្រោះជាហេតុឱ្យចិត្ត ចេតសិកកើត អង្គធម៌ បានដល់ ឃានបសាទរូប ។

៤. ជិវ្ហាយតន ជិវ្ហា ឈ្មោះថា អាយតន: ព្រោះជាហេតុឱ្យចិត្ត ចេតសិកកើត អង្គធម៌ បានដល់ ជិវ្ហាបសាទរូប ។

៥. កាយាយតន កាយ: ឈ្មោះថា អាយតន: ព្រោះជាហេតុឱ្យចិត្ត

ចេតសិកកើត អង្គធម៌ បានដល់ កាយបសាទរូប ។

៦. រូបាយតន រូបារម្មណ៍ ឈ្មោះថា អាយតនៈ ព្រោះជាហេតុឱ្យ ចិត្ត ចេតសិកកើត អង្គធម៌ បានដល់ វណ្ណរូប ។

៧. សទ្ទាយតន សទ្ទារម្មណ៍ ឈ្មោះថា អាយតនៈ ព្រោះជាហេតុ ឱ្យចិត្ត ចេតសិកកើត អង្គធម៌ បានដល់ សទ្ទរូប ។

៨. គន្ធាយតន គន្ធារម្មណ៍ ឈ្មោះថា អាយតនៈ ព្រោះជាហេតុឱ្យ ចិត្ត ចេតសិកកើត អង្គធម៌ បានដល់ គន្ធរូប ។

៩. រសាយតន រសារម្មណ៍ ឈ្មោះថា អាយតនៈ ព្រោះជាហេតុឱ្យ ចិត្ត ចេតសិកកើត អង្គធម៌ បានដល់ រសរូប ។

១០. ផោដ្ឋព្វាយតន ផោដ្ឋព្វារម្មណ៍ ឈ្មោះថា អាយតនៈ ព្រោះ ជាហេតុឱ្យចិត្ត ចេតសិកកើត អង្គធម៌ បានដល់ បឋវីរូប តេជោរូប និងវាយោរូប ។

១១. មនាយតន ចិត្ត ឈ្មោះថា អាយតនៈ ព្រោះជាហេតុឱ្យ ចេតសិកកើត អង្គធម៌ បានដល់ ចិត្តទាំងអស់ ។

១២. ធម្មាយតន ធម៌ ឈ្មោះថា អាយតនៈ ព្រោះជាហេតុឱ្យចិត្ត ចេតសិកកើត អង្គធម៌ បានដល់ សុខុមរូប ១៦ ចេតសិក ៥២ និព្វាន ។

អាយតនៈដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ទុក ១២ យ៉ាង ព្រោះទ្រង់ កំណត់ដល់ទ្វារដែលជាទីកើត និងអារម្មណ៍ ដែលជាទីដឹងនៃវិញ្ញាណ ៦ កាលចែកចេញជា អាយតនៈខាងក្នុង និងអាយតនៈខាងក្រៅហើយ នីមួយៗ បាន ៦ ដូច្នេះ គឺ

អាយតនៈខាងក្នុង ៦	**អាយតនៈខាងក្រៅ ៦**
ចក្ខាយតនៈ	រូបាយតនៈ
សោតាយតនៈ	សទ្ទាយតនៈ
ឃានាយតនៈ	គន្ធាយតនៈ
ជិវ្ហាយតនៈ	រសាយតនៈ
កាយាយតនៈ	ផោដ្ឋព្វាយតនៈ
មនាយតនៈ	ធម្មាយតនៈ

ការចែកអាយតនៈ ១២ ដែលជាហេតុឱ្យចិត្ត ចេតសិក កើតឡើងជាអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅនោះ អាស្រ័យអាយតនៈដែលកើតឡើងក្នុងខន្ធសន្តានរបស់សត្ត្ব ដែលជាប់មកពីកម្មរបស់ខ្លួនដោយត្រង់ ចាត់ជាអាយតនៈខាងក្នុង បានដល់ អជ្ឈត្តិកាយតនៈ ៦ ចំណែកអារម្មណ៍ ដូចជាវត្ថុដែលបង្ហោនចូលមករកអាយតនៈ ចូលមកកាន់ខ្លួនឱ្យកើតការដឹង ការឃើញឡើង ដូច្នេះអារម្មណ៍ដែលហាក់បីដូចជាត្រូវកាន់យក ទើបចាត់ជាអាយតនៈខាងក្រៅ បានដល់ ពហិទ្ធា-យតនៈ ៦ ។

ន័យម្យ៉ាងទៀត ដែលឈ្មោះថា ជាអាយតនៈខាងក្នុង ព្រោះកើតនៅជាប្រចាំក្នុងខន្ធសន្តានរបស់សត្ត្ব គឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត រមែងកើតនៅជាប្រចាំយ៉ាងជិតស្និត ចំណែកដែលឈ្មោះថាអាយតនៈខាងក្រៅ ព្រោះមិនបានកើតនៅជាប្រចាំ និងអាយតនៈ

ខាងក្រៅខ្លះមិនមានប្រាកដនៅក្នុងខន្ធសន្តាន ដូចជាព្រះនិព្វានដែលជាធម្មាយតន: ។

អាយតន:ទាំង ១២ កាលពោលដោយភាពជាអារម្មណ៍ របស់បញ្ញាក្នុងវិបស្សនាភូមិ ដោយសង្ខេបហើយ ក្នុងសម្មោហវិនោទនីអដ្ឋកថា ចាត់មនាយតន: និងធម្មាយតន: សង្គ្រោះចូលក្នុង នាមាយតន: អាយតន:ដ៏សេសទាំង ១0 នោះ សង្គ្រោះចូលក្នុង រូបាយតន: ។

៤. ធាតុ

ធាតុ គឺ ធម៌ដែលទ្រទ្រង់សភាវលក្ខណៈរបស់ខ្លួន ដោយមិនវិបរិតប្រែប្រួល មានវចនត្ថ:ថា

អត្តនោ សភាវំ ធារេតីតិ = ធាតុ

ប្រែថា ធម្មជាតិណាទ្រទ្រង់ទុកនូវសភាវ:របស់ខ្លួន ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **ធាតុ** ។

ធាតុនៅមានអត្ថដទៃៗ ច្រើនប្រការទៀត ដូចជាអដ្ឋកថា ថា ដែលសត្វទ្រទ្រង់ទុក គឺ ធាតុទាំងឡាយ ដែលសត្វទាំងពួងត្រូវទ្រទ្រង់ទុក ឬទទួលទុកដូចជាសម្ភារ:ដែលត្រូវមនុស្សលីសែងទទួលទុកដូច្នោះ និងព្រោះអត្ថថា ជាការចាត់ចែង សេចក្ដីថា ធាតុទាំងឡាយត្រឹមតែជាការចាត់ចែងទុក្ខទុកប៉ុណ្ណោះ ឬជាតួហេតុ ដែលធ្វើឱ្យសត្វប្រព្រឹត្តទៅក្នុងសង្សារទុក្ខផ្សេងៗ រឿយៗ ឬធាតុទាំងនេះ ជាទីតាំង គឺ ទីស្ថិតនៅនៃសង្សារទុក្ខ ដែលសត្វបានធ្វើទុក្ខផ្សេងៗ ដូចជាចក្ខុ សោត: ជាដើម

រួមសេចក្ដីថា ដែលឈ្មោះថា ធាតុ ព្រោះជាធម្មជាតិដែលទ្រទ្រង់សភាវ លក្ខណៈរបស់ខ្លួន ដោយមិនប្រែប្រួលផ្លាស់ប្តូរ ឬធម្មជាតិដែលទ្រទ្រង់ ទុក ឬចាត់ចែងទុកជាដើម ធាតុទាំងនេះ ដូចអត្តារបស់ពួកតិរ្ថិយ ដែល យល់ឃើញថា ជាតួខ្លួន តែនឹងថាមិនមានពិតដោយសភាវៈក៏ទេ កាល កំណត់តាមសភាវលក្ខណៈ ដែលជាចំណែកផ្សេងៗ របស់រាងកាយ ហើយ រមែងមានឈ្មោះថា ធាតុ ដូចជាចំណែកផ្សេងៗ របស់អត្តភាព ដែលហៅថា ខន្ធ ៥ ក៏មានឈ្មោះថា ធាតុ បានដូចគ្នា ។

ន័យម្យ៉ាងទៀត ពាក្យថា ធាតុ ជាឈ្មោះរបស់វត្ថុដែលប្រាសចាក ជីវៈប៉ុណ្ណោះ ពោលគឺ ក្រៅពីធាតុ នឹងបដិសេធភាពជាសត្វហើយ ថែម ទាំងបដិសេធ ជីវិត ទៀតផង ដូចវចនត្ថៈ ដែលសម្ដែងថា

និស្សត្តនិជ្ជីវដ្ឋេន = ធាតុ

ប្រែថា ធាតុមិនមែនសត្វ មិនមែនជីវៈ តែជាសភាវធម៌ប៉ុណ្ណោះ។

ដូច្នោះព្រះពុទ្ធអង្គទើបទ្រង់សម្ដែងថា ចក្ខុបសាទ ជាដើម ឈ្មោះថា ធាតុ ព្រោះមានសេចក្ដីថា មិនមែនសត្វ មិនមែនជីវៈ សូម្បីមហាភូតរូប ឧបាទាយរូបដទៃៗ រហូតដល់ ចិត្ត ចេតសិក និងនិព្វាន ក៏ចាត់ជា ធាតុ ទាំងអស់ ដោយហេតុនេះ ធាតុ ទើបមានឈ្មោះផ្សេងៗ សេចក្ដីថា ដូចជា អាភាធាតុ សុភធាតុ អាកាសានញ្ចាយតនធាតុ នេវសញ្ញានា-សញ្ញាយតនធាតុ សញ្ញាវេទយិតនិរោធធាតុ កាមធាតុ ព្យាបាទធាតុ វិហិង្សធាតុ នេក្ខម្មធាតុ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ សង្ខតធាតុ អសង្ខតធាតុ និងដទៃៗ យ៉ាងច្រើនទៀត ។

ព្រះពុទ្ធអង្គទ្រង់សង្ខេបធាតុទាំងអស់ សម្តែងទុកក្នុងព្រះសូត្រ ត្រាស់ថា ធាតុមាន ៦ យ៉ាង បានដល់

១. បឋវីធាតុ = ធាតុដី, ២. អាបោធាតុ = ធាតុទឹក, ៣. តេជោធាតុ = ធាតុភ្លើង, ៤. វាយោធាតុ = ធាតុខ្យល់, ៥. អាកាសធាតុ = លម្ហូទទេ, ៦. វិញ្ញាណធាតុ = ធាតុដឹង ។

ដោយអត្ថរបស់ធាតុទាំង ៦ នេះ មានសេចក្តីថា បឋវីធាតុ ជាធាតុរឹង អាបោធាតុ ជាធាតុហូរ តេជោធាតុ ជាធាតុក្តៅ វាយោធាតុ ជាធាតុតឹងញ័រ អាកាសធាតុ ជាលម្ហូទទេដែលប៉ះមិនបាន វិញ្ញាណធាតុ ជាធាតុដឹង សំដៅយក ដែលនឹងសម្តែងចំពោះធាតុដែលទាក់ទងគ្នានឹងសន្តានរបស់សត្វដោយសង្ខេប ដើម្បីឱ្យដឹងថា ជាសភាវ: ជារបស់សោះសូន្យ ប្រាសចាកភាពជាសត្ត ។

ចំណែកដែលព្រះពុទ្ធអង្គទ្រង់សម្តែងទុកក្នុងព្រះអភិធម្ម សម្តែងធាតុ មានចំនួន ១៨ ធាតុ បំណងសម្តែងសភាវ:ដែលជាប់ទាក់ទងក្នុងសន្តានរបស់សត្ត ដោយអាស្រ័យទ្វារ អារម្មណ៍ និងវិញ្ញាណ នីមួយៗ មាន ៦ ពួក ។

ធាតុ ១៨

១. ចក្ខុធាតុ ចក្ខុ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវភាពថ្លា ដែលនឹងទទួលរូបារម្មណ៍ មកប៉ះខ្ជប់បាន អង្គធម៌ បានដល់ ចក្ខុបសាទ រូប ។

២. សោតធាតុ សោត: ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវភាពថ្លាដែលនឹងទទួលសទ្ទារម្មណ៍ មកប៉ះខ្ទប់បាន អង្គធម៌ បានដល់ សោតបសាទរូប ។

៣. ឃានធាតុ ឃាន: ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវភាពថ្លាដែលនឹងទទួលគន្ធារម្មណ៍ មកប៉ះខ្ទប់បាន អង្គធម៌ បានដល់ ឃានបសាទរូប ។

៤. ជិវ្ហាធាតុ ជិវ្ហា ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវភាពថ្លា ដែលនឹងទទួលរសារម្មណ៍ មកប៉ះខ្ទប់បាន អង្គធម៌ បានដល់ ជិវ្ហាបសាទរូប ។

៥. កាយធាតុ កាយ: ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវភាពថ្លាដែលនឹងទទួលផោដ្ឋព្វារម្មណ៍ មកប៉ះខ្ទប់បាន អង្គធម៌ បានដល់ កាយបសាទរូប ។

៦. រូបធាតុ រូបារម្មណ៍ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការប៉ះខ្ទប់ចក្ខុបសាទបាន អង្គធម៌ បានដល់ វណ្ណរូប គឺ ពណ៌ផ្សេងៗ ។

៧. សទ្ទធាតុ សទ្ទារម្មណ៍ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការប៉ះខ្ទប់សោតបសាទបាន អង្គធម៌ បានដល់ សទ្ទរូប គឺ សំឡេងផ្សេងៗ ។

៨. គន្ធធាតុ គន្ធារម្មណ៍ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការប៉ះខ្ទប់ឃានបសាទ អង្គធម៌ បានដល់ គន្ធរូប គឺ ក្លិនផ្សេងៗ ។

៩. រសធាតុ រសារម្មណ៍ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការប៉ះខ្ទប់ជិវ្ហាបសាទ អង្គធម៌ បានដល់ រសរូប គឺ រសផ្សេងៗ ។

១០. ផោដ្ឋព្វធាតុ ផោដ្ឋព្វារម្មណ៍ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការប៉ះខ្ទប់កាយបសាទ អង្គធម៌ បានដល់ បឋវីរូប តេជោរូប និងវាយោរូប គឺ សម្ផស្សផ្សេងៗ ។

១១. ចក្ខុវិញ្ញាណធាតុ ចក្ខុវិញ្ញាណ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការឃើញរូបារម្មណ៍ អង្គធម៌ បានដល់ ចក្ខុវិញ្ញាណចិត្ត ២ ។

១២. សោតវិញ្ញាណធាតុ សោតវិញ្ញាណ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការឮ អង្គធម៌ បានដល់ សោតវិញ្ញាណចិត្ត ២ ។

១៣. ឃានវិញ្ញាណធាតុ ឃានវិញ្ញាណ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការដឹងក្លិន អង្គធម៌ បានដល់ ឃានវិញ្ញាណចិត្ត ២ ។

១៤. ជិវ្ហាវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការដឹងរស អង្គធម៌ បានដល់ ជិវ្ហាវិញ្ញាណចិត្ត ២ ។

១៥. កាយវិញ្ញាណធាតុ កាយវិញ្ញាណ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការដឹងសម្ផស្ស អង្គធម៌ បានដល់ កាយវិញ្ញាណចិត្ត ២ ។

១៦. មនោធាតុ ចិត្ត ៣ ដួង ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការដឹងបញ្ចារម្មណ៍ អង្គធម៌ បានដល់ បញ្ចទ្វារាវជ្ជន: ១ សម្បដិច្ឆន: ២។

១៧. មនោវិញ្ញាណធាតុ ចិត្ត ៧៦ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវការដឹងអារម្មណ៍ អង្គធម៌ បានដល់ ចិត្ត ៧៦ ដួង (រៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣) ។

១៨. ធម្មធាតុ សភាវធម៌ ៦៩ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវ សភាវលក្ខណៈរបស់ខ្លួនៗ អង្គធម៌ បានដល់ ចេតសិក ៥២ សុខុមរូប ១៦ និព្វាន ១ ។

ធាតុទាំង ១៨ នេះ កាលចែកចេញតាមទ្វារ អារម្មណ៍ និង វិញ្ញាណនីមួយៗ បាន ៦ ដូច្នេះ គឺ

ទ្វារ	អារម្មណ៍	វិញ្ញាណ
ចក្ខុធាតុ	រូបធាតុ	ចក្ខុវិញ្ញាណធាតុ
សោតធាតុ	សទ្ទធាតុ	សោតវិញ្ញាណធាតុ
ឃានធាតុ	គន្ធធាតុ	ឃានវិញ្ញាណធាតុ
ជិវ្ហាធាតុ	រសធាតុ	ជិវ្ហាវិញ្ញាណធាតុ
កាយធាតុ	ផោដ្ឋព្វធាតុ	កាយវិញ្ញាណធាតុ
(បញ្ចទ្វារ)	បញ្ចារម្មណ៍	មនោធាតុ
មនោទ្វារ	ធម្មធាតុ	មនោវិញ្ញាណធាតុ

ព្រះពុទ្ធអង្គទ្រង់សម្តែង ធាតុ ដោយភាពជាសភាវៈបដិសេធ ភាពជាសត្ត្ব ជាជីវិត ដូចដែលសត្ត្ববទាំងឡាយយល់ ព្រោះធម្មតាសត្ត្ববទាំងឡាយក្នុងលោកនេះ រមែងមានការឃើញ ឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ និងមានការនឹកគិតដូចគ្នាទាំងអស់ ដែលកិច្ចការងារផ្សេងៗ ទាំងនោះ នឹងមានឡើងបានក៏ត្រូវអាស្រ័យការប្រជុំរួមគ្នា រវាងទ្វារ អារម្មណ៍ វិញ្ញាណ ដែលជាធាតុទាំង ១៨ ដូចពោលហើយ ក្រៅពីការ ប្រជុំគ្នារបស់ធាតុទាំង ១៨ នេះហើយ ការងារផ្សេងៗ របស់សត្ត្ববទាំង

នោះក៏រមែងមានមិនបាន ដូច្នោះធាតុទាំង ១៨ នោះ ទើបហៅថា ជានិស្សត្ត បដិសេធសត្វបុគ្គលថា មិនមែនសត្វ និងការយល់របស់មនុស្សទាំងឡាយដែលយល់ថា កាលសត្វទាំងឡាយដល់នូវសេចក្តីស្លាប់ រាងកាយប៉ុណ្ណោះដែលស្លាប់ តែវិញ្ញាណមិនបានស្លាប់ទៅផងទេ កាលសត្វស្លាប់ហើយវិញ្ញាណក៏នឹងចេញចាករាងកាយចាស់ ផ្លាស់ទៅរករាងកាយថ្មីតទៅទៀត ការយល់ដូច្នេះចាត់ថា ជាអត្តវាទុបាទាន គឺមានសេចក្តីប្រកាន់មាំថា សត្វទាំងឡាយនោះ មានជីវអត្ត ជាវត្ថុមានឫទ្ធិតេជផ្សេងៗ នៅក្នុងខ្លួនទៀងទាត់ សេចក្តីពិត ត្ងជីវអត្តនេះមិនស្លាប់ នឹងផ្លាស់ពីភពចាស់ទៅរកទីកើតថ្មីនោះមិនមាន ការកើត ការតាំងនៅ និងការស្លាប់ទាំងនេះ សុទ្ធតែប្រព្រឹត្តទៅតាមសភាពរបស់ធាតុទាំងអស់ ពោលគឺ កាលស្លាប់នោះ វិញ្ញាណធាតុ ធម្មធាតុ និងចក្ខុធាតុ ជាដើមដែលជាកម្មជរូបក៏រលត់ និងកាលកើតវិញ្ញាណធាតុ ធម្មធាតុ និងចក្ខុធាតុ ជាដើមនោះឯង ដែលជាអ្នកកើត អាស្រ័យសភាពការប្រព្រឹត្តទៅរបស់ធាតុទាំង ១៨ នេះ ទើបបដិសេធ ជីវអត្ត និងពោលថា ជានិជ្ជីវ គឺមិនមែនជីវអត្ត និងបណ្តាធាតុទាំង ១៨ ប្រការ កាលពោលដោយសង្ខេបហើយ ក៏បានដល់ រូបធាតុ និងធម្មធាតុ នោះឯង ។

៥. អរិយសច្ច:

អរិយសច្ច គឺ ធម៌ដែលជាសេចក្ដីពិតរបស់ព្រះអរិយទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម រមែងដឹងច្បាស់ចាក់ធ្លុះក្នុងសច្ចធម៌ទាំងនេះ ព្រះមានព្រះភាគទើបត្រាស់ហៅថា អរិយសច្ច: មានព្រះបាលីថា

អរិយានំ សច្ចានិ = អរិយសច្ចានិ

ប្រែថា ធម៌ដែលជាសេចក្ដីពិតរបស់ព្រះអរិយទាំងឡាយ ឈ្មោះថា អរិយសច្ច: ។

សច្ចធម៌ទាំងនោះ បុថុជ្ជនទាំងឡាយរមែងដឹងមិនបាន គឺ ចូលមិនដល់ជម្រៅរបស់សច្ចធម៌នោះ ដូច្នោះទើបសម្ដែងថា នរណាក្ដីដែលចូលដល់សច្ច:នោះ រមែងឱ្យសម្រេចភាពជាព្រះអរិយឡើងមក ព្រះពុទ្ធអង្គទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាព្រះអរហន្ត សម្មាសម្ពុទ្ធដែលសត្វលោក ហៅថា ព្រះអរិយ: ព្រោះជាអ្នកត្រាស់ដឹងអរិយសច្ច:នេះតាមសេចក្ដីពិត ។

ន័យម្យ៉ាងទៀត អរិយសច្ច: បានសេចក្ដីថា ជាសច្ច:ដែលពិតប្រាកដ មិនខុសភ្លាត់ឃ្លៀងឃ្លាត ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច: ៤ នេះ ជារបស់ពិតប្រាកដ មិនខុស មិនមែនជាប្រការដទៃ តថាគតទើបហៅថា **អរិយសច្ច** ដូចមានព្រះបាលីថា

អរិយានិ តថានិ សច្ចានិ = អរិយសច្ចានិ

ប្រែថា សច្ចធម៌ទាំង ៤ ដែលជាសេចក្ដីពិតមិនប្រែប្រួល ឈ្មោះថា អរិយសច្ច: ។

អរិយសច្ច:មាន ៤ ប្រការ មានគាថាសង្គហ:សម្តែងថា

គាថាសङ्គហ:ទី ១៣

១៣. ទុក្ខं តេភូមកं វដ្ដं តណ្ហា សមុទយោ ភវេ
និរោធោ នាម និព្ពានं មគ្គោ លោកុត្តរោ មតោ ។

ប្រែថា វដ្ដ:ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ឈ្មោះថា ទុក្ខ តណ្ហា ឈ្មោះថា សមុទយ និព្វាន ឈ្មោះថា និរោធ លោកុត្តរ ឈ្មោះថា មគ្ត ។

អរិយសច្ច: ៤

១. ទុក្ខសច្ច ធម្មដែលជាទុក្ខតាមសេចក្តីពិតរបស់ព្រះអរិយ: អង្គធម្ម បានដល់ លោកិយចិត្ត ៨១ ចេតសិក ៥១ (រៀរលោភ) រូប ២៨ (ឥន្ទ្រិយពទ្ធរូប) ។

២. សមុទយសច្ច ធម្មដែលជាហេតុឱ្យកើតទុក្ខ អង្គធម្ម បានដល់ លោភចេតសិក ។

៣. និរោធសច្ច ធម្មដែលជាទីរំលត់ទុក្ខ អង្គធម្ម បានដល់ និព្វាន។

៤. មគ្គសច្ច ធម្មដែលជាហេតុឱ្យដល់ការរំលត់ទុក្ខ អង្គធម្ម បានដល់ អង្គមគ្ត ៨ ដែលនៅក្នុងមគ្គចិត្ត ៤ ។

អធិប្បាយអរិយសច្ច: ៤

ទុក្ខសច្ច

ទុក្ខសច្ច មានអត្ថ ៤ ប្រការ គឺ

១. បីឡនត្ថោ មានអត្ថថា គាបសង្កត់ ។

២. សង្ខតត្ថោ មានអត្ថថា ដែលបច្ច័យតាក់តែង ។

៣. សន្តាបត្ថោ មានអត្ថថា ឱ្យក្តៅក្រហាយ ។

៤. វិបរិណាមត្ថោ មានអត្ថថា ប្រែប្រួល ។

កាលពោលដោយសុត្តន្តន័យ សម្តែងទុក្ខ ទុក ១២ ប្រការ គឺ

១. ជាតិទុក្ខ = ការកើតជាទុក្ខ ។

២. ជរាទុក្ខ = ការចាស់ជាទុក្ខ ។

៣. មរណទុក្ខ = ការស្លាប់ជាទុក្ខ ។

៤. សោកទុក្ខ = សេចក្តីសោកសៅជាទុក្ខ ។

៥. បរិទេវទុក្ខ = សេចក្តីខ្សឹកខ្សួលជាទុក្ខ ។

៦. ទុក្ខទុក្ខ = សេចក្តីទុក្ខកាយជាទុក្ខ ។

៧. ទោមនស្សទុក្ខ = សេចក្តីលំបាកចិត្តជាទុក្ខ ។

៨. ឧបាយាសទុក្ខ = សេចក្តីតានតឹងការចង្អៀតចិត្តជាទុក្ខ ។

៩. អប្បិយេហិសម្បយោគទុក្ខ = ជួបវត្ថុដែលមិនជាទីស្រឡាញ់ជាទុក្ខ ។

១០. បិយេហិវិប្បយោគទុក្ខ = ការព្រាត់ប្រាសចាកវត្ថុដែលជាទីស្រឡាញ់ជាទុក្ខ ។

១១. យម្បិច្ឆं ន លភតិ តម្បិទុក្ខ = ប្រាថ្នាវត្ថុណាមិនបានវត្ថុនោះ ជាទុក្ខ ។

១២. សង្ខិត្តេន បញ្ចុបាទានក្ខន្ធាទុក្ខា = ដោយសង្ខេបឧបាទានខន្ធ ៥ ជាទុក្ខ ។

កាលពោលដោយអភិធម្មន័យ ទុក្ខសច្ច រួមធម៌ ១៦០ (ចិត្ត ៨១ ចេតសិក ៥១ រូប ២៨) ប្រការ ដោយសង្ខេបបានដល់ រូប និងនាម ។

រួមសេចក្ដីថា កាយនិងចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ គឺ កាមភូមិ រូបភូមិ និងអរូបភូមិនោះឯងជាសេចក្ដីពិត គឺ ទុក្ខសច្ច: ។

ដោយកិច្ច ជាបរិញ្ញាកិច្ច គឺ កិច្ចដែលត្រូវកំណត់ដឹង សំដៅដល់ ទុក្ខសច្ច:នោះមាននៅជាប្រចាំ តែយើងមិនបានកំណត់ដឹង ទើបគួរ កំណត់ដឹង ។

សមុទយសច្ច

សមុទយសច្ច មានអត្ថ ៤ ប្រការ គឺ

១. អាយូហនត្ថោ មានអត្ថថា ប្រមូលមក ។

២. និទានត្ថោ មានអត្ថថា ជាហេតុប្រគល់ឱ្យនូវផល ។

៣. សំយោគត្ថោ មានអត្ថថា ប្រកបទុកនូវទុក្ខ ។

៤. បលិពោធត្ថោ មានអត្ថថា ជាគ្រឿងកង្ងល់ ។

ដោយសុត្តន្តន័យសម្ដែងហេតុឱ្យកើតទុក្ខ បានដល់ តណ្ហា ៣ គឺ

១. កាមតណ្ហា គឺ សេចក្ដីប្រាថ្នាកាមភពដោយត្រេកអរជាប់ចិត្ត ក្នុងបញ្ចកាមគុណារម្មណ៍ ព្រះអនាគামីលះបានដាច់ខាត ។

២. ភវតណ្ហា គឺ សេចក្ដីប្រាថ្នារូបភព អរូបភព ដោយត្រេកអរដល់ឈានសមាបត្តិ និងសេចក្ដីប្រាថ្នាអារម្មណ៍ដែលប្រកបដោយសស្សតទិដ្ឋិ ភវតណ្ហាទាំងអស់នេះអរហត្តមគ្គ ទើបលះបាន ។

៣. វិភវតណ្ហា គឺ ការប្រាថ្នាដាច់ចាកភព ដោយត្រេកអរដល់ឧច្ឆេទទិដ្ឋិ តណ្ហាក្នុងភពទាំង ៣ នេះ គឺ ធម៌ដែលជាហេតុនៃទុក្ខសច្ច: ហៅថា សមុទយសច្ច: កាលពោលដោយអភិធម្មន័យហើយ សមុទយសច្ច: បានដល់ លោភចេតសិក វិភវតណ្ហា មានចំពោះក្នុងកាមភូមិ លះបានដោយ សោតាបត្តិមគ្គ ។

និរោធសច្ច

និរោធសច្ច ជាឈ្មោះរបស់ធម៌ដែលរលត់ទុក្ខ ទើបហៅឈ្មោះបានម្យ៉ាងទៀតថា **ទុក្ខនិរោធ** ។

ក្នុងសច្ច:នេះ ពាក្យថា **និ** រមែងសម្ដែងការមិនមាន **រោធ** សំដៅដល់ ការគ្រាច់ទៅ **និរោធ** សំដៅដល់ មិនមានការគ្រាច់ទៅ **ទុក្ខនិរោធ** ទើបមានសេចក្ដីថា មិនមានការគ្រាច់ទៅក្នុងទុក្ខ ឬការមិនគ្រាច់ទៅក្នុងសង្ខារ ព្រោះជាសច្ច:ដែលផុតចាកគតិទាំងពួង ន័យម្យ៉ាងទៀត កាលសច្ច:ទី ៣ ដែលបុគ្គលបានសម្រេចហើយ រមែងមានការមិនគ្រាច់ទៅក្នុងទុក្ខ ទើបហៅថា **ទុក្ខនិរោធ** ឬព្រោះជាបដិបក្ខដល់ការគ្រាច់ទៅក្នុងទុក្ខនោះ និងព្រោះជាបច្ច័យដល់ការរលត់ទុក្ខ គ្រប់យ៉ាងកើតឡើងមិនបាន អង្គធម៌ បានដល់ ព្រះនិព្វាន ។

ការដែលព្រះនិព្វានជាធម៌ដែលរលត់ទុក្ខនោះ មានព្រះបាលីសម្តែងថា **អសេសវិរាគនិរោធោ, ចាគো, បដិនិស្សគ្គো, មុត្តি, អនាលយো,** អធិប្បាយថា ប្រហារតណ្ហាដោយវិរាគមគ្គហើយ រមែងសម្រេចដល់ភវនិរោធនិព្វាន បរិយាយសេចក្តីតទៅថា

អាស្រ័យព្រះនិព្វានហើយ ប្រហារតណ្ហាបាន ប្រហារភវ:ទាំង ៣ បាន មិនឱ្យមានការត្រេកអរតទៅទៀត ព្រោះដូច្នោះ ព្រះនិព្វានទើបជាការរលត់ទុក្ខសច្ច:ដែលជាផល និងសមុទយសច្ច:ដែលជាហេតុ ប្រហារតណ្ហាដោយវិរាគមគ្គ នោះក៏គឺ ព្រះនិព្វានជាធម៌រលត់តណ្ហាដែលជាហេតុឱ្យកើតទុក្ខ ទើបជាធម៌រំលត់ទុក្ខដែលជាផលរបស់តណ្ហាផង ។

ទុក្ខនិរោធសច្ច

មានអត្ថ ៤ ប្រការ គឺ

១. និស្សរណត្ថো មានការរលាស់ចេញចាកទុក្ខទាំងពួង ។

២. វិវេកត្ថো ជាធម៌ដែលស្ងាត់ចាកកិលេសនិងកងទុក្ខ ។

៣. អសង្ខតត្ថো ដែលបច្ច័យតាក់តែងមិនបាន ។

៤. អមតត្ថো មិនមានការកើត ការស្លាប់តទៅ ។

មានវចនត្ថ:ថា **វដ្ដទុក្ខស្ស និរុជ្ឌនំ អនុប្បាទ ធម្មតាបត្តি វសেন ខិយ្យានំ ទុក្ខនិរোធো ។**

ប្រែថា ការរលត់ទៅនៃទុក្ខ គឺ ការអស់ទៅដោយមិនកើតឡើង

ទៀត នឹងមិនប្រព្រឹត្តទៅទៀត ឈ្មោះថា ទុក្ខនិរោធ ឬន័យម្យ៉ាងទៀតថា

ទុក្ខំ វា និរុជ្ឈតិ នបវត្តតិ ឯតស្មិន្តិ ទុក្ខនិរោធោ ។

ទុក្ខរមែងរលត់ទៅ រមែងមិនប្រព្រឹត្តទៅក្នុងនិព្វានធម៌នេះ ដូច្នោះ និព្វានធម៌នេះ ទើបឈ្មោះថា ទុក្ខនិរោធ ។

អង្គធម៌របស់ទុក្ខនិរោធសច្ច: ទើបបានដល់ ព្រះនិព្វាន ឈ្មោះ របស់ព្រះនិព្វាននោះមានច្រើន ដោយហៅឈ្មោះផ្ទុយគ្នាជាមួយសង្ខតធម៌ គឺ

១. អសេសតោ វិរាគោ =	អស់រាគ:មិនមានសល់ ។
២. និរោធោ =	ការរលត់ ។
៣. ចាគោ =	ការលះ ។
៤. បដិនិស្សគ្គោ =	ការលះបង់ ។
៥. មុត្តិ =	ការរួច ។
៦. អនាលយោ =	ការមិនមានអាល័យ ។
៧. រាគក្ខយោ =	ការអស់រាគ: ។
៨. ទោសក្ខយោ =	ការអស់ទោស: ។
៩. មោហក្ខយោ =	ការអស់មោហ: ។
១០. តណ្ហក្ខយោ =	ការអស់តណ្ហា ។
១១. អនុប្បាទោ =	ការមិនកើតឡើង ។
១២. អប្បវត្តំ =	ការមិនប្រព្រឹត្តទៅ ។
១៣. អនិមិត្តំ =	ការមិនមានគ្រឿងសម្គាល់ ។

១៤. អប្បណិហិតំ = ការមិនមានទីតាំង ។

១៥. អនាយូហនំ = ការមិនព្យាយាម ។

១៦. អប្បដិសន្ធិ = ការមិនមានបដិសន្ធិ ។

១៧. អនុប្បដិវត្តិ = ការមិនវិលត្រឡប់ ។

១៨. អគតិ = ការមិនមានគតិ ។

១៩. អជាតំ = ការមិនកើត ។

២០. អជរំ = ការមិនចាស់ ។

២១. អព្យាធិ = ការមិនឈឺ ។

២២. អមតំ = ការមិនស្លាប់

២៣. អសោកំ = ការមិនមានសេចក្តីសោក ។

២៤. អបរិទេវំ = ការមិនមានបរិទេវ: ។

២៥. អនុបាយាសំ = ការមិនចង្អៀតចង្អល់ ។

២៦. អសង្កិលិដ្ឋំ = មិនមានសេចក្តីសៅហ្មង ។

ទាំងនេះសុទ្ធតែជាឈ្មោះរបស់ព្រះនិព្វានទាំងអស់ ក្នុងសតិប្បដ្ឋានសូត្រ មានទេសនាទុកជា ២ ន័យគឺ

អនុលោមទេសនាសម្តែងថា **យាយំ តណ្ហា បោនោព្ភវិកា** ជាដើម មានសេចក្តីថា កាលនៅមិនទាន់បានប្រហារតណ្ហាដោយអរិយមគ្គនោះ តណ្ហាក៏រមែងកើតក្នុងអារម្មណ៍ និងទ្វារទាំង ៦ នោះបាន និងតាមន័យបដិលោមទេសនាសម្តែងថា **សាខោ បនេសា ភិក្ខវេ តណ្ហា** ជាដើម ដែលសម្តែងចំណែករលត់របស់តណ្ហាជាសេចក្តីថា កាលប្រហារតណ្ហា

ដោយអរិយមគ្គហើយ តណ្ហានោះរមែងរលត់ក្នុងអារម្មណ៍ និងទ្វារទាំង ៦ ដូច្នេះ ។

មគ្គសច្ច

មគ្គសច្ច មានអត្ថ ៤ ប្រការ គឺ

១. និយ្យានត្ថោ គឺ សភាវៈដែលនាំចេញចាកសង្សារវដ្ត ។

២. ហេតុត្ថោ គឺ សភាវៈដែលជាហេតុឱ្យដល់ព្រះនិព្វាន ។

៣. ទស្សនត្ថោ គឺ សភាវៈដែលឃើញព្រះនិព្វាន ។

៤. អធិបតេយ្យត្ថោ គឺ សភាវៈដែលជាធំក្នុងការឃើញព្រះនិព្វានរបស់សហជាតធម៌ ។

មគ្គសច្ច ជាផ្លូវបដិបត្តិដែលជាហេតុឱ្យចូលដល់ព្រះនិព្វាន ទើបមានឈ្មោះហៅថា ទុក្ខនិរោធគាមិនីបដិបទា ជាបដិបទាដើម្បីសម្រេចការរលត់ទុក្ខនោះឯង មានវចនត្ថៈថា

កិលេសេ មារយន្តោ និព្វានំ គច្ឆន្តិ ឯតេនាតិ = មគ្គោ ។

ធម្មជាតិណា ដែលប្រហារកិលេសហើយរមែងដល់ព្រះនិព្វាន ធម្មជាតិនោះ ឈ្មោះថា មគ្គ បានដល់ អដ្ឋង្គិកមគ្គ គឺ អង្គមគ្គ ៨ ។

អង្គមគ្គ ៨ ទើបមាននាទីទាំងប្រហារកិលេសផង សម្រេចដល់ព្រះនិព្វានផង បដិបទាដែលនាំអ្នកបដិបត្តិឱ្យដល់ព្រះនិព្វាននោះក៏គឺមគ្គទាំង ៨ ប្រការនោះឯង បានដល់

១. សម្មាទិដ្ឋិ, ២. សម្មាសង្កប្ប, ៣. សម្មាវាចា, ៤. សម្មាកម្មន្ត, ៥. សម្មាអាជីវៈ, ៦. សម្មាវាយាមៈ, ៧. សម្មាសតិ, ៨. សម្មាសមាធិ ។

អរិយមគ្គទាំង ៨ ប្រការនេះ ហៅថា ទុក្ខនិរោធគាមិនីបដិបទា-អរិយសច្ច: ព្រោះជាបដិបទាដែលជាហេតុឱ្យសម្រេចដល់ព្រះនិព្វានធាតុដោយពិតប្រាកដ ។

ពោលដោយកិច្ចរបស់អរិយសច្ច:មាន ៤ ប្រការ គឺ

១. ទុក្ខសច្ច ជាបរិញ្ញេយ្យកិច្ច គឺ កិច្ចដែលគួរកំណត់ដឹង សេចក្ដីថា នាមរូបខន្ធ ៥ ដោយសភាវធម៌ ១៦០ ប្រការនោះ ជាទុក្ខសច្ច: ដែលត្រូវកំណត់ដឹងព្រោះជាផលដែលកើតពីហេតុ គឺ សមុទយ ។

២. សមុទយសច្ច ជាបហានកិច្ច គឺ កិច្ចដែលត្រូវលះបង់ឱ្យអស់ទៅ សេចក្ដីថា តណ្ហា ៣ ដោយសភាវ: បានដល់ លោភចេតសិកនោះ ត្រឹមតែកំណត់ដឹងប៉ុណ្ណោះមិនបាន ព្រោះជាតួហេតុឱ្យកើតទុក្ខសច្ច: ទើបមាននាទីនឹងត្រូវធ្វើឱ្យអស់ទៅ កាលអាចធ្វើឱ្យអស់ទៅបានច្រើនប៉ុនណា ទុក្ខសច្ច:ដែលជាផលក៏អស់ទៅប៉ុណ្ណោះ ។

៣. និរោធសច្ច ជាសច្ឆិកិរិយាកិច្ច គឺ ជាធម៌ដែលត្រូវធ្វើឱ្យជាក់ច្បាស់ បានដល់ព្រះនិព្វានជាធម៌ដែលរលត់ទុក្ខ និងរលត់តណ្ហានោះ មាននាទីត្រូវសម្រេចដល់ ឬធ្វើឱ្យជាក់ច្បាស់ គឺ ត្រូវធ្វើឱ្យដល់ ធម៌ដែលរលត់តណ្ហា សេចក្ដីថា កាលលះតណ្ហាដែលជាធម៌ដែលគួរលះរហូតដល់តណ្ហាអស់ទៅហើយ ទើបដល់ព្រះនិព្វាន កាលតណ្ហាមិនមាននៅក្នុងទីនោះ ធម៌នោះឈ្មោះថា និរោធសច្ច: គឺ ព្រះនិព្វាន ។

៤. មគ្គសច្ច ជាភាវនាកិច្ច គឺ កិច្ចដែលត្រូវចម្រើនឱ្យកើតឡើង មគ្គសច្ច:នេះ ជាអ្នកធ្វើការ មិនមែនជាតួអារម្មណ៍កម្មដ្ឋាន ត្រឹមតែកំណត់ដឹងប៉ុណ្ណោះមិនបាន ដូចជាអ្នកដើរផ្លូវ ដែលនឹងត្រូវដើរផ្លូវទៅឱ្យដល់គោលដៅ គឺ និរោធសច្ច: ដោយហេតុនេះ កិច្ចរបស់មគ្គសច្ច: ទើបត្រូវបដិបត្តិឱ្យកើតឡើង តាមន័យព្រះសូត្រសង្គ្រោះដោយការបដិបត្តិ សមថ: និងវិបស្សនា ដោយន័យមហាសតិប្ឋដ្ឋាន សង្គ្រោះដោយការចម្រើនសតិប្ឋដ្ឋាន ដែលជាបុព្វភាគរបស់មគ្គខាងដើម ដែលនៅក្នុងមគ្គខាងដើមនេះ ត្រូវយល់ថាមគ្គមានទាំង សីល សមាធិ និងបញ្ញា ដូចគ្នា ។

ដូច្នោះ ភាវនាកិច្ចដែលនឹងត្រូវធ្វើឱ្យចម្រើនឡើងនោះ អាចចម្រើនសមថកម្មដ្ឋានឱ្យបានឈានមុនសិន ហើយលើកអង្គឈាន ចម្រើនវិបស្សនាកម្មដ្ឋានក៏បាន ឬនឹងផ្តើមពីការចម្រើនសតិប្ឋដ្ឋាន ពិចារណារូប នាម ឱ្យវិបស្សនាញាណកើតដោយត្រង់ក៏បាន នេះគឺ ការធ្វើការងារ ឬបដិបទាក្នុងភាវនាកិច្ចរបស់មគ្គសច្ច: ។

ចែកអរិយសច្ច: ៤ ដោយហេតុនិងផល

ទុក្ខសច្ច: ជាផល សមុទយសច្ច: ជាហេតុ ។

និរោធសច្ច: ជាផល មគ្គសច្ច: ជាហេតុ ។

ក្នុងអរិយសច្ច: ៤ នេះ ចាត់ធម៌ដែលជាហេតុទុក ២ សច្ច: និងធម៌ដែលជាផល ២ សច្ច: ដូចគ្នា ។

ក្នុងសច្ច:ដែលជាហេតុ បានដល់ សមុទយសច្ច: និងមគ្គសច្ច: សម្រាប់សមុទយសច្ច: ជាហេតុឱ្យកើតទុក្ខសច្ច:ដោយត្រង់ ។

ចំណែកមគ្គសច្ច:ដែលជាហេតុឱ្យដល់និរោធសច្ច: ជាការសម្តែងដោយអម ព្រោះមគ្គសច្ច:មិនមែនជាហេតុឱ្យនិរោធកើតឡើងទេ ។

និរោធសច្ច: គឺ ព្រះនិព្វានជាអសង្ខតធម៌ ជាធម៌ដែលក្រៅចាកហេតុបច្ច័យណាៗ តាក់តែងបាន និងជាធម៌ដែលរលត់អស់នូវបច្ច័យទាំងពួង ដូច្នោះមគ្គសច្ច: ត្រឹមតែជាហេតុឱ្យដល់និរោធប៉ុណ្ណោះ និងការដល់និរោធសច្ច:ក៏ជាផលដែលកើតពីបដិបទារបស់មគ្គសច្ច:នោះឯង ទើបជាការពោលដោយអម ។

ចែកអរិយសច្ច: ៤ ដោយលោកិយ និងលោកុត្តរ:

ទុក្ខសច្ច: និងសមុទយសច្ច: ជាលោកិយធម៌ ទើបជាលោកិយសច្ច: ។

និរោធសច្ច: និងមគ្គសច្ច: ជាលោកុត្តរធម៌ ទើបជាលោកុត្តរសច្ច:

ក្នុងសច្ច:ទាំង ២ ប្រការនេះ លោកិយសច្ច: ឈ្មោះថា វដ្តសច្ច: ព្រោះទុក្ខសច្ច:នោះ ជាទីតាំងនៃនាមរូប និងសមុទយសច្ច:នោះ ជាហេតុឱ្យកើតទុក្ខសច្ច: និងកាលទុក្ខសច្ច: គឺ នាមរូបប្រាកដឡើងហើយ ក៏ជាអារម្មណ៍ឱ្យកើតតណ្ហា ឧបាទាន ជាតួកិលេសជាហេតុឱ្យធ្វើកម្ម និងធ្វើឱ្យផលរបស់កម្ម គឺ នាមរូបថ្មីកើតឡើងទៀត ទើបហៅថា វដ្តសច្ច: ។

លោកុត្តរសច្ច: គឺ និរោធសច្ច: និងមគ្គសច្ច: នោះហៅថា វិវដ្ដសច្ច: ព្រោះសច្ច:ទាំង ២ នេះ ធ្វើឱ្យទុក្ខសច្ច: និងសមុទយសច្ច:ឈប់ គឺ មិនឱ្យមានឱកាសដែលនឹងកើតតទៅខាងមុខបានទៀតឡើយ ។

ក្នុងអរិយសច្ច: ៤ នេះ ព្រះពុទ្ធអង្គទ្រង់បង្ហាញឱ្យឃើញធម៌ដែលប្រព្រឹត្តទៅដើម្បីទុក្ខ គឺ ការកើត ចាស់ ឈឺ ស្លាប់ ដែលហៅថា លោកិយសច្ច: ឬវដ្ដសច្ច: ដោយទុក្ខសច្ច: និងសមុទយសច្ច: និងធម៌ដែលប្រព្រឹត្តទៅដើម្បីការផុតទុក្ខ គឺ ផុតចាកការកើត ចាស់ ឈឺ ស្លាប់ ដែលហៅថា លោកុត្តរសច្ច: ឬវិវដ្ដសច្ច: ដោយនិរោធសច្ច: ជាមួយមគ្គសច្ច: ។

ដើម្បីប្រយោជន៍ចម្រើនភាវនា ដោយផ្តើមពីការស្វែងរកបដិវេធញ្ញាណ ដែលមាន ២ ប្រការ គឺ

១. លោកិយបដិវេធញ្ញាណ បានដល់ ការសិក្សាបរិយត្តិសាសនាឱ្យយល់ទុក្ខនិងសមុទយ: រហូតដល់ខន្ធ អាយតន: ធាតុ ត្រូវសិក្សាដល់និរោធសច្ច: និងមគ្គសច្ច: ថាព្រះនិព្វានមានសភាពយ៉ាងណា និងការស្វែងរកព្រះនិព្វាននោះ ត្រូវអាស្រ័យបដិបទាយ៉ាងណា ដូច្នេះជាដើមរហូតដល់ដឹងនាមរូប ដោយវិបស្សនាញ្ញាណ ។

២. លោកុត្តរបដិវេធញ្ញាណ ជាបញ្ញាដែលកើតព្រមជាមួយអរិយមគ្ត ធ្វើកិច្ចក្នុងការប្រហារកិលេស និងឱ្យយល់ដឹងអរិយសច្ច:ទាំង ៤ ប្រការ មែនពិតបដិវេធញ្ញាណ គឺ បញ្ញាដែលចូលទៅឃើញច្បាស់អរិយសច្ច: ៤ នោះ និងកើតឡើងបានក៏ចំពោះតែលោកុត្តរបដិវេធញ្ញាណ

ប៉ុណ្ណោះ តែដោយវោហារទេសនាក៏សង្គ្រោះយកលោកិយបដិវេធនោះ កាលសិក្សាឱ្យយល់ល្អជាមុនសិនហើយ ក៏ជួយឧបការ:ដល់ការបដិបត្តិ ដើម្បីស្វែងរកលោកុត្តរបដិវេធញ្ញាណ បានស្រួលក្រៃលែងឡើង បើ ប្រាសចាកការសិក្សាបរិយត្តិសាសនាហើយ ក៏នឹងមិនដឹងថាអ្វីជាទុក្ខ ជាទុក្ខយ៉ាងណា អ្វីជាអ្នកធ្វើឱ្យកើតទុក្ខ និងលះហេតុឱ្យកើតទុក្ខនោះ បានយ៉ាងណា និងការរលត់ទុក្ខមានសភាពយ៉ាងណា រហូតការ សម្រេចនិព្វាន ជាយ៉ាងណា ដូច្នេះជាដើម ។

ញាណក្នុងអរិយសច្ច: ៤

ញាណ គឺ បញ្ញា បានដល់ សម្មាទិដ្ឋិ ដែលឃើញច្បាស់ក្នុង អរិយសច្ច: ៤ និងត្រូវកើតឡើង ៣ ជុំ ហៅថា បរិវដ្ដ: ៣ និងមាន ញាណ ការដឹងគ្រប់ ១២ ប្រការ ទើបរាប់ថាជាអ្នកសម្រេចអរិយសច្ចធម៌ និងកាលសម្រេចអរិយសច្ច: ៤ គ្រា ដោយបរិបូណ៌ហើយ គឺ ចូលដល់ ភាពជាព្រះខីណាស្រព អ្នកអស់អាសវក្កិលេសជាព្រះអសេក្ខបុគ្គល ដែលផុតចាកការសិក្សា និងបដិបត្តិហើយ ជាអ្នកបរិសុទ្ធបរិបូណ៌ ពោលគឺ ព្រហ្មចរិយ:នៅចប់ហើយ ។

បរិវដ្ដ: ៣

បញ្ញាដែលដឹងអរិយសច្ច: ៤ មាន ៣ ជុំ ហៅថា បរិវដ្ដ: ៣

បរិវដ្ដទី ១ ជុំដំបូងហៅថា សច្ចញ្ញាណ ជាបញ្ញាដែលកើតពីការ

សិក្សាដឹងថា រូប នាម ខន្ធ ៥ ជាទុក្ខសច្ច: កើតពីតណ្ហាដែលជាសេចក្តីត្រេកអរជាប់ចិត្តក្នុងកាមគុណារម្មណ៍ និងជាប់ចិត្តក្នុងភពជា សមុទយសច្ច: កាលរលត់ទុក្ខឱ្យអស់ទៅ សត្វទាំងឡាយក៏នឹងផុតចាកទុក្ខ សភាវ:ការរលត់ទុក្ខនោះ គឺ ព្រះនិព្វាន ជានិរោធសច្ច: ចំណែកដែលនិងបដិបត្តិយ៉ាងណា ទើបរលត់ទុក្ខបានអស់រលីងនោះ ត្រូវអាស្រ័យបដិបទាពីការចម្រើនសតិប្បដ្ឋាន រហូតដល់វិបស្សនាញាណកើត ចម្រើនឡើងតាមពោធិបក្ខិយធម៌ ឱ្យចូលដល់ការគ្រាស់ដឹងអរិយសច្ច:ទាំង ៤ បដិបទាដែលចូលដល់អរិយសច្ចធម៌ទាំង ៤ បាន គឺ មគ្គសច្ច: ការដឹងទាំងនេះកើតពីការសិក្សាបរិយត្តិធម៌ ជាសច្ចញ្ញាណ បានដល់ ការសិក្សាអរិយសច្ច: ៤ ។

បរិវដ្តទី ២ ហៅថា **កិច្ចញ្ញាណ** ជាបញ្ញាដែលដឹងអរិយសច្ច: ថ្នាក់បដិបត្តិ កាលមានការយល់ក្នុង **ទុក្ខសច្ច** ពីការសិក្សាហើយក៏នាំមកបដិបត្តិ មកកំណត់ដឹងទុក្ខផង កាលកំណត់ដឹងទុក្ខក៏ជាហេតុឱ្យជាការលះសមុទយ: តួតណ្ហាផង ទាំងជាការធ្វើឱ្យជាក់ច្បាស់ព្រះនិព្វាន និងការចម្រើន មគ្គ មានអង្គ ៨ ដោយការដឹងរបស់បញ្ញាក្នុងជុំទី ២ នេះ ជាការដឹងថ្នាក់បដិបត្តិ ទើបហៅថា កិច្ចញ្ញាណ ជាការបដិបត្តិកិច្ចក្នុងអរិយសច្ច: ៤ ជុំទី ១ ដល់ជុំទី ២ ទើបដឹងអរិយសច្ចធម៌ ៨ ញាណជាមួយគ្នា ។

បរិវដ្តទី ៣ ជុំទី ៣ ហៅថា កតញ្ញាណ ជាបញ្ញាការដឹងថ្នាក់បដិវេធ ជាការដឹងទុក្ខបរិបូណ៌ហើយ សមុទយ: គឺ តណ្ហាក៏លះបានអស់ហើយ

និរោធ គឺ ព្រះនិព្វានក៏ជាក់ច្បាស់ហើយ បដិបទា គឺ មគ្គ មានអង្គ ៨ ក៏បានចម្រើនហើយ ការដឹងជុំទី ៣ ចូលដល់ថ្នាក់ដឹងច្បាស់ ចាក់ផ្លុះក្នុងអរិយសច្ចធម៌ ដោយពិតប្រាកដ រួមសេចក្ដីថា ដឹងអរិយសច្ចធម៌ដោយញាណបរិវដ្ដ ៣ ជុំនីមួយៗ មាន ៤ សច្ច: រួមញាណដែលជាការដឹងក្នុងអរិយសច្ចធម៌ទាំងអស់ ១២ ប្រការ ។

បរិវដ្ដ ៣ អាការ ១២ របស់ញាណក្នុងអរិយសច្ចធម៌នេះ មានឧបការ:ដែលជាប់ទាក់ទងគ្នា គឺ **សច្ចញ្ញាណ** ឧបការ:ដល់ **កិច្ចញ្ញាណ** ទាំង**សច្ចញ្ញាណ** និង**កិច្ចញ្ញាណ** ឧបការ:ដល់ **កតញ្ញាណ** ឧបមាដូចការធ្វើការងារ ត្រូវមានការយល់ដឹងទាក់ទងជាមួយការងារ កាលមានការយល់ដឹងហើយ ក៏ចាប់ផ្ដើមធ្វើ កាលធ្វើត្រូវតាមការយល់ដឹង ការងារនោះក៏សម្រេចបានផល សេចក្ដីឧបមានេះយ៉ាងណា **សច្ចញ្ញាណ** **កិច្ចញ្ញាណ** និង **កតញ្ញាណ** ដែលជាការធ្វើឱ្យអស់វដ្ដទុក្ខបាន ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

សច្ចវិមុត្តិ

អរិយសច្ចធម៌ ៤ ប្រការ គឺ ទុក្ខសច្ច សមុទយសច្ច និរោធសច្ច និងមគ្គសច្ចនោះ កាលពិចារណាដល់អង្គធម៌ហើយ លោកិយចិត្ត ៨១ ចេតសិក ៥១ (រៀរលោភ) រូប ២៨ ជាអង្គធម៌របស់ ទុក្ខសច្ច លោភចេតសិក ជាអង្គធម៌របស់ សមុទយសច្ច និព្វាន ជាអង្គធម៌របស់ និរោធសច្ច និងអង្គមគ្គ ៨ បានដល់ បញ្ញាចេតសិក វិតក្កចេតសិក

វិរតិចេតសិក ៣ វីរិយចេតសិក សតិចេតសិក និង ឯកគ្គតាចេតសិក ដែលប្រកបក្នុងមគ្គចិត្ត ៤ ជាអង្គធម៌របស់ មគ្គសច្ច: ។

បរមត្ថធម៌ទាំង ៤ ប្រការ គឺ ចិត្ត ចេតសិក រូប និងនិព្វាន កាលសង្ត្រោះចូលក្នុងអរិយសច្ចធម៌ទាំង ៤ ហើយ នៅមានសល់ទៀត គឺ មគ្គចិត្ត ៤ និងចេតសិកដែលប្រកបក្រៅពីចេតសិកដែលជាអង្គមគ្គ ៨ និងផលចិត្ត ៤ ចេតសិកដែលប្រកបជាមួយផលចិត្តទាំង ៤ នោះ សង្ត្រោះចូលក្នុងអរិយសច្ចណាមិនបាន ទើបឈ្មោះថា ជាសច្ចវិមុត្តិទៅ ដូចក្នុងគាថាសង្គហ:ដែលសម្តែងថា

គាថាសង្គហ:ទី ១៤

១៤. មគ្គយុត្តា ផលា ចេវ ចតុសច្ចវិនិស្សដា
ឥតិ បញ្ចប្បភេទេន បវុត្តោ សព្វសង្គហោ ។

ប្រែថា ធម៌ដែលប្រកបជាមួយមគ្គចិត្តនិងផលចិត្តុប្បាទ (ក្រៅពីអដ្ឋង្គិកមគ្គ) នោះ ឈ្មោះថា ជាធម៌ដែលរួចចាកអរិយសច្ច: ៤ ការរួបរួមធម៌ទាំងឡាយទាំងពួងដោយប្រភេទ ៥ យ៉ាង ដោយប្រការដូចដែលបានពោលមកហើយ ។

សេចក្តីថា ធម៌ដែលផុតចាកអរិយសច្ច: ៤ បានដល់ មគ្គចិត្តទាំង ៤ និងចេតសិកដែលប្រកប ២៨ (រៀរអង្គមគ្គ ៨) ហៅថា មគ្គចិត្តុប្បាទ ដែលសល់ ២៩ (រាប់មគ្គចិត្ត ១ និងចេតសិក ២៨) ផលចិត្តទាំង ៤ និងចេតសិកដែលប្រកប ៣៦ ហៅថា ផលចិត្តុប្បាទ ៣៧ (រាប់ផលចិត្ត ១ និងចេតសិក ៣៦) ធម៌ទាំងនេះមិនចាត់នៅក្នុងសច្ច:ណាៗ ទាំងអស់

ទើបមានហាន:ផុតវិសេសចាកអរិយសច្ច:ទាំង ៤ ទើបហៅធម៌ទាំងនេះ ថា សច្ចវិមុត្តិ ។

ម្យ៉ាងទៀត អនិន្ទ្រិយពទ្ធរូប គឺ រូបធម៌ដែលមិនបានទាក់ទងក្នុងឥន្ទ្រីយ៍ សំដៅដល់ រូបខាងក្រៅដែលមិនជាប់ទាក់ទងនឹងវត្ថុមានជីវិត និងបញ្ញត្តិធម៌ គឺ ធម៌ដែលជាបញ្ញត្តិ តាមវោហាររបស់សត្វលោក ជាសម្មតិសច្ច: មិនមែនជាបរមត្ថសច្ច: ទើបសង្គ្រោះចូលក្នុងអរិយសច្ចធម៌ទាំង ៤ មិនបាន អនុលោមថាជាសច្ចវិមុត្តិបានដូចគ្នា ។

រួមសេចក្តីថា សព្វសង្គហ: គឺ ការរួបរួមបរមត្ថធម៌ទាំងអស់ សង្គ្រោះក្នុងធម៌ ៥ ប្រភេទ គឺ ខន្ធ ៥ ឧបាទានក្ខន្ធ ៥ អាយតន: ១២ ធាតុ ១៨ និងអរិយសច្ច: ៤ មានត្រឹមប៉ុណ្ណោះ ។

អវសានគាថា

ឥច្ចានុរុទ្ធរចិតេ អភិធម្មត្ថសង្គហេ
សត្តមោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ ។

អភិធម្មត្ថសង្គហបរិច្ឆេទទី ៧ ឈ្មោះថា សមុច្ចយសង្គហវិភាគ ដែលព្រះអនុរុទ្ធាចារ្យរចនាទុកហើយដោយសង្ខេបចប់តែត្រឹមនេះ ។

ចប់ បរិច្ឆេទទី ៧

ព្រះអភិធម្មត្ថសង្គហបាលី-ប្រែ

សត្តមោ បរិច្ឆេទោ សមុច្ចយសង្គហវិភាគោ

បរិច្ឆេទទី ៧ ឈ្មោះសមុច្ចយសង្គហវិភាគ

(១) ទ្វាសត្តតិវិធា រុត្តា រត្ថុធម្មា សលក្ខណា
តេសំ ទានិ យថាយោគំ បវក្ខាមិ សមុច្ចយំ ។

ប្រែថា សភាវធម៌ទាំងឡាយដែលមានលក្ខណៈរបស់ខ្លួន មាន ៧២ ប្រការនោះ គឺ ខ្ញុំពោលរួចហើយ ឥឡូវនេះនឹងពោលនូវពួកធម៌ទាំងនោះ តាមសមគួរដល់ការប្រកប ។

(២) អកុសលសង្គហោ មិស្សកសង្គហោ ពោធិបក្ខិយសង្គហោ សព្វសង្គហោ ចេតិ សមុច្ចយសង្គហោ ចតុព្វិធោ វេទិតព្វោ ។

បណ្ឌិតគប្បីជ្រាបថា សមុច្ចយសង្គហៈមាន ៤ ប្រការ គឺ អកុសលសង្គហៈ ១ មិស្សកសង្គហៈ ១ ពោធិបក្ខិយសង្គហៈ ១ និងសព្វសង្គហៈ ១ ។

អកុសលសង្គហោ

ការប្រមូលពួកអកុសលធម៌

(៣) កថំ? អកុសលសង្គហោ តាវ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។

អកុសលសង្គហៈដូចម្តេច? លំដាប់ដំបូងក្នុងអកុសលសង្គហៈ

(នេះ) អាសវ:មាន ៤ គឺ កាមាសវ: ១ ភវាសវ: ១ ទិដ្ឋាសវ: ១ និងអវិជ្ជាសវ: ១ ។

(៤) ចត្តារោ ឱឃា កាមោឃោ ភវោឃោ ទិដ្ឋោឃោ អវិជ្ជោឃោ ។

ឱឃ:ទាំងឡាយមាន ៤ ប្រការ គឺ កាមោឃ ១ ភវោឃ ១ ទិដ្ឋោឃ ១ និងអវិជ្ជោឃ ១ ។

(៥) ចត្តារោ យោគា កាមយោគោ ភវយោគោ ទិដ្ឋិយោគោ អវិជ្ជាយោគោ ។

យោគទាំងឡាយមាន ៤ ប្រការ គឺ កាមយោគ ១ ភវយោគ ១ ទិដ្ឋិយោគ ១ និងអវិជ្ជាយោគ ១ ។

(៦) ចត្តារោ គន្ថា អភិជ្ឌាកាយគន្ថោ, ព្យាបាទោ កាយគន្ថោ, សីលព្ពតបរាមាសោ កាយគន្ថោ, ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។

គន្ថទាំងឡាយមាន ៤ ប្រការ គឺ អភិជ្ឌាកាយគន្ថ ១ ព្យាបាទ-កាយគន្ថ ១ សីលព្ពតបរាមាសកាយគន្ថ ១ និងឥទំសច្ចាភិនិវេស-កាយគន្ថ ១ ។

(៧) ចត្តារោ ឧបាទានា កាមុបាទានំ ទិដ្ឋុបាទានំ សីលព្ពតុបាទានំ អត្តវាទុបាទានំ ។

ឧបាទានទាំងឡាយមាន ៤ ប្រការ គឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្ពតុបាទាន ១ និងអត្តវាទុបាទាន ១ ។

(៨) ឆ នីវរណានិ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថិនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ អវិជ្ជានីវរណំ ។

នីវរណទាំងឡាយមាន ៦ ប្រការ គឺ កាមច្ឆន្ទនីវរណ ១ ព្យាបាទ-នីវរណ ១ ថិនមិទ្ធនីវរណ ១ ឧទ្ធច្ចកុក្កុច្ចនីវរណ ១ វិចិកិច្ឆានីវរណ ១ និងអវិជ្ជានីវរណ ១ ។

(៩) សត្ត អនុសយា កាមរាគានុសយោ ភវរាគានុសយោ បដិឃានុសយោ មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ អវិជ្ជានុសយោ ។

អនុស័យទាំងឡាយមាន ៧ ប្រការ គឺ កាមរាគានុស័យ ១ ភវរាគានុស័យ ១ បដិឃានុស័យ ១ មានានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ និងអវិជ្ជានុស័យ ១ ។

(១០) ទស សំយោជនានិ កាមរាគសំយោជនំ រូបរាគសំយោជនំ អរូបរាគសំយោជនំ បដិឃសំយោជនំ មានសំយោជនំ ទិដ្ឋិសំយោជនំ សីលព្វតបរាមាសសំយោជនំ វិចិកិច្ឆាសំយោជនំ ឧទ្ធច្ចសំយោជនំ អវិជ្ជាសំយោជនំ សុត្តន្តេ ។

សំយោជន:ទាំងឡាយមាន ១០ ប្រការ ក្នុងសុត្តន្តន័យ គឺ កាមរាគសំយោជន ១ រូបរាគសំយោជន ១ អរូបរាគសំយោជន ១ បដិឃសំយោជន ១ មានសំយោជន ១ ទិដ្ឋិសំយោជន ១ សីលព្វតបរាមាសសំយោជន ១ វិចិកិច្ឆាសំយោជន ១ ឧទ្ធច្ចសំយោជន ១ និងអវិជ្ជាសំយោជន ១ ។

(១១) អបរានិបិ ទស សំយោជនានិ កាមរាគសំយោជនំ ភវរាគសំយោជនំ បដិឃសំយោជនំ មានសំយោជនំ ទិដ្ឋិសំយោជនំ

សីលព្វតបរាមាសសំយោជនំ វិចិកិច្ឆាសំយោជនំ ឥស្សាសំយោជនំ មច្ឆរិយសំយោជនំ អវិជ្ជាសំយោជនំ អភិធម្មេ ។

សំយោជន:ទាំងឡាយមាន ១០ ប្រការ សូម្បីយ៉ាងដទៃក្នុងអភិធម្ម គឺ កាមរាគសំយោជន ១ ភវរាគសំយោជន ១ បដិឃសំយោជន ១ មានសំយោជន ១ ទិដ្ឋិសំយោជន ១ សីលព្វតបរាមាសសំយោជន ១ វិចិកិច្ឆាសំយោជន ១ ឥស្សាសំយោជន ១ មច្ឆរិយសំយោជន ១ និងអវិជ្ជាសំយោជន ១ ។

(១២) ទស កិលេសា លោភោ ទោសោ មោហো មានោ ទិដ្ឋិ វិចិកិច្ឆា ថិនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ។

កិលេស (គ្រឿងសៅហ្មង) ទាំងឡាយមាន ១០ ប្រការ គឺ លោភ ១ ទោស ១ មោហ ១ មាន: ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ ថិន ១ ឧទ្ធច្ច ១ អហិរិក ១ និងអនោត្តប្ប ១ ។

(១៣) អាសវាទីសុ បនេត្ថ កាមភវនាមេន តព្វត្ថុកា តណ្ហា អធិប្បេតា, សីលព្វតបរាមាសោ ឥទំសច្ចាភិនិវេសោ អត្តវាទុបាទោ ច តថាបវត្តំ ទិដ្ឋិគតមេវ បវុច្ចតិ ។

ម្យ៉ាងទៀត បណ្តាពួកអកុសលទាំងឡាយ មានអាសវជាដើមនេះ ព្រះមានព្រះភាគទ្រង់បំណងយកតណ្ហា ដែលមានវត្ថុកាមនិងភពនោះ ជាទីតាំងដោយឱ្យឈ្មោះថា កាមនិងភវ ហើយត្រាស់ហៅ ទិដ្ឋិដែលប្រព្រឹត្តទៅយ៉ាងនេះថា សីលព្វតបរាមាស ឥទំសច្ចាភិនិវេស និងអត្តវាទុបាទាន ។

(១៤) អាសវោយា ច យោគា ច,
តយោ គន្ថា ច វត្ថុតោ,
ឧបាទានា ទុវេ វុត្តា,
អដ្ឋ នីវរណា សិយុំ ។

ឆឡេវានុសយា ហោន្តិ នវ សំយោជនា មតា
កិលេសា ទស វុត្តោយំ នវធា បាបសង្គហោ ។

ប្រែថា អាសវ: ឱយ: យោគ: និងគន្ថ: ទាំងនេះ កាលពោល ដោយអង្គធម៌មួយៗ មាន ៣ ឧបាទានមាន ២ និងនីវរណ:មាន ៨ ។

អនុស័យ មានអង្គធម៌បរមត្ថ ៦ សំយោជន:មាន ៩ កិលេសមាន ១០ អកុសលសង្គហ:រមែងមាន ៩ កង ដូច្នេះ ។

មិស្សកសង្គហោ

មិស្សកសង្គហ

(១៥) មិស្សសង្គហោ ឆ ហេតូ លោភោ ទោសោ មោហោ អលោភោ អទោសោ អមោហោ ។

ក្នុងមិស្សសង្គហ ហេតុទាំងឡាយមាន ៦ គឺ លោភ ១ ទោស ១ មោហ ១ អលោភ ១ អទោស ១ និងអមោហ ១ ។

(១៦) សត្ត ឈានង្គានិ វិតក្កោ វិចារោ បីតិ ឯកគ្គតា សោមនស្សំ ទោមនស្សំ ឧបេក្ខា ។

ឈានង្គ (អង្គរបស់ឈាន) ទាំងឡាយមាន ៧ គឺ វិតក្ក ១ វិចារ ១

ជីតិ ១ ឯកគ្គតា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ និងឧបេក្ខាវេទនា ។

(១៧) ទ្វាទស មគ្គង្គានិ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាយាមោ មិច្ឆាសមាធិ ។

មគ្គង្គ (អង្គមគ្គ) ទាំងឡាយមាន ១២ គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្ត ១ សម្មាអាជីវ ១ សម្មាវាយាម ១ សម្មាសតិ ១ សម្មាសមាធិ ១ មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្ប ១ មិច្ឆាវាយាម ១ និងមិច្ឆាសមាធិ ១ ។

(១៨) ពាវីសតិន្ទ្រិយានិ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ មនិន្ទ្រិយំ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ អញ្ញាតាវិន្ទ្រិយំ ។

ឥន្ទ្រិយទាំងឡាយមាន ២២ គឺ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ មនិន្ទ្រិយ ១ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ និងអញ្ញាតាវិន្ទ្រិយ ១ ។

(១៩) នវ ពលានិ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ហិរិពលំ ឱត្តប្បពលំ អហិរិកពលំ អនោត្តប្បពលំ ។

ពលទាំងឡាយមាន ៩ ប្រការ គឺ សទ្ធាពល ១ វីរិយពល ១ សតិពល ១ សមាធិពល ១ បញ្ញាពល ១ ហិរិពល ១ ឱត្តប្បពល ១ អហិរិកពល ១ និងអនោត្តប្បពល ១ ។

(២០ ចត្តារោ អធិបតី ឆន្ទាធិបតិ វីរិយាធិបតិ ចិត្តាធិបតិ វីមំសាធិបតិ ។

អធិបតីមាន ៤ ប្រការ គឺ ឆន្ទាធិបតិ ១ វីរិយាធិបតិ ១ ចិត្តាធិបតិ ១ និងវីមំសាធិបតិ ១ ។

(២១) ចត្តារោ អាហារា កពឡីការោ អាហារោ, ផស្សោ ទុតិយោ, មនោសញ្ចេតនា តតិយា, វិញ្ញាណំ ចតុត្ថំ ។

អាហារទាំងឡាយមាន ៤ ប្រការ គឺ ករលិង្ការាហារ ១ ផស្សាហារ ទី ២ មនោសញ្ចេតនាហារទី ៣ និងវិញ្ញាណាហារទី ៤ ។

(២២) ឥន្ទ្រិយេសុ បនេត្ថ សោតាបត្តិមគ្គញ្ញាណំ អនញ្ញាតញ្ញស្សា-មីតិន្ទ្រិយំ ។

ម្យ៉ាងទៀត ក្នុងមិស្សកសង្គហនេះ បណ្តាឥន្ទ្រិយទាំងឡាយ សោតាបត្តិមគ្គញ្ញាណ ឈ្មោះថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ។

(២៣) អរហត្តផលញ្ញាណំ អញ្ញាតាវិន្ទ្រិយំ ។

អរហត្តផលញ្ញាណ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។

(២៤) មជ្ឈេ ឆ ញ្ញាណានិ អញ្ញិន្ទ្រិយានីតិ បវុច្ចន្តិ ។

ញាណទាំងឡាយ ៦ ត្រង់កណ្ដាលលោកហៅថា អញ្ញិន្ទ្រិយ ។

(២៥) ជីវិតិន្ទ្រិយញ្ច រូបារូបវសេន ទ្វិធំ ហោតិ ។

ជីវិតិន្ទ្រិយមាន ២ ប្រការ ដោយការចែកជារូបនិងនាម ។

(២៦) បញ្ចវិញ្ញាណេសុ ឈានង្គានិ, អវីរិយេសុ ពលានិ, អហេតុកេសុ មគ្គង្គានិ ន លព្ភន្តិ ។

អង្គនៃឈានទាំងឡាយ រមែងមិនមានក្នុងវិញ្ញាណទាំងឡាយ ៥ ពលទាំងឡាយ រមែងមិនមានក្នុងចិត្តដែលប្រាសចាកសេចក្ដីព្យាយាមទាំងឡាយ អង្គមគ្គទាំងឡាយ រមែងមិនមានក្នុងអហេតុកចិត្តទាំងឡាយ ។

(២៧) តថា វិចិកិច្ឆាចិត្តេ ឯកគ្គតា មគ្គិន្ទ្រិយពលភាវំ ន គច្ឆតិ ។

ដោយប្រការដូច្នោះ ឯកគ្គតារមែងមិនដល់ភាពជាមគ្គ ឥន្ទ្រិយ ឬពលក្នុងចិត្តដែលប្រកបដោយសេចក្ដីសង្ស័យ (វិចិកិច្ឆា) ។

(២៨) ទ្វិហេតុកតិហេតុកជវនេស្វេវ យថាសម្ភវំ អធិបតិ ឯកោវ លព្ភតីតិ ។

អធិបតិ តែម្យ៉ាងគត់ រមែងមានក្នុងជវនចិត្ត ដែលជាទ្វិហេតុកនិងតិហេតុកទាំងឡាយតាមសមគួរ ។

(២៩) ឆ ហេតូ បញ្ច ឈានង្គា មគ្គង្គា នវ វត្ថុតោ
សោឡសិន្ទ្រិយធម្មា ច ពលធម្មា នវេរិតា ។
ចត្តារោធិបតិ រុត្តា តថាហារាតិ សត្តធា
កុសលាទិសមាកិណ្ណា រុត្តោមិស្សកសង្គហោ ។

ហេតុ មានអង្គធម៌ ៦, ឈានង្គ មានអង្គធម៌ ៥, មគ្គង្គ មានអង្គធម៌ ៩,

ឥន្ទ្រិយ មានអង្គធម៌ ១៦, ពល មានអង្គធម៌ ៩, អធិបតី មានអង្គធម៌ ៤, អាហារ មានអង្គធម៌ ៤ ដូចគ្នា គប្បីជ្រាបការសម្តែងមិស្សកសង្គហ: ដែលមានកុសលជាដើម លាយគ្នា ដោយមាន ៧ កង ដូច្នេះ ។

ពោធិបក្ខិយសङ्គហោ

ពោធិបក្ខិយសង្គហ

(៣០) ពោធិបក្ខិយសង្គហោ ចត្តារោ សតិបដ្ឋានា កាយានុបស្សនា-សតិបដ្ឋានំ វេទនានុបស្សនាសតិបដ្ឋានំ ចិត្តានុបស្សនាសតិបដ្ឋានំ ធម្មានុបស្សនាសតិបដ្ឋានំ ។

ក្នុងពោធិបក្ខិយធម៌ (ធម៌ជាចំណែកនៃការត្រាស់ដឹង) សតិប្បដ្ឋាន មាន ៤ គឺ កាយានុបស្សនាសតិប្បដ្ឋាន ១ វេទនានុបស្សនាសតិប្បដ្ឋាន ១ ចិត្តានុបស្សនាសតិប្បដ្ឋាន ១ និងធម្មានុបស្សនាសតិប្បដ្ឋាន ១ ។

(៣១) ចត្តារោ សម្មប្បធានា ឧប្បន្នានំ បាបកានំ បហានាយ វាយាមោ, អនុប្បន្នានំ បាបកានំ អនុប្ផាទាយ វាយាមោ, អនុប្បន្នានំ កុសលានំ ឧប្ផាទាយ វាយាមោ, ឧប្បន្នានំ កុសលានំ ភិយ្យោភាវាយ វាយាមោ ។

សម្មប្បធានទាំងឡាយមាន ៤ គឺ សេចក្តីព្យាយាមកម្ចាត់នូវអកុសលធម៌ទាំងឡាយដែលកើតឡើងហើយ ១ សេចក្តីព្យាយាមដើម្បីញ៉ាំងអកុសលធម៌ទាំងឡាយដែលមិនទាន់កើតឡើងមិនឱ្យកើតឡើង ១ សេចក្តីព្យាយាមញ៉ាំងកុសលធម៌ទាំងឡាយដែលមិនទាន់កើតឡើងឱ្យ

កើតឡើង ១ សេចក្តីព្យាយាមញ៉ាំងកុសលធម៌ទាំងឡាយដែលកើតឡើងហើយឱ្យចម្រើនឡើងយ៉ាងក្រៃលែងថែមទៀត ១ ។

(៣២) ចត្តារោ ឥទ្ធិបាទា ឆន្ទិទ្ធិបាទោ វីរិយិទ្ធិបាទោ ចិត្តិទ្ធិបាទោ វីមំសិទ្ធិបាទោ ។

ឥទ្ធិបាទទាំងឡាយមាន ៤ ប្រការ គឺ ឆន្ទិទ្ធិបាទ ១ វីរិយិទ្ធិបាទ ១ ចិត្តិទ្ធិបាទ ១ និងវីមំសិទ្ធិបាទ ១ ។

(៣៣) បញ្ចិន្ទ្រិយានិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។

ឥន្ទ្រិយទាំងឡាយមាន ៥ គឺ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ និងបញ្ញិន្ទ្រិយ ១ ។

(៣៤) បញ្ច ពលានិ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។

ពលទាំងឡាយមាន ៥ គឺ សទ្ធាពល ១ វីរិយពល ១ សតិពល ១ សមាធិពល ១ និងបញ្ញាពល ១ ។

(៣៥) សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិ-សម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ។

ពោជ្ឈង្គទាំងឡាយមាន ៧ គឺ សតិសម្ពោជ្ឈង្គ ១ ធម្មវិចយ-សម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ និងឧបេក្ខាសម្ពោជ្ឈង្គ ១ ។

(៣៦) អដ្ឋ មគ្គង្គានិ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។

អង្គនៃមគ្គទាំងឡាយមាន ៨ គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្ត ១ សម្មាអាជីវ ១ សម្មាវាយាម ១ សម្មាសតិ ១ និងសម្មាសមាធិ ១ ។

(៣៧) ឯត្ថ បន ចត្តារោ សតិបដ្ឋានាតិ សម្មាសតិ ឯការ បវុច្ចតិ ។

ម្យ៉ាងទៀត ក្នុងពោធិបក្ខិយសង្គហនេះ លោកហៅ សម្មាសតិ តែមួយប៉ុណ្ណោះថា សតិប្បដ្ឋាន ។

(៣៨) តថា ចត្តារោ សម្មប្បធានានិ ច សម្មាវាយាមោ ។

ដោយប្រការដូច្នោះ សម្មាវាយាម តែមួយប៉ុណ្ណោះ លោកហៅថា សម្មប្បធាន ។

(៣៩) ឆន្ទោ ចិត្តមុបេក្ខា ច សទ្ធាបស្សទ្ធិបីតិយោ
សម្មាទិដ្ឋិ ច សង្កប្បោ វាយាមោ វិរតិត្តយំ ។
សម្មាសតិ សមាធីតិ ចុទ្ទសេតេ សភាវតោ
សត្តតឹសប្បភេទេន សត្តធា ឥត្ថ សង្គហោ ។

ប្រែថា ពោធិបក្ខិយធម៌ទាំងឡាយនេះ ដោយសភាវអង្គធម៌មាន ១៤ គឺ ឆន្ទ: ១, ចិត្ត ១, ឧបេក្ខា ១, សទ្ធា ១, បស្សទ្ធិ ១, (កាយបស្សទ្ធិ និងចិត្តបស្សទ្ធិទាំង ២ នេះរាប់ ១) បីតិ ១, សម្មាទិដ្ឋិ ១, សម្មាសង្កប្ប ១, សម្មាវាយាម ១, វិរតិ ៣, សម្មាសតិ ១, សម្មាសមាធិ ១, ដោយប្រភេទមាន ៣៧ ការប្រមូលធម៌ជាចំណែកក្នុងការត្រាស់ដឹងនោះមាន ៧ យ៉ាង ។

(៤០) សង្កប្បបស្សទ្ធិ ច បីតុបេក្ខា ឆន្ទោ ច ចិត្តំ វិរតិត្តយញ្ច
នវេកឋានា វីរិយំ នវដ្ឋ សតី សមាធី ចតុ បញ្ច បញ្ញា
សទ្ធា ទុឋានុត្តមសត្តតឹស- ធម្មានមេសោ បវរោ វិភាគោ ។

ប្រែថា ធម៌ ៩ ប្រការ គឺ សម្មាសង្កប្ប បស្សទ្ធិ បីតិ ឧបេក្ខា ឆន្ទ: ចិត្ត: និងវិរតិ ៣ ជាធម៌ប្រាកដក្នុងឋានតែ ១ វីរិយប្រាកដក្នុងឋាន ៩ សតិប្រាកដក្នុងឋាន ៨ សមាធិប្រាកដក្នុងឋាន ៤ បញ្ញាប្រាកដក្នុងឋាន ៥ សទ្ធាប្រាកដក្នុងឋាន ២ ទាំងអស់នេះជាការចែកធម៌ដ៏ឧត្តម ៣៧ ប្រការ យ៉ាងប្រសើរ ។

(៤១) សព្វេ លោកុត្តរេ ហោន្តិ ន វា សង្កប្បបីតិយោ
លោកិយេបិ យថាយោគំ ឆព្វិសុទ្ធិបវត្តិយំ ។

ប្រែថា ពោធិបក្ខិយធម៌ទាំងឡាយទាំងពួងរមែងមានក្នុងលោកុត្តរចិត្ត សម្មាសង្កប្ប និងបីតិរមែងមិនមានក្នុងលោកុត្តរចិត្តដូងខ្លះ ប៉ុន្តែរមែងមានតាមសមគួរដល់ការប្រកបក្នុងការប្រព្រឹត្តទៅនៃវិសុទ្ធិទាំងឡាយ ៦ សូម្បីក្នុងលោកិយកុសលចិត្តទាំងឡាយ ១៧ ។

សព្វសន្តហោ

ការប្រមូលពួកធម៌ទាំងឡាយ

(៤២) សព្វសង្គហោ បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។

ក្នុងសព្វសង្គហ (នេះ) ខន្ធ ៥ ទាំងឡាយ គឺ រូបក្ខន្ធ ១ វេទនាខន្ធ ១

សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ និងវិញ្ញាណក្ខន្ធ ១ ។

(៤៣) បញ្ចុបាទានក្ខន្ធា រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ។

ឧបាទានក្ខន្ធទាំងឡាយ ៥ គឺ រូបុបាទានក្ខន្ធ ១ វេទនុបាទានក្ខន្ធ ១ សញ្ញុបាទានក្ខន្ធ ១ សង្ខារុបាទានក្ខន្ធ ១ និងវិញ្ញាណុបាទានក្ខន្ធ ១ ។

(៤៤) ទ្វាទសាយតនានិ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ រូបាយតនំ សទ្ទាយតនំ គន្ធាយតនំ រសាយតនំ ផោដ្ឋព្វាយតនំ ធម្មាយតនំ ។

អាយតនទាំងឡាយ ១២ គឺ ចក្ខាយតន ១ សោតាយតន ១ ឃានាយតន ១ ជិវ្ហាយតន ១ កាយាយតន ១ មនាយតន ១ រូបាយតន ១ សទ្ទាយតន ១ គន្ធាយតន ១ រសាយតន ១ ផោដ្ឋព្វាយតន ១ និងធម្មាយតន ១ ។

(៤៥) អដ្ឋារស ធាតុយោ ចក្ខុធាតុ សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ រូបធាតុ សទ្ទធាតុ គន្ធធាតុ រសធាតុ ផោដ្ឋព្វធាតុ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណ-ធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ។

ធាតុទាំងឡាយ ១៨ គឺ ចក្ខុធាតុ ១ សោតធាតុ ១ ឃានធាតុ ១ ជិវ្ហាធាតុ ១ កាយធាតុ ១ រូបធាតុ ១ សទ្ទធាតុ ១ គន្ធធាតុ ១ រសធាតុ ១ ផោដ្ឋព្វធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានវិញ្ញាណ

ធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយវិញ្ញាណធាតុ ១ មនោធាតុ ១ ធម្មធាតុ ១ និងមនោវិញ្ញាណធាតុ ១ ។

(៤៦) ចត្តារិ អរិយសច្ចានិ ទុក្ខं អរិយសច្ចं, ទុក្ខសមុទយោ អរិយសច្ចं, ទុក្ខនិរោធោ អរិយសច្ចं, ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចं ។

អរិយសច្ចទាំងឡាយមាន ៤ គឺ ទុក្ខអរិយសច្ច ១ ទុក្ខសមុទយ អរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ និងទុក្ខនិរោធគាមិនីបដិបទា អរិយសច្ច ១ ។

(៤៧) ឯត្ថ បន ចេតសិកសុខុមរូបនិព្ពានវសេន ឯកូនសត្តតិ ធម្មា ធម្មាយតនធម្មធាតូតិ សង្ខं គচ্ছន្តি ។

ចំណែកបណ្តាធម៌ទាំងឡាយនេះ ធម៌ទាំង ៦៩ ដោយការចែកជា ចេតសិក (៥២) សុខុមរូប (១៦) និងនិព្ពាន (១) រមែងដល់នូវការរាប់ថា ធម្មាយតន និងធម្មធាតុ ។

(៤៨) មនាយតនមេវ សត្តវិញ្ញាណធាតុវសេន ភិជ្ជតি ។

មនាយតនតែប៉ុណ្ណោះ រមែងចែកដោយអំណាចរបស់វិញ្ញាណ ធាតុ ៧ ។

(៤៩) រូបញ្ច វេទនា សញ្ញា សេសចេតសិកា តថា
វិញ្ញាណមិតি បញ្ចេតে បញ្ចក្ខន្ធাতি ภาสิตา ។

ប្រែថា ធម៌ទាំងឡាយ ៥ នេះ គឺ រូប វេទនា សញ្ញា ចេតសិក ដ៏សេស (៥០ ដូង) និងវិញ្ញាណ គឺ ព្រះមានព្រះភាគទ្រង់ត្រាស់ ហៅថា

បញ្ចក្ខន្ធ ដូច្នេះ ។

(៥០) បញ្ចុបាទានក្ខន្ធាតិ តថា តេភូមកា មតា
ភេទាភាវេន និព្ពានំ ខន្ធសង្គហានិស្សដំ ។

ប្រែថា បណ្ឌិតគប្បីជ្រាបថា ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ គឺ ឧបាទានក្ខន្ធ ៥, ព្រះនិព្វាន គឺ ធម៌ដែលរួចផុតចាកការរាប់ថាជាខន្ធ ព្រោះមិនមានសេចក្តីផ្សេងគ្នា (ទាំងប្រភេទនិងកាល) ។

(៥១) ទ្វារារម្មណភេទេន ភវន្តាយតនានិ ច
ទ្វារាលម្ពតទុប្បន្ន- បរិយាយេន ធាតុយោ ។

ប្រែថា អាយតនទាំងឡាយ ១២ ដោយប្រភេទនៃទ្វារ និងអារម្មណ៍ ចំណែកធាតុទាំងឡាយមាន ១៨ យ៉ាង តាមលំដាប់នៃវិញ្ញាណដែលកើតឡើង ព្រោះអាស្រ័យទ្វារ និងអារម្មណ៍ទាំងនោះ ។

(៥២) ទុក្ខំ តេភូមកំ វដ្តំ តណ្ហា សមុទយោ ភវេ
និរោធោ នាម និព្ពានំ មគ្គោ លោកុត្តរោ មតោ ។

ប្រែថា វដ្ត:ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ឈ្មោះថា ទុក្ខ តណ្ហា ឈ្មោះថា សមុទយ និព្វាន ឈ្មោះថា និរោធ លោកុត្តរ ឈ្មោះថា មគ្គ ។

(៥៣) មគ្គយុត្តា ផលា ចេវ ចតុសច្ចវិនិស្សដា
ឥតិ បញ្ចប្បភេទេន បវុត្តោ សព្ពសង្គហោ ។

ប្រែថា ធម៌ដែលប្រកបជាមួយមគ្គចិត្តនិងផលចិត្តុប្បាទ (ក្រៅពីអដ្ឋង្គិកមគ្គ) នោះ ឈ្មោះថា ជាធម៌ដែលរួចចាកអរិយសច្ច: ៤ ការរួបរួម

ធម៌ទាំងទ្បាយទាំងពួងដោយប្រភេទ ៥ យ៉ាង ដោយប្រការដូចដែលបានពោលមកហើយ ។

ឥតិ អភិធម្មត្ថសង្គហោ សមុច្ចយសង្គហវិភាគោ នាម
សត្តមោ បរិច្ឆេទោ ។

បរិច្ឆេទទី ៧ ឈ្មោះថា
សមុច្ចយសង្គហវិភាគក្នុងគម្ពីរអភិធម្មត្ថសង្គហចប់ដោយប្រការដូច្នេះ ។

ចប់

អចារុតា តេ អមតស្ស ទ្វារ

យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ

ទ្វារនៃព្រះនិញ្ជានទាំងនោះបើកហើយ

សត្វទាំងឡាយណាមានសោតប្បសាទ

សត្វទាំងឡាយនោះចូរបញ្ចេញនូវសទ្ធាចុះ។